01624237 D382

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| ឯកសារបកប្រែ |
|---|
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 14-Aug-2019, 14:10 |
| CMS/CFO: Sann Rada |

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ/Public**

# ដីកាដំណោះស្រាយ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី យឹម តិត្យ**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ាន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

# មាតិកា

១. ប្រវត្តិនីតិវិធី ....... 8

២. បញ្ហាបឋម ....... 18

២.១. ការពិចារណារបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/១ និងផលប៉ះពាល់លើដីកាដំណោះស្រាយ ....... 18

២.២. មេធាវីការពារក្តីស្នើសុំឲ្យលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤ ដោយក្នុងនោះបានឈរលើមូលដ្ឋាននៃស្ថានភាពថវិកា ....... 18

២.៣. បទដ្ឋាននៃការបង្ហាញភ័ស្តុតាង ....... 19

២.៤. ស.ព.អ ស្នើសុំចោទប្រកាន់បញ្ជូនទៅជំនុំជម្រះលើឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ ប៉ុន្តែពុំទាន់មានការចោទប្រកាន់ផ្លូវការនៅឡើយ ....... 19

៣. ច្បាប់ជាធរមាន ....... 20

៣.១. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក ....... 20

៣.២. ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ....... 22

៣.២.១. ឧក្រិដ្ឋកម្មអន្តរជាតិ ....... 22

៣.២.២. ឧក្រិដ្ឋកម្មជាតិ ....... 57

៣.៣. ទម្រង់នៃការទទួលខុសត្រូវ ....... 58

៣.៣.១. ទម្រង់នៃការទទួលខុសត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ....... 58

៣.៣.២. ទម្រង់នៃការទទួលខុសត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មជាតិ ....... 71

៤. ការពិចារណាលើភ័ស្តុតាង ....... 72

៤.១. កំណត់ហេតុស្តាប់ចម្លើយនានាក្រៅពីកំណត់ហេតុនៃការស្តាប់ចម្លើយដែលធ្វើឡើងដោយ ក.ស.ច.ស ....... 72

៤.២. ភ័ស្តុតាងចចាមអារ៉ាម និងការសំអាងលើភ័ស្តុតាងដែលពុំស៊ីសង្វាក់គ្នា ....... 74

៤.៣. ភ័ស្តុតាងដែលប្រមូលបានក្រោមទារុណកម្ម ....... 75

៤.៤. របាយការណ៍កំណត់ផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ....... 79

៤.៥. ចំនួនជនរងគ្រោះ ....... 80

៤.៥.១. ការរាប់ចំនួនជនរងគ្រោះដោយផ្អែកលើភ័ស្តុតាងផ្តល់ជូនដោយសាក្សីម្នាក់ ....... 80

៤.៥.២. ការគណនាចំនួនជនរងគ្រោះដោយផ្អែកលើភ័ស្តុតាងពីសាក្សីច្រើននាក់ ....... 81

៤.៥.៣. ការរាប់គ្រួសារ ....... 82

៤.៦. បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស ....... 83

៤.៧. លិខិតធានា ....... 84

៤.៨. ផលប៉ះពាល់នៃសាលក្រមសំណុំរឿង០០២/២ ....... 85

៤.៩. ការព្យាយាមស្នើសុំការជួយជ្រោមជ្រែងពីវៀតណាម ថៃ និងអង្គការសហប្រជាជាតិ ....... 86

៥. ការវិភាគ និងសំអាងហេតុ ....... 86

៥.១. រចនាសម្ព័ន្ធរដ្ឋបាល ....... 86

៥.១.១. នៅថ្នាក់ជាតិ ....... 86

៥.១.២. ភូមិភាគនិរតី ....... 91

៥.១.២.១. តំបន់ ១៣ ....... 91

៥.១.៣. ភូមិភាគពាយ័ព្យ ....... 92

៥.១.៣.១. តំបន់ ១ ....... 92

៥.១.៣.២. តំបន់ ២ ....... 93

៥.១.៣.៣. តំបន់៣ ....... 94

៥.១.៣.៤. តំបន់៤ ....... 96

៥.១.៣.៥. តំបន់៧ ....... 98

៥.១.៤. សិទ្ធិអំណាចតាមផ្លូវច្បាប់ របស់ភូមិភាគ តំបន់ និងស្រុកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ....... 99

៥.២. សំអាងហេតុអំពីសហឧក្រិដ្ឋកម្មរួម ....... 110

៥.២.១. សំអាងហេតុអំពីសហឧក្រិដ្ឋកម្មរួមដែលកំណត់គោលដៅលើខ្មែរក្រោម ....... 110

៥.២.១.១. អត្តសញ្ញាណខ្មែរក្រោម ....... 110

៥.២.១.២. ប្រវត្តិរបស់ខ្មែរក្រោម ....... 114

៥.២.១.៣. គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ទៅលើខ្មែរក្រោម ....... 120

៥.២.១.៤. ប្រជាសាស្ត្រ ....... 129

៥.២.១.៥. ប្រតិបត្តិការសម្លាប់មនុស្សនៅក្នុងតំបន់១៣ ....... 131

៥.២.១.៦. ប្រតិបត្តិការសម្លាប់មនុស្សនៅតំបន់១ ....... 154

៥.២.១.៧. ប្រតិបត្តិការសម្លាប់មនុស្សនៅតំបន់២ ....... 156

៥.២.១.៨. ប្រតិបត្តិការសម្លាប់មនុស្សនៅតំបន់៤ ....... 165

៥.២.១.៩. ប្រតិបត្តិការសម្លាប់មនុស្សនៅតំបន់៧ ....... 174

៥.២.២. សហឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ ..... 176
៥.២.២.១. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន ..... 176
៥.២.២.២. ការរៀនសូត្រ និងការសម្លាប់ "ខ្មាំង" និង "សមាសភាពមិនល្អ" និងការកំណត់គោលដៅទៅលើក្រុមជាក់លាក់ ..... 190
៥.២.២.៣. ការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍ ..... 248
៥.៣. សំអាងហេតុអំពីតួនាទីរបស់ យឹម ទិត្យ ..... 269
៥.៣.១. នៅមុនខែមេសា ឆ្នាំ១៩៧៥ និងនៅក្រោយថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ..... 269
៥.៣.១.១. ប្រវត្តិផ្ទាល់ខ្លួន ..... 269
៥.៣.១.២. សកម្មភាពនយោបាយ ..... 270
៥.៣.២. តួនាទី និងសិទ្ធិអំណាចរបស់ យឹម ទិត្យ នៅក្នុងភូមិភាគនិរតី ..... 272
៥.៣.២.១. ស្រុកគីរីវង្ស ..... 272
៥.៣.២.២. តំបន់១៣ ..... 281
៥.៣.៣. តួនាទី និងសិទ្ធិអំណាចរបស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ ..... 290
៥.៣.៣.១. យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ..... 290
៥.៣.៣.២. ការតែងតាំង យឹម ទិត្យ ទៅក្នុងតំណែងនៅភូមិភាគពាយ័ព្យ នៅអំឡុងខែមិថុនា ឆ្នាំ ១៩៧៨ ..... 293
៥.៣.៤. ការប្រព្រឹត្តិ និងការចូលរួមចំណែករបស់ យឹម ទិត្យ ទៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលប៉ុនប៉ងលុបបំបាត់ប្រជាជនខ្មែរក្រោម ..... 310
៥.៣.៤.១. តំបន់ ១៣ ភូមិភាគនិរតី ..... 311
៥.៣.៤.២. តំបន់ ១ ភូមិភាគពាយ័ព្យ ..... 313
៥.៣.៥. ការប្រព្រឹត្តិ និងការចូលរួមរបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួមនៅភូមិភាគពាយ័ព្យ ..... 318
៥.៣.៥.១. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន ..... 318
៥.៣.៥.២. ការបោសសម្អាតភូមិភាគពាយ័ព្យ និងការកំណត់ជាគោលដៅលើក្រុមជាក់លាក់ ..... 329
៥.៣.៥.៣. បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ..... 341
៥.៤. សេចក្តីសន្និដ្ឋានលើអង្គហេតុស្តីពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម ..... 342
៥.៥. សេចក្តីសន្និដ្ឋានអង្គហេតុទៅលើឧក្រិដ្ឋកម្ម ..... 349

៥.៥.១. តំបន់ ១៣ ....... 349

៥.៥.១.១. មន្ទីរសន្តិសុខវត្តព្រះធាតុ ....... 349

៥.៥.១.២. មន្ទីរសន្តិសុខក្រាំងតាចាន់ ....... 373

៥.៥.១.៣. កន្លែងសម្លាប់នៅភូមិព្រាល ....... 416

៥.៥.១.៤. ទីតាំងសម្លាប់វត្តអង្គុញ ....... 425

៥.៥.១.៥. ទីកន្លែងសម្លាប់នៅភូមិព្រៃស្លែង ....... 429

៥.៥.១.៦. វត្តអង្គសិរីមាលី និងកន្លែងសម្លាប់ព្រៃសុខុន ....... 435

៥.៥.២. តំបន់ ១ ....... 444

៥.៥.២.១. មន្ទីរសន្តិសុខគាស់ក្រឡ ....... 444

៥.៥.២.២. សហករណ៍ធិបតី (រួមមានមន្ទីរសន្តិសុខវត្តធិបតី និង មន្ទីរសន្តិសុខទួលម្ទេស និង ការដ្ឋានទួលម្ទេស ....... 452

៥.៥.២.៣. ការដ្ឋានទំនប់កង្កួត ....... 488

៥.៥.២.៤. មន្ទីរសន្តិសុខបាណន់ ....... 516

៥.៥.២.៥. មន្ទីរសន្តិសុខខ្នងគូ ....... 529

៥.៥.២.៦. ការដ្ឋានរោងចក្រស្ករកំពង់កុល ....... 539

៥.៥.៣. តំបន់២ ....... 549

៥.៥.៣.១. មន្ទីរសន្តិសុខភូមិវាល ....... 549

៥.៥.៣.២. មន្ទីរសន្តិសុខស្វាយជ្រុំ ....... 571

៥.៥.៣.៣. កន្លែងសម្លាប់ទួលសេះញ៉ូវ ....... 587

៥.៥.៣.៤. កន្លែងសម្លាប់ព្រៃក្របៅ ....... 603

៥.៥.៣.៥. ទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សី ....... 613

៥.៥.៤. តំបន់៣ ....... 614

៥.៥.៤.១. មន្ទីរសន្តិសុខវត្តគិរីរម្យ ....... 614

៥.៥.៥. តំបន់៤ ....... 625

៥.៥.៥.១. មន្ទីរសន្តិសុខវត្តសម្តេច ....... 625

៥.៥.៥.២. មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ/កាច់រទេះ ....... 636

៥.៥.៥.៣. ការកំណត់គោលដៅទៅលើខ្មែរក្រោម នៅឃុំកំពង់ព្រៀង និងវាំងកេសី ....... 652

៥.៥.៦. តំបន់៧ ....... 670

៥.៥.៦.១. គុកលេខ៨ ..... 670
៥.៥.៦.២. ទីតាំងសម្លាប់មនុស្សវាលបាក់ចិញ្ចៀន ..... 678
៥.៥.៧. ការរៀបការដោយបង្ខំនៅតំបន់១ និងតំបន់៤ ..... 682
៥.៥.៧.១. សេចក្តីផ្តើម ..... 682
៥.៥.៧.២. តំបន់ទី៤ ឃុំវាំងកេសី និងឃុំកំពង់ព្រៀង ..... 682
៥.៥.៧.៣. តំបន់១៖ ស្រុកសំឡូត ..... 699
៦. របកគំហើញផ្នែកច្បាប់ស្តីពីយុត្តាធិការបុគ្គល ..... 706
៧. របកគំហើញផ្លូវច្បាប់អំពីឧក្រិដ្ឋកម្ម ..... 709
៧.១. ធាតុផ្សំគ្របដណ្តប់រួមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ..... 709
៧.២. ធាតុផ្សំគ្របដណ្តប់រួមនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ..... 711
៧.៣. របកគំហើញអំពីឧក្រិដ្ឋកម្មនីមួយៗ ..... 711
៧.៣.១. អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ..... 711
៧.៣.២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ..... 714
៧.៣.៣. ឧក្រិដ្ឋកម្មសង្គ្រាម ..... 719
៧.៣.៤. ការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ..... 720
៨. របកគំហើញផ្លូវច្បាប់អំពីទម្រង់នៃការទទួលខុសត្រូវ ..... 721
៨.១. ឧក្រិដ្ឋកម្មអន្តរជាតិ ..... 721
៨.១.១. ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (JCE) ..... 721
៨.១.២. ការប្រព្រឹត្តដោយផ្ទាល់ ..... 725
៨.១.៣. ការធ្វើផែនការ ..... 725
៨.១.៤. ការបញ្ជា ..... 726
៨.១.៥. ការញុះញង់ ..... 727
៨.១.៦. ការទទួលខុសត្រូវរបស់ថ្នាក់លើ ..... 728
៨.១.៧. បទចោទដែលត្រូវលើកលែង ..... 729
៨.២. ឧក្រិដ្ឋកម្មក្នុងស្រុក ..... 729
៨.២.១. សហប្រព្រឹត្តកម្ម ..... 729
៨.២.២. ការធ្វើផែនការ ..... 729

៨.២.៣. ការបញ្ចោ ... 729
៨.៣. ចេតនាឧក្រិដ្ឋ ... 730
៩. សេចក្តីសម្រេចស្តីពីការឃុំឃាំងមុនសវនាការ ... 730
១០. ដីកាសម្រេចបញ្ចប់កិច្ចស៊ើបសួរ តាមវិធានវិធាន ៦៦ស្ទួន ... 731
១១. ដីកាសម្រេចលើកលែងចោទប្រកាន់មួយផ្នែក ... 731
១២. ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ... 732
១៣. ការបញ្ចប់កិច្ចស៊ើបសួរដែលនៅសល់ទាក់ទងនឹងសំណុំរឿង ០០៤ ... 745

ឧបសម្ព័ន្ធ I កាលប្បវត្តិនៃគម្រោងបញ្ចប់ផែនការ
ឧបសម្ព័ន្ធ II ពាក្យសុំ និងសំណើដែលបានដាក់នៅ ស.ច.ស
ឧបសម្ព័ន្ធ III សាក្សីនៃការរៀបការដោយបង្ខំតាមខេត្ត
ឧបសម្ព័ន្ធ IV អក្សរកាត់

# ១. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ស.ព.អ បានចេញ*ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី* (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ”) ដែលក្នុងនោះគាត់ចោទប្រកាន់ថា យឹម ទិត្យ ទទួលខុសត្រូវព្រហ្មទណ្ឌលើឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិមួយចំនួន ដែលបានប្រព្រឹត្តឡើងនៅក្រោមយុត្តាធិការពេលវេលា និងដែនដីរបស់តុលាការ[1]។ ដោយសារការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបាន ស.ព.អ ស្តីទី បញ្ជូនទៅ ស.ច.ស នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩[2]។

2. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដោយបានស្នើសុំឲ្យ ស.ច.ស ធ្វើការស៊ើបអង្កេតទៅលើការចោទប្រកាន់ថ្មីៗប្រឆាំងនឹង **យឹម ទិត្យ** អនុលោមតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង[3]។

3. ករណីខ្វែងយោបល់គ្នារវាង ស.ច.ស នៅក្នុងរឿងក្តីនេះ បានចុះក្នុងកំណត់ហេតុនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ និងថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥។

4. នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ខ្ញុំបានដាក់ **យឹម ទិត្យ** ឲ្យស្ថិតក្រោមការពិនិត្យពីបទរំលោភលើមាត្រា ៥០១ និងមាត្រា ៥០៦ (មនុស្សឃាតគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍[4]។ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ក្រោយពីបានជូនដំណឹងដល់

---

[1] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។

[2] ឯកសារ **D1/1** *សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣* ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩។

[3] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១។ ឯកសារ **D191** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤។ ឯកសារ **D254/1** *ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តអង្គតាមាក់* ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥។ ឯកសារ **D272/1** *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១ និងតំបន់៤* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥។

[4] ឯកសារ **D281** *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ* ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥។

ភាគីអំពីបំណងធ្វើការចោទប្រកាន់[5] ខ្ញុំបានបន្ថែមទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលបានដាក់ឱ្យស្ថិតក្រោមការពិនិត្យនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ តាមវិធីដីកាបង្គាប់របស់តុលាការ[6]។ បញ្ជីស្ដីពីបទចោទទាំងអស់ប្រឆាំងនឹង **យឹម ទិត្យ** បានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ដែលដាក់ភ្ជាប់ជាមួយដីកាដំណោះស្រាយនេះ[7]។

5. នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ខ្ញុំបានជូនដំណឹងភាគីថា អង្គហេតុដូចបានចោទប្រកាន់ខាងក្រោមទំនងជាត្រូវបានលើកលែងការចោទប្រកាន់មួយចំនួន អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង[8]៖

ក. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តសុបិន[9]

ខ. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងភូមិសោម[10]

គ. ការចោទប្រកាន់ពាក់ព័ន្ធនឹងការកំណត់គោលដៅ ការចាប់ខ្លួន និងការសម្លាប់ខ្មែរក្រោម និងវៀតណាមនៅសហករណ៍ធិបតី[11]

ឃ. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តបន្ទាយត្រែង[12]

ង. ការសម្លាប់រង្គាលនៅភ្នំត្រជាក់ចិត្ត[13]

---

[5] ឯកសារ **D342** *សេចក្ដីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្ដោះអាសន្ន* ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧។

[6] ឯកសារ **D350** *ដីកាសម្រេចកែប្រែបែបបទចោទប្រឆាំង យឹម ទិត្យ* ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧។ ឯកសារ **D350.1** *ឧបសម្ព័ន្ធ៖ សេចក្ដីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ* ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧។

[7] ឯកសារ **D350** *ដីកាសម្រេចកែប្រែបែបបទចោទប្រឆាំង យឹម ទិត្យ* ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ៦។ ឯកសារ **D350.1** *ឧបសម្ព័ន្ធ៖ សេចក្ដីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ* ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧។

[8] ឯកសារ **D302/3** *សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ២៧។

[9] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១២។

[10] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១២។

[11] ឯកសារ **D191** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៨។

[12] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។

ច. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខត្រាចក្រោល ហៅ បឹងបាតកណ្ដាល[14]

ឆ. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងល្អាងភ្នំត្នួយឃុំ[15]

ជ. ការចោទប្រកាន់ពាក់ព័ន្ធនឹងការក្លាយជាគោលដៅ ការចាប់ខ្លួន និងការកាប់សម្លាប់ជនជាតិវៀតណាមនៅក្នុងឃុំវាំងកេសី[16]

ឈ. ការចោទប្រកាន់ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ និងការសម្លាប់នារីពីរនាក់ដែលមានដើមកំណើតជាជនជាតិវៀតណាមនៅស្រុកព្រះនេត្រព្រះ[17] និង

ញ. ឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ[18]

(ហៅរួមគ្នាថា "អង្គហេតុនៃវិធាន ៦៧")

6. សំអាងហេតុពាក់ព័ន្ធនឹងការពិចារណាលើអង្គហេតុនៃវិធាន ៦៧ ត្រូវបានលើកឡើងនៅក្នុង *សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់ពីអង្គហេតុដែលមិនស៊ើបអង្កេតថែមទេ*[19] និង*សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ*[20]។ ទោះបីជាវាក្យស័ព្ទដែល

---

[13] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៧។

[14] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៦។

[15] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧០។

[16] ឯកសារ **D191** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៨។

[17] ឯកសារ **D191** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៩។

[18] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧៣។ ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៨-១៩។

[19] ឯកសារ **D302** *សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់ពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៣-៥។

[20] ឯកសារ **D302/3** *សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ២៧-៣១។

បានប្រើប្រាស់ពាក់ព័ន្ធនឹងអង្គហេតុនៃវិធាន ៦៧ គឺ "*ការលើកលែងការចោទប្រកាន់មួយចំនួន*" ដោយសារពុំមានបទចោទលើកឡើងជាក់ស្តែងពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនោះក៏ដោយ ក៏វាត្រូវលុបចោលនៅក្នុងដីកាសម្រេចវិលត់ដោយឡែករួមគ្នា ដែលបានចេញដោយ ស.ច.ស នៅក្នុងថ្ងៃនេះ។

7. ករណីខ្វែងយោបល់គ្នាបន្ថែមរវាង ស.ច.ស ត្រូវបានចុះក្នុងកំណត់ហេតុនៅថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៧។

8. នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ខ្ញុំបានចេញដីកាសម្រេចបន្ថយវិសាលភាពនៃការស៊ើបអង្កេតដោយបានដកចេញអង្គហេតុដែលបានចោទប្រកាន់ ដូចខាងក្រោមអនុលោមតាមវិធាន ៦៦*ស្ទួន* ("ដីកាសម្រេចវិធាន ៦៦*ស្ទួន*")[21]៖

ក. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធទីកន្លែងសម្លាប់នៅតំណាក់វាំង[22]

ខ. ការចោទប្រកាន់ពាក់ព័ន្ធអាពាហ៍ពិពាហ៍ដោយបង្ខំនៅជិតទំនប់កង្កួត[23]

គ. ការចោទប្រកាន់ពាក់ព័ន្ធទីតាំងនៅតំបន់ ៥ ភូមិភាគពាយ័ព្យ

i. មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង[24]

ii. ការដ្ឋានស្ពានស្រែង និងការដ្ឋានទំនប់ព្រៃរនាម[25]

iii. ទីតាំងសម្លាប់មនុស្សនៅវត្តព្រះនេត្រព្រះ និងទីតាំងឃុំខ្លួន និងទីតាំងកាប់សម្លាប់ពាក់ព័ន្ធ[26]

---

[21] ឯកសារ **D359** *ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ៤* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧។

[22] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៩។

[23] ឯកសារ **D272/1** *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១ និងតំបន់៤* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ៦។

[24] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧៤-៧៥។

[25] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧៩។

iv. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅភូមិចក្រី[27]

v. ទីតាំងសម្លាប់មនុស្សនៅព្រៃតារ៉ូត[28]

vi. ទីតាំកាប់សម្លាប់នៅវត្តចំការខ្នុរ[29] និង

vii. ការដ្ឋានទំនប់ត្រពាំងថ្ម[30]

ឃ. អង្គហេតុពាក់ព័ន្ធទីតាំងសម្លាប់មនុស្សនៅអន្លង់វាលប្រែង និងទីតាំងសម្លាប់មនុស្សនៅកន្លែងពាក់ព័ន្ធផ្សេងទៀត[31]

ង. អង្គហេតុពាក់ព័ន្ធការដ្ឋានភ្នំត្រជាក់ចិត្ត[32]

ច. អង្គហេតុពាក់ព័ន្ធទីតាំងសម្លាប់មនុស្សនៅបន្ទាយអូតាក្រែ[33]

ឆ. អង្គហេតុពាក់ព័ន្ធមន្ទីរសន្តិសុខវត្តកណ្តាល[34]

ជ. អង្គហេតុពាក់ព័ន្ធមន្ទីរសន្តិសុខវត្តបន្ទាយនាង[35] និង

---

[26] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧៧។

[27] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧៦។

[28] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧៦។

[29] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧១។

[30] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧៨។

[31] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៧។

[32] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៧។

[33] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៦១។

[34] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៦៥-៦៦។

ឈ. អង្គហេតុពាក់ព័ន្ធមន្ទីរសុខសន្តិសុខវត្តធម្មយុត[36]

(ហៅជារួមថា "អង្គហេតុដែលត្រូវបានដកចេញ")

9. អង្គហេតុដែលត្រូវបានដកចេញមួយចំនួន បានបង្កើតជាមូលដ្ឋាននៃបទចោទជាក់លាក់ប្រឆាំងនឹង **យឹម ទិត្យ** ពោលគឺ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង/ឬ មនុស្សឃាតដោយគិតទុកជាមុន ដែលត្រូវបានប្រព្រឹត្តឡើងនៅអន្លង់វាលប្រែង និងទីតាំងសម្លាប់មនុស្សនៅកន្លែងពាក់ព័ន្ធ ការដ្ឋានភ្នំត្រជាក់ចិត្ត ទីតាំងសម្លាប់មនុស្សនៅបន្ទាយអូតាក្រែ មន្ទីរសន្តិសុខវត្តកណ្តាល មន្ទីរសន្តិសុខវត្តបន្ទាយនាង មន្ទីរសន្តិសុខវត្តធម្មយុត មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ការដ្ឋានទំនប់ស្ពានស្រែង និងព្រៃរនាម ទីតាំងសម្លាប់មនុស្សនៅវត្តព្រះនេត្រព្រះ និងទីតាំងសម្លាប់មនុស្ស និងឃុំខ្លួនពាក់ព័ន្ធ មន្ទីរសន្តិសុខ និងទីតាំងវាលពិឃាតនៅភូមិចក្រី ទីតាំងសម្លាប់មនុស្សនៅព្រៃតារ៉ូត ទីតាំងសម្លាប់មនុស្សនៅវត្តចំការខ្នុរ និងការដ្ឋានទំនប់ត្រពាំងថ្ម[37]។

10. សំអាងហេតុសម្រាប់ការកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតត្រូវបានបង្ហាញនៅក្នុង *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ*[38] *សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវតាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន*[39] *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងទីតាំង*

---

[35] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៦៩។

[36] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣ របស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៦៣-៦៤។

[37] ឯកសារ **D350** *ដីកាសម្រេចកែប្រែបែបបទចោទប្រឆាំង យឹម ទិត្យ* ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧។ ឯកសារ **D350.1** *ឧបសម្ព័ន្ធ៖ សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ* ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ទំព័រ ២-៣, ៧-៨, ១០-១៥។

[38] ឯកសារ **D302/3** *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ១, ៦, ១៧-២៦។

[39] ឯកសារ **D342** *សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន* ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ ៧។ ឯកសារ **D342** *សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន* ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ ៧-៤៤។

*ឧក្រិដ្ឋកម្មចំនួន ៦ កន្លែង*[40] និង*សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៩ស្ទួន(២)*[41]។ ការស៊ើបអង្កេតលើអង្គហេតុដែលត្រូវបានដកចេញ ត្រូវតែរំលត់អនុលោមតាមវិធាន ៦៦*ស្ទួន*(៥) ហើយខ្ញុំនឹងចេញដីកានោះ។

11. នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ស.ច.ស បានជូនដំណឹងដល់ភាគីអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង អំពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង **យឹម ទិត្យ** និងបានជូនដំណឹងថា ភាគីអាចស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមនៅក្នុងរយៈពេល ១៥ ថ្ងៃបាន[42]។ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៧ ស.ច.ស បានពន្យាររយៈពេលសម្រាប់ភាគីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមរហូតដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧[43]។

12. សំណើសុំបំពេញកិច្ចស៊ើបសួរមួយចំនួនត្រូវបានភាគីដាក់អនុលោមតាមការណែនាំនេះ។ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ក្រោយពេលចេញដីកាសម្រេចមួយចំនួនលើសំណើសុំបំពេញកិច្ចស៊ើបសួរទាំងនោះ ស.ច.ស បានចេញសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរជាលើកទី២ ប្រឆាំងនឹង **យឹម ទិត្យ** និងបានជូនដំណឹងភាគីថា ពុំមានរយៈពេលបន្ថែមសម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ទៅតាមច្បាប់តម្រូវនោះទេ[44]។

---

[40] ឯកសារ **D349** *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ១-៥។

[41] ឯកសារ **D354** *សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន(២)* ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៨-១០។

[42] ឯកសារ **D358** *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧។

[43] ឯកសារ **D361/4** *ដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់* ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧។

[44] ឯកសារ **D368** *សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ* ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។ ទោះបីជាពុំបានទទួលបណ្តឹងជាផ្លូវការពាក់ព័ន្ធនឹងចំណុចនេះ នាពេលនោះក្តី ក៏ អ.ប.ជ បានលើកឡើង*តាមផ្លូវច្បាប់យ៉ាងសង្ខេប*នៅក្នុងសេចក្តីសម្រេចក្នុងសំណុំរឿង ០០៤ ថា យោងតាមការបកស្រាយរបស់ខ្លួនទៅលើវិធាន ៦៦(១) រយៈពេល ១៥ ថ្ងៃបន្ថែម គិតពីថ្ងៃជូនដំណឹងនៃសេចក្តីជូនដំណឹងលើកទីពីរអំពីការបញ្ចប់កិច្ចស៊ើបសួរ គួរណាស់តែផ្តល់ជូនភាគី តាមរយៈ ស.ច.ស ដើម្បីពិនិត្យមើលឡើងវិញលើភស្តុតាងដែលទើបតែប្រមូលបានថ្មី (*សូមមើល* ឯកសារ **D361/4/1/10** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់* ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ២៣-២៧។ យោងទៅលើមតិយោបល់របស់ អ.ប.ជ យើងពុំគិតថា ចាំបាច់ត្រូវផ្តល់ទៅឱ្យភាគីក្នុងសំណុំរឿង ០០៤ នូវរយៈពេល ១៥ ថ្ងៃបន្ថែម ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរនោះទេ ដោយយើងបានពិចារណាថា វាហាក់ដូចជាពុំមានភាគីណាមួយបានទទួលរងការខូចខាត ដែលបណ្តាលមកពីយើងពុំបានផ្តល់រយៈពេល ១៥ ថ្ងៃបន្ថែមនោះទេ ហើយច្បាស់ណាស់ថា វាមិនមែនជាព្យសនកម្មដល់កម្រិតដែលអាចបង្កើតបានជាករណីលើកលែង ធានាឱ្យមានការពិចារណាឡើងវិញទៅ

13. នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ស.ច.ស បានជូនដំណឹងភាគីនៃសំណុំរឿង ០០៤/២ ថា ស.ច.ស បានចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដោយឡែកពីគ្នា ដោយផ្អែកលើការខ្វែងយោបល់គ្នារវាង ស.ច.ស ដូចច្បាប់បានអនុញ្ញាតអនុលោមតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ហើយក៏បានជូនដំណឹងអំពីផលវិបាកនៃដំណើរការបណ្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៧(១៣) ផងដែរ[45]។ ភាគីនៃសំណុំរឿង ០០៤ ក៏ទទួលបានការជូនដំណឹងអំពីសេចក្ដីសម្រេចនេះផងដែរ ដែលក្រោយមកត្រូវបានធ្វើចំណាត់ថ្នាក់ជាឯកសារសាធារណៈឡើងវិញ។

14. នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ស.ច.ស បានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ ហើយបានអនុញ្ញាតឱ្យ ស.ព.អ ដាក់ដីកាសន្និដ្ឋានស្ថាពរជាភាសាអង់គ្លេសតែម្នាក់ឯងនៅក្នុងរយៈពេល ០៣ខែ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅពិនិត្យ ដោយសំណៅបកប្រែជាភាសាខ្មែរទាំងមូល អាចឱ្យបានឆាប់តាមក្រោយបាន[46]។

---

លើសេចក្ដីសម្រេចរបស់យើងនោះទេ។ ចំណុចនេះត្រូវបានគាំទ្រវឹងមាំដោយអង្គហេតុថា ពុំមានភាគីណាមួយនៅក្នុងសំណុំរឿង ០០៤ បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីជូនដំណឹងលើកទីពីររបស់យោង ឬបានលើកឡើងពីកង្វះរយៈពេល ១៥ ថ្ងៃបន្ថែម ថាជាបញ្ហានោះទេ ហើយពួកគេក៏ពុំបានស្នើសុំឱ្យមានការពិចារណាឡើងវិញទៅលើ សេចក្ដីជូនដំណឹងលើកទីពីរស្ដីពីការបញ្ចប់កិច្ចស៊ើបសួរ ចាប់តាំងពីមតិយោបល់របស់ អ.ប.ជ ត្រូវបានលើកឡើងមក។ ចំណុចនេះបង្កបានជាការលះបង់សិទ្ធិបញ្ជាក់តាមរយៈដែលព័ត៌មានទទួលបានអំពីចិរវេលា ១៥ ថ្ងៃបន្ថែម ស្របតាមវិធាន ៦៦(១) ដែលមានន័យថា មតិយោបល់របស់ អ.ប.ជ ស្ដីពីអង្គច្បាប់ចាត់ទុកជាឥតបានការនោះឡើយ។ នៅក្នុងបរិបទនេះ វាមានការជាប់ពាក់ព័ន្ធថា អ.ប.ជ ពុំបានមើលឃើញថា វាសមស្របដើម្បីបង្គាប់ ស.ច.ស ជាផ្លូវការ ឱ្យផ្ដល់រយៈពេល ១៥ ថ្ងៃបន្ថែមទៀត ដែលយោងតាមទ្រឹស្ដី អ.ប.ជ អាចសម្រេចបាន ពីព្រោះថា សរុបមក បណ្ដឹងឧទ្ធរណ៍គឺនិយាយអំពីពេលវេលាដើម្បីធ្វើការត្រៀមរៀបចំឱ្យបានគ្រប់គ្រាន់ (ទោះបីជានៅក្នុងសំអាងហេតុរបស់ខ្លួន ដែលមិនពាក់ព័ន្ធជាមួយនឹងមតិយោបល់ផ្ទុយប្រកបដោយហេតុផលរបស់ ស.ច.ស ជាលម្អិតក្ដី ក៏កង្វះរយៈពេល ១៥ ថ្ងៃបន្ថែម អាចចាត់ទុកថាជាវិការៈផ្នែកនីតិវិធី) ហើយ អ.ប.ជ ក៏ពុំបានពិចារណាចំណុចនេះថាមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីពន្យារពេលវេលាធ្វើការរៀបចំដូចដែល មេធាវីការពារក្ដីបានស្នើសុំនោះដែរ។

[45] សំណុំរឿង ០០៤/២ ឯកសារ **D355/1** *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់* ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ១៣-១៦។

[46] ឯកសារ **D378** *ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤)* ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៣។

15. នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ស.ព.ជ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ដោយបានស្នើសុំឱ្យលើកលែងការចោទប្រកាន់ប្រឆាំង **យឹម ទិត្យ** ដោយផ្អែកលើមូលដ្ឋានថា **យឹម ទិត្យ** ពុំស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ")[47]។

16. នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ត្រូវបានជូនដំណឹង ដោយបានស្នើសុំឱ្យបញ្ជូន **យឹម ទិត្យ** ទៅជំនុំជម្រះលើបទចោទដូចបានលើកឡើងនៅក្នុងនោះ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ" ដែលហៅរួមគ្នាជាមួយដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ ថាជា "ដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព")[48]។

17. នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ស.ច.ស បានយល់ព្រមផ្តល់រយៈពេល ០៣ខែ ដល់មេធាវីការពារក្តី ឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព ជាភាសាអង់គ្លេស ដោយគិតរាប់ចាប់ពីថ្ងៃជូនដំណឹងនៃសំណៅដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ដែលបានបកប្រែជាភាសាខ្មែរ ហើយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនឆាប់ៗតាមក្រោយ[49]។

18. នៅថ្ងៃទី២០ ខែសីហា និងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ អ.ប.ជ បានច្រានចោលសំណើសុំមោឃភាពរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងសំណើសុំ និងការប្រើប្រាស់ទម្រង់បែបបទស្តីពីព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងលទ្ធផលនៃការស៊ើបអង្កេតពាក់ព័ន្ធ[50] ហើយនឹងភស្តុតាងដែលត្រូវបានចោទប្រកាន់ថាទទួលបានពីការធ្វើទារុណកម្ម ឬ កើតចេញពីទារុណកម្ម[51]។ នៅថ្ងៃទី

---

[47] ឯកសារ **D378/1** *ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ កថាខណ្ឌ ៣៤, ៣៦។

[48] ឯកសារ **D378/2** *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ* ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ១១៥៥-១១៨៣។

[49] ឯកសារ **D378/4** *ដីកាសម្រេចលើចំនួនពេលវេលាដែលផ្តល់ជូនមេធាវីការពារក្តីដើម្បីឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

[50] ឯកសារ **D370/1/1/6** *សេចក្តីសម្រេចលើពាក្យសុំរបស់ យឹម ទិត្យ សុំធ្វើមោឃភាពលើសំណើសុំ និងការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធ នៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨។

[51] ឯកសារ **D372/1/7** *សេចក្តីសម្រេចលើពាក្យសុំរបស់ យឹម ទិត្យ ស្នើឱ្យធ្វើមោឃភាពភស្តុតាងនានាដែលទទួលបានដោយការធ្វើ* ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨។

១៩ ខែតុលា ឆ្នាំ២០១៨ អ.ប.ជ បានរកឃើញថា បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ខ្ញុំលើសំណើសុំកែកំហុសបកប្រែ នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយ ពុំអាចទទួលយកបាន[52]។

19. នៅថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០១៨ មេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ពួកគេទៅនឹងសេចក្តីសន្និដ្ឋានរបស់ ក.ស.ព ដោយបានស្នើសុំឱ្យ ស.ច.ស លើកលែងការចោទប្រកាន់ប្រឆាំងនឹង **យឹម ទិត្យ** ដោយផ្អែកលើមូលដ្ឋានថា (ក) **យឹម ទិត្យ** ពុំស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ឬ (ខ) ភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង **យឹម ទិត្យ** ត្រូវបានប៉ះពាល់មិនអាចជួសជុលបាន រហូតដល់កម្រិតថាមិនអាចឱ្យកិច្ចដំណើរការនីតិវិធីដំណើរការទៅលឿន និងយុត្តិធម៌ ឬ (គ) ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជូន **យឹម ទិត្យ** ទៅជំនុំជម្រះលើឧក្រិដ្ឋកម្មដូចបានចោទប្រកាន់[53]។

20. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ ស.ច.ស បានចេញដីកាពាក់ព័ន្ធនឹងការកែប្រតិចារឹកជំនុំជម្រះ និងកំណត់ហេតុនៃការស្តាប់ចម្លើយ ដោយក្នុងនោះបានជូនដំណឹងដល់ភាគីថា ស.ច.ស នឹងពុំពិចារណាលើសំណើសុំឱ្យកែប្រតិចារឹកនៃការជំនុំជម្រះ ឬ កំណត់ហេតុនៃការស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៤ បន្ថែមទៀតទេ[54]។

21. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ ស.ច.ស បានចុះការខ្វែងយោបល់គ្នានៅក្នុងកំណត់ហេតុពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយដែលបានចេញផ្ទុយគ្នា និងដោយឡែកពីគ្នា។

22. នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ស.ច.ស បានធ្វើចំណាត់ថ្នាក់កំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ០៣ ឡើងវិញ ហើយបានជូនដំណឹងភាគីថា មានតែភស្តុតាងដោះបន្ទុកតែប៉ុណ្ណោះដែលមាននៅក្នុងនោះនឹងត្រូវយកមកពិចារណានៅក្នុងធ្វើសេចក្តីព្រាងដីកាដំណោះស្រាយ[55]។

---

[52] ឯកសារ **D377/1/1/3** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំធ្វើការកែតម្រូវកំហុសឆ្គង នៃការបកប្រែនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយ* ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨។

[53] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៥៨១។

[54] ឯកសារ **D379** *ដីកាសម្រេចលើការកែសម្រួលប្រតិចារឹកសវនាការសំណុំរឿង ០០២ ដែលបានដាក់ចូលក្នុងសំណុំរឿង ០០៤ និងការកែសម្រួលកំណត់ហេតុស្តាប់ចម្លើយក្នុងសំណុំរឿង* ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

[55] ឯកសារ **D380** *ដីកាសម្រេចធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញលើកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩។

## ២. បញ្ហាបឋម

### ២.១. ការពិចារណារបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/១ និងផលប៉ះពាល់លើដីកាដំណោះស្រាយ

23. នៅក្នុងសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១[56] អ.ប.ជ និង/ឬ ចៅក្រមអន្តរជាតិ បានធ្វើការសម្រេចមួយចំនួនដែលយោងតាមទ្រឹស្តី អាចមានផលប៉ះពាល់លើខ្លឹមសារនៃដីកាដំណោះស្រាយ។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ការលើកយោងលើទឡ្ហីករណ៍របស់ខ្ញុំនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/១ គឺគ្រប់គ្រាន់ ដែលនៅក្នុងដីកានោះ ខ្ញុំបានលើកឡើងចំណុចទាំងនេះ[57]។

### ២.២. មេធាវីការពារក្តីស្នើសុំឲ្យលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤ ដោយក្នុងនោះធានឈរលើមូលដ្ឋាននៃស្ថានភាពថវិកា

24. មេធាវីការពារក្តីបានធ្វើសេចក្តីសន្និដ្ឋានបឋមមួយចំនួន[58]ដែលខ្ញុំបានចាត់ទុកថាបានដោះស្រាយបញ្ហារួចរាល់អស់ហើយ ហើយ ដោយសារពុំមានហេតុផលគួរឲ្យជឿជាក់ ខ្ញុំនឹងមិនពិនិត្យបញ្ហានេះឡើងវិញទេ។ មេធាវីការពារក្តីសន្និដ្ឋានថា ដោយសារស្ថានភាពនានា *ក្នុងនោះ* រួមទាំង ស្ថានភាពថវិការបស់ អ.វ.ត.ក ស.ច.ស ត្រូវលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤[59]។ ស.ច.ស បានបង្ហាញការយល់ឃើញរបស់ខ្លួនរួចហើយពាក់ព័ន្ធនឹងស្ថានភាពថវិកានៅក្នុងដីកាសម្រេចចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ហើយបញ្ហានេះស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួននៅឡើយ[60]។

---

[56] សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (អ.ប.ជ)* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

[57] សំណុំរឿង ០០៤/២ ឯកសារ **D360** *[កោសលុប] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ១៧-៣៨។

[58] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ផ្នែកទី I ស្តីពីអញ្ញត្រកម្ម។។

[59] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៣០៧-៣៥១។

[60] ឯកសារ **D355/9** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧។

ដូចបានកត់សម្គាល់ដោយមេធាវីការពារក្តី[61] ក្រុមប្រទេសម្ចាស់ជំនួយចំបងបានបង្ហាញអំពីការបន្តប្តេជ្ញាមុះមុតផ្តល់ហិរញ្ញវត្ថុសមស្របជូនដល់តុលាការ នៅក្នុងពេលប្រជុំជាមួយ ស.ច.ស កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។ នៅពេលចេញដីកាដំណោះស្រាយរួចហើយ ស.ច.ស បានបំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់ ដោយសំណុំរឿងនេះនឹងបន្តនៅចំពោះមុខចៅក្រម អ.ប.ជ អ.ជ.ស.ជ និង អ.ជ.ត.ក ដើម្បីធានាសិទ្ធិជំនុំជម្រះប្រកបដោយយុត្តិធម៌[62]។

## ២.៣. បទដ្ឋាននៃការបង្ហាញភ័ស្តុតាង

25. ទោះបីជាមេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានផ្ទុយពីនេះក្តី[63] យុត្តិសាស្ត្រជាធរមានបង្ហាញថា បទដ្ឋាននៃការបង្ហាញភ័ស្តុតាងចំពោះសេចក្តីសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺបទដ្ឋាននៃភវនីយភាព[64]។

## ២.៤. ស.ព.អ ស្នើសុំចោទប្រកាន់បញ្ជូនទៅជំនុំជម្រះលើឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ ប៉ុន្តែពុំទាន់មានការចោទប្រកាន់ផ្លូវការនៅឡើយ

26. ទោះបីជា ស.ព.អ ស្នើសុំ ស.ច.ស ចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ[65] ក៏ ស.ច.ស បានបញ្ជាក់ច្បាស់ថា ច្បាប់ពុំអនុញ្ញាតចោទប្រកាន់បញ្ជូនទៅជំនុំជម្រះលើឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ ប៉ុន្តែពុំទាន់មានការចោទប្រកាន់ផ្លូវការនៅឡើយនោះទេ[66]។

---

[61] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៣៤៣។

[62] ឯកសារ **D355/9** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ១៨។ សំណុំរឿង ០០៤/២ ឯកសារ **D360/3** [សាធារណៈ] *សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន* ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៦, ១៣។ សំណុំរឿង ០០៤/២ ឯកសារ **D360** *[កោសលុប] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៤៤-៤៥។

[63] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ទំព័រ ៤៦៩-៤៧៨។

[64] សំណុំរឿង ០០៤/១ ឯកសារ **D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២។

[65] ឯកសារ **D378/2** *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ* ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ១០៧៧-១០៧៩។

[66] សំណុំរឿង ០០៤/១ ឯកសារ **D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២៤៥។ *សូមមើល ផងដែរ* សំណុំរឿង ០០៤/២ ឯកសារ **D360** *[កោសលុប] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំ*

## ៣. ច្បាប់ជាធរមាន

### ៣.១. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក

27. អនុលោមតាមមាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក៖

> "គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ០៦ មករា ១៩៧៩។ ក្នុងចំណោមប្រការផ្សេងៗទៀត កិច្ចព្រមព្រៀងនេះផ្តល់មូលដ្ឋានគតិយុត្តគោលការណ៍ និងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ"។

28. មាត្រា ១ នៃច្បាប់ អ.វ.ត.ក ផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង អ.វ.ត.ក[67] ចែងថា

> "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ៦ មករា ១៩៧៩"។

29. មាត្រា ២ នៃច្បាប់ អ.វ.ត.ក គូសបញ្ជាក់ទៀតថា អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បីនាំមកកាត់ទោស "*មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...] ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ៦ មករា ១៩៧៩*"។

30. អ.ជ.ត.ក បានបកស្រាយពាក្យ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅទៅលើបុគ្គលពីរប្រភេទ ពោលគឺ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម

---

*ជម្រះ)* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៤៧។ សំណុំរឿង ០០៣ ឯកសារ **D267** [កោសលុប] *ដីកាដំណោះស្រាយ* ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[67] មាត្រា ២ នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក។

ដែលស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ព្រមទាំង អ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត។ បុគ្គលទាំងពីរប្រភេទនេះត្រូវជាកម្មាភិបាលខ្មែរក្រហម *និង*ស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ដើម្បីអាចឱ្យ អ.វ.ត.ក អនុវត្តយុត្តាធិការបុគ្គលរបស់ខ្លួនបានសមស្រប។ លក្ខណៈវិនិច្ឆ័យទាំងនេះទាក់ទងគ្នាពុំមែនដាច់ដោយឡែកពីគ្នានោះឡើយ[68]។

31. អ.ជ.ត.ក ក៏បានប្រកាសដោយខ្លួនឯងអំពីយុត្តាធិការនៃមាត្រា ១ នៃច្បាប់ អ.វ.ត.ក។ ដូច្នេះ អ.ជ.ត.ក បានរកឃើញថា បញ្ហាថាតើជនជាប់ចោទគឺជាកម្មាភិបាលខ្មែរក្រហម *"ពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុប្រវត្តិសាស្ត្រ ដែលមានលក្ខណៈងាយយល់ និងច្បាស់លាស់ ហើយផ្ដល់ឆន្ទានុសិទ្ធិតិចតួច ឬ មិនបានផ្តល់ឆន្ទានុសិទ្ធិទាល់តែសោះដល់អង្គជំនុំជម្រះសាលាដំបូង"* ហេតុដូច្នេះ គឺជាបញ្ហាដែលអាចវិនិច្ឆ័យបានដែលមានបញ្ចូលនៅក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក[69]។

32. ផ្ទុយមកវិញ ចំពោះពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អ.ជ.ត.ក បានសម្រេចថា ប្រភេទទាំងពីរនេះពុំមែនជាលក្ខណៈវិនិច្ឆ័យផ្នែកយុត្តាធិការ *យោងតាមន័យដ៏តឹងរ៉ឹងរបស់វានោះទេ* ប៉ុន្តែវាត្រឹមតែពិពណ៌នាទម្រង់នៃគោលនយោបាយចោទប្រកាន់ និងស៊ើបអង្កេតដែលបានប្រើប្រាស់ដោយ ក.ស.ព និងដោយ ក.ស.ច.ស ដោយឯករាជ្យតែប៉ុណ្ណោះ។ អ.ជ.ត.ក បានរកឃើញថា គោលការណ៍ទាំងនេះ ជាគោលការណ៍ ពុំកម្រិតដោយវិធានបកស្រាយតឹងរ៉ឹង និង យោងតាមខ្លឹមសាររបស់វា ពុំអាចយកមកវិនិច្ឆ័យនៅចំពោះមុខ អ.ជ.ស.ដ ឬ អ.ជ.ត.ក ដោយពុំមានបង្ហាញអំពីការបំពានឆន្ទានុសិទ្ធិតាមរយៈការវិនិច្ឆ័យតាមបែបវិជ្ជាជីវៈដែលអសុទ្ធចិត្ត ឬ មិនសមហេតុផល[70]។ ស.ច.ស បានបង្ហាញការយល់ឃើញរបស់ខ្លួនរួមគ្នាចំពោះការបកស្រាយ និងប្រភេទនៃលក្ខណៈវិនិច្ឆ័យនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/០១ (សំអាងហេតុ)[71]។ ដូច្នេះ ចំណុចនេះអនុវត្តដូចគ្នានៅក្នុងរឿងក្ដីនេះ។

*គោលការណ៍ច្បាប់ - អានុភាពនៃ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" និង "ការបកស្រាយតឹងរ៉ឹង"*

---

[68] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៥៧។

[69] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦១។

[70] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៧៩-៨១។

[71] សំណុំរឿង ០០៤/១ ឯកសារ **D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ៩-១០។

33. ក្នុងចំណោមកត្តានានាដែលត្រូវយកមកពិចារណា នៅពេលអនុវត្តឆន្ទានុសិទ្ធិគឺគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយតឹងរ៉ឹងនៃច្បាប់ព្រហ្មទណ្ឌ។ ខ្ញុំសូមយោងលើ *ដីកាដំណោះស្រាយ (សំអាងហេតុ)* នៅក្នុងសំណុំរឿង ០០៤/០១ ចំពោះទឡ្ហីករណ៍លម្អិតលើចំណុចនេះ[72]។

*លក្ខណៈវិនិច្ឆ័យនៃការអនុវត្តឆន្ទានុសិទ្ធិ - ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ*

34. ខ្ញុំសូមកត់សម្គាល់ថា យោងតាមនិយមន័យដូចបានលើកឡើងនៅក្នុងសាលដីកាលើសំណុំរឿង ០០១ អ.ជ.ត.ក បានសម្រេចដោយប្រយោលថា ការអះអាងប្រវត្តិសាស្ត្រ និងនយោបាយពុំសមហេតុផលថា ការចរចាលើការបង្កើត អ.វ.ត.ក នាំឲ្យមានការយល់ឃើញរួមគ្នាជាក់លាក់ថា មានតែបុគ្គល(ដូចមានឈ្មោះ)មួយចំនួនជាក់លាក់ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ ការជ្រើសរើសបុគ្គលមកស៊ើបអង្កេត និងចោទប្រកាន់ គឺជាបញ្ហាឆន្ទានុសិទ្ធិរបស់ ក.ស.ព និង ក.ស.ច.ស សុទ្ធសាធ និងដោយផ្អែកទាំងស្រុងលើអង្គសេចក្តីនៃរឿងក្តីនីមួយៗ។ សម្រាប់ចំណុចលម្អិតពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធិនេះ ខ្ញុំសូមយោងលើ *ដីកាដំណោះស្រាយ (សំអាងហេតុ)* នៅក្នុងសំណុំរឿង ០០៤/១[73]។

## ៣.២. ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក

35. ឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិក្រោមយុត្តាធិការរបស់ អ.វ.ត.ក មានរៀបរាប់នៅក្នុងមាត្រា ៣ ដល់មាត្រា ៨ នៃច្បាប់ អ.វ.ត.ក។ ផ្នែកនេះនឹងសង្ខេបលើតែច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ និងដែលត្រូវបានចោទប្រកាន់ជាផ្លូវការប្រឆាំងនឹង **យឹម ទិត្យ**។

### ៣.២.១. ឧក្រិដ្ឋកម្មអន្តរជាតិ

36. ប្រភពនៃច្បាប់អន្តរជាតិជាធរមាននៅក្នុងអំឡុងពេលពាក់ព័ន្ធគឺអនុសញ្ញាអន្តជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ ដែលសហគមន៍ប្រជាជាតិបានទទួលស្គាល់[74]។ ទោះបីជាយុត្តិសាស្ត្រនៃសាលាក្តី *មិនអចិន្ត្រៃយ៍* ដែលបានបង្កើតឡើងតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ពុំ

---

[72] សំណុំរឿង ០០៤/១ ឯកសារ **D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២៦-៣៦។

[73] សំណុំរឿង ០០៤/១ ឯកសារ **D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ៣៧-៤១។

[74] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧-១៨។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩២។

ចងកាតព្វកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក ក៏ដោយ[75] ក៏អង្គជំនុំជម្រះនៃ អ.វ.ត.ក បានសំអាងយ៉ាងពេញទំហឹងលើការសម្រេចរបស់សាលាក្តីទាំងនេះពាក់ព័ន្ធនឹងធាតុផ្សំនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ដោយ អ.ជ.ត.ក បានកត់សម្គាល់ថា អង្គជំនុំជម្រះមានកាតព្វកិច្ចសម្រេចថា ការសម្រេចបែបនោះអាចអនុវត្តដែរឬទេនៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយអាចប្រមើលមើល និងជនជាប់ចោទអាចដឹងថាមានច្បាប់ចែងនៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងបទចោទដែរឬទេ[76]។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*

37. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការដល់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយចែងថាជា "*អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនាណាមួយ*" ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

38. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លើកលែងតែការរំលោភលើផ្លូវភេទ គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩[77]។ ពាក់ព័ន្ធនឹងការរំលោភលើផ្លូវភេទ អ.ជ.ត.ក បានសម្រេចថា ការរំលោភសេពសន្ថវៈពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដោយឡែក

---

[75] សំណុំរឿង ០០១ ឯកសារ F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧ ដែលយោងទៅមាត្រា ៣៨ នៃលក្ខន្តិកៈសម្រាប់តុលាការយុត្តិធម៌អន្តរជាតិ។

[76] សំណុំរឿង ០០១ ឯកសារ F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧។

[77] <u>ការធ្វើមនុស្សឃាត៖</u> សំណុំរឿង ០០២ ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១១។ <u>ការសម្លាប់រង្គាល៖</u> សំណុំរឿង ០០២ ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៥។ <u>ការធ្វើឲ្យទៅជាទាសករ៖</u> សំណុំរឿង ០០១ ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤២។ <u>ការនិរទេស៖</u> ឯកសារ D427 *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣១៤។ <u>ការដាក់ក្នុងមន្ទីរឃុំឃាំង៖</u> សំណុំរឿង ០០១ ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៧។ <u>ការធ្វើទារុណកម្ម៖</u> សំណុំរឿង ០០១ ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥៣។ សំណុំរឿង ០០១ ឯកសារ F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-២០៥។ <u>ការធ្វើទុកបុកម្នេញ៖</u> សំណុំរឿង ០០២ ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៦។ សំណុំរឿង ០០១ ឯកសារ F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២២៥។ <u>អំពើអមនុស្សធម៌ផ្សេងទៀត៖</u> សំណុំរឿង ០០២ ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៧៦។ សំណុំរឿង ០០២ ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៥។

ពីគេនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ នោះទេ ដែលជារយៈពេលស្ថិតនៅក្រោមយុត្តាធិការ អ.វ.ត.ក[78]។ ទោះបីជាយ៉ាងនេះក៏ដោយ អ.វ.ត.ក មានយុត្តាធិការលើការរំលោភលើផ្លូវភេទ ដែលជាអំពើទារុណកម្ម នៅពេលធាតុផ្សំនៃអំពើទារុណកម្មផ្សេងទៀតបានបំពេញ[79] និងជាអំពើមួយដែលជាអំពើអមនុស្សធម៌ផ្សេងទៀត[80]។

*ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

39. ***អត្ថិភាពនៃការវាយប្រហារ*** - ការវាយប្រហារគឺជាដំណើរនៃការប្រព្រឹត្តពាក់ព័ន្ធនឹងអំពើហិង្សាដែលពុំកម្រិតត្រឹមការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធតែប៉ុណ្ណោះនោះទេ វាអាចរួមបញ្ចូលការធ្វើបាបលើប្រជាជនស៊ីវិលផងដែរ។ ការវាយប្រហារលើប្រជាជនស៊ីវិលគឺជាទស្សនទានមួយខុសពីទស្សនទាននៃជម្លោះប្រដាប់អាវុធ[81]។

40. ***ការវាយប្រហារដែលមានលក្ខណៈប្រព័ន្ធ ឬ រីករាលដាល*** - លក្ខខណ្ឌនៃ "ការរីករាលដាល" សំដៅលើការវាយប្រហារដែលមានទ្រង់ទ្រាយធំ និងចំនួនជនរងគ្រោះ ចំណែកធាតុផ្សំនៃលក្ខណៈ "ជាប្រព័ន្ធ" សំដៅលើអំពើហិង្សាដែលមានការរៀបចំ។ បទដ្ឋានភ័ស្តុតាងនៃលក្ខណៈជាប្រព័ន្ធ ឬ រីករាលដាល នៃការវាយប្រហារ មានលក្ខណៈគ្រប់គ្រាន់សម្រាប់បំពេញ*ធាតុផ្សំទូទៅ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[82]។

41. ***ការសំដៅលើប្រជាជនស៊ីវិល*** - ការវាយប្រហារត្រូវសំដៅជាចំបងលើប្រជាជនស៊ីវិល[83]។ គេពុំចាំបាច់បង្ហាញថា ប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រមួយជាកម្មវត្ថុនៃការវាយប្រហារនោះ

---

[78] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៨០-១៨៣។

[79] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៧-២០៨, ២១៣។

[80] សំណុំរឿង ០០២ ឯកសារ **D427/2/12** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ* សេចក្តីបង្គាប់ចំណុច ១១(២)។ សំណុំរឿង ០០២ ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៤៣៣។ *សូមមើល ផងដែរ រឿងក្តីរវាងរដ្ឋអាជ្ញា ទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿង ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦៦៨។

[81] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៨។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៩៨-២៩៩។

[82] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៩។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០០។

[83] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨២។ រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩១-៩២។

ទេ។ វាគ្រប់គ្រាន់ដោយគ្រាន់តែបង្ហាញថា បុគ្គលក្នុងចំនួនគ្រប់គ្រាន់ត្រូវបានគេកំណត់គោលដៅនៅក្នុងពេលវាយប្រហារ ឬ ពួកគេគឺជាគោលដៅ ដោយត្រូវបង្ហាញថា ការវាយប្រហារនោះគឺសំដៅលើ "ប្រជាជន" ស៊ីវិល ពុំមែនបុគ្គលមួយចំនួនដែលគេកម្រិត និងជ្រើសរើសចោះៗនោះទេ[84]។ ប្រជាជនដែលរងការវាយប្រហារត្រូវភាគច្រើនមានលក្ខណៈជាជនស៊ីវិល[85]។ ពីបុរមបុរាណមក វត្តមាន នៅក្នុងចំណោមប្រជាជនស៊ីវិល របស់បុគ្គលដែលពុំចាត់ទុកជាជនស៊ីវិល ពុំធ្វើឲ្យប្រជាជនបាត់បង់លក្ខណៈជាជនស៊ីវិលរបស់ខ្លួននោះទេ[86]។ ខ្ញុំយល់ឃើញថា ការវាយប្រហារដោយរដ្ឋ ឬ អង្គការមួយប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធខ្លួនឯង គឺជាការវាយប្រហារលើជនស៊ីវិល លើកលែងតែ កងកម្លាំងប្រដាប់អាវុធដែលត្រូវបានគេវាយប្រហារនោះគឺជាសម្ព័ន្ធមិត្តជាមួយ ឬ បានផ្ដល់ការគាំទ្រពាក់ព័ន្ធនឹងផ្នែកយោធាដល់គូបដិបក្ខនៃជម្លោះប្រដាប់អាវុធ[87]។

42. ***មូលហេតុជាតិសាសន៍ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនា*** - មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ទាមទារលក្ខខណ្ឌថា ការវាយប្រហារដូចបានកំណត់នៅក្នុងចំណុចខាងលើ ត្រូវធ្វើឡើងដោយផ្អែកលើមូលហេតុជាតិសាសន៍ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនា ប៉ុន្តែ ពុំចាំបាច់ដោយមូលហេតុនៃការរើសអើងនោះឡើយ។ នេះគឺជាលក្ខខណ្ឌយុត្តាធិការ ដែលអនុវត្តចំពោះការវាយប្រហារទូទៅ ហើយពុំមែនចំពោះបទល្មើសជាក់លាក់ណាមួយនោះទេ។ ហេតុដូច្នេះ គេពុំចាំបាច់

---

[84] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧-១៨។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨២។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០៣។

[85] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៣៨, ៧៤០។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្ដីរវាងរដ្ឋអាជ្ញា ទល់នឹង Milošević* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-98-29/1-A) ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៥០-៥១។

[86] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤០។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្ដីរវាងរដ្ឋអាជ្ញា ទល់នឹង Galić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-98-29-A) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៣៦- ១៣៨។

[87] សំណុំរឿង ០០៤/២ ឯកសារ **D347.1** *ការជូនដំណឹងស្ដីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ* ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ ៦៩។ ខ្ញុំកត់សម្គាល់លើជំហររបស់អង្គជំនុំជម្រះសាលាដំបូងអំពីបញ្ហានេះ ដូចបានលើកឡើងនៅក្នុងសាលក្រមសំណុំរឿង ០០២/០២ (សំណុំរឿង ០០២ ឯកសារ **E465** *សាលក្រមសំណុំរឿង ០០២/០២* ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៣០៦) ប៉ុន្តែ ដោយសារសាលក្រមនេះក្នុងកំពុងរងការប្ដឹងសាទុក្ខ ខ្ញុំមិនអាចយកចំណុចនេះមកលើកឡើងនៅពេលនេះបានទេ។

បង្ហាញចេតនារើសអើងសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ណាមួយនោះទេ។ ចេតនារើសអើងគឺជាលក្ខខណ្ឌតែមួយគត់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ[88]។

43. ***ចំណងទាក់ទងរវាងអំពើរបស់ជនត្រូវចោទ និងការវាយប្រហារ*** - អំពើរបស់ចារី យោងតាមធម្មជាតិ ឬ ផលវិបាករបស់វា តាមលក្ខណៈសត្យានុម័ត ត្រូវជាផ្នែកនៃការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល[89]។

44. ***លក្ខខណ្ឌនៃការដឹងឮ*** - ចារីត្រូវដឹងថាមានការវាយប្រហារលើជនស៊ីវិល ហើយអំពើរបស់ខ្លួនគឺជាផ្នែកនៃការវាយប្រហារនោះ។ ចារីពុំចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬ មានគោលបំណង ឬ គោលដៅរួមនៃការវាយប្រហារក្នុងលក្ខណៈទូលំទូលាយឡើយ[90]។

45. ***ពុំចាំបាច់មានចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធនោះឡើយ*** - នៅក្នុងសេចក្ដីសម្រេចជាសាធារណៈមួយដែលបានធ្វើឡើងនៅក្នុងសំណុំរឿង ០០៣ ខ្ញុំបានសម្រេចថា អត្ថិភាពនៃចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាមួយនឹងជម្លោះប្រដាប់អាវុធ លែងជាធាតុផ្សំតាម

---

[88] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤២, ៧៤៤-៧៤៥។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៨-១៨៩។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨។ *សូមមើល ផងដែរ* រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Akayes សាលដីកា* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR (សំណុំរឿង ICTR-96-4-A) ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៤៦៥-៤៦៦។

[89] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៥៣-៧៥៤។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩០។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣១៨។ រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩៩។

[90] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩១។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣១៩។ រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១០២-១០៣។

ផ្លូវច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៀតហើយគិតត្រឹមឆ្នាំ១៩៧៥[91]។ អ.ប.ជ អ.ជ.ស.ដ និង អ.ជ.ត.ក បានធ្វើការសម្រេចដូចគ្នាទាំងអស់[92]។

*ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក*

46. ធាតុផ្សំនៃ**អំពើមនុស្សឃាត** រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬ អកម្ម ដែលបណ្ដាលឲ្យជនរងគ្រោះស្លាប់[93]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចេតនារបស់ចារីចង់សម្លាប់ ឬ បង្កឲ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ[94]។

47. ធាតុផ្សំនៃ**ការសម្លាប់រង្គាល**រួមមាន៖

---

[91] សំណុំរឿង ០០៣ ឯកសារ **D87/2/1.7/1** *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦។

[92] *សូមមើល* សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៧ និង សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧២១។ អ.ប.ជ ពិតជាបានសម្រេចនៅក្នុងឆ្នាំ ២០១១ ថាចំណងទាក់ទង គឺជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ *សូមមើល* សំណុំរឿង ០០២ ឯកសារ **D427/3/15** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៤៤ និង សំណុំរឿង ០០២ ឯកសារ **D427/1/30** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៣១១។ ប៉ុន្តែ តាមរយៈបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណុំរឿង ០០៣ របស់ខ្ញុំ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ (សំណុំរឿង០០៣ ឯកសារ **D87/2/1.7/1** *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦) អ.ប.ជ បានពិចារណាឡើងវិញទៅលើជំហរពីមុនរបស់ខ្លួន និងបានសម្រេចថា ពុំតម្រូវឲ្យមានចំណងទាក់ទងទេ ដើម្បីឲ្យស្របគ្នាជាមួយនឹងអង្គជំនុំជម្រះដទៃទៀតរបស់ អ.វ.ត.ក។ *សូមមើល* សំណុំរឿង ០០៣ ឯកសារ **D87/2/1.7/1/1/7** *សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧។

[93] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១២។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣១។

[94] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣៩១, ៤០៩, ៤១០។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១២។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៣។

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម អកម្ម ឬ អំពើនេះទាំងពីររួមគ្នា ដែលបណ្តាលឲ្យមនុស្សច្រើនស្លាប់[95]។ គ្មានលក្ខខណ្ឌទាមទារចំនួនអប្បបរមានៃជនរងគ្រោះ ដើម្បីបង្ហាញអំពីការសម្លាប់រង្គាលនេះឡើយ[96]។ ការវាយតម្លៃនៃលក្ខខណ្ឌ "ទ្រង់ទ្រាយធំ" ត្រូវធ្វើឡើងទៅតាមករណីនីមួយៗ ដោយត្រូវពិចារណាលើកត្តានានា ដូចជា ពេលវេលា និងទីកន្លែងកាប់សម្លាប់ ការជ្រើសរើសជនរងគ្រោះ និងវិធីដែលពួកគេត្រូវបានកំណត់គោលដៅ ហើយថាតើការកាប់សម្លាប់បានសំដៅលើក្រុមរួម ពុំមែនសំដៅលើជនរងគ្រោះដោយសារមុខងាររបស់ពួកគេម្នាក់ៗនោះទេ[97]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬ បង្កព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ឬ បង្កើតលក្ខខណ្ឌរស់នៅដែលនាំឲ្យការបំផ្លិចបំផ្លាញប្រជាជនមួយផ្នែកធំ[98]។ អ.ជ.ត.ក បានប្រកាន់ជំហរថា គោលបំណងនៃការសម្លាប់រង្គាល គឺត្រូវកម្ចាត់បុគ្គលដែលជាផ្នែកមួយនៃក្រុម ហេតុដូច្នេះ វាពុំស៊ីសង្វាក់ជាមួយនឹងសញ្ញាណ *ចេតនាប្រយោល* ។ បន្ទាប់មក អ.ជ.ត.ក បានបញ្ជាក់បំភ្លឺថា ការដឹងឮថា *ធាតុផ្សំសត្យានុម័ត* នឹងបង្កឲ្យមានមរណភាពជាក់លាក់ ពុំជាលក្ខខណ្ឌទាមទារ ប៉ុន្តែ អ្វីដែលសំខាន់គឺ *"ការបង្ហាញឲ្យឃើញថា ការសម្លាប់សមាជិកនៃក្រុមមួយ គឺជាចេតនារបស់ចារី ដោយពុំគិតពីបញ្ហាថាតើចារីបានដឹងច្បាស់ថា ការសម្លាប់នេះនឹងកើតឡើងជាក់ស្តែងដែរ ឬ យ៉ាងណានោះឡើយ។ ការគ្រាន់តែដឹងថា មានការស្លាប់កើតឡើងពុំគ្រប់គ្រាន់ឡើយ"*[99]។

---

[95] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៤។

[96] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៦។

[97] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២៥, ៥២៧។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Lukić និង Lukić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-98-32/1-A) ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៥៣៨។

[98] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០-៥២២ ដែលយោងទៅរឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿង IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥០៣។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៨។

[99] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០។

48. ធាតុផ្សំនៃ**ការធ្វើឲ្យទៅជាទាសករ**រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការប្រើប្រាស់អំណាចណាមួយ ឬ អំណាចទាំងអស់នៃសិទ្ធិកម្មសិទ្ធិលើបុគ្គល[100]។ ការងារដោយបង្ខំ ឬ ដោយមិនស្ម័គ្រចិត្តអាចជាការធ្វើឲ្យទៅជាទាសករ[101]។ ការបង្ហាញភ័ស្តុតាងនៃការធ្វើបាបពុំចាំបាច់ក្នុងការសម្រេចអំពីអត្ថិភាពចំពោះឧក្រិដ្ឋកម្មនៃការធ្វើឲ្យទៅជាទាសករឡើយ[102]។

ខ. ធាតុផ្សំ*អត្តនោម័ត៖* ចារីត្រូវមានចេតនាប្រើប្រាស់អំណាច ដែលមានជាប់មកជាមួយនឹងភាពជាកម្មសិទ្ធិលើបុគ្គលម្នាក់[103]។

49. ធាតុផ្សំនៃ**ការនិរទេស**រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការជម្លៀសប្រជាជនដោយបង្ខំដោយការបណ្ដេញចេញ ឬ តាមរយៈអំពើចាប់បង្ខំណាមួយ ចេញពីតំបន់ដែលពួកគេមានវត្តមានដោយស្របច្បាប់ ឆ្លងកាត់ព្រំដែនជាតិដោយពុំមានមូលដ្ឋានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ[104]។ ការបង្ខំលើរូបកាយពុំមែនជាលក្ខខណ្ឌ

---

[100] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៥២-១៥៣។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤២។

[101] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៤។ រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿង IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ៣៥៩។ រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៥៤២-៥៤៣។

[102] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៤។ រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១២៣ ដែលយោងទៅរឿងក្ដីរវាង *ស.រ.អា ទល់នឹង Oswald Pohl និងអ្នកផ្សេងទៀត* សាលដីកា ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៤៧ ដែលបានបោះពុម្ពឡើងវិញក្នុង*ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធានូរ៉ឹមប៊ឺក* នៅក្រោមច្បាប់ស្ដីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល ៥ (១៩៩៧) កថាខណ្ឌ ៩៥៦ ទំព័រ ៩៧០។

[103] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៥២។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៥។ រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១២២។

[104] រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Stakić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-97-24-A) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៧៨-២៧៩, ២៨១, ៣០០។

តម្រូវនោះទេ ពោលគឺ ការជម្លៀសដោយបង្ខំត្រូវកំណត់ដោយនត្ថិភាពនៃជម្រើសពិតប្រាកដរបស់បុគ្គល[105]។ ការជម្លៀសដោយមូលហេតុមនុស្សធម៌ពុំមែនជាហេតុផលអាចយកមកបង្ហាញនោះទេ ដែលវិបត្តិតម្រូវឱ្យជម្លៀសបែបនោះបានបណ្ដាលមកពីសកម្មភាពខុសច្បាប់របស់អ្នកជម្លៀសគេនោះ[106]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីមានចេតនាជម្លៀសដោយបង្ខំជនរងគ្រោះឆ្លងកាត់ព្រំដែន។ ចេតនាជម្លៀសបុគ្គលឆ្លងកាត់ព្រំដែនជាអចិន្ត្រៃយ៍ពុំមែនជាលក្ខខណ្ឌតម្រូវនោះទេ[107]។

50. ធាតុផ្សំនៃ**ការដាក់ក្នុងមន្ទីរឃុំឃាំង**រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការដកហូតសេរីភាពតាមអំពើចិត្តដោយពុំមានការដំណើរការត្រឹមត្រូវតាមផ្លូវចិត្ត ឬ ដោយផ្អែកលើបទប្បញ្ញត្តិច្បាប់ជាតិ ដែលរំលោភច្បាប់អន្តរជាតិ[108]។ ពុំមែនរាល់ការរំលោភអប្បបរមាលើសិទ្ធិសេរីភាពគឺជាការដាក់ក្នុងមន្ទីរឃុំឃាំងនោះទេ ហើយការដកហូតបែបនេះត្រូវមានស្ថានទម្ងន់ និងមានភាពធ្ងន់ធ្ងរស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀត ដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[109]។

---

[105] រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង* *Stakić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-97-24-A) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៧៩-២៨១។

[106] រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង* *Stakić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-97-24-A) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៨៧។

[107] រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង* *Stakić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-97-24-A) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៧៨, ៣០៧។

[108] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៧-៣៤៨។

[109] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៩ *ដែលយោងទៅលើរឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង* *Ntagerura* *និងជនជាប់ចោទផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿង ICTR-99-46-T) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ៧០២។ *ផ្ទុយពីរឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង* *Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿង IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១១២។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីមានចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល ឬ បានធ្វើសកម្មភាពដោយដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនទំនងជាបង្កការដកហូតដល់ការដកហូតសេរីភាពតាមអំពើចិត្ត[110]។

51. ធាតុផ្សំនៃ**ការធ្វើទារុណកម្ម**រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើណាមួយដែលបណ្តាលឲ្យមានការឈឺចាប់ ឬ រងទុក្ខធ្ងន់ធ្ងរ ដោយត្រូវពិចារណាលើភាពធ្ងន់ធរនៃព្យសនកម្មទាំងលើកត្តាអត្តនោម័ត និងកត្តាសត្យានុម័តចំពោះជនរងគ្រោះ មិនថាផ្នែករាងកាយ ឬ ស្មារតី ដែលត្រូវបានប្រព្រឹត្ត ឬ ញុះញង់ដោយមន្ត្រីសាធារណៈ[111]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវមានចេតនាបង្កការឈឺចាប់ ឬ ទុក្ខវេទនាលើជនរងគ្រោះ[112]។

គ. អំពើត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានព័ត៌មាន ឬ ចម្លើយសារភាព ដាក់ទណ្ឌកម្ម ឬ ការបំភិតបំភ័យ[113]។

52. អ.ជ.ត.ក បានសម្រេចថា **ការរំលោភសេពសន្ថវៈ** អាចជាអំពើទារុណកម្ម នៅពេលដែលធាតុផ្សំទាំងអស់ផ្សេងទៀតនៃបទទារុណកម្ម ត្រូវបានរកឃើញ[114]។ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០១ បានឯកភាពជាមួយនឹង អ.ជ.ត.ក[115] ដោយបានកំណត់ការរំលោភសន្ថវៈដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការបញ្ចូលអង្គជាតិ ទោះបីជាមិនបានស៊ីជម្រៅក៏ដោយ ទៅក្នុងរន្ធយោនី ឬ រន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតិរបស់ចារី ឬ វត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬ ការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតិរបស់ចារី នៅពេលដែលការបញ្ចូលអង្គជាតិនោះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ។ ការយល់ព្រម ក្នុងគោលបំណងនេះ

---

[110] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥០។ *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿង IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០២ កថាខណ្ឌ ១១៥។

[111] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥៥។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[112] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[113] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[114] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៧-២០៨, ២១៣។

[115] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៨។

ត្រូវធ្វើការវាយតម្លៃដោយស្ម័គ្រចិត្តនៅក្នុងបរិបទនៃកាលៈទេសៈជុំវិញ ដោយសារលទ្ធផលនៃឆន្ទៈដោយសេរីរបស់ជនរងគ្រោះ [116]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវធ្វើសកម្មភាពក្នុងចេតនាដើម្បីសម្រេចការសកបញ្ចូលអង្គជាតិ ទោះដឹងថាពុំមានការយល់ព្រមពីជនរងគ្រោះក៏ដោយ[117]។

53. ធាតុផ្សំនៃ**ការធ្វើទុក្ខបុកម្នេញ**រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬ អកម្ម ដែលមានការរើសអើងជាក់ស្តែង និងបដិសេធ ឬ រំលោភលើសិទ្ធិជាមូលដ្ឋាន ដែលមានចែងនៅក្នុងសន្ធិសញ្ញា ឬ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ[118]។ ធាតុផ្សំរើសអើងនៅក្នុង*ធាតុផ្សំសត្យានុម័ត* ត្រូវបង្ហាញនៅពេលជនរងគ្រោះត្រូវបានកំណត់គោលដៅ ដោយសារសមាជិកភាពក្រុម ដែលត្រូវបានកំណត់និយមន័យតាមកត្តាអត្តនោម័ត ហើយត្រូវបានចារីធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា[119]។ ជនរងគ្រោះត្រូវជាក្រុមនយោបាយ ឬ សាសនា ជាក់ស្តែងគ្រប់គ្រាន់ ដែលកើតមានផលវិបាកនៃការធ្វើទុក្ខបុកម្នេញលើក្រុមនេះ[120]។ ត្រង់ចំណុចនេះ អ.ជ.ត.ក បានសម្រេចថា គ្មានការរើសអើងនៅពេលមានការភាន់ច្រឡំអង្គហេតុដោយចារីមិនដឹងថាជនរងគ្រោះស្ថិតនៅក្នុងក្រុមគោលដៅដូចបានកំណត់ដែរឬទេ ឬ នៅពេលចារីកំណត់គោលដៅជនរងគ្រោះ ដោយមិនគិតថាជនរងគ្រោះស្ថិតនៅក្នុង លក្ខណៈវិនិច្ឆ័យនៃការរើសអើង ដែរឬយ៉ាងណា ឬក៏អាចនិយាយបានថា នៅពេលមានការ

---

[116] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦២។ រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១២៧។

[117] សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦៥។

[118] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៧-៦៦៨។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៥៧, ២៦១-២៦២, ២៦៧, ២៧១-២៧៨។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៧-៤២៨។

[119] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៧, ៦៦៨-៦៦៩, ៦៨៧, ៦៩៥។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧២-២៧៣, ២៧៤, ២៧៦-២៧៧។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៨។

[120] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៨។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧៤-២៧៧។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៨។

កំណត់គោលដៅ "*ដោយមិនរើសមុខ*"[121]។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវពិចារណាលើទស្សនៈរបស់ចារី នៅពេលកំណត់និយមន័យលើក្រុមដែលកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ ហើយពុំទាមទារលក្ខខណ្ឌថា សមាជិកនៃក្រុមគោលដៅមានការប្រកាន់ទស្សនៈនយោបាយរួមនោះទេ[122]។

ខ. ការធ្វើទុក្ខបុកម្នេញអាចត្រូវបានប្រព្រឹត្តឡើងតាមរយៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ ឬច្រើន ដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ព្រមទាំងតាមរយៈអំពើផ្សេងទៀត ដែលត្រូវបានកំណត់លក្ខណៈដោយកម្រិតនៃស្ថានភាព ឬ ភាពធ្ងន់ធ្ងរដូចគ្នា រួមទាំងអំពើដែលពុំចាំបាច់ជាឧក្រិដ្ឋកម្មអន្តរជាតិដោយខ្លួនវា[123]។

គ. *ធាតុផ្សំអត្តនោម័ត៖* ការប្រព្រឹត្តដោយចេតនានៃអំពើសកម្ម ឬ អំពើអកម្មដោយមានចេតនារើសអើងលើមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា[124]។ សូម្បីនៅពេលអំពើទាំងនោះគឺជាឧក្រិដ្ឋកម្មនៅក្រោមច្បាប់អន្តរជាតិ *ធាតុផ្សំអត្តនោម័ត* ដែលទាមទារចំពោះឧក្រិដ្ឋកម្មទាំងនោះ ពុំចាំបាច់បង្ហាញនោះទេ ពោលគឺ វាគ្រប់គ្រាន់នៅពេលត្រឹមតែបង្ហាញថា អំពើទាំងនោះត្រូវបានប្រព្រឹត្តឡើងក្នុងចេតនារើសអើង ស្របតាមលក្ខខណ្ឌដែលមានចែង[125]។

54. ធាតុផ្សំនៃ**អំពើអមនុស្សធម៌ផ្សេងទៀត**រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬ អកម្មរបស់ចារី ដែលបណ្តាលឱ្យមានការឈឺចាប់ ឬ ព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬ ផ្លូវចិត្ត ឬ ជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស

---

[121] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧៧ *សូមមើល ផងដែរ* កថាខណ្ឌ ២៧២-២៧៦។

[122] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៨-៦៦៩, ៦៧៧-៦៨០។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧២-២៧៣។

[123] សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៦១។ *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ២៩៦។ *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Blaškić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៣៥។

[124] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៧។ សំណុំរឿង ០០១ ឯកសារ **F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២២៩, ២៣៦, ២៤០។

[125] *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Popović និងជនជាប់ចោទដទៃទៀត* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿង IT-05-88-A) ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៧៣៨។

ជាតិ[126]។ អំពើសកម្ម ឬ អំពើអកម្មរបស់ចារីត្រូវមានលក្ខណៈ និងភាពធ្ងន់ធ្ងរស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដូចមានចែងរៀបរាប់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដោយត្រូវវាយតម្លៃទៅតាមករណីនីមួយៗ និងពិចារណាលើកាលៈទេសៈនៃរឿងក្តីនីមួយៗ[127]។ ផលប៉ះពាល់នៃការឈឺចាប់ ពុំចាំបាច់ទាល់តែមានរយៈពេលយូរនោះទេ ទោះបីជាករណីនេះអាចជាកត្តាពាក់ព័ន្ធសម្រាប់កំណត់លើភាពធ្ងន់ធ្ងរនៃអំពើក៏ដោយ[128]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវធ្វើសកម្មភាពសកម្ម ឬ អកម្មក្នុងចេតនាដើម្បីបណ្តាលឱ្យមានការឈឺចាប់ ឬ ព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬ ផ្លូវចិត្ត ឬ ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិរបស់ជនរងគ្រោះនៅពេលប្រព្រឹត្តអំពើសកម្ម ឬ អកម្ម ឬ ដោយបានដឹងថា អំពើសកម្ម ឬ អំពើអកម្មនោះទំនងជាបណ្តាលឱ្យមានការឈឺចាប់ ឬ ព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬ ផ្លូវចិត្ត ឬ ជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[129]។

55. អំពើអមនុស្សធម៌អន្តរជាតិមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាប្រភេទដែលនៅសេសសល់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៥[130]។ ការប្រព្រឹត្តដែលជាអំពើអមនុស្សធម៌ផ្សេងទៀតពុំចាំបាច់ត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌនៅក្រោមច្បាប់អន្តរជាតិនោះទេ នៅពេលប្រព្រឹត្តនោះ[131]។ វាគ្រប់គ្រាន់ប្រសិនបើអំពើមួយជាក់លាក់បានបំពេញធាតុផ្សំផ្លូវច្បាប់នៃអំពើអមនុស្សធម៌ផ្សេងទៀត នៅបេលពិចារណាលើកាលៈទេសៈនានានៃរឿងក្តីនៅចំពោះមុខ[132]។ អាស្រ័យហេតុនេះ ធាតុផ្សំនៃអំពើដែលត្រូវបានចោទប្រកាន់ថាជាអំពើអមនុស្សធម៌ផ្សេងទៀត ពុំចាំបាច់ទាល់តែមានចែងនោះទេ។

---

[126] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨០។

[127] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៦៧, ៥៨៦។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៨។

[128] សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៩។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦៩។

[129] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨០។ សំណុំរឿង ០០២ ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៧។ សំណុំរឿង ០០១ ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៧១។

[130] សំណុំរឿង ០០២ ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៧៦។

[131] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៥៨៤។

[132] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៥៨៩។

56. ទោះបីជាយ៉ាងនេះក្ដី វាអាចគ្រប់គ្រាន់ដោយត្រឹមបង្ហាញឱ្យឃើញដែនកំណត់នៃអំពើជាក់លាក់មួយ ដើម្បីកំណត់ថាតើ ជនត្រូវចោទអាចប្រមើលមើលឃើញ និងអាចដឹងថាមានច្បាប់ចែងថា ខ្លួនអាចត្រូវបានស៊ើបអង្កេត និងចោទប្រកាន់ចំពោះអំពើបែបនោះ[133]។ គោលការណ៍*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ត្រូវគោរពប្រសិនបើការប្រព្រឹត្តជាក់លាក់មួយរំលោភលើសិទ្ធិមូលដ្ឋានរបស់ជនរងគ្រោះ ហើយមានលក្ខណៈ និងទម្ងន់ស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀត ដែលតម្រូវឱ្យមានការវិភាគអំពើនោះទៅតាមករណីនីមួយៗ[134]។

57. ដើម្បីអនុវត្តតាមលក្ខខណ្ឌនៃសច្ចភាពផ្លូវច្បាប់ ការប្រៀបធៀបប្រភេទ និងភាពធ្ងន់ធ្ងរនៃអំពើជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែង ត្រូវធ្វើឡើងស្របតាមទ្រឹស្ដីនៃ*ការប្រៀបធៀបទូទៅ*[135]។ ចំពោះលក្ខណៈនៃការប្រព្រឹត្តដែលអាចជាអំពើអមនុស្សធម៌ផ្សេងទៀត គេអាចមើលយោងលើការបំពានធ្ងន់ធ្ងរនៃច្បាប់អន្តរជាតិ ដែលចែងអំពីជម្លោះប្រដាប់អាវុធចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩ រួមទាំង បទប្បញ្ញត្តិស្ដីពីការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឬ ការរំលោភធ្ងន់ធ្ងរនៃនិយាមសិទ្ធិមនុស្សជាមូលដ្ឋាន ដែលត្រូវបានការពារនៅក្រោមច្បាប់អន្តរជាតិនៅពេលនោះ[136]។

58. ករណីនៃការបាត់ខ្លួនដោយបង្ខំ[137] ការរំលោភសេពសន្ថវៈ[138] ការបំពានរូបកាយអ្នកទោស[139] លក្ខខណ្ឌអមនុស្សធម៌នៃការឃុំខ្លួន[140] ការជម្លៀសដោយបង្ខំ[141] និងអាពាហ៍ពិពាហ៍ដោយបង្ខំ[142]

---

[133] ឯកសារ **D301/5** *ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និងបង្កឱ្យមានផ្ទៃពោះដោយបង្ខំ* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ៥១, ៦៣។

[134] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៥៨៦។ *សូមមើលផងដែរ* ឯកសារ **D301/5** *ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និងបង្កឱ្យមានផ្ទៃពោះដោយបង្ខំ* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ៦៤។

[135] *Ejusdem generis* ត្រូវបានកំណត់និយមន័យថាជា "*គោលការណ៍នៃការបង្កើតឃ្លាប្រយោគ គឺថា នៅពេលដែលពាក្យ ឬប្រយោគទូទៅមួយ ដាក់នៅខាងក្រោយបញ្ជីពាក្យជាក់លាក់ ពាក្យ ឬប្រយោគទូទៅនោះ ត្រូវបកស្រាយដោយដាក់បញ្ចូលតែចំនួនពាក្យទាំងឡាយដែលស្ថិតក្នុងប្រភេទដូចគ្នាទៅនឹងពាក្យដែលមានក្នុងបញ្ជី*" (វេចនានុក្រមច្បាប់ Black កំណែទី៩)។

[136] សំណុំរឿង ០០២-ឯកសារ **D427/3/15** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១៦៤។ ឯកសារ **D301/5** *ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និងបង្កឱ្យមានផ្ទៃពោះដោយបង្ខំ* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ៦៣។

[137] សំណុំរឿង ០០២-ឯកសារ **E313** *សាលក្រម* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៤៤-៤៤៨។ *រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-16-T) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០

ធ្លាប់ត្រូវបានរកឃើញថាមានលក្ខណៈ និងភាពធ្ងន់ធ្ងរដូចគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀតដូចមានចែង។

*អំពើប្រល័យពូជសាសន៍*

59. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក បានផ្តល់យុត្តាធិការដល់ អ.វ.ត.ក លើបទប្រល័យពូជសាសន៍ ដោយផ្អែកលើមាត្រា II និង III នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍[143] ដែលជាផ្នែកមួយនៃច្បាប់

---

កថាខណ្ឌ៥៦៦។ *រដ្ឋអាជ្ញា តទល់នឹង* Brima *និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ SCSL ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ១៨៤។

[138] សំណុំរឿង ០០២-ឯកសារ **D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១៥៤។ សំណុំរឿង ០០២-ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៤៣៣។ *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៦៨៨។

[139] *រដ្ឋអាជ្ញា តទល់នឹង Kvocka* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-30/1-T) ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ២០៨, ២០៩។

[140] *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៣៣។

[141] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៦៥៤-៦៦០។

[142] សំណុំរឿង ០០២-ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៣១៤។

[143] មាត្រា៤ នៃច្បាប់ អ.វ.ត.ក មិនដាក់ទណ្ឌកម្មចំពោះការញុះញង់ជាសាធារណៈ និងដោយផ្ទាល់ ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬសមគំនិតក្នុងអំពើប្រល័យពូជសាសន៍ទេ ដោយបញ្ញត្តិនេះមានចែងក្នុងកថាខណ្ឌ (គ) និង (ង) នៃមាត្រា III នៃអនុសញ្ញាស្តីពីការបង្ការ និងដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ("អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍")។ និយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍ ដែលមានចែងនៅក្នុងមាត្រា៤ នៃច្បាប់ អ.វ.ត.ក ជាភាសាអង់គ្លេស អាចត្រូវបានបកស្រាយថា បានបង្កើតបញ្ជីមិនពិស្តារនៃអំពើដែលបង្កើតបានជា អំពើប្រល័យពូជសាសន៍ (*"បែបនេះ"*) និងបានដកចេញការយោងទៅការបំផ្លាញ (ទាំងស្រុង ឬមួយផ្នែក) នៃក្រុមដែលទទួលបានការការពារ *"បែបនេះ"* ដែលចំណុចទាំងពីរនេះផ្ទុយទៅនឹងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងបង្កើតបានជាយុត្តិសាស្ត្រ។ ផ្ទុយទៅនឹងចំណុចនេះ មាត្រា៤ ជាភាសាបារាំង ឆ្លុះបញ្ចាំងពីបទបញ្ញត្តិនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍: *"On entend par crime de génocide, qui est imprescriptible l'un quelconque des actes ci-après, commis dans l'intention de détruire, en tout ou en partie, un groupe national, ethnique, racial ou religieux, comme tel"*។ ច្បាប់ អ.វ.ត.ក ជាភាសាខ្មែរ មានភាពស្រដៀងគ្នាបំផុតទៅនឹងអត្ថបទនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ក្នុងន័យថា ច្បាប់នេះកម្រិតអំពើដែលបង្កើតបានជាអំពើប្រល័យពូជសាសន៍ ដូចមានចែងក្នុងមាត្រា៤នៃច្បាប់ "អំពើប្រល័យពូជសាសន៍ ដែលគ្មានអាជ្ញាយុកាល គឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា" ។ មាត្រា៩ នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា៤ នៃច្បាប់ អ.វ.ត.ក ទាំងពីរកំណត់ថា យុត្តាធិការរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹង អំពើប្រល័យពូជសាសន៍ ត្រូវបានកម្រិតត្រឹមឧក្រិដ្ឋកម្ម *"ដូចដែលត្រូវបានកំណត់និយមន័យ"* នៅ

ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[144]។ យោងតាមគោលការណ៍*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* និងយុត្តិសាស្ត្រជាធរមាន និយមន័យនៃបទប្រល័យពូជសាសន៍ដែលអនុវត្តនៅក្នុងដីកាដំណោះស្រាយនេះ គឺសំដៅលើការប្រព្រឹត្តអំពើណាមួយដែលមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃក្រុមជាតិសាស្ត្រ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនា ជាពិសេស ដែលត្រូវបានកំណត់គោលដៅដូចជា[145]។

*ធាតុផ្សំទូទៅនៃអំពើប្រល័យពូជសាសន៍*

60. ពុំមានលក្ខខណ្ឌទាមទារថា ការប្រព្រឹត្តដូចបានចោទប្រកាន់ត្រូវកើតឡើងនៅក្នុងបរិបទនៃបែបផែនជាក់ស្តែងនៃអំពើស្រដៀងគ្នានោះទេ[146]។ ស្រដៀងគ្នានេះដែរ អត្ថិភាពនៃគោលនយោបាយរដ្ឋ (ឬគោលនយោបាយផ្សេងទៀត ឬ ផែនការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ពុំមែនជាធាតុផ្សំនៃ

---

ក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។ ដូច្នេះ និយមន័យដែលយកមកប្រើនៅក្នុងដីកាដំណោះស្រាយនេះ គឺប្រកាន់ខ្ជាប់តាមនិយមន័យដែលមាននៅក្នុងមាត្រា៤ ជាភាសាខ្មែរ និងភាសាបារាំង ក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងយុត្តាធិការដែលត្រូវបានបង្កើតឡើង។ *សូមមើល៖* សំណុំរឿង ០០២-ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៣១១។

[144] *ការរក្សាសិទ្ធិចំពោះអនុសញ្ញាស្តីពីការបង្ការ និងដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍* មតិសម្រាប់ពិគ្រោះយោបល់ របាយការណ៍តុលាការព្រហ្មទណ្ឌអន្តរជាតិ (១៩៥១) ទ.២៣។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៣៩។ *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៤៩៥។ សំណុំរឿង ០០២-ឯកសារ **D427/2/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១០៨។ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០ បន្ទាប់ពីទទួលបានអធិបតេយ្យភាព អនុលោមតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋបារាំងទីបួន។ ការចូលជាសមាជិករបស់ប្រទេសកម្ពុជា ត្រូវបានឯកភាពដោយអង្គការសហប្រជាជាតិ ហើយពុំមានកំណត់ត្រាស្តីពីការជំទាស់ផ្លូវច្បាប់ប្រឆាំងនឹងការចូលជាសមាជិកនោះទេ។ បន្ទាប់ពីទទួលបានចំនួនសមាជិកដែលជាលក្ខខណ្ឌចាំបាច់ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍បានចូលជាធរមាន នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១។ *សូមមើល* សំណុំរឿងលេខ ០០២-ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៣១០។

[145] សំណុំរឿងលេខ **002-D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៣១២។ *រដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៥៩។ *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៤៩៨-៤៩៩។ *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៥២។

[146] *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ២២៣-២២៤។

អំពើប្រល័យពូជសាសន៍នោះទេ[147] ហើយពុំមានលក្ខខណ្ឌទាមទារថា អំពើដូចបានចោទប្រកាន់ បានបង្កើតជាផ្នែកមួយនៃការវាយប្រហារជាលក្ខណៈទូទៅ ឬ ប្រព័ន្ធលើជនស៊ីវិលនោះឡើយ[148]។ ទោះបីជាយ៉ាងនេះក្តី កត្តាបែបនេះអាចគាំទ្រដល់ការសម្រេចលើចេតនាជាក់លាក់[149]។

*ក្រុមជនដែលទទួលបានការការពារ*

61. អ.វ.ត.ក មានយុត្តាធិការលើអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងសំដៅលើក្រុមជាតិសាសន៍ ជាតិពិន្ទុ ពូជសាសន៍ និងសាសនា[150]។ មានតែក្រុមជាក់ចំនួនបួនដូចបានរៀបរាប់ប៉ុណ្ណោះដែល ទទួលបានការការពារ[151]។

---

[147] *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-05-88-A) ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ៤៣០, ៤៣៦, ៤៤០។ *រដ្ឋអាជ្ញា តទល់នឹង* Rutaganda សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៥២៥។

[148] *រដ្ឋអាជ្ញា តទល់នឹង* Krstić សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០០៤ កថាខណ្ឌ២២៣។ *រដ្ឋអាជ្ញា តទល់នឹង* Jelisić សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-10-A) ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ៤៨។

[149] *រដ្ឋអាជ្ញា តទល់នឹង* Krstić *សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ* ICTY (IT-98-33-A) *ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ២២៣។ រដ្ឋអាជ្ញា តទល់នឹង* Jelisić សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-10-A) ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ៤៨។ *រដ្ឋអាជ្ញា តទល់នឹង* Rutaganda សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៥២៥។

[150] មាត្រា៤ នៃច្បាប់ អ.វ.ត.ក។ មាត្រា II, III នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។

[151] *រដ្ឋអាជ្ញា តទល់នឹង* Krstić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ ២០០១ កថាខណ្ឌ៥៥៤។ *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨០៩។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤១។ *រដ្ឋអាជ្ញា តទល់នឹង* *Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ៩៨។ *រដ្ឋអាជ្ញា តទល់នឹង* Bagilishema សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៦០-៦១។ *រដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១១។ *ទោះបីជា សូមមើល រដ្ឋអាជ្ញា តទល់នឹង* Akayesu សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥១៦ ដោយអង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR ថ្លែងថា អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មានចេតនាការពារ *"ក្រុមអចិន្ត្រៃយ៍ និងថិតថេរណាមួយ"* (មានការសង្កត់អត្ថន័យ) ក្នុងការឆ្លើយទៅនឹងសំណួរថាតើ អំពើប្រល័យពូជសាសន៍ត្រូវបានកម្រិតត្រឹមអំពើប្រឆាំងនឹងក្រុមទាំងបួនដែលមានចែងយ៉ាងច្បាស់លាស់។ បើពុំនោះទេ របកគំហើញបន្ថែមច្រើនទៀតនៅក្នុងបរិបទនេះ ត្រូវបានកម្រិតត្រឹមការលើកឡើងថា ទំហំនៃការអនុវត្តអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ត្រូវបានកម្រិត

62. ពុំមាននិយមន័យដែលទទួលយកជាទូទៅលើក្រុមជនដែលទទួលបានការការពារចំនួនបួនក្រុមនោះឡើយ[152]។ យុត្តិសាស្ត្រនៃសាលាក្តី *មិនអចិន្ត្រៃយ៍* ជម្រុញឱ្យបង្កើតតេស្តចម្រុះ និងទៅតាមករណីជាក់ស្តែងដើម្បីកំណត់ថាជនរងគ្រោះ (ឬ ក្រុមដែលត្រូវបានកំណត់គោលដៅ) ស្ថិតនៅក្នុងក្រុមណាមួយដែលទទួលបានការការពារ[153]។ ចំណុចទី១ គួរមានការយោងលើលក្ខណៈសត្យានុម័តនៃបរិបទនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលពាក់ព័ន្ធគ្នា[154]។ ទោះបីជាយ៉ាងនេះក្តី ដោយសារក្រុមគោលដៅមិនអាចត្រូវបានកំណត់ព្រំដែនជាក់លាក់ ហើយអាចត្រូវបានកំណត់លក្ខណៈដោយចារី នៅក្នុងលក្ខណៈមួយផ្សេងពីទស្សនទាននៃក្រុម ដែលត្រូវបានសង្គមទូទៅ ឬ មួយ

---

ត្រឹមក្រុមអចិន្ត្រៃយ៍ និងចិតថេរប៉ុណ្ណោះ ដែលមិនបញ្ចូល *"ក្រុមចល័ត"* មួយចំនួន ប៉ុន្តែ មិនបានធ្វើសេចក្តីសន្និដ្ឋានថា ដូច្នេះ ក្រុមអចិន្ត្រៃយ៍ និងចិតថេរ*ណាមួយ* ត្រូវបានការពារនោះទេ។ *សូមមើល រដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៦៩។ *រដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៥៧។ *រដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៦២។

[152] *រដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៥៦។ *រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៦៥។ *រដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ១៦១។ *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៥៥-៥៥៦។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៧០។ ទោះបីជានៅពេលខ្លះ អង្គជំនុំជម្រះសាលាដំបូង ICTR បានព្យាយាមកំណត់និយមន័យនៃក្រុមទាំងបួនដែលទទួលបានការការពារ។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥១២-៥១៥។ *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ៩៨។

[153] *ទោះបីជា សូមមើល រដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៧០ ដែលមើលទៅឃើញថា លក្ខខណ្ឌអត្តនោម័តទាំងស្រុងត្រូវបានអនុម័ត។

[154] *រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១៧។ *រដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៥៦-៥៨។ *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៥៧។

ផ្នែកយល់ឃើញរួមគ្នា[155] ការយល់ឃើញជាអត្តនោម័តនៃជនរងគ្រោះ និងចារី ពាក់ព័ន្ធនឹងសមាជិកភាពរបស់ជនរងគ្រោះនៃក្រុមដែលត្រូវបានកំណត់គោលដៅគួរត្រូវបានយកមកពិចារណាផងដែរ[156]។

63. ក្រុមដែលត្រូវបានកំណត់គោលដៅត្រូវមានអត្តសញ្ញាណវិជ្ជមានជាក់លាក់ ដូច្នេះ មិនអាចត្រូវបានកំណត់តាមបែបអវិជ្ជមាននោះទេ[157]។ ប្រសិនបើក្រុមលើសពីមួយត្រូវបានកំណត់គោលដៅសម្រាប់ការកំទេចចោល ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ត្រូវបានបំពេញចំពោះក្រុមនីមួយៗ[158]។

*ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ជាក់លាក់ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក*

64. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ចែងអំពីអំពើប្រល័យពូជសាសន៍ជាក់លាក់ដែលត្រូវបង្ហាញ*ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័ត* (ក្រៅពីចេតនាជាក់លាក់នៃអំពើប្រល័យពូជសាសន៍[159] ដូចបានលើកឡើងខាងក្រោម)។ អំពើជាក់លាក់ដូចខាងក្រោមពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៤៖ (១) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម (២) ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម និង (៣) ការធ្វើដោយចេតនាឲ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬ មួយផ្នែក។

---

[155] *រដ្ឋអាជ្ញា តទល់នឹង* *Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៦៥។ *រដ្ឋអាជ្ញា តទល់នឹង* *Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៧០។

[156] *រដ្ឋអាជ្ញា តទល់នឹង* *Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១៧។ *រដ្ឋអាជ្ញា តទល់នឹង* *Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ១៦១។ *រដ្ឋអាជ្ញា តទល់នឹង* *Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៥៧។

[157] *រដ្ឋអាជ្ញា តទល់នឹង* *Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤១។

[158] *រដ្ឋអាជ្ញា តទល់នឹង* *Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤១។

[159] *រដ្ឋអាជ្ញា តទល់នឹង* *Krstić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ២០។

65. ធាតុផ្សំនៃ**ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម**គឺដូចនឹងធាតុផ្សំនៃការធ្វើមនុស្សឃាតិដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[160]។ មរណភាពនៃជនរងគ្រោះអាចត្រូវបានបង្ហាញដោយភ័ស្តុ

---

[160] *សូមមើលខាងលើ កថាខណ្ឌ៤៦។ រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១០, ៧៨៧-៧៨៨ ដោយតុលាការ ICTY នៅខណៈយល់ឃើញថា ធាតុផ្សំនៃការសម្លាប់សមាជិករបស់ក្រុម មានន័យស្មើនឹងបទឃាតកម្ម យល់ឃើញថា ធាតុផ្សំនៃបទឃាតកម្ម ដែលជាការរំលោភបំពានច្បាប់ ឬទំនៀមទំលាប់នៃសង្គ្រាម (ដូចមានចែងក្នុងមាត្រា៣ នៃលក្ខន្តិកៈរបស់តុលាការ ICTY) និងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដូចមានចែងក្នុងមាត្រា៥ នៃលក្ខន្តិកៈរបស់តុលាការ ICTY) មានលក្ខណៈដូចគ្នា។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤២។ "ការសម្លាប់" ត្រូវបានបកស្រាយថាជាការសម្លាប់ដោយចេតនា (*សូមមើល រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១៩)។ *រដ្ឋអាជ្ញា តទល់នឹង Kayishema នឹង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ១០៣។ បទមនុស្សឃាត ដែលត្រូវបានប្រព្រឹត្តក្នុងចេតនាធ្វើឱ្យប៉ះពាក់ដល់អាយុជីវិត (*សូមមើល រដ្ឋអាជ្ញា តទល់នឹង* Seromba សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-2001-66-I) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ៣១៧។ *រដ្ឋអាជ្ញា តទល់នឹង* Musema សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ១៥៥។) និងបទឃាតកម្ម (*សូមមើល រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១០, ៧៨៧-៧៨៨។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤២)។ នៅក្នុង *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ នៅកំណត់សម្គាល់លេខ ២៩១៨ អង្គជំនុំជម្រះសាលាដំបូងព្រមព្រៀងយោងទៅ *រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១៩។ *រដ្ឋអាជ្ញា តទល់នឹង* Seromba សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-2001-66-I) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ៣១៧។ និង *រដ្ឋអាជ្ញា តទល់នឹង* Musema សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ១៥៥ ដោយចង្អុលបង្ហាញសមមូល្យនៃធាតុផ្សំ ទោះពីជាមាននាមផ្សេងគ្នាក៏ដោយ។ ពាក់ព័ន្ធនឹង *ចេតនាឧក្រិដ្ឋ* អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ជាភាសាអង់គ្លេស ហាមឃាត់ *"ការសម្លាប់"* ដែលមានន័យអព្យាក្រឹត្យ ពាក់ព័ន្ធនឹងចេតនានៃអំពើ ហើយក្នុងភាសាបារាំង *"meurtre"* មានអត្ថន័យស្មើនឹង ការសម្លាប់ដោយចេតនា។ អង្គជំនុំជម្រះតុលាការ ICTR បានអនុម័តយកការបកស្រាយ ដែលជាប្រយោជន៍ច្រើនបំផុតដល់ជនជាប់ចោទ ដែលពាក្យ *"meurtre"* តម្រូវឱ្យមានបង្ហាញចេតនាសម្លាប់ ឬធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត ប៉ុន្តែ ពុំមានការគិតទុកជាមុននោះទេ។ (*សូមមើល រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥០០-៥០១។ *រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៩។ *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-95-1-A) ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១៥១)។ អង្គជំនុំជម្រះតុលាការ ICTY

តាងប្រយោល ប្រសិនបើសេចក្តីសន្និដ្ឋានដ៏សមហេតុតែមួយគត់ដែលអាចទាញចេញពីភ័ស្តុតាងបែបនោះបង្ហាញថាជនរងគ្រោះមានទទួលមរណភាព[161] ហេតុដូច្នេះហើយវាទាមទារការបង្ហាញភ័ស្តុតាងអំពីលទ្ធផល (មិនថាតាមការសន្និដ្ឋាន)[162]។ ការវាយតម្លៃលើតួលេខនៃចំនួនដែលត្រូវបានសម្លាប់ពុំទាមទារសម្រាប់ការបង្ហាញ*ធាតុផ្សំសត្យានុម័ត*នោះទេ[163]។

66. ធាតុផ្សំនៃការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុមជនដែលទទួលបានការការពារ រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖*

i. អំពើសកម្ម ឬ អកម្ម ដែលធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកម្នាក់ ឬ ច្រើននាក់នៃក្រុមជនដែលទទួលបានការការពារត្រូវបាន

---

បានកំណត់ជំហរស្រដៀងគ្នានេះដែរ ដោយធ្វើការប្រៀបធៀបពាក្យ *សម្លាប់* និង *មនុស្សឃាត* ហើយនៅពេលធ្វើការប្រៀបធៀបបែបនេះ បានឯកភាពនឹងវិធីសាស្ត្ររបស់តុលាការ ICTR។ (*សូមមើល រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤២។ *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១០។ *រដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៦៣។ *រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦៤២)។ ទោះក្នុងករណីណាក៏ដោយ មានការសង្កេតថា នៅក្នុងបរិបទនៃចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ពុំមាន *"ភាពខុសគ្នាជាក់ស្តែង"* រវាងពាក្យ ការសម្លាប់ និង *meurtre* ទេ។ (*សូមមើល រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-95-1-A) ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ១៥១)។

[161] *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៧៨៩, ៨១០។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៤៤៦, ៥៤២។ *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ២៦០។

[162] *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤២។

[163] *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤២។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលដីកា យោងវិធាន៩៨ស្ទួន អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-5/18-AR98bis.1) ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ២៣។

វាយតម្លៃទៅតាមករណីនីមួយៗពាក់ព័ន្ធនឹងកាលៈទេសៈជាក់លាក់[164]។ តុលាការតម្រូវឱ្យបង្ហាញភ័ស្តុតាងនៃលទ្ធផល[165]។ ព្យសនកម្មធ្ងន់ធ្ងរពុំចាំបាច់ទាល់តែមានលក្ខណៈអចិន្ត្រៃយ៍ ឬ មិនអាចជួសជុលបាននោះទេ ប៉ុន្តែព្យសនកម្មនោះត្រូវតែលើសពីកម្រិតអប្បរមារ និងបណ្តោះអាសន្ននៃការខូចខាតផ្លូវកាយ ឬ ផ្លូវចិត្ត ហើយបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងររយៈពេលយូរលើលទ្ធភាពរបស់បុគ្គលក្នុងការដឹកនាំជីវិតរស់នៅជាក់ស្តែងធម្មតារបស់ខ្លួន[166]។

ii. ពុំមានលក្ខខណ្ឌទាមទារថា ព្យសនកម្មដែលបង្កឡើងត្រូវមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ដែលគម្រាមកំហែងបំផ្លិចបំផ្លាញក្រុមជនដែលទទួលបានការការពារទាំងស្រុង ឬ មួយផ្នែក ក៏ប៉ុន្តែ កម្រិតនៃការគម្រាមកំហែងដល់ការបំផ្លិចបំផ្លាញក្រុមនោះអាចចាត់ទុកជាវិធានការនៃភាពធ្ងន់ធ្ងរចំពោះព្យសនកម្មដែលបានបង្កឡើង[167]។

---

[164] *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១១។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៣, ៥៤៥។ *រដ្ឋអាជ្ញា តទល់នឹង* Kayishema *និង* Ruzindana សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ១០៨, ១១០។ *រដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣២៣។

[165] *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១១។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៣។

[166] *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១១។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៣។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង* Seromba សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-2001-66-A) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ៤៦។ *រដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣២០-៣២២។

[167] *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៤។ ដូចមានថ្លែងនៅក្នុង *រដ្ឋអាជ្ញា តទល់នឹង* Seromba សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-2001-66-A) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ៤៦ និងនៅក្នុង *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ

៨១១ ដែលថា មានលក្ខខណ្ឌបែបនេះ ទោះជាយ៉ាងនេះក្តី ពុំមាននៅក្នុងសំណុំរឿងណាមួយដែលអង្គជំនុំជម្រះបានពិនិត្យមើលជាក់ស្តែងថាតើ ភ័ស្តុតាងបានបង្ហាញថា ព្យសនកម្មមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការគំរាមកំហែងដល់ការបំផ្លាញទាំងស្រុង ឬជាផ្នែកនៃក្រុមដែលទទួលបានការការពារ ហើយសាលក្រមភាគច្រើន ដែលបានសម្រេចនៅពេលមុន និងបន្ទាប់មក សេចក្តីថ្លែងការណ៍បឋម នៅក្នុងសាលដីកា *Seromba* មានលក្ខណៈស្របគ្នា ហើយបានលុបចោលលក្ខខណ្ឌបែបនេះ (*សូមមើលឧទាហរណ៍ រដ្ឋអាជ្ញា តទល់នឹង* *Blagojević* *និង* *Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦៤៥។ *រដ្ឋអាជ្ញា តទល់នឹង* *Brđanin* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៦៩០។ *រដ្ឋអាជ្ញា តទល់នឹង* *Stakić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-97-24-T) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៥១៦។ *រដ្ឋអាជ្ញា តទល់នឹង* *Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥១៣។ *រដ្ឋអាជ្ញា តទល់នឹង* *Ntawukulilyayo* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-05-82-T) ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០ កថាខណ្ឌ៤៥២។ *រដ្ឋអាជ្ញា តទល់នឹង* *Kalimanzira* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-05-88-T) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ១៥៩។ *រដ្ឋអាជ្ញា តទល់នឹង* *Renzaho* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-31-T) ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ កថាខណ្ឌ៧៦២។ *រដ្ឋអាជ្ញា តទល់នឹង* *Bagosora* *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-98-41-T) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ២១១៧។ *រដ្ឋអាជ្ញា តទល់នឹង* *Gacumbtsi* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-2001-64-T) ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤ កថាខណ្ឌ២៩១។ *រដ្ឋអាជ្ញា តទល់នឹង* *Ntagerura* *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-99-46-T) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ៦៦៤។ *រដ្ឋអាជ្ញា តទល់នឹង* *Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣២០-៣២៣។ *រដ្ឋអាជ្ញា តទល់នឹង* *Ntakirutimana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-10 និង ICTR-96-17-T) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ៧៨៤។ *រដ្ឋអាជ្ញា តទល់នឹង* *Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៥៩។ *រដ្ឋអាជ្ញា តទល់នឹង* *Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ១៥៦។ *រដ្ឋអាជ្ញា តទល់នឹង* *Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៥១។ *រដ្ឋអាជ្ញា តទល់នឹង* *Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥០២-៥០៤)។ *សូមមើលផងដែរ* ការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ *សូមមើលផងដែរ* ការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ *(ប្រទេសបូស្នៀរ និង ហឺហ្គោវីណា តទល់នឹង ប្រទេសស៊ែប៊ី និង ម៉ុងតានីក្រូ)* តុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ៣១៩ ដែលក្នុងនោះ តុលាការព្រហ្មទណ្ឌអន្តរជាតិពុំបានអនុវត្តលក្ខខណ្ឌបន្ថែមទៅលើសំអាងហេតុនោះទេ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY បានធ្វើការរម្លឹកស្រដៀងគ្នានេះដែរនូវពាក្យពេជន៍នៃបទបញ្ញត្តិពាក់ព័ន្ធក្នុងលក្ខន្តិកៈតុលាការ ដោយមិនមានដាក់បញ្ចូលលក្ខខណ្ឌបែបនេះឡើយ (*សូមមើល រដ្ឋអាជ្ញា តទល់នឹង* *Karadžić* សាលដីកា យោងវិធាន៩៨ស្ទួន អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-5/18-AR98bis.1) ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ៣៣)។

iii. ការប្រព្រឹត្តអមនុស្សធម៌ ឬ បន្ថោកបន្ទាប ការធ្វើទារុណកម្មលើផ្លូវចិត្ត ឬ រាងកាយ ការរំលោភលើផ្លូវភេទ ការបំពានផ្លូវភេទ ការនិរទេស ការសួរចម្លើយ រួមជាមួយនឹងការវាយដំ និង/ឬ ការគម្រាមសម្លាប់ចោល អំពើហិង្សាលើរូបកាយពុំបណ្តាលឱ្យស្លាប់ ដែលបំផ្លាញសុខភាព ឬ បណ្តាលឱ្យខូចកាយសម្បទា ឬ បង្កព្យសនកម្មធ្ងន់ធ្ងរដល់សមាជិកនៃក្រុមជនដែលទទួលបានការការពារ និងការធ្វើទុក្ខបុកម្នេញ គឺស្ថិតនៅក្នុងចំណោមអំពើដែលអាចបង្កព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ ឬ ផ្លូវចិត្ត[168]។ ការបាក់ស្បាត និងរបួសដែលអ្នកសល់ជីវិតពីការសម្លាប់រង្គាលបានទទួលរងគឺជាព្យសនកម្មធ្ងន់ធ្ងរលើផ្លូវចិត្ត (ព្រមទាំង រាងកាយ)[169]។ ការជម្លៀសដោយបង្ខំពុំមែនជាអំពើប្រល័យពូជសាសន៍នោះទេ ក៏ប៉ុន្តែ វាអាចជាអំពើដែលជាការបង្កព្យសនកម្មធ្ងន់ធ្ងរដល់រាងកាយ ឬ ផ្លូវចិត្ត ជាពិសេសប្រសិនបើកាលៈទេសៈ នៃប្រតិបត្តិការនាំឱ្យប្រជាជនដែលត្រូវបានជម្លៀសសម្លាប់ទាំងអស់គ្នា ឬ មួយផ្នែកណានោះ[170]។

[168] *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥១៣។ *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១២។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៥។ *រដ្ឋអាជ្ញា តទល់នឹង Seromba* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-2001-66-A) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ៤៦។ *រដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ១៥៦។

[169] *រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-02-60-T) ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦៤៧, ៦៤៩។ នៅកថាខណ្ឌ៦៤៧ “*ការភ័យខ្លាចត្រូវបានគេចាប់ខ្លួន ហើយនៅខណៈដែលត្រូវបានបែកគ្នា អារម្មណ៍ដែលអស់សង្ឃឹមខ្លាំងបំផុតដោយគិតថាពុំមានអ្នកណាជួយបាន និងការភ័យខ្លាចខ្លាំងបំផុតចំពោះសុវត្ថិភាពរបស់គ្រួសារ និងមិត្តភក្តិ ព្រមទាំងសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ គឺជាបទពិសោធន៍នៃការប៉ះទង្គិចផ្លូវចិត្ត ដែលពុំមាននរណាម្នាក់ងាយនឹងវិលត្រឡប់មករកសភាពដើមវិញ បើទោះជាមានក្តី។ លើសពីនេះទៀត* [...] *បុរសទាំងនោះបានទទួលរងការឈឺចាប់ផ្លូវចិត្ត ដោយសារតែឯកសារអត្តសញ្ញាណរបស់ពួកគេ ត្រូវបានគេដកយក ហើយដោយដឹងថា ពួកគេនឹងមិនត្រូវបានគេយកទៅដោះដូរដូចដែលគេប្រាប់ពីមុនមកនោះទេ ហើយនៅពេលដែលពួកគេបានដឹងពីវាសនាចុងក្រោយរបស់ពួកគេនោះ*”។

[170] *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ 813; *រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦៥០, ៦៥៤។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៥។

iv. ទំនាក់ទំនងជាក់លាក់រវាងអំពើប្រល័យពូជសាសន៍ផ្សេងៗគ្នាក្រោមមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ដែលដូចនឹងមាត្រា II(ក) និង (ខ) នៃអនុសញ្ញាទីក្រុងហ្សឺណែវ ពុំទាន់បានបញ្ជាក់បំភ្លឺជាមួយនឹងហេតុផលជាក់លាក់នៅក្នុងយុត្តិសាស្ត្រនោះទេ តាមដែលបានដឹង[171] នេះប្រហែលដោយសារករណីនេះត្រូវបានចាត់ទុកថាមានលក្ខណៈច្បាស់ទៅហើយ។ យោងតាមសំអាងហេតុជាក់លាក់ ដែលយកគម្រូតាមសេណារីយ៉ូនៃការធ្វើមនុស្សឃាតជាមូលដ្ឋាន ជាក់ស្តែង គ្រប់អំពើនៃការធ្វើមនុស្សឃាតពាក់ព័ន្ធនឹងការបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ បើទោះជានៅក្នុងករណីខ្លះ ត្រឹមតែអំពើមួយរយៈពេលខ្លី វាបង្កឲ្យមានការស្លាប់ភ្លាមៗ។ ប្រសិនបើមរណភាពកើតឡើង ហើយចេតនាបង្កឡើងដោយជនជាប់ចោទត្រូវបានរកឃើញ គ្មានតុលាការជាតិណាមួយអាចសម្រេចពិរុទ្ធភាពបន្ថែមដោយផ្អែកលើអង្គហេតុដដែលចំពោះការបង្កព្យសនកម្មធ្ងន់ធ្ងរនេះទេ[172]។ នៅក្នុងប្រព័ន្ធតុលាការជាតិ ករណីទាំងនេះជាធម្មតាមានចែងនៅក្នុងគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ស្តីពីអង្គហេតុនៃបទល្មើសត្រួតគ្នា[173]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន គេអាចព្យាយាមពិចារណាលើទស្សនទាននៃទំនាក់ទំនងបទល្មើសដែលមានទោសស្រាលរវាង (ក) និង (ខ)។ ទោះបីជាយ៉ាងនេះក៏ដោយ សេចក្តីសន្និដ្ឋានមានលក្ខណៈស្រពិចស្រពិល ពោលគឺ សាលាក្តី*មិនអចិន្ត្រៃយ៍* ដូចបានពន្យល់ខាងលើ បានបកស្រាយធាតុផ្សំនៃព្យសនកម្មធ្ងន់ធ្ងរលើរាងកាយតាមជម្រើស (ខ) ថាជាការ *"បណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងររយៈពេលយូរលើលទ្ធភាពរបស់បុគ្គលក្នុងការដឹកនាំជីវិតរស់នៅជាក់ស្តែងធម្មតារបស់ខ្លួន"* ហើយការសម្រេចនាពេលមុនបានប្រកាសសម្រេចលើបញ្ហានេះក្នុងបរិបទនៃព្យសនកម្ម*ដែលអ្នកនៅរស់បានទទួល*

---

171 មានច្បាប់យុត្តិសាស្ត្រមួយចំនួនស្តីពីទំនាក់ទំនងរវាងអំពើប្រល័យពូជសាសន៍ និងការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលទស្សនៈទូទៅបង្ហាញថា ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ មិនគួរត្រូវបានប្រើសម្រាប់ការផ្តន្ទាទោសត្រួតនោះទេ។ *សូមមើល* Stuckenberg *ការចោទប្រកាន់ត្រួត និងការផ្តន្ទាទោសត្រួត* នៅក្នុង Stahn (ការបោះពុម្ពផ្សាយ) ច្បាប់ និងការអនុវត្តនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, OUP ឆ្នាំ២០១៥, 850 f។

172 ជាការពិត វិធីសាស្ត្របែបនេះ នឹងនាំទៅរក *យ៉ាងតិចបំផុត* ការវិលត្រឡប់ថយក្រោយវិញ។ ជាចុងក្រោយ សង្វាក់វិលត្រឡប់ថយក្រោយនៃការផ្តន្ទាទោសបន្ថែមទៀត នឹងបញ្ចប់ត្រឹមការបំពារបំពាន និងការរំលោភលើរាងកាយធម្មតាប៉ុណ្ណោះ។

173 Stuckenberg *ការចោទប្រកាន់ត្រួត និងការផ្តន្ទាទោសត្រួត* នៅក្នុង Stahn (ការបោះពុម្ពផ្សាយ) ច្បាប់ និងការអនុវត្តនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, OUP ឆ្នាំ២០១៥, 840 ff ដោយមានយោង។ ការអនុវត្តរបស់តុលាការលើបញ្ហានេះ នៅឆ្ងាយពីការព្រមព្រៀងគ្នាជាគោលការណ៍។

*រង*[174]។ ដូច្នេះ ចំណុចនេះពុំស៊ីសង្វាក់គ្នាជាមួយនឹងរឿងក្ដីដែល*លទ្ធផលសម្រេចបានដោយចេតនា* គឺការធ្វើមនុស្សឃាតឱ្យបានឆាប់រហ័សលើសមាជិកនៃក្រុមជនដែលទទួលបានការការពារ បើទោះជាអាចមាន ឧទាហរណ៍ ការឃុំឃាំងដែលរួមបញ្ចូលការបំពានលើរាងកាយ និងផ្លូវចិត្តនៅមុនពេលការធ្វើមនុស្សឃាតបានកើតឡើងក៏ដោយ។ ជម្រើស (ខ) មានន័យថា នៅក្នុង*ធាតុផ្សំសត្យានុម័ត* ដោយប្រយោល វាតម្រូវលក្ខខណ្ឌថា ជនរងគ្រោះនីមួយៗ*នៅរស់* ហើយយោងតាមទ្រឹស្ដីវិធីសាស្ត្រ គេមិនអាចអនុវត្តត្រួតគ្នានៅពេលជនរងគ្រោះត្រូវបានសម្លាប់នោះទេ។ វាពុំមានបទល្មើសដែលមានទោសស្រាលជាជម្រើស (ក) នោះឡើយ។ ហើយវាក៏ពុំចាំបាច់ពង្រីកការបកស្រាយជម្រើស (ខ) ឱ្យរួមបញ្ចូលសេណារីយ៉ូនៃការធ្វើមនុស្សឃាតដោយចេតនាដើម្បីជៀសវាងចន្លោះប្រហោងនិទណ្ឌភាព*ដោយអចេតនា និងដោយគ្មានបំណងធ្វើឡើងនោះឡើយ* ពោលគឺ ប្រសិនបើជនរងគ្រោះណាម្នាក់ត្រូវបានគេកំណត់យកទៅសម្លាប់ចោល បែរជានៅរស់ *ធាតុផ្សំអត្តនោម័ត* ចំពោះការធ្វើមនុស្សឃាត (សូមមើលកថាខណ្ឌ ៤៦ ខាងលើ) គឺគ្រប់គ្រាន់ក្នុងការបង្ហាញបទចោទក្រោមជម្រើស (ខ) បាន ទោះក្នុងករណីណាក៏ដោយ[175]។

v. ការប៉ុនប៉ងអំពើប្រល័យពូជសាសន៍ពុំត្រូវបានចោទប្រកាន់នៅក្នុងរឿងក្ដីនេះ ដូច្នេះ ពុំចាំបាច់ពិភាក្សាទំនាក់ទំនងនៃទម្រង់អំពើប្រល័យពូជសាសន៍ជាមួយនឹងសេណារីយ៉ូនៃប្រភេទដូចបានពិពណ៌នាខាងលើនោះឡើយ។

ខ. *ធាតុផ្សំអត្តនោម័ត៖* អំពើសកម្ម ឬ អំពើអកម្មត្រូវធ្វើឡើងដោយចេតនាក្នុងបំណងបង្កព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ ឬ ផ្លូវចិត្ត[176]។

---

[174] *សូមមើល* Tams/Berster/Schiffbauer អនុសញ្ញាស្ដីពីការបង្ការ និងការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ - សេចក្ដីអធិប្បាយ ឆ្នាំ២០១៤ មាត្រាII, mn 69។

[175] សូមមើលបរិបទជាមូលដ្ឋាននៃសំណួរថាតើអ្នកធ្វើពង្រាងអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ មានលទ្ធភាព ឬមានចេតនាត្រឹមកម្រិតណា ក្នុងការដោះស្រាយផលវិបាកជាគោលការណ៍ នៃឥទ្ធិពលទៅវិញទៅមករវាងទម្រង់ផ្សេងគ្នានៃអំពើប្រល័យពូជសាសន៍។ Kreß *ការប្រឈមដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍* នៅក្នុង Stahn (ដូចខាងលើ, កំណត់សម្គាល់ជើងទំព័រ២២៤) ទំព័រ៧០០។

[176] *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១១។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY

67. ធាតុផ្សំនៃ**ការធ្វើដោយចេតនាឲ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬ មួយផ្នែក** រួមមាន៖

ក. *ធាតុផ្សំសត្យានុម័ត៖* វិធីសាស្ត្រនៃការបំផ្លាញដែលពុំនាំដល់ការធ្វើមនុស្សឃាតសមាជិកនៃក្រុមជនដែលទទួលបានការការពារភ្លាមៗ ប៉ុន្តែដែលនៅទីបំផុតមានបំណងបំផ្លាញរាងកាយរបស់ពួកគេ។ ដូច្នេះ ពុំចាំបាច់ទាមទារបង្ហាញភ័ស្តុតាងនៃលទ្ធផលនោះឡើយ[177]។ ឧទាហរណ៍រួមមានការរំលោភផ្លូវភេទ[178] ការបដិសេធសេវាសុខភាព ការកំណត់របបអាហារូបត្ថម្ភ ការបង្កើតកាលៈទេសៈដែលនាំឲ្យឈានដល់ការទទួលមរណភាពជាបណ្ដើរៗ ដូចជា គ្មានម្ហូបអាហារ ទឹក ជម្រក សម្លៀកបំពាក់ សុខភាពអនាម័យ ជម្រុញឲ្យធ្វើការងារហួសកម្រិត ឬ ការបង្ខំលើរាងកាយ និងការបណ្ដេញជាលក្ខណៈប្រព័ន្ធឲ្យបុគ្គលទាំងនោះចាកចេញពីលំនៅដ្ឋាន[179]។ ស្ថានភាពទាំងនេះត្រូវធ្វើឡើងដើម្បីកំទេចរូបរាងកាយរបស់ក្រុមទាំងស្រុង ឬ មួយផ្នែក ខុសពីការរៀបចំបង្កឲ្យមានការរលួយក្រុមនោះ[180]។ នៅពេលពុំមានភ័ស្តុតាងដោយផ្ទាល់បង្ហាញថា លក្ខខណ្ឌទាំងនោះត្រូវបានធ្វើ

---

(IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៣។ *រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣២៣។

[177] *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១៤។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៦។ *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥០៥។ *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ១១៦។

[178] *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ១១៦។

[179] *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ៨១៥។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៧។ *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥០៦។ *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ១១៥-១១៦។

[180] *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៧។

ឡើងដើម្បីបំផ្លាញរាងកាយក្រុមនោះ ការផ្ដោតសំខាន់គឺលើ *"ភាវនិយភាពសត្យានុម័ត"* នៃលក្ខខណ្ឌទាំងនោះដែលនាំដល់ការបំផ្លាញរូបរាងកាយក្រុម ដោយមានកត្តាពាក់ព័ន្ធ ដូចជាធម្មជាតិនៃលក្ខខណ្ឌ រយៈពេលដែលបុគ្គលនោះទទួលរង និងបុគ្គលិកលក្ខណៈនៃសមាជិកក្រុមគោលដៅ ឧទាហរណ៍ ភាពងាយរងគ្រោះរបស់ពួកគេ[181]។ លក្ខខណ្ឌដែលពុំសមស្របយោងតាមបទដ្ឋានមួយចំនួន ប៉ុន្តែនៅតែសមស្របចំពោះការរស់រានមានជីវិតនៃក្រុម ហេតុដូច្នេះ ពុំចូលរួមចំណែកដល់ការបំផ្លាញក្រុមនេះ នឹងពុំអាចបំពេញលក្ខខណ្ឌ*ធាតុផ្សំសត្យានុម័ត*ឡើយ[182]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ការបង្ក *"ដោយចេតនា"* ឲ្យមានលក្ខខណ្ឌបែបនេះដែលនាំឲ្យបំផ្លាញរាងកាយក្រុមទាំងស្រុង ឬ មួយផ្នែក[183]។

*ចេតនាប្រល័យពូជសាសន៍*

68. ក្រៅពីមាន*ធាតុផ្សំអត្តនោម័ត* ដូចទាមទារពាក់ព័ន្ធនឹងអំពើពាក់ព័ន្ធជាក់លាក់ដូចបានលើកឡើងខាងលើ ចារីត្រូវមានចេតនាជាក់លាក់ក្នុងការបំផ្លិចផ្លាញទាំងស្រុង ឬ មួយផ្នែក ចំពោះក្រុមពាក់ព័ន្ធដែលទទួលបានការការពារ ដូចជា[184]។

69. "**បំផ្លិចបំផ្លាញ**" អំពើប្រល័យពូជសាសន៍គ្របដណ្ដប់រួមអំពើដែលអាចជាការបំផ្លិចបំផ្លាញរូបកាយ ឬ ជីវសាស្ត្រនៃក្រុមជនដែលទទួលបានការការពារទាំងស្រុង ឬ មួយផ្នែក[185]។ អាស្រ័យហេតុនេះ

---

[181] *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១៦។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៨។ *រដ្ឋអាជ្ញា តទល់នឹង* Kayishema *និង* Ruzindana សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ៥៤៨។

[182] *រដ្ឋអាជ្ញា តទល់នឹង* Krajišnik សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-00-39-T) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ៨៦៣។ *រដ្ឋអាជ្ញា តទល់នឹង* Kayishema *និង* Ruzindana សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ៥៤៨។

[183] *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨១៧។ *រដ្ឋអាជ្ញា តទល់នឹង* Brđanin សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៦៩២។

[184] *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨០៨។ *រដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៤៩។ *រដ្ឋអាជ្ញា តទល់នឹង* Krstić សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ២០។

អំពើដែលវាយប្រហារលើបុគ្គលិកលក្ខណៈវប្បធម៌ ឬ សង្គម នៃក្រុមជនដែលទទួលបានការការពារដើម្បីបដិសេធក្រុមនោះនូវអត្តសញ្ញាណផ្ទាល់ខ្លួន (ឧទាហរណ៍ ការបំផ្លិចបំផ្លាញការកសាងសាសនា ឬ ផ្ទះសម្បែងរបស់សមាជិកនៃក្រុម) ពុំស្ថិតនៅក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍។ ទោះបីជាយ៉ាងនេះក្តី អំពើបែបនេះអាចបង្ហាញភ័ស្តុតាងដែលអាចទាញការសន្និដ្ឋានចេញពីចេតនាបំផ្លិចបំផ្លាញរូបកាយ ឬ ជីវសាស្ត្រ[186]។

70. "*ទាំងស្រុង ឬ មួយផ្នែក*" ឃ្លានេះសំដៅលើចេតនាបំផ្លាញ *ទាំងស្រុង ឬ មួយផ្នែក* នៃក្រុមជនដែលទទួលបានការការពារ ពោលគឺ ការបំផ្លាញផ្នែកនៃក្រុមដែលពុំត្រូវអមជាមួយនឹងចេនាបំផ្លិចបំផ្លាញក្រុមទាំងមូល[187]។ នៅពេលពុំមានការណែនាំនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឬ នៅក្នុងលក្ខន្តិកៈ សាលាក្តី *មិនអចិន្ត្រៃយ៍* បានបង្កើតចេតនាក្នុងការបំផ្លិចបំផ្លាញក្រុមមួយផ្នែកជាចេតនាបំផ្លិចបំផ្លាញយ៉ាងហោចណាស់ផ្នែក "សំខាន់" នៃក្រុម ពោលគឺ វាសំខាន់គ្រប់គ្រាន់ដែលមានឥទ្ធិពលលើក្រុមទាំងមូល ដោយពិចារណាលើបរិបទដែលការប្រព្រឹត្តដូចបានចោទប្រកាន់កើតឡើង[188]។

---

[185] *រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១៥។ *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ២៥។ *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨២២។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៥៣។

[186] *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ២៥។ *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨២២។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៥៣។

[187] *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៨៣-៥៨៤។

[188] *រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៦៤។ *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៩០។ *ការអនុវត្តអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ប្រទេសបូស្នៀ និង ហឺហ្កេហ្គោវីណា តទល់នឹង ប្រទេសស៊ែប៊ី និង ម៉ុងតេណេហ្គ្រូ)* តុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ១៩៨។ *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ៨-៩។ *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨៣១។ *រដ្ឋអាជ្ញា តទល់នឹង Karadžić*

71. ក្រុមគោលដៅអាចរួមបញ្ចូលបុគ្គលិកយោធា នៅពេលដែលបុគ្គលយោធាត្រូវបានកំណត់គោលដៅ ដោយសារសមាជិកភាពនៅក្នុងក្រុមជនដែលទទួលបានការការពារ[189]។

72. *"ដូចជា"* អំពើជាក់លាក់ត្រូវប្រព្រឹត្ត ក្នុងចេតនាបំផ្លិចបំផ្លាញក្រុមគោលដៅ ដែលជាអង្គភាពដាច់ដោយឡែកពីជនរងគ្រោះ ពោលគឺ៖ ជនរងគ្រោះចុងក្រោយឧក្រិដ្ឋកម្មគឺជាក្រុមមួយ[190]។ ជនរងគ្រោះត្រូវបាន*កំណត់គោលដៅដោយសារ*ពួកគេគឺជាសមាជិកនៃក្រុម (ប៉ុន្តែពុំមែនចាំបាច់*តែ*ដោយសារសមាជិកភាព) ហេតុដូច្នេះ សមាជិកភាពតែមួយពុំគ្រប់គ្រាន់នោះទេ[191]។

*ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*

---

សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៥៥។ *រដ្ឋអាជ្ញា តទល់នឹង* *Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១៦។ ទោះបីនៅក្នុង *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ៩៧ ភាសាដែលប្រើគឺ "*ចំនួនបុគ្គលទាំងឡាយដែលត្រូវយកមកពិចារណា*" នៅក្នុង *រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ (នៅកថាខណ្ឌ៦៤) បានដកស្រង់ *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ (ដែលសាលក្រមនេះ បានដកស្រង់នៅក្នុង *រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣១៦)។ អង្គជំនុំជម្រះសាលាដំបូង ប្រើឃ្លា "*ផ្នែកសំខាន់*" ដូច្នេះហើយ វាមានភាពច្បាស់លាស់ដែលថា អង្គជំនុំជម្រះ *Kayishema* ពុំមានចេតនាអនុម័តនូវបទដ្ឋានផ្សេងនោះទេ។ *សូមមើល រដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កំណត់សម្គាល់១៥ កថាខណ្ឌ៩។

[189] *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨៣៣។ *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ២២៦។

[190] *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៨២១។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៥១។ *រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៦១។

[191] *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៦១។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ៥៥១។ *រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៦១។ *រដ្ឋអាជ្ញា តទល់នឹង Niyitegeka* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-96-14-A) ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៥៣។

73. មាត្រា ៦ នៃច្បាប់ អ.វ.ត.ក ចែងថា អ.វ.ត.ក មានយុត្តាធិការកម្មវត្ថុលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ (“អនុសញ្ញាទីក្រុងហ្សឺណែវ”)។

74. អនុសញ្ញាទីក្រុងហ្សឺណែវ ទាមទារលក្ខខណ្ឌកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើដែលមានចែងនៅក្នុងមាត្រា ៦[192]។ ក្រោយផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨ ប្រទេសកម្ពុជាគឺជាភាគីនៃអនុសញ្ញាទាំងនេះនៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ម្យ៉ាងវិញទៀត ការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[193]។ អាស្រ័យហេតុនេះ ការហាមឃាត់ និងការចោទប្រកាន់នាពេលក្រោយៗទៀតចំពោះបទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ៦ គឺ **យឹម ទិត្យ** អាចប្រមើលមើលដឹង និងដឹងថាមានច្បាប់ចែងនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[194]។

---

[192] អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន ហាមឃាត់ការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម ឬការប្រព្រឹត្តិអមនុស្សធម៌ ការបង្កឱ្យឈឺចាប់ខ្លាំង ឬរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការបំផ្លាញ និងធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ដែលមិនមែនជាមូលហេតុនៃភាពចាំបាច់ផ្នែកយោធា និងដែលបានប្រព្រឹត្តដោយខុសច្បាប់ និងគ្មានមេត្តា។ (អនុសញ្ញាទីក្រុងហ្សឺណែវ I មាត្រា ៤៩-៥០។ អនុសញ្ញាទីក្រុងហ្សឺណែវ II មាត្រា៥០-៥១។ អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១២៩-១៣០។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៦-១៤៧)។ អនុសញ្ញាទីក្រុងហ្សឺណែវ III (មាត្រា១២៩-១៣០) ហាមឃាត់ការដកហូតដោយចេតនានូវសិទ្ធិអ្នកទោសសង្គ្រាមក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងទៀងទាត់។ អនុសញ្ញាទីក្រុងហ្សឺណែវ IV (មាត្រា ១៤៦-១៤៧) ហាមឃាត់ការដកហូតដោយចេតនានូវសិទ្ធិជនស៊ីវិលក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងទៀងទាត់ ការបង្ខាំងជនស៊ីវិលដោយខុសច្បាប់ និងការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង។

[193] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤០៥។ សំណុំរឿង ០០២-ឯកសារ **D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដោយ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ២៥៦-២៥៨។ សំណុំរឿង ០០២-ឯកសារ **D427/2/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១១៧-១១៨។ *សូមមើលផងដែរ* សំណុំរឿង ០០២-ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៣១៦។

[194] សំណុំរឿង ០០២-ឯកសារ **D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដោយ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ២៥៧។ សំណុំរឿង ០០២-ឯកសារ **D427/2/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១១៩-១២១, ១២៣។ សំណុំរឿងលេខ ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤០៤-៤០៨។

75. អ.ជ.ស.ដ និង អ.ប.ជ ធ្លាប់បានសម្រេចទាំងអស់គ្នាថា អាជ្ញាយុកាលពុំអនុវត្តចំពោះការបំពារបំពានធ្ងន់ធ្ងរអនុលោមតាមមាត្រា ៦ នោះទេ[195] ហើយអាស្រ័យហេតុនេះ វាបង្ហាញច្បាស់ដោយគ្មានវិមតិសង្ស័យថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវអនុលោមតាមមាត្រា ៦ មានអាជ្ញាយុកាលរារាំងនោះឡើយ។

76. នៅក្នុងសេចក្តីសន្និដ្ឋានស្ថាពរ ស.ព.អ លើកឡើងថា គាត់ពុំស្នើសុំឱ្យបញ្ជូន **យឹម ទិត្យ** ទៅជំនុំជម្រះចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយផ្អែកលើមូលដ្ឋានថា អំពើរបស់ **យឹម ទិត្យ** មានកំណត់ក្នុងច្បាប់គ្រប់គ្រាន់ ដោយបានកំណត់ជាក់លាក់ក្នុងច្បាប់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយការទម្លាក់ចោលបទចោទនៃការបំពារបំពានធ្ងន់ធ្ងរនឹងជៀសវាងបណ្តឹងពុំចាំបាច់ ហើយនឹងជួយពន្លឿនកិច្ចដំណើរការនីតិវិធីផងដែរ[196]។ មេធាវីការពារក្តីក៏សន្និដ្ឋានផងដែរថា ការពុំចោទប្រកាន់បទចោទនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរនឹងសន្សំពេលវេលានៅដំណាក់កាលជំនុំជម្រះក្តី[197]។ ខ្ញុំពុំជឿថាចាំបាច់ ឬ ជាប្រយោជន៍ក្នុងការទម្លាក់បទចោទនៃការបំពារបំពានធ្ងន់ធ្ងរដោយមូលដ្ឋានបែបនោះទេ ពោលគឺ វាពុំចំណេញពេលវេលាតាមរយៈវិធីនេះនោះទេ ដោយសារថា អង្គហេតុ និងភ័ស្តុតាងទាមទារយកមកបង្ហាញអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងមានលក្ខណៈជាន់គ្នាច្រើននឹងអង្គហេតុ និងភ័ស្តុតាងសម្រាប់បង្ហាញការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។

*លក្ខខណ្ឌទូទៅនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ*

77. ***អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ*** - *មាត្រា២ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវទាមទារ អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ* ដែលកើតមាននៅពេលណាដែលមានការងាកទៅប្រើ

[195] សំណុំរឿង ០០២-ឯកសារ **E306/6** *សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩* ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ៨-១២។ សំណុំរឿង ០០២-ឯកសារ **D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដោយ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ៧៣។

[196] ឯកសារ **D378/2** *ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ* ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ១០៨១។

[197] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាជាតិ និងព្រះរាជអាជ្ញាអន្តរជាតិ* ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ៤៦៧-៤៦៨។

ប្រាស់កងកម្លាំងប្រដាប់អាវុធរវាងរដ្ឋ និងរដ្ឋ ដោយមិនគិតថាតើរដ្ឋទាំងនោះទទួលស្គាល់ថា ស្ថានភាពសង្គ្រាមកើតឡើងឬក៏អត់នោះឡើយ[198]។

78. អនុសញ្ញាទីក្រុងហ្សឺណែវអនុវត្តចាប់តាំងពីពេលកើតមានជម្លោះប្រដាប់អាវុធ និងនៅក្រោយបញ្ចប់អារិភាពនឹងគ្នា រហូតដល់ពេលមានការព្រមព្រៀងសន្តិភាពជារួមមួយលើទឹកដីទាំងមូលនៃរដ្ឋភាគីនៃជម្លោះ មិនគិតថាការប្រយុទ្ធគ្នានោះកើតឡើងនៅទីនោះឡើយ[199]។

79. ***ចំណងទាក់ទងរវាងបទឧក្រិដ្ឋដូចបានចោទប្រកាន់ និងជម្លោះប្រដាប់អាវុធ*** - ឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ត្រូវជាប់ពាក់ព័ន្ធជិតស្និទ្ធជាមួយនឹងជម្លោះប្រដាប់អាវុធទាំងមូល ពោលគឺ វាពុំចាំបាច់បង្ហាញថាមានការប្រយុទ្ធជាក់ស្តែងនៅក្នុងតំបន់ដែលឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់ថាប្រព្រឹត្តឡើងនោះទេ។ ជម្លោះប្រដាប់អាវុធពុំចាំបាច់តែជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះទេ ប៉ុន្តែវាត្រូវតែជាផ្នែកសំខាន់មួយនៃការសម្រេចរបស់ចារី និងលទ្ធភាពក្នុងការប្រព្រឹត្តវា វិធីប្រព្រឹត្តវា ឬ គោលបំណងនៃការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[200]។

---

[198] មាត្រា២ នៃអនុសញ្ញាទីក្រុងហ្សឺណែវ។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤១១-៤១៤។ *រដ្ឋអាជ្ញា តទល់នឹង* Kordić *និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣៧៣។ *រដ្ឋអាជ្ញា តទល់នឹង* Tadić សាលដីកាសម្រេចលើសារណារបស់មេធាវីការពារក្តីស្នើសុំបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ *ICTY (IT-94-1-AR72)* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៨៤។ *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ១៨៣។ *សូមមើលផងដែរ* គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ *សេចក្តីអធិប្បាយលើអនុសញ្ញាទីក្រុងហ្សឺណែវ IV* ទីក្រុងហ្សឺណែវ ទំព័រ២០-២១។

[199] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤១៥។ *រដ្ឋអាជ្ញា តទល់នឹង* Kordić *និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣១៩-៣២១។ *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ១៨៣ ដែលបានដកស្រង់ *រដ្ឋអាជ្ញា តទល់នឹង* Tadić សាលដីកាសម្រេចលើសារណារបស់មេធាវីការពារក្តីស្នើសុំបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ *ICTY (IT-94-1-AR72)* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៧០។

[200] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤១៦។ *រដ្ឋអាជ្ញា តទល់នឹង* Tadić សាលដីកាសម្រេចលើសារណារបស់មេធាវីការពារក្តីស្នើសុំបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ *ICTY (IT-94-1-AR72)* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៧០។ *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៥៧-៥៩។ *រដ្ឋអាជ្ញា តទល់នឹង* *Duško Tadić* មតិចៅក្រម និង សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-94-1-T) ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៥៧២-៥៧៣។

80. ***ឋានៈនៃជនរងគ្រោះដែលជាបុគ្គលត្រូវបានការពារ*** - មាត្រា ៦ នៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការដល់ អ.វ.ត.ក លើអំពើប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិដែលត្រូវបានការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ។ ដោយសារវាពាក់ព័ន្ធនឹងបទចោទនៅក្នុងសំណុំរឿង ០០៤ អនុសញ្ញានេះរួមបញ្ចូលទាំងឈ្លើយសឹក (បុគ្គលដែលត្រូវបានការពារអនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវទីIII) និងជនស៊ីវិល (បុគ្គលដែលត្រូវបានការពារអនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវទីIV)[201]។

81. ឈ្លើយសឹកគឺជាបុគ្គលដែល *"ធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ"* និងស្ថិតនៅក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទដែលជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីនៃជម្លោះ និងជាសមាជិកយុទ្ធជន ឬ ក្រុមស្ម័គ្រចិត្តដែលបង្កើតជាផ្នែកមួយនៃកងកម្លាំងប្រដាប់អាវុធបែបនោះ[202]។ ការការពារផ្តល់ជូនឈ្លើយសឹកគិតចាប់ពីពេលដែលពួកគេធ្លាក់ក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវរហូតដល់ពេលដោះលែង ឬ ធ្វើមាតុភូមិនិវត្តន៍ចុងក្រោយរបស់ពួកគេ[203]។

82. ពាក់ព័ន្ធនឹងជនស៊ីវិល អនុសញ្ញាទីក្រុងហ្សឺណែវទីIV ការពារ *"ជនទាំងឡាយណាដែលស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីដែលមានជម្លោះ ឬ ដែលកាន់កាប់អំណាច ដែលពួកគេមិនមែនជាប្រជាជាតិដូចគ្នា"* [204]។ ការពិចារណាសំខាន់នៅពេលសម្រេចថាតើជនស៊ីវិលស្ថិតនៅក្រោមការការពារអនុសញ្ញាទីក្រុងហ្សឺណែវទីIV ដែរឬទេនោះគឺភាពស្មោះត្រង់ ឬ ការគ្មានភាពស្មោះត្រង់របស់បុគ្គលចំពោះភាគីនៃជម្លោះ ពោលគឺ ជនស៊ីវិលអាចត្រូវបានចាត់ទុកថាជាបុគ្គលដែលត្រូវបានការពារប្រសិនបើពួកគេត្រូវបានរដ្ឋដែលកាន់កាប់ពួកគេយល់ថាជាសមាជិកភាគីបដិបក្ខនៃជម្លោះប្រដាប់អាវុធ ហើយបង្កគ្រោះថ្នាក់ដល់រដ្ឋរបស់ខ្លួន បើទោះជាពួកគេគឺជាប្រជាជាតិរបស់រដ្ឋនោះក៏ដោយ[205]។

---

[201] ត្រូវបានការពារនៅក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ៤, ១២៩-១៣០ និងអនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៤, ១៤៦-១៤៧។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤១៧។

[202] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ៤(ក)។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤១៨។

[203] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៥។

[204] អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៤។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤១៨។

[205] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤១៩។ *រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៦៤-១៦៦, ១៦៨។ *រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែក

83. *ការដឹងឮរបស់ចារី* - *ចារីត្រូវដឹងគ្រប់គ្រាន់អំពីអង្គហេតុដែលបង្កើតជាលក្ខណៈអន្តរជាតិនៃជម្លោះប្រដាប់អាវុធ និងឋានៈដែលជនរងគ្រោះត្រូវបានការពារអនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវ*[206]។ ការដឹងរបស់ចារីថា រដ្ឋបរទេសមួយបានចូលរួមនៅក្នុងជម្លោះប្រដាប់អាវុធ ហើយជនរងគ្រោះជាសមាជិកនៃភាគីបដិបក្ខនៃជម្លោះគឺមានលក្ខណៈគ្រប់គ្រាន់[207]។

*ធាតុផ្សំនៃបទឧក្រិដ្ឋដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*

84. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវដូចខាងក្រោមជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០៤ ពោលគឺ ការធ្វើមនុស្សឃាតដោយចេតនា និងការនិរទេសខ្លួន ឬ ការជម្លៀសជនស៊ីវិលដោយខុសច្បាប់[208]។

85. ធាតុផ្សំនៃ ***ការធ្វើមនុស្សឃាតដោយចេតនា*** គឺដូចគ្នានឹងធាតុផ្សំនៃអំពើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[209]។

86. ធាតុផ្សំនៃ ***ការជម្លៀសជនស៊ីវិលដោយបង្ខំ*** គឺដូចគ្នានឹងធាតុផ្សំនៃការនិរទេសខ្លួនដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[210] លើកលែងតែការជម្លៀសដោយខុសច្បាប់ដែលពុំទាមទារការជម្លៀសនៅទូទាំងព្រំប្រទល់ប្រទេស[211]។

---

កក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១៧២, ១៨០-១៨១។ *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកដទៃ (“សំណុំរឿង* Čelebići*”)* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៧៣, ៩៨។

[206] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤២១-៤២២។ *រដ្ឋអាជ្ញា តទល់នឹង* *Naletilic និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-34-A) ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ១១៣-១២១។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង* Kordić *និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣១១។

[207] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤២១-៤២២។

[208] ច្បាប់ អ.វ.ត.ក មាត្រា៦។

[209] *សូមមើល កថាខណ្ឌ៤៦។* សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៣១។ *រដ្ឋអាជ្ញា តទល់នឹង* Brđanin សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ៣៨០។

[210] *សូមមើល* កថាខណ្ឌ៤៩។

[211] *រដ្ឋអាជ្ញា តទល់នឹង* Krnojelac សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ៤៧៤, កំណត់សម្គាល់។ *រដ្ឋអាជ្ញា តទល់នឹង* Stakić សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-97-24-A) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ៣១៧។

87. ធាតុផ្សំនៃ***ការនិរទេសជនស៊ីវិលដោយខុសច្បាប់*** គឺដូចនឹងធាតុផ្សំនៃការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[212]។

### ៣.២.២. ឧក្រិដ្ឋកម្មជាតិ

88. មាត្រា៣ថ្មីនៃច្បាប់ អ.វ.ត.ក យល់យុត្តាធិការដល់ ស.ច.ស លើឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត[213] ដែលជាការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពោលគឺ ក្រមព្រហ្មទណ្ឌជាធរមានអនុវត្តចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[214]។

89. នៅក្នុងសេចក្ដីសន្និដ្ឋានស្ថាពររបស់ខ្លួន ស.ព.អ លើកឡើងថា គាត់ពុំស្នើសុំបញ្ជូន **យឹម ទិត្យ** ទៅជំនុំជម្រះចំពោះបទល្មើសក្រោមច្បាប់ជាតិឡើយ ដោយឈរលើមូលដ្ឋានថា ការប្រព្រឹត្តរបស់ **យឹម ទិត្យ** គួរត្រូវបានកំណត់លក្ខណៈជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិនៃអំពើប្រល័យពូជសាសន៍ និងអំពើប្រឆាំងនឹងមនុស្សជាតិ ហើយការមិនចាត់ទុកថាជាឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ នឹងបញ្ចៀសមិនឱ្យមានបណ្ដឹងពុំចាំបាច់ ដូច្នេះហើយអាចនឹងជួយពន្លឿនកិច្ចដំណើរការនីតិវិធី[215]។ មេធាវីការពារក្ដីក៏សន្និដ្ឋានផងដែរថា ការពុំចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិនឹងសន្សំពេលវេលានៅដំណាក់កាលជំនុំជម្រះក្ដី[216]។ ខ្ញុំមិនជឿជាក់ថា ការមិនចាត់ទុកថាជាឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិដោយមូលដ្ឋានបែបនេះ មានភាពចាំបាច់ និងមានប្រយោជន៍នោះទេ ពោលគឺ វាពុំចំណេញពេលវេលាតាមរយៈវិធីនេះនោះទេ ដោយសារថា អង្គហេតុ និងភ័ស្តុតាងដែលតម្រូវសម្រាប់បង្ហាញអំពើឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ នឹងជាន់គ្នាច្រើន បើទោះជាមិនទាំងអស់ក៏ដោយ ជាមួយនឹងអង្គហេតុ និងភ័ស្តុតាងដែលតម្រូវសម្រាប់បង្ហាញអំពីឧក្រិដ្ឋកម្មក្រោមច្បាប់ ជាតិ។

*អំពើមនុស្សឃាត*

---

[212] *សូមមើល* កថាខណ្ឌ ៥៩។

[213] មាត្រា៥០១, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

[214] សំណុំរឿង ០០១-ឯកសារ **F28** *សាលដីកាសម្រេចលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១* ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩២។

[215] ឯកសារ **D378/2** *ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ* ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ១០៨០។

[216] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាជាតិ និងព្រះរាជអាជ្ញាអន្តរជាតិ* ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៤៦៧-៤៦៨។

90. ទម្រង់មួយក្នុងចំណោមទម្រង់នៃអំពើមនុស្សឃាតក្រោមច្បាប់ជាតិចំនួនពីរអនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺការធ្វើមនុស្សឃាតដោយគិតទុកជាមុន[217] ដែលទាមទារធាតុផ្សំដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ចារីត្រូវបង្កឱ្យមានការស្លាប់ដល់បុគ្គលម្នាក់ទៀត[218]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវធ្វើអំពើ *"ដោយគិតទុកជាមុន"* និង *"មានមរណចេតនា"*[219]។ ការគិតទុកជាមុនត្រូវបានកំណត់និយមន័យថាជា *"ការតាំងចិត្តជាស្រេចថានឹងប្រព្រឹត្តនូវអំពើណាមួយមុនពេលដែលប្រព្រឹត្តនូវអំពើនោះគឺថា ពេលសម្រេចនឹងពេលដែលប្រព្រឹត្តមានចន្លោះឃ្លាតពីគ្នាល្មមឱ្យចារីរៀបចំដំណើរការនេះបាន"*[220]។

91. អ.ប.ជ បានរកឃើញថា ការធ្វើមនុស្សឃាតគិតទុកជាមុនគឺពុំស្របចូលក្នុងឧក្រិដ្ឋកម្មអន្តរជាតិនៃការធ្វើមនុស្សឃាតនោះឡើយ ដែលវាតម្រូវការគិតទុកជាមុន និង*ធាតុផ្សំអត្តនោម័ត*ខ្ពស់ជាងពោលគឺ ចេតនាសម្លាប់ជាជាងចេតនាបង្កគ្រោះថ្នាក់ដល់រូបរាងកាយធ្ងន់ធ្ងរ ដែលមានលក្ខណៈស្រាលជាង[221]។

## ៣.៣. ទម្រង់នៃការទទួលខុសត្រូវ

### ៣.៣.១. ទម្រង់នៃការទទួលខុសត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិ

92. អនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក បុគ្គលណាក៏ដោយអាចទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈទម្រង់នៃការទទួលខុសត្រូវនៃការប្រព្រឹត្ត (រួមទាំងតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម) ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការទទួលខុសត្រូវរបស់ថ្នាក់លើ។

---

217 មាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ សំណុំរឿង ០០១-ឯកសារ **D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ៧៤, ៧៦។

218 សំណុំរឿង ០០១-ឯកសារ **D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ៧៤។

219 សំណុំរឿង ០០១-ឯកសារ **D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ៧៦។

220 សំណុំរឿង ០០១-ឯកសារ **D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ៧៨។

221 សំណុំរឿង ០០១-ឯកសារ **D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ៨៤។

ទម្រង់នៃការទទួលខុសត្រូវទាំងនេះគឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទាំងអស់ នៅក្នុងអំឡុងពេលដែលមានចែងនៅក្នុងយុត្តាធិការពេលវេលានៃ អ.វ.ត.ក[222]។

93. ***ការប្រព្រឹត្ត*** - ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយនេះរួមបញ្ចូលការប្រព្រឹត្តជាក់ស្តែង ឬ អំពើអកម្មដែលមានពិរុទ្ធ[223]។ ចារីត្រូវតែធ្វើសកម្មភាពណាមួយដោយមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ ដោយដឹងអំពីភាពសំខាន់ដែលថា ឧក្រិដ្ឋកម្មនឹងកើតឡើងដោយសារផលវិបាកនៃការប្រព្រឹត្តដូចបានចោទប្រកាន់[224]។ ការប្រព្រឹត្តក៏រួមបញ្ចូលការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម[225] ដែលនឹងពិភាក្សាក្នុងចំណុចខាងក្រោម។

94. ***ការរៀបចំផែនការ*** - ទម្រង់នៃការទទួលខុសត្រូវមួយនេះកើតឡើងនៅពេលមនុស្សម្នាក់ ឬ ច្រើននាក់រៀបចំការប្រព្រឹត្តល្មើសណាមួយដែលជាឧក្រិដ្ឋកម្មមួយ ឬ ច្រើន ត្រូវបានប្រព្រឹត្តឡើងនៅពេលក្រោយមក[226]។ ការរៀបចំផែនការត្រូវធ្វើឡើងមុន ឬ បានចូលរួមចំណែកសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម[227]។ ចារីត្រូវមានចេតនាលើឧក្រិដ្ឋកម្មដែលនឹងប្រព្រឹត្តឡើង ឬ បានដឹងអំពីភាពសំខាន់ថា ឧក្រិដ្ឋកម្មនោះនឹងប្រព្រឹត្តឡើងដើម្បីអនុវត្តផែនការ[228]។

---

[222] <u>ការប្រព្រឹត្ត៖</u> សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៧៨-៤៧៩។ <u>ការរៀបចំផែនការ៖</u> សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៧។ <u>ការញុះញង់៖</u> សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៩។ <u>ការបញ្ជា៖</u> សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០១។ <u>ការទទួលខុសត្រូវរបស់ថ្នាក់លើ៖</u> សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧១៤។

[223] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៧៩។

[224] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៨១។

[225] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៧៩។

[226] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៨។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥១៨។ *រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៦។

[227] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥១៨។

[228] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៨។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥១៩។

95. ***ការញុះញង់*** - ទម្រង់នៃការទទួលខុសត្រូវមួយនេះកើតឡើងនៅពេលបុគ្គលម្នាក់ តាមរយៈអំពើសកម្ម ឬ អំពើអកម្ម ជម្រុញឱ្យបុគ្គលម្នាក់ទៀតប្រព្រឹត្តឧក្រិដ្ឋកម្ម[229]។ ការញុះញង់អាចបង្ហាញតាមរយៈការជម្រុញដោយអំពើស្ងៀមស្ងាត់ ជាលាយលក្ខណ៍អក្សរ ឬ ដោយទម្រង់អ្វីក៏ដោយមិនចាំបាច់តែជាការនិយាយនោះទេ ហើយវាពុំចាំបាច់បង្ហាញអំពីសិទ្ធិអំណាចរវាងអ្នកត្រូវបានចោទប្រកាន់ថាជាអ្នកញុះញង់ និងចារីនោះឡើយ[230]។ ការញុះញង់ត្រូវកើតឡើងមុន ឬ បានចូលរួមចំណែកសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម[231]។ អ្នកញុះញង់ត្រូវមានចេតនាបង្កហេតុ ឬ នាំហេតុឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ ដឹងអំពីភាពសំខាន់ថា ឧក្រិដ្ឋកម្មនឹងប្រព្រឹត្តឡើងដោយសារការញុះញង់នោះ[232]។

96. ***ការបញ្ជា*** - ទម្រង់នៃការទទួលខុសត្រូវមួយនេះកើតឡើងនៅពេលបុគ្គលម្នាក់ ដែលមានសិទ្ធិអំណាច*តាមអង្គហេតុ ឬ តាមផ្លូវច្បាប់* បង្គាប់បុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[233]។ គ្មានចាំបាច់ត្រូវការមានទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោមនោះឡើយ[234]។ បញ្ជានោះ ដែលពុំចាំបាច់ធ្វើឡើងក្នុងទម្រង់ណាមួយជាក់លាក់នោះឡើយ ត្រូវកើតឡើងមុន ឬ បានចូលរួមចំណែកសំខាន់ដល់ការប្រព្រឹត្តអំពើល្មើស[235]។ ការទទួលខុសត្រូវចំពោះការបញ្ជាអាចកើតឡើងផងដែរក្នុង

---

[229] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០០។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២២។

[230] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០០។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២២។

[231] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០០។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២២។ *រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៧។

[232] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០០។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២៤។

[233] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០២។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២៧។

[234] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០២។សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២៧។

[235] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០២។សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២៧។

ករណីបុគ្គលម្នាក់ដាក់ចេញ ឬ បញ្ជូនបញ្ជានោះ ដែលរួមទាំងតាមរយៈអន្តរការី[236]។ អ្នកដែលចេញបញ្ជាត្រូវមានចេតនាឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ ដឹងអំពីភាពសំខាន់ថា ឧក្រិដ្ឋកម្មនោះនឹងប្រព្រឹត្តឡើងដោយសារផលវិបាកនៃការធ្វើតាមបញ្ជា[237]។

97. ***ការទទួលខុសត្រូវរបស់ថ្នាក់លើ*** - ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដោយសារអំពើអកម្មដែលមានពិរុទ្ធ ដែលថ្នាក់លើជាយោធា ឬ ស៊ីវិល អាចទទួលខុសត្រូវព្រហ្មទណ្ឌដោយសារខកខានមិនបានទប់ស្កាត់ និង/ឬ ដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោម។

98. លក្ខខណ្ឌដំបូងគឺអត្ថិភាពនៃទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោម[238] ដែលអាចតាមរយៈអង្គហេតុ ឬ ផ្លូវច្បាប់[239]។ម្យ៉ាងវិញទៀត ការទទួលខុសត្រូវរបស់ថ្នាក់លើ និងថ្នាក់ក្រោម អនុវត្តចំពោះថ្នាក់លើទាំងយោធា និងស៊ីវិល[240]។ ថ្នាក់លើ មិនថាជាយោធា ឬ ស៊ីវិល ត្រូវមានការគ្រប់គ្រងដោយប្រសិទ្ធភាព ដែលជាសមត្ថភាពខាងសម្ភារៈដើម្បីទប់ស្កាត់ និង/ឬ ដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ចារីនៅថ្នាក់ក្រោម[241]។ ចំណុចចុងក្រោយ ថ្នាក់លើត្រូវតែខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្របដើម្បីទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ ដាក់ទណ្ឌកម្មចារី[242]។ យោងតាមយុត្តិសាស្ត្រនៃសាលាក្តី*មិនអចិន្ត្រៃយ៍* គេពុំចាំបាច់បង្ហាញទំនាក់ទំនង

---

[236] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០២។សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២៧។

[237] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧០២។សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥២៨។

[238] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧១៥។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៣៨។

[239] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៤០។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកដទៃ (“សំណុំរឿង Čelebići”)* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ១៩១-១៩២ និង *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ១០៣៨។

[240] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧១៤។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៧៦-៤៧៧។

[241] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧១៥។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៤០-៥៤២។

[242] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧១៦។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៤៥-៥៤៧។

ហេតុ និងបច្ច័យរវាងការខកខានរបស់ថ្នាក់លើក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មរបស់ថ្នាក់ក្រោម និងការកើតឡើងនៃឧក្រិដ្ឋកម្មទាំងនោះឡើយ[243]។

99. ក្រៅពីនេះ ដើម្បីអាចឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន ថ្នាក់លើត្រូវតែបានដឹង ឬ មានហេតុផលដឹងថា ក្នុងស្ថានភាពដែលគាត់មានព័ត៌មានគ្រប់គ្រាន់សម្រាប់ធ្វើការបញ្ជាក់ក្នុងការស៊ើបអង្កេត ឧក្រិដ្ឋកម្ម បម្រុងនឹងប្រព្រឹត្ត ឬ បានប្រព្រឹត្តដោយថ្នាក់លើរបស់ខ្លួនម្នាក់ ឬ ច្រើននាក់[244]។ ថ្នាក់លើពុំចាំបាច់ដឹងអត្តសញ្ញាណរបស់ចារីថ្នាក់ក្រោមជាក់លាក់នោះទេ ពោលគឺ ត្រូវបង្ហាញអត្ថិភាពរបស់វា[245]។

100. ការខកខានមិនបានទប់ស្កាត់ និងការខកខានមិនបានដាក់ទណ្ឌកម្មគឺជាទម្រង់នៃការទទួលខុសត្រូវតាមផ្លូវច្បាប់ និងអង្គហេតុ ដែលតំណាងកាតព្វកិច្ចផ្លូវច្បាប់ពីរដោយឡែកពីគ្នា។ ថ្នាក់លើអាចទទួលខុសត្រូវចំពោះការខកខានទាំងពីរ[246]។

101. ថ្នាក់លើអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយថ្នាក់ក្រោម ដែលពុំស្ថិតនៅក្រោមការគ្រប់គ្រង*ដោយផ្ទាល់* ផ្លូវការ ប្រសិនបើបានបំពេញលក្ខខណ្ឌផ្សេងទៀតនៃការទទួលខុសត្រូវរបស់ថ្នាក់លើ[247]។

---

[243] *រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និង Kubura* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ *ICTY (IT-01-47-A)* ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ៤០។

[244] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧១៥។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៤៣-៥៤៤។

[245] *រដ្ឋអាជ្ញា តទល់នឹង* Blagojević *និង Jokić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-02-60-A) ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ២៨៧។ *រដ្ឋអាជ្ញា តទល់នឹង Orić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-03-68-A) ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ៣៥។

[246] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៤៥-៥៤៧។ *សូមមើលផងដែររដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និង Kubura* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ *ICTY (IT-01-47-A)* ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ២៥៩-២៦០។

[247] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧២១។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៤២ ដែលបានដកស្រង់ *រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៦៧ និង *រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកដទៃ ("សំណុំរឿង Čelebići")* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២៥២។

102. *ធាតុផ្សំអត្តនោម័ត* ដែលតម្រូវឱ្យថ្នាក់លើទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់គឺ ថ្នាក់លើបានដឹង ឬ មានហេតុផលដឹងថា ថ្នាក់ក្រោមរបស់ពួកគេ (i) បម្រុងប្រព្រឹត្ត ឬ បាន ប្រព្រឹត្តឧក្រិដ្ឋកម្មពាក់ព័ន្ធ និង (ii) មានចេតនាជាក់លាក់ទៅតាមលក្ខខណ្ឌតម្រូវ[248]។

103. មេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍តវ៉ាថា ការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តតែចំពោះឧក្រិដ្ឋ កម្មដែលជាប់ទាក់ទងនឹងជម្លោះប្រដាប់អាវុធ[249]។ ខ្ញុំយល់ឃើញថា វាឆ្លើយតបទៅនឹងច្បាប់នៅ អ .វ.ត.ក ដែលថា ទ្រឹស្តីអនុវត្ត នៅមុនពេលឆ្នាំ១៩៧៥ ចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិន មែនអន្តរជាតិ ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[250] ហើយសំដៅលើ និងសំអាងលើវិធីសាស្ត្រ ស៊ីសង្វាក់គ្នាចំពោះទ្រឹស្តីនៅ អ.វ.ត.ក ពោលគឺ ការទទួលខុសត្រូវរបស់ថ្នាក់លើមានអត្ថិភាពនៅ ក្នុងច្បាប់អន្តរជាតិ ដោយមិនគិតពីបរិបទ នៅត្រឹមឆ្នាំ១៩៧៥[251]។

---

[248] *រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-02-60-T) ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦៨២, ៦៨៦។ *រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៧១៥-៧២១។

[249] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាជាតិ និងព្រះរាជអាជ្ញាអន្តរជាតិ* ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ៦០៣-៦០៤។

[250] សំណុំរឿង ០០១-ឯកសារ **D267** *[កោសលុប] ដីកាដំណោះស្រាយ* ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ១០៤។

[251] ក្នុងសំណុំរឿង ០០២ ពុំមានការបង្ហាញពីភាពខុសគ្នារវាងជម្លោះលក្ខណៈអន្តរជាតិ និងជម្លោះពុំមានលក្ខណៈអន្តរជាតិ ពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ (សំណុំរឿង ០០២-ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៣០៧, ១៣១៩, ១៥៥៨-១៥៦២) ដោយអង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំណុំរឿង ០០២-ឯកសារ **D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១៩០-២៣២។ សំណុំរឿង ០០២-ឯកសារ **D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដោយ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ៤១៣-៤៦០) ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រមរបស់ខ្លួន (សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧១៤-៧១៩) និងក៏មិនមែនដោយភាគីទាំងឡាយនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ (សំណុំរឿង ០០២-ឯកសារ **E457/6/3/1** *សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ១២១៣។ សំណុំរឿង ០០២-ឯកសារ **E457/6/1/1** *សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ២៩៦-២៥៥។ សំណុំរឿង ០០២-ឯកសារ **E457/6/2/3** *សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧។ សំណុំរឿង ០០២-ឯកសារ **E457/ E457/6/4/1.2** *សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ២៤៦៩-២៤៧០)។

104. *សហឧក្រិដ្ឋកម្មរួម* - ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្ម ("សហឧក្រិដ្ឋកម្មរួម") គឺជាការប្រព្រឹត្ត អនុលោតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[252]។ សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការប្រព្រឹត្តរួមគ្នា ដែលមានមនុស្សច្រើនមានគោលបំណង ឬ គោលដៅរួម ដែលស្មើទៅនឹង ឬ ពាក់ព័ន្ធនឹងការ ប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬ ច្រើន[253]។

105. តុលាការ និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិបានកំណត់សហឧក្រិដ្ឋកម្មរួមជាបីទម្រង់[254]។ ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី[255] សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ទី២ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ហើយអាចអនុវត្តបាននៅ អ.វ.ត.ក[256]។ សហឧក្រិដ្ឋកម្មរួមទម្រង់ទីបីពុំមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលនោះទេ ហេតុដូច្នេះ ពុំអាចអនុវត្តបាននៅ អ.វ.ត.ក នោះឡើយ[257]។ សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ទី២ មានធាតុផ្សំគោលបំណងរួមចំនួនបីដូចបង្ហាញនៅក្នុងកថាខណ្ឌខាង

---

[252] សំណុំរឿង ០០២-ឯកសារ **E100/6** *សេចក្តីសម្រេចលើភាពអនុវត្តបានទូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ២២។ សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩០។

[253] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩២។

[254] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩០។ *រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៩៦-២០៤។

[255] ឯកសារ **D378/5** *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាជាតិ និងព្រះរាជអាជ្ញាអន្តរជាតិ* ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ៥២៤-៥៩៨។

[256] សំណុំរឿង ០០២-ឯកសារ **E100/6** *សេចក្តីសម្រេចលើភាពអនុវត្តបានទូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ២២។ សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩១។ សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៧៩១។

[257] សំណុំរឿង ០០២-ឯកសារ **E100/6** *សេចក្តីសម្រេចលើភាពអនុវត្តបានទូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ៣៥, ៣៨។ សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៧៩១។ សំណុំរឿង ០០២-ឯកសារ **D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ៧៧, ៨៧-៨៨។

ក្រោម[258]។ ទោះបីជាយ៉ាងនេះក្ដី ទម្រង់ទី២ ត្រូវបានកំណត់លក្ខណៈតាមរយៈអត្ថិភាពនៃប្រព័ន្ធធ្វើបាបដែលមានការរៀបចំ[259]។

106. *គោលបំណងរួម* - គោលបំណងរួម ឬ គោលដៅរួម អាចមានលក្ខណៈឧក្រិដ្ឋជាប់មកជាមួយ (ពោលគឺ គោលបំណងរួម*គឺស្មើនឹង*ការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬ ច្រើន) ឬ មានគោលដៅមិនមែនជាលក្ខណៈព្រហ្មទណ្ឌ ដែលមនុស្សច្រើនមានចេតនាសម្រេច តាមរយៈមធ្យោបាយឧក្រិដ្ឋ (ពោលគឺ គោលបំណងរួម*ជាប់ពាក់ព័ន្ធនឹង*ការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬ ច្រើន)[260]។

107. ឧទាហរណ៍ នៅក្នុងសំណុំរឿង ០០២/១ អ.ជ.ស.ដ និង អ.ជ.ត.ក បានរកឃើញថា សមាជិកសហឧក្រិដ្ឋកម្មរួមមានគោលបំណងរួមនៅក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមនៅកម្ពុជា ដែលពុំមែនជាគោលបំណងឧក្រិដ្ឋនោះឡើយ ប៉ុន្តែវាជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដើម្បីសម្រេចគោលបំណងរួម[261]។

---

[258] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩២។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥០៨។

[259] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥០៧។ សំណុំរឿង ០០២-ឯកសារ **E100/6** *សេចក្ដីសម្រេចលើភាពអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ២២។

[260] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៨១៤។ សំណុំរឿង ០០២-ឯកសារ **E100/6** *សេចក្ដីសម្រេចលើភាពអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ១៧។ សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៦។ *រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤១៨។ *រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ SCSL (SCSL-04-16-A) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ៨០។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ៩៦។

[261] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៧៧៨, ៨០៤, ៨៣៤។ សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៨១៦។ ស្រដៀងគ្នានេះដែរ នៅក្នុង *រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកដទៃ* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-04-74-T) ក្បាលទី៤ នៃក្បាល៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ២៤, ៤១-៤៣, ៦៥-៦៨ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា សមាជិកឧក្រិដ្ឋកម្មរួម មានគោលបំណងបង្កើតរដ្ឋឯករាជ្យមួយ ផ្ដាច់ពីប្រទេសបូស្នៀរ និងហឺហ្គោវីណា។ ទោះបីជាគោលបំណងនេះពុំមែនជាបទឧក្រិដ្ឋក្ដី សមាជិកសហឧក្រិដ្ឋកម្មរួមបានព្យាយាមសម្រេចគោលបំណងតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងប្រជាជនមូស្លីម។

108. ពុំមានលក្ខខណ្ឌតម្រូវចំពោះផែនការដែលបានបង្កើតឡើង ឬ រៀបចំពីមុន ដោយអ្នកចូលរួមនោះទេ។ គោលបំណង ឬ គោលដៅរួមអាចស្តែងចេញភ្លាមៗ និងអាចសន្និដ្ឋានចេញពីអង្គហេតុដែលថា មនុស្សច្រើនបានធ្វើសកម្មភាពរួមគ្នាដើម្បីសម្រេចសហឧក្រិដ្ឋកម្មរួម[262]។

109. *មនុស្សច្រើន* - សហឧក្រិដ្ឋកម្មរួមតម្រូវឱ្យមានការចូលរួមពីមនុស្សច្រើននៅក្នុងគោលបំណងរួម[263] ដោយពុំចាំបាច់កំណត់អត្តសញ្ញាណអ្នកចូលរួមទាំងអស់នៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយចំឈ្មោះនោះទេ ហើយវាគ្រប់គ្រាន់ត្រឹមសំដៅលើប្រភេទ ឬ ក្រុមមនុស្ស[264]។ មនុស្សច្រើនពុំចាំបាច់រៀបចំជារចនាសម្ព័ន្ធយោធា នយោបាយ ឬ រដ្ឋបាលនោះឡើយ[265]។

110. *ការចូលរួមនៅក្នុងគោលបំណងរួម* - ការចូលរួមនៅក្នុងគោលបំណងរួមពុំចាំបាច់ពាក់ព័ន្ធនឹងការអនុវត្ត*ធាតុផ្សំសត្យានុម័ត* ផ្នែកណាមួយ នៃឧក្រិដ្ឋកម្ម ដែលបង្កើតជាគោលបំណងរួមនោះ

---

[262] *រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ២២៧(ii)។ *រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ៤១៨។ *រដ្ឋអាជ្ញា តទល់នឹង Mpambara* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTR (ICTR-01-65-T) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ១៣ ដែលចែងថា "មិនដូចគ្នានឹងបទសមគំនិត ពុំមានការព្រមព្រៀងគ្នាជាក់លាក់ណាមួយដែលចាំបាច់ដើម្បីបង្ហាញពីការប្រព្រឹត្តិបទឧក្រិដ្ឋ: គោលបំណងរួមអាចកើតឡើងភ្លាមៗ និងក្រៅផ្លូវការ ហើយបុគ្គលទាំងឡាយដែលពាក់ព័ន្ធ មិនចាំបាច់ត្រូវចូលរួមតាមរយៈអង្គការផ្លូវការនោះទេ"។

[263] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩២។ *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ៨១។

[264] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩២។ *រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ៤៣០។ *រដ្ឋអាជ្ញា តទល់នឹង Đorđević* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-87/1-T) ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១៨៦១៖ "*ការកំណត់ឈ្មោះបុគ្គលម្នាក់ៗដែលពាក់ព័ន្ធមិនមែនជាការចាំបាច់ឡើយ អាស្រ័យលើកាលៈទេសៈនៃសំណុំរឿង វាអាចមានន័យគ្រប់គ្រាន់ដោយយោងទៅប្រភេទ ឬក្រុមរបស់បុគ្គលទាំងនោះ។ ទោះជាយ៉ាងនេះក្តី ប្រភេទ ឬក្រុមបុគ្គលបែបនេះ ត្រូវតែមានការកំណត់អត្តសញ្ញាណគ្រប់គ្រាន់ ដើម្បីជៀសវាងភាពស្រពិចស្រពិល ឬមិនច្បាស់លាស់*"។ ជាឧទាហរណ៍បង្ហាញពីភាពមិនច្បាស់លាស់ខ្លាំងនៃការកំណត់ចរិកលក្ខណៈនៃសមាជិកសហឧក្រិដ្ឋកម្ម *សូមមើល រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៥៦-១៥៧។ *សូមមើល រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៥៦-១៥៧។

[265] *រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ 227(i); *រដ្ឋអាជ្ញា តទល់នឹង Đorđević* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-05-87/1-T) ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១៨៦១។

ឡើយ[266]។ វាគ្រប់គ្រាន់នៅពេលការប្រព្រឹត្តរបស់អ្នកចូលរួមមានលក្ខណៈសំដៅលើការ ជម្រុញសម្រេចគោលបំណងរួម[267]។ ការប្រព្រឹត្តរបស់សមាជិកសហឧក្រិដ្ឋកម្មរួមអាចមានទម្រង់ជាអំពើសកម្ម ឬ អំពើអកម្មដែលមានពិរុទ្ធ[268]។ ការចូលរួមចំណែករបស់សមាជិកសហឧក្រិដ្ឋកម្មរួមពុំចាំបាច់ទាល់តែមានលក្ខណៈចាំបាច់ រហូតដល់ថ្នាក់ថា ប្រសិនបើគ្មានវា ផ្នែកឧក្រិដ្ឋកម្មនៃគោល

---

[266] *រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២00៧ កថាខណ្ឌ 427; *រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ 227(iii); *រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២00៩ កថាខណ្ឌ២១៥។

[267] *រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ 191, 227 (iii), 229 (iii); *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២00៥ កថាខណ្ឌ១៨៧។ សាលក្រម *Krajišnik* ផ្តល់នូវឧទាហរណ៍ល្អមួយ នៃការប្រព្រឹត្តដែលពុំមែនជាបទឧក្រិដ្ឋ*ដោយខ្លួនឯង*នោះទេ ប៉ុន្តែ នៅក្នុងកាលៈទេសៈនៃសំណុំរឿង បានផ្តល់ការចូលរួមសំខាន់នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។ ក្នុងកថាខណ្ឌ១១២0 និង១១២១ នៃ *រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលក្រម អង្គជំនុំជម្រះសាលាដំបូង តុលាការ ICTY (IT-00-39-T) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២00៦ អង្គជំនុំជម្រះរកឃើញថា ការចូលរួមជាសរុបរបស់ *Krajišnik* ទៅក្នុងសហឧក្រិដ្ឋកម្មរួម គឺដើម្បីជួយបង្កើត និងរក្សាគណៈបក្ស SDS និងរចនាសម្ព័ន្ធរដ្ឋ *"ដែលជួយឱ្យបានសម្រេចដល់ការប្រព្រឹត្តិបទឧក្រិដ្ឋ។"* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានតម្កល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយថ្លែងថា *"ការចូលរួមរបស់ជនជាប់ចោទ នៅក្នុងសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ។ អ្វីដែលសំខាន់គឺថា ការចូលរួមនេះបានជំរុញឱ្យមានការអនុវត្តគោលបំណង ឬកម្មវត្ថុរួម ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ។"* *រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ ២00៩ កថាខណ្ឌ២១៥, ២១៨។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២00៧ កថាខណ្ឌ៤៣0។

[268] សំណុំរឿង 00១-ឯកសារ **E313** *សាលក្រមសំណុំរឿង 00២/0១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២0១៤ កថាខណ្ឌ៦៩៣។ *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២00៥ កថាខណ្ឌ១៨៧, ៤២១, ៥៥៦។ ជាគោលការណ៍ទូទៅ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ តុលាការ ICTY និង តុលាការ ICTR បានធ្វើការសម្រេចដោយមានភាពស៊ីសង្វាក់គ្នាថា ឧក្រិដ្ឋកម្មមួយអាចត្រូវបានប្រព្រឹត្តដោយការខកខានដែលគួរដាក់ទណ្ឌកម្ម នៅពេលដែលមានភារកិច្ចត្រូវបំពេញ ហើយថា ជនជាប់ចោទអាចត្រូវទទួលខុសត្រូវផ្ទាល់សម្រាប់ការចូលរួមឧក្រិដ្ឋកម្ម ដោយសារការខកខាន នៅពេលដែលជនជាប់ចោទមានភារកិច្ចត្រូវបំពេញ។ *សូមមើល រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២00៤ កថាខណ្ឌ៦៦៣។ *រដ្ឋអាជ្ញា តទល់នឹង Galić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-29-A) ចុះថ្ងៃទី៣0 ខែវិច្ឆិកា ឆ្នាំ ២00៦ កថាខណ្ឌ១៧៥។

បំណងរួមអាច ឬ ទំនងអាចប្រព្រឹត្តឡើង[269] ប៉ុន្តែ យ៉ាងហោចណាស់ ត្រូវមានការចូលរួមចំណែកសំខាន់លើឧក្រិដ្ឋកម្ម[270]។

111. សូម្បីសកម្មភាពដែលមើលទៅពុំពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម អាចយកមកពិចារណា នៅពេលកំណត់ថាតើសមាជិកសហឧក្រិដ្ឋកម្មរួមបានចូលរួមចំណែកសំខាន់ដែរឬទេ[271]។ សកម្មភាពបែបនេះអាចជម្រុញ និងគាំទ្រការប្រព្រឹត្តឧក្រិដ្ឋកម្ម បើទោះជាដោយប្រយោលក៏ដោយ[272]។ នៅពេលវាយតម្លៃ សកម្មភាពទាំងអស់គួរយកមកពិចារណា ហើយការចូលរួមចំណែកសំខាន់មិនគួរយកមកវាយតម្លៃដាច់ដោយឡែកនោះឡើយ[273]។ ភាពសំខាន់នៃការចូលរួមចំណែកចំពោះសហឧក្រិដ្ឋកម្មរួមគួរសម្រេចទៅតាមករណីនីមួយៗ ដោយត្រូវពិចារណាកត្តាជាច្រើន រួមទាំង តួនាទីរបស់ជនត្រូវចោទ កម្រិត និងប្រសិទ្ធភាព នៃការចូលរួម និងកិច្ចប្រឹងប្រែងក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម[274]។

112. *ធាតុផ្សំអត្តនោម័ត* - ចំពោះសហឧក្រិដ្ឋកម្មទម្រង់ទី១ សមាជិកសហឧក្រិដ្ឋកម្មរួមត្រូវមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗ ដែលជាផ្នែកមួយនៃគោលបំណងរួម ពោលគឺ ចេតនាត្រូវរួមបញ្ចូលទាំងគោលបំណងរួម និងឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងគោលបំណងរួមទាំងនោះ[275]។ ចេតនានេះត្រូវធ្វើឡើងរួមគ្នា និងមានដូចគ្នាក្នុងចំណោមសមាជិកសហឧក្រិដ្ឋកម្មទាំងអស់[276]។ ចំពោះសហឧក្រិដ្ឋ

---

[269] *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ៩៨, ១៩៣។

[270] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៩៨០។ *រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ៤៣០។ *រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២១៥, ៦៩៦។

[271] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៩៨៤។

[272] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៩៨៤។

[273] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៩៨០។

[274] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៩៨០។

[275] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ១០៥៣។

[276] *រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ៤៣០។ *រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២០០។ *រដ្ឋអាជ្ញា តទល់នឹង Stakić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-97-24-A) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ៦៥។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៩៦៖

កម្មវិធីរួមទម្រង់ទី២ សមាជិកសហឧក្រិដ្ឋកម្មរួមត្រូវដឹងអំពីលក្ខណៈឧក្រិដ្ឋនៃប្រពន្ធធ្វើបាប និង ចេតនាជម្រុញសម្រេចប្រព័ន្ធនោះ[277]។ ក្នុងករណីឧក្រិដ្ឋកម្មជាប់ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ ឬ អំពើប្រល័យពូជសាសន៍ សមាជិកសហឧក្រិដ្ឋកម្មរួមត្រូវមានចេតនាពិសេសរួមគ្នាដែលជា លក្ខខណ្ឌតម្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ[278]។

113. អ.ជ.ត.ក បញ្ជាក់បំភ្លឺថា នៅក្នុងករណីគោលបំណងរួម *ដែលជាប់ពាក់ព័ន្ធនឹង*ការប្រព្រឹត្តឧក្រិដ្ឋកម្ម មួយ ឬ ច្រើន ពុំចាំបាច់ថា អ្នកដែលយល់ស្របជាមួយគោលបំណងរួមជាក់ស្តែងត្រូវតែ *"មាន ចេតនា"* ចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ដរាបណាអ្នកទាំងនោះទទួលស្គាល់ថា ឧក្រិដ្ឋកម្ម នឹងត្រូវប្រព្រឹត្តឡើងដើម្បីសម្រេចគោលបំណងចុងក្រោយ[279]។ អ.ជ.ត.ក បន្ថែមថា ករណីនេះ

---

*"ប្រភេទដំបូងបែបនេះ គឺតំណាងដោយសំណុំរឿងនានា ដែលសហជនជាប់ចោទ ដោយធ្វើសកម្មភាពតាមការរៀបចំផែនការរួម មានចេតនាឧក្រិដ្ឋដូចគ្នា ឧទាហរណ៍ ក្នុងការបង្កើតផែនការក្នុងចំណោមសហចារី ដើម្បីសម្លាប់ ដែលដើម្បីសម្រេចផែនការរួម នេះ (ហើយទោះបីជា សហចារីម្នាក់ៗ មានតួនាទីផ្សេងៗគ្នាក៏ដោយ) ពួកគេទាំងអស់នៅតែមានចេតនាសម្លាប់។ លក្ខខណ្ឌ សត្យានុម័ត និងអត្តនោម័តជាមុន សម្រាប់សន្មតការទទួលខុសត្រូវព្រហ្មទណ្ឌ សម្រាប់អ្នកចូលរួមដែលមិនបាន ឬមិនអាច បង្ហាញថា ធ្វើឱ្យការសម្លាប់បានសម្រេច មានដូចតទៅ: (i) ជនជាប់ចោទត្រូវតែចូលរួមដោយស្ម័គ្រចិត្តនៅក្នុងផ្នែកណាមួយនៃ ការរៀបចំផែនការរួម (ឧទាហរណ៍ ដោយបណ្តាលឱ្យមានអំពើហិង្សាតែមិនបានធ្វើឱ្យជនរងគ្រោះស្លាប់ ឬដោយផ្តល់ជំនួយ ជាសម្ភារៈដល់ ឬជួយដល់សកម្មភាពរបស់សហចារី) និង (ii) ជនជាប់ចោទ ទោះបីពុំបានធ្វើឱ្យសម្រេចការសម្លាប់ដោយផ្ទាល់ ខ្លួនក្តី ត្រូវតែមានចេតនាចង់ទទួលបានលទ្ធផលបែបនេះ"* និងកថាខណ្ឌ២២៨។ *រដ្ឋអាជ្ញា តទល់នឹង Ntakirutimana* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-96-10-A និង ICTR-96-17-A) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៤៦៣៖ *"ប្រភេទដំបូង គឺជាទម្រង់ 'មូលដ្ឋាន' នៃសហឧក្រិដ្ឋកម្មរួម។ ទម្រង់នេះត្រូវបានតំណាងដោយករណីដែលសហចារី ទាំងអស់ ដោយធ្វើសកម្មភាពតាមគោលបំណងរួម មានចេតនាឧក្រិដ្ឋដូចគ្នា"*។ សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រម សំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៤។ *រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលដីកា អង្គជំនុំជម្រះ សាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-32-A) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ១០១។

[277] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៤។ សំណុំ រឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥០៩។

[278] សំណុំរឿង ០០២-ឯកសារ **E100/6** *សេចក្តីសម្រេចលើភាពអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ១៦។ សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៤។ *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកដទៃ* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-98-30/1-A) ចុះ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ១០៩-១១០។ *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-97-25-A) ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ១១១-១១២។

[279] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៨០៨។

អាចរួមបញ្ចូលឧក្រិដ្ឋកម្មដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយក្នុងការសម្រេចគោលបំណងរួមណាមួយ បើទោះជាការប្រព្រឹត្តពុំមានលក្ខណៈច្បាស់លាស់ជាក់លាក់ក៏ដោយ[280]។ អ.ជ.ត.ក បានពន្យល់ថា ប្រសិនបើគោលដៅនៃគោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តឧក្រិដ្ឋកម្ម និងមានការព្រមព្រៀងគ្នាបន្តសម្រេចគោលដៅនេះដោយពុំគិតពីបញ្ហាពាក់ព័ន្ធនោះ ទើបកំណត់ថា ឧក្រិដ្ឋកម្មនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ព្រោះបើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏បទឧក្រិដ្ឋនេះត្រូវបានគ្រោងទុកដោយគោលបំណងរួម[281]។ ខ្ញុំបកស្រាយការសម្រេចរបស់ អ.ជ.ត.ក ដោយផ្អែកលើការប្រើប្រាស់ពាក្យថា *"មានចេតនា"* ថាជាការបញ្ជាក់បំភ្លឺថា ការប្រព្រឹត្តឧក្រិដ្ឋកម្មពុំចាំបាច់ជាគោលដៅចំបងនៃសមាជិកសហឧក្រិដ្ឋកម្មរួមនោះឡើយ។ ទោះបីជាយ៉ាងនេះក្តី នៅចាំបាច់បង្ហាញចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដោយសមាជិកសហឧក្រិដ្ឋកម្មរួម ដែលជាលក្ខខណ្ឌមូលដ្ឋានមួយនៃសហឧក្រិដ្ឋកម្មរួមប្រភេទនេះ។

114. *ចារីផ្ទាល់* - សមាជិកសហឧក្រិដ្ឋកម្មរួមអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយចារីផ្ទាល់ ដែលពុំមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមបាន ដរាបណាឧក្រិដ្ឋកម្មទាំងនោះគឺជាផ្នែកមួយនៃគោលបំណងរួម និងប្រព្រឹត្តដើម្បីសម្រេចគោលបំណងរួមនោះ[282]។ ដើម្បីឱ្យសមាជិកនៃសហឧក្រិដ្ឋកម្មណាមួយទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយអ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម គេត្រូវបង្ហាញថា យ៉ាងហោចណាស់ ឧក្រិដ្ឋកម្មនោះជាការទទួលខុសត្រូវរបស់សមាជិកណាមួយនៅក្នុងសហឧក្រិដ្ឋកម្មរួម ហើយសមាជិកនេះ នៅពេលប្រើប្រាស់ចារីផ្ទាល់ដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម បានធ្វើសកម្មភាពដើម្បីសម្រេចគោលបំណងរួម[283]។ អត្ថិភាពនៃចំណងទាក់ទងគឺជាបញ្ហាដែលត្រូវយកទៅវាយតម្លៃទៅតាមករណីនីមួយៗ[284]។

---

[280] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៨០៨។

[281] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៨០៨។

[282] *រដ្ឋអាជ្ញា តទល់នឹង* *Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ៤១០-៤១៣។ *រដ្ឋអាជ្ញា តទល់នឹង* *Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២២៥។

[283] សំណុំរឿង ០០១-ឯកសារ **E313** *សាលក្រមសំណុំរឿង ០០២/០១* ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ៦៩៣។ *រដ្ឋអាជ្ញា តទល់នឹង* *Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ៤១៣។

[284] *រដ្ឋអាជ្ញា តទល់នឹង* *Brđanin* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ៤១៣, ៤១៨។ *រដ្ឋអាជ្ញា តទល់នឹង* *Krajišnik* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY

### ៣.៣.២. ទម្រង់នៃការទទួលខុសត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មជាតិ

115. ស.ច.ស នៅក្នុងសំណុំរឿង ០០២ បានសម្រេចថា ការប្រព្រឹត្តតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់អនុវត្តតែចំពោះឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ[285]។ អ.ប.ជ ពុំបានសម្រេចជាក់លាក់លើភាពអាចអនុវត្តបាននៃការទទួលខុសត្រូវរបស់ថ្នាក់លើនោះឡើយ ហើយនឹងការញុះញង់ចំពោះឧក្រិដ្ឋកម្មជាតិ ប៉ុន្តែបានច្រានចោលទឡ្ហីករណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងថា សហឧក្រិដ្ឋកម្មរួមអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ។ នៅក្នុងការយល់ឃើញរបស់ អ.ប.ជ ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម រួមបញ្ចូលស្ថានភាពដែលជនត្រូវចោទអាច *"នឹងមានលក្ខណៈដាច់ឆ្ងាយចេញពីការរួមប្រព្រឹត្តជាក់ស្តែងនៃអំពើពិរុទ្ធនៃបទឧក្រិដ្ឋ ជាជាងស្ថានភាពទាំងឡាយដែលត្រូវបានដឹងមុនតាមរយៈការចូលរួមផ្ទាល់ ដែលត្រូវបានកំណត់លក្ខខណ្ឌ យោងតាមច្បាប់ក្នុងស្រុក"*[286]។ អ.ប.ជ ក៏បានបង្ហាញការយល់ឃើញផងដែរថា ទម្រង់នៃការប្រព្រឹត្តរួមនៅក្នុងច្បាប់ជាតិ មានចែងនៅក្នុងមាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺជាទម្រង់នៃការប្រព្រឹត្ត ដូចសហឧក្រិដ្ឋកម្មរួម ដែលស្ថិតនៅក្រោមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[287]។

---

(IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២២៥-២២៦។ កថាខណ្ឌ២ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Krajišnik* ថ្លែងថា: *"កត្តានានាដែលចង្អុលបង្ហាញទំនាក់ទំនងបែបនេះ រួមបញ្ចូលទាំងភស្តុតាងដែលថា សមាជិកនៃសហឧក្រិដ្ឋកម្មបានស្នើដោយជាក់ច្បាស់ ឬមិនជាក់ច្បាស់ ដល់សមាជិកមិននៅក្នុងសហឧក្រិដ្ឋកម្ម ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ឬដោយញុះញង់ ឬបញ្ជា ជំរុញ ឬពុំនោះសោតទេ ឱ្យបុគ្គលដែលជាសមាជិកមិននៅក្នុងសហឧក្រិដ្ឋកម្ម ប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។"* កថាខណ្ឌ៤០ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Brđanin* ថ្លែងថា: *"ក្នុងករណីនានាដែលចារីជាមេក្លោងនៃឧក្រិដ្ឋកម្មជាក់លាក់ណាមួយ មិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម លក្ខខណ្ឌសំខាន់មួយនេះ អាចនឹងត្រូវបានសន្និដ្ឋានពីកាលៈទេសៈផ្សេងៗ រួមបញ្ចូលទាំងអង្គហេតុដែលថា ជនជាប់ចោទ ឬសមាជិកដទៃផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួម បានសហការជិតស្និទ្ធជាមួយចារីជាមេក្លោង ដើម្បីជំរុញគោលបំណងឧក្រិដ្ឋរួម។"*

[285] សំណុំរឿង ០០២-ឯកសារ **D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៣០៧។ សំណុំរឿង ០០២-ឯកសារ **D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដោយ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ២៩៦។ *សូមមើលផងដែរ* សំណុំរឿង ០០២-ឯកសារ **D97/13** *ដីកាសម្រេចស្តីពីការអនុវត្តនៅ អ.វ.ត.ក នៅទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថាសហឧក្រិដ្ឋកម្មរួម (JCE)* ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ២២។

[286] សំណុំរឿង ០០២-ឯកសារ **D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ១០១។

[287] មាត្រា៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងជាភាសាបារាំងថា: "*Toute personne participant volontairement, soit directement, soit indirectement, à la perpétration d'un crime ou d'un délit, est passible des peines applicables à l'auteur principal. La participation directe constitue la coaction, la participation indirecte constitue la*

116. ដូច្នេះ ស្របជាមួយដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ សំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ អនុវត្តចំពោះការសម្រេចរបស់ អ.ប.ជ លើទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ជាតិ ហើយដោយពិចារណាលើវិធីសាស្ត្ររបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០២ ទម្រង់នៃការទទួលខុសត្រូវលើការប្រព្រឹត្ត (ដូចជា សហចារី) ការរៀបចំផែនការ និងការបញ្ជានឹងត្រូវយកមកពិចារណាចំពោះការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

## ៤. ការពិចារណាលើភស្តុតាង

### ៤.១. កំណត់ហេតុស្តាប់ចម្លើយនានាក្រៅពីកំណត់ហេតុនៃការស្តាប់ចម្លើយដែលធ្វើឡើងដោយ ក.ស.ច.ស

117. ភស្តុតាងភាគច្រើនដែលសំអាងនៅក្នុងសំណុំរឿង ០០៤ រួមមានកំណត់ហេតុនៃការស្តាប់ចម្លើយដែលបានធ្វើឡើងដោយ ក.ស.ច.ស នៅក្នុងអំឡុងពេលស៊ើបអង្កេត ដែលត្រូវបានរៀបចំក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងស្ថិតនៅក្រោមការធានាផ្នែកនីតិវិធី និងផ្លូវច្បាប់ជាក់លាក់ ហេតុដូច្នេះ ភស្តុតាងទាំងនេះទទួលបានសច្ចធារណ៍នៃភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធ[288]។ ខ្ញុំយល់ឃើញថា ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះពីរឿងក្តីផ្សេងទៀតនៅ អ.វ.ត.ក និងដែលបានដាក់នៅក្នុងសំណុំរឿង ០០៤ ដោយសារភាពពាក់ព័ន្ធនឹងការចោទប្រកាន់ ទទួលបានសច្ចធារណ៍នេះដូចគ្នា។

118. កំណត់ហេតុស្តាប់ចម្លើយ និងភស្តុតាងផ្សេងទៀតដែលប្រមូលបានដោយការត្រួតពិនិត្យតាមផ្លូវតុលាការពីស្ថាប័ននានាក្រៅពី អ.វ.ត.ក រួមទាំង មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងដោយគ្មានការធានាតាមផ្លូវតុលាការ និងដោយពុំគោរពតាមទម្រង់ ដែលកំណត់បែបបែទនៃ

---

*complicité.”*។ សំណុំរឿង ០០២-ឯកសារ **D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ១០២។

[288] សំណុំរឿង ០០២-ឯកសារ **E96/7** *សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ២៦-២៧, ២៩។ សំណុំរឿង ០០២-ឯកសារ **E162** *ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9. E131/6, E136 និង E158* ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ៣។ សំណុំរឿង ០០២-ឯកសារ **E185** *សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១* ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ២០។

កំណត់ហេតុនៃការស្តាប់ចម្លើយ ហេតុដូច្នេះ ពុំទទួលសច្ចធារណ៍បែបនោះឡើយ[289]។ ទោះជាយ៉ាងនេះក៏ដោយ វាមិនរាប់បញ្ចូលឯកសារដែលនៅសេសសល់ពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ ដែល អ.ជ.ស.ដ បានសម្រេចថាទទួលបានសច្ចធារណ៍ដែលអាចជំទាស់តវ៉ាបាននៃភាពពាក់ព័ន្ធ និងភាពអាចទុកចិត្តបាន *បឋម*[290]។

119. ការស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញានៅក្នុងអំឡុងពេលស៊ើបសួរបឋម ទោះបីជាបានរៀបចំឡើងជាក់លាក់សម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ពុំត្រូវបានធ្វើឡើងក្រោមសម្បថ ហើយត្រូវបានរៀបចំឡើងដោយភាគីដែលមានផលប្រយោជន៍ជាក់លាក់នៅក្នុងលទ្ធផលនៃរឿងក្តីនេះ។ ក៏ប៉ុន្តែ ចម្លើយបែបនេះត្រូវបានប្រមូលសម្រាប់គោលបំណងនៃការជំនុំជម្រះក្តីលើសំណុំរឿងព្រហ្មទណ្ឌ ហេតុដូច្នេះ ជាគោលការណ៍ បានទទួលតម្លៃភស្តុតាងខ្ពស់ជាងភស្តុតាងដែលពុំបានប្រមូលជាក់លាក់សម្រាប់គោលបំណងនេះ (រួមទាំងកំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ)[291]។

120. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពុំទទួលបានសច្ចធារណ៍នៃភាពអាចទុកចិត្តបាន ហើយប្រសិនបើអាចនោះ បានទទួលតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ នៅពេលកាលៈទេសៈក្នុងពេលរៀបចំឡើងពុំបានដឹង[292]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះដែលបានផ្តល់ការសន្និដ្ឋានទូទៅ ហើយតំណាង “” ប្រសិនបើប្រៀបធៀបជាមួយនឹងបទពិសោធន៍បុគ្គល ត្រូវបានចាត់ទុកថាមិនគ្រប់គ្រាន់សម្រាប់បង្ហាញអង្គហេតុពាក់ព័ន្ធនោះឡើយ[293]។ ចម្លើយដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្រៅក្របខ័ណ្ឌតុលាការ ក្រៅពី

---

[289] សំណុំរឿង ០០២-ឯកសារ **E96/7** *សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ២៩។

[290] សំណុំរឿង ០០២-ឯកសារ **E185** *សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១* ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ២៨។ សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៣៧៣។

[291] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ២៩៦។

[292] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ២៩៦។

[293] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៤៥៧។

កំណត់ហេតុដែលបានធ្វើឡើងដោយ ក.ស.ច.ស បានទទួលតម្លៃភស្តុតាងទាប[294] ចំណែកសក្ខីកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការត្រូវបានវាយតម្លៃដោយប្រុងប្រយ័ត្ន[295]។

121. សរុបសេចក្តីមក និងនៅពេលថ្លឹងថ្លែងសេចក្តីពិចារណាទាំងនេះ កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលបានធ្វើឡើងដោយ ក.ស.ច.ស និងប្រតិចារឹកនៃការជំនុំជម្រះទទួលបានសច្ចធារណ៍នៃភាព អាចទុកចិត្តបានខ្ពស់ ហើយតម្លៃនៃភស្តុតាងក៏ទទួលបានខ្ពស់ជាងចម្លើយដែលរៀបចំឡើងដោយ ស្ថាប័នផ្សេងទៀត។ ចំពោះកំណត់ហេតុស្តាប់ចម្លើយដែលរៀបចំឡើដោយស្ថាប័នផ្សេង នៅពេល វាយតម្លៃ ត្រូវអនុវត្តវិធីសាស្ត្រវាយតម្លៃដោយប្រុងប្រយ័ត្ន ហើយព័ត៌មាននៅក្នុងនោះត្រូវបានយក មកសំអាងនៅពេលមានចំណុចស៊ីសង្វាក់គ្នាជាមួយនឹងប្រភពផ្សេងទៀតតែប៉ុណ្ណោះ។

## ៤.២. ភស្តុតាងចចាមអារ៉ាម និងការសំអាងលើភស្តុតាងដែលពុំស៊ីសង្វាក់គ្នា

122. អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង ភស្តុតាងទាំងអស់អាចទួលយកបាននៅក្នុងសំណុំរឿង នៅចំពោះមុខ អ.វ.ត.ក រួមទាំង ភស្តុតាងចចាមអារ៉ាមផងដែរ។ អ.ជ.ស.ដ និង អ.ជ.ត.ក ពិចារណាឃើញថា ភស្តុតាងចចាមអារ៉ាមអាចយកមកសំអាងបាន ក្នុងករណីមានភាពពាក់ព័ន្ធ និង តម្លៃគ្រប់គ្រាន់[296]។ តុលាការអន្តរជាតិផ្សេងទៀតក៏បានទទួលស្គាល់ផងដែរថា ចៅក្រម អាច សំអាងលើភស្តុតាងចចាមអារ៉ាមដោយប្រុងប្រយ័ត្ន ដោយត្រូវសម្រេចលើភាពអាចទុកចិត្តបាន និង តម្លៃភស្តុតាងទៅតាមករណីនីមួយៗ[297]។ នេះគឺជាវិធីសាស្ត្រដែលអនុវត្តនៅក្នុងដីកាដំណោះ ស្រាយនេះ។

---

[294] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៥៥០។

[295] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៣១៥។

[296] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៣។ *សូមមើលផងដែរ* សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៣០២។

[297] *រដ្ឋអាជ្ញា តទល់នឹង Ndindabahizi* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-01-71-A) ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ កថាខណ្ឌ១១៥។ *រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-2001-64-A) ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១១៥។ *រដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-96-3-A) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៤, ២០៧, ៣១១។ *រដ្ឋអាជ្ញា តទល់នឹង Karera* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-01-74-A) ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ៣៩, ១៧៨។ *រដ្ឋអាជ្ញា តទល់នឹង Kordić និង Cerkez* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៨១-២៨៤។ *រដ្ឋអាជ្ញា តទល់នឹង Gatete* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR00-61-A) ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២ កថាខណ្ឌ៩៩។ *រដ្ឋអាជ្ញា តទល់នឹង*

123. សក្ខីកម្មនៃសាក្សីតែម្នាក់អាចគ្រប់គ្រាន់សម្រាប់ការបង្ហាញអង្គហេតុដែលមានភាពអាចទុកចិត្តបាន និងតម្លៃភស្តុតាងគ្រប់គ្រាន់ (ទោះបី ដូចបានកត់សម្គាល់ខាងលើ វិធីសាស្ត្រនេះត្រូវអនុវត្តចំពោះតែកំណត់ហេតុនៃការស្តាប់ចម្លើយធ្វើឡើងដោយ ក.ស.ច.ស និងប្រតិចារឹកនៃការជំនុំជម្រះក្តីនៅ អ.វ.ត.ក តែប៉ុណ្ណោះ)[298]។ ជាគោលការណ៍ ភស្តុតាងចចាមអារ៉ាមដែលពុំស៊ីសង្វាក់គ្នាក៏អាចយកមកជាសំអាងផងដែរ[299]។ ទោះបីជាយ៉ាងនេះក្តី កត្តានានា ដូចជា ប្រភពនៃភស្តុតាងបែបនោះ កាលៈទេសៈដែលសាក្សីបានដឹង ភាពស៊ីសង្វាក់គ្នាជាមួយភស្តុតាងជាមួយនឹងភស្តុតាងពាក់ព័ន្ធនៅក្នុងសំណុំរឿង និងកាលៈទេសៈពាក់ព័ន្ធទាំងអស់ផ្សេងទៀត ចាំបាច់ត្រូវវាយតម្លៃដោយប្រុងប្រយ័ត្ននៅក្នុងករណីដែលមានភស្តុតាងចចាមអារ៉ាមពុំស៊ីសង្វាក់គ្នា ជាពិសេស នៅពេលភស្តុតាងទាំងនោះពាក់ព័ន្ធនឹងធាតុផ្សំជាក់លាក់នៃបទឧក្រិដ្ឋ ឬ ការប្រព្រឹត្តរបស់ជនត្រូវចោទ។

124. ឯកសារដែលនៅសេសសល់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពដោយផ្ទាល់ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខុសពីកំណត់ហេតុស្តាប់ចម្លើយដែលបានប្រមូលក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ត្រូវបានកត់ត្រានៅក្នុងហេតុការណ៍ ឬ នៅកៀកនឹងពេលវេលានៃហេតុការណ៍ដូចបានបង្ហាញនៅក្នុងនោះ ហើយវាជាភស្តុតាងផ្ទាល់ ឯកសារដែលនៅសេសសល់ទាំងនេះពុំមានវិការៈពាក់ព័ន្ធនឹងការចងចាំពាក់ព័ន្ធនឹងចម្លើយរបស់សាក្សី ហើយពុំត្រូវបានរៀបចំឡើងដោយភាគីណាមួយដែលមានប្រយោជន៍នៅក្នុងលទ្ធផលនៃរឿងក្តីនេះ នៅពេលបង្កើតឯកសារទាំងអស់នេះឡើង។ ដូចបានកត់សម្គាល់ខាងលើ ឯកសារទាំងនេះក៏ទទួលបានសច្ចធារណ៍ដែលអាចជំទាស់តវ៉ាបាននៃភាពពាក់ព័ន្ធ នឹងភាពអាចទុកចិត្តបានផងដែរ។ អាស្រ័យហេតុនេះ ទោះបីជាតម្រូវឱ្យអនុវត្តវិធីសាស្ត្រប្រកបដោយការប្រុងប្រយ័ត្នក៏ដោយ ភស្តុតាងពុំស៊ីសង្វាក់គ្នាប្រភេទនេះត្រូវបានយកមកសំអាងនៅក្នុងករណីសមស្រប។

## ៤.៣. ភស្តុតាងដែលប្រមូលបានក្រោមទារុណកម្ម

125. អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាស្តីពីការប្រឆាំងនឹងទារុណកម្ម មានការហាមឃាត់ដាច់ខាតចំពោះការប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងចម្លើយទទួលបានក្រោមទារុណកម្ម យកមកធ្វើជាភ័

---

*Đorđević* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTY (IT-05-87/1-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ៣៩៧។

[298] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៥៣។

[299] សំណុំរឿង ០០២-ឯកសារ **F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៣០២។ *រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការ ICTR (ICTR-2001-64-A) ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១៣៣។

ស្តុតាង[300] ហើយនឹងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយទាំងនេះយកមកសួរដេញដោលសាក្សី[301] លើកលែងតែយកមកប្រើប្រាស់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទដែលជាអ្នកធ្វើទារុណកម្ម ដើម្បីទាញយកជាភស្តុតាងបង្ហាញថា ចម្លើយនោះត្រូវបានធ្វើឡើងក្រោមទារុណកម្ម។

126. ចម្លើយសារភាពរបស់អ្នកទោសដែលជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានសន្មតថាបានធ្វើឡើងក្រោមទារុណកម្ម។ ករណីនេះជាសច្ចធារណ៍ដែលអាចជំទាស់តវ៉ាបាន[302]។

127. ព័ត៌មាននៅក្នុង "ប្រវត្តិរូបអ្នកជាប់ឃុំ" នៅ ស-២១[303] ក្រៅពីឈ្មោះអ្នកទោស ភេទ និងថ្ងៃខែឆ្នាំចាប់ខ្លួន ថ្ងៃខែឆ្នាំចូល ស-២១ ឬថ្ងៃខែឆ្នាំសម្លាប់ចោល ស្ថិតក្រោមលក្ខខណ្ឌនៃការហាមឃាត់នេះ[304]។ ទោះបីជាយ៉ាងនេះក្តី ព័ត៌មាននៅក្នុងចម្លើយសារភាពនៅ ស-២១ ដែលទទួលបានដោយផ្ទាល់ពីបុគ្គលនានា ក្រៅពីជនរងគ្រោះនៃអំពើទារុណកម្ម ឧទាហរណ៍ ចំណាររបស់អ្នកធ្វើ

---

[300] សំណុំរឿង 00២-ឯកសារ **D130/9/21** *សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម* ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២00៩ កថាខណ្ឌ៣0។ សំណុំរឿង 00១-ឯកសារ **E1/27.1** ប្រតិចារឹកនៃដំណើរការនីតិវិធីជំនុំជម្រះក្តីករណី ឌុច ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២00៩ ERN 00337065 បន្ទាត់១១ ដល់ ERN 00337066 បន្ទាត់ ៧។ សំណុំរឿង 00១-ឯកសារ **E176** *សេចក្តីសម្រេចលើសំណើរបស់ភាគីនានា សុំដាក់សម្ភារមួយចំនួនទៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២)* ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២00៩ កថាខណ្ឌ៨។ សំណុំរឿង 00២-ឯកសារ **E1/129.1** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង 00២ [មាស វឿន] ថ្ងៃទី៣ ខែតុលា ឆ្នាំ២0១២ ERN 00851054 បន្ទាត់២0 ដល់ ERN 00851055 បន្ទាត់២។

[301] សំណុំរឿង 00២-ឯកសារ **F26/12** *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២0១៥ កថាខណ្ឌ៤៧។ សំណុំរឿង 00២-ឯកសារ **E1/129.1** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង 00២ [មាស វឿន] ថ្ងៃទី៣ ខែតុលា ឆ្នាំ២0១២ ERN 00851054 បន្ទាត់២0 ដល់ ERN 00851055 បន្ទាត់២។

[302] សំណុំរឿង 00២-ឯកសារ **F26/12** *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២0១៥ កថាខណ្ឌ៥៧-៥៨។

[303] ជាធម្មតា ឯកសារមួយសន្លឹក បង្ហាញពីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរ ស-២១ ឈ្មោះហៅក្រៅ ថ្ងៃខែឆ្នាំកំណើត ភេទ សញ្ជាតិ តួនាទី និងមន្ទីរនៅក្នុង *"បដិវត្តន៍"* ទីកន្លែងកំណើត ចំនួនកូន និងថ្ងៃខែនិងទីកន្លែងចាប់ខ្លួន។

[304] ឯកសារ **D372/1/7** *សេចក្តីសម្រេចលើពាក្យសុំរបស់ យឹម ទិត្យ ស្នើឱ្យធ្វើមោឃភាពភស្តុតាងនានាដែលទទួលបានពីការធ្វើទារុណកម្ម* ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២0១៨ កថាខណ្ឌ២0-២១។ សំណុំរឿង 00៣-ឯកសារ **D257/1/8** *[កោសលុប] សេចក្តីសម្រេចលើពាក្យសុំរបស់ [កោសលុប] សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម* ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២0១៨ កថាខណ្ឌ២៦។

ទារុណកម្ម ពុំស្ថិតក្រោមលក្ខខណ្ឌនៃការហាមឃាត់នោះទេ[305]។ មាត្រា ១៥ ពុំបានហាមឃាត់ការប្រើប្រាស់ព័ត៌មានដែលបានរកឃើញនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងក្រោមទារុណកម្មនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរសាក្សី និងអាចសម្ភាសពួកគេនោះឡើយ[306]។ អាស្រ័យហេតុនេះ ពុំមានការហាមឃាត់ប្រឆាំងនឹងការប្រើប្រាស់ភ័ស្តុតាងរបស់សាក្សី

---

[305] ឯកសារ **D372/1/7** *សេចក្តីសម្រេចលើពាក្យសុំរបស់ យឹម ទិត្យ ស្នើឱ្យធ្វើមោឃភាពភ័ស្តុតាងនានាដែលទទួលបានពីការធ្វើទារុណកម្ម* ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ២១។ សំណុំរឿង ០០៣-ឯកសារ **D257/1/8** *[កោសលុប] សេចក្តីសម្រេចលើពាក្យសុំរបស់ [កោសលុប] សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម* ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ កថាខណ្ឌ២៦។ សំណុំរឿង ០០២-ឯកសារ **F26/12** *សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ* ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ៦៦-៦៨។

[306] សនិទានភាពនយោបាយមួយដែលជាមូលដ្ឋាននៃមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មគឺការដកចេញនូវការលើកទឹកចិត្តណាមួយពីរដ្ឋទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម។ ដើម្បីជៀសវាងការរារាំងដល់សនិទានភាពនយោបាយនេះ នៅក្នុងការថ្លែងពីភាពស្របច្បាប់នៃការប្រើប្រាស់ភ័ស្តុតាង តាមរយៈព័ត៌មានដែលទទួលបានដោយការធ្វើទារុណកម្ម វាចាំបាច់ត្រូវធ្វើការបង្ហាញពីភាពខុសគ្នានៃសេណារីយ៉ូពីរដូចតទៅ។ ជាដំបូង ស្ថានភាពដែលព័ត៌មាននៃការធ្វើទារុណកម្មត្រូវបានប្រើដោយអាជ្ញាធរដែលធ្វើទារុណកម្ម ដើម្បីស្វែងរកសាក្សី ជនសង្ស័យ ជនគេចខ្លួន ឬពុំនោះសោតទេ ជម្រុញការស៊ើបអង្កេតដែលកំពុងបន្ត និងទីពីរ ស្ថានភាពដែលស្ថាប័នតុលាការធ្វើការស៊ើបអង្កេតអ្នកធ្វើទារុណកម្ម ព្យាយាមប្រើប្រាស់ព័ត៌មានដែលបានមកពីអ្នកធ្វើទារុណកម្មនោះ ដើម្បីកំណត់ប្រភពនៃភ័ស្តុតាងដែលអាចមាន យកមកប្រើប្រឆាំងនឹងពួកគេ។ ការអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម ជាតម្រុយនៃការស៊ើបអង្កេតនៅក្នុងសេណារីយ៉ូទី១ អាចនាំឱ្យមានការលើកទឹកចិត្តដល់ការប្រើប្រាស់ការធ្វើទារុណកម្ម។ ដូច្នេះហើយ ជាឧទាហរណ៍ ក្នុងករណីភ្នាក់ងារសម្ងាត់ទទួលបានសេចក្តីថ្លែងការណ៍តាមរយៈការធ្វើទារុណកម្ម ហើយបន្ទាប់មក ប្រើឈ្មោះនានាដែលមានផ្តល់នៅក្នុងសេចក្តីថ្លែងការណ៍នោះ ដើម្បីស្វែងរកទីតាំងគំនរឯកសារ ឬបុគ្គលដែលមានព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត ឯកសារទាំងនោះ ឬសក្ខីកម្មរបស់បុគ្គលនោះ គួរតែត្រូវបានទទួលយកជាភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយ។ ទោះជាយ៉ាងនេះក្តី នៅក្នុងសេណារីយ៉ូទី២ ស្ថាប័នតុលាការ មិនមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងអាជ្ញាធរដែលធ្វើទារុណកម្មនោះទេ ហើយនឹងប្រើប្រាស់រាល់តម្រុយដែលមានដើម្បីស្វែងរកភ័ស្តុតាង *ប្រឆាំងនឹង* អ្នកធ្វើទារុណកម្ម។ ខ្ញុំយល់ឃើញថា ភ័ស្តុតាងរបស់សាក្សីដែលត្រូវបានរកឃើញ តាមរយៈសេចក្តីថ្លែងការណ៍ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម អាចនឹងយកមកប្រើបានតែក្នុងសេណារីយ៉ូទី២ប៉ុណ្ណោះ។ អង្គបុរេជំនុំជម្រះក៏បានធ្វើការបញ្ជាក់ថា ការប្រើប្រាស់ព័ត៌មានពីសម្ភារៈដែលបានមកពីការធ្វើទារុណកម្ម ជាតម្រុយនៃការស៊ើបអង្កេត មិនមានន័យស្មើនឹងការប្រើប្រាស់ព័ត៌មានជា "ភ័ស្តុតាង" នោះទេ។ (ឯកសារ **D372/1/7** *សេចក្តីសម្រេចលើពាក្យសុំរបស់ យឹម ទិត្យ ស្នើឱ្យធ្វើមោឃភាពភ័ស្តុតាងនានាដែលទទួលបានពីការធ្វើទារុណកម្ម* ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ២៣-២៥។ សំណុំរឿង ០០៣-ឯកសារ **D257/1/8** *[កោសលុប] សេចក្តីសម្រេចលើពាក្យសុំរបស់ [កោសលុប] សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម* ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ កថាខណ្ឌ២៨។ សំណុំរឿង ០០៣-ឯកសារ **D253/1/8** [កោសលុប] *សេចក្តីសម្រេចលើសំណើរបស់* [កោសលុប] *សុំធ្វើមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171* ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ កថាខណ្ឌ៣០, ៣២)។

ដែលមានឈ្មោះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលបានទទួលក្រោមទារុណកម្ម ដូចជា ចម្លើយសារភាព និងក្រោយមកសម្គាល់ដោយ ក.ស.ច.ស នោះទេ[307]។

128. នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ក.ស.ច.ស បានបង្កើតតារាងរចនាសម្ព័ន្ធនៃអង្គការចាត់តាំងរដ្ឋបាល ក្នុងតំបន់ ៥ នៅភូមិភាគពាយ័ព្យ រួមទាំង ស្រុកព្រះនេត្រព្រះ ក្នុងគោលបំណងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង។ ឈ្មោះបុគ្គលមួយចំនួននៅក្នុងតារាងអង្គការចាត់តាំងនេះត្រូវបានដកស្រង់ចេញមកពីចម្លើយសារភាពនៅ ស-២១។ នៅក្នុងករណីមួយចំនួនតូច តារាងអង្គការចាត់តាំងនេះត្រូវបានប្រើប្រាស់ហួសពីក្របខ័ណ្ឌគោលបំណងផ្ទៃក្នុង ហើយត្រូវបានយកមកសួរដេញដោលសាក្សី ហើយសុំឱ្យសាក្សីផ្តល់យោបល់លើតារាងអង្គការចាត់តាំងនេះ[308]។ នៅពេលពិចារណាលើសច្ចធារណ៍នៃអំពើទារុណកម្ម ដែលជាប់មកជាមួយនឹងចម្លើយសារភាពនេះ និងការហាមឃាត់ប្រឆាំងនឹងការប្រើប្រាស់ព័ត៌មាននៅក្នុងចម្លើយសារភាព ចំពោះការសាកសួរដេញដោលសាក្សី ចម្លើយរបស់សាក្សីដែលផ្អែកលើ ឬ ជាប់ទាក់ទងនឹងតារាងអង្គការចាត់តាំងនេះត្រូវបានច្រានចោល។ យោងតាមហេតុផលដូចគ្នានេះ *កំណត់ត្រារបស់អ្នកស៊ើបអង្កេត*ក្រោយសំណួរចម្លើយទី៣២ ព្រមទាំងសំណួរចម្លើយទី៣៣ នៅក្នុងឯកសារ D219/477 (ERN ជាភាសាអង់គ្លេស 01141203-01141204) ត្រូវបានច្រានចោលដូចគ្នា។

---

[307] [307] សំណុំរឿង ០០២-ឯកសារ **E350/8** *សេចក្តីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម* ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ៦៣, ៧០។

[308] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលប៉ះពាល់ដោយការអនុវត្តបែបនេះមាន: ឯកសារ **D119/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ សំណួរនិងចម្លើយ១៧ (ERN 00895161-00895162 ជាភាសាខ្មែរ)។ ឯកសារ **D119/33** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ សំណួរនិងចម្លើយ១៣ រហូតដល់សំណួរនិងចម្លើយ៣២ (ERN 00907525-00907530 ជាភាសាខ្មែរ)។ ឯកសារ **D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ សំណួរនិងចម្លើយ៩៥ (ERN 00980397-00980398 ជាភាសាខ្មែរ)។ ឯកសារ **D119/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ សំណួរនិងចម្លើយ៤០ (ERN 00982235-00982236 ជាភាសាខ្មែរ)។ ឯកសារ **D119/135** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម រៀម ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ កំណត់សម្គាល់របស់អ្នកស៊ើបអង្កេត បន្ទាប់ពីសំណួរនិងចម្លើយ៥៧ (ERN 01003836-01003837 ជាភាសាខ្មែរ)។ ឯកសារ **D119/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិត អៀត ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤ កំណត់សម្គាល់របស់អ្នកស៊ើបអង្កេត បន្ទាប់ពីសំណួរនិងចម្លើយ២៦ (ERN 01003857-01003858 ជាភាសាខ្មែរ)។ ឯកសារ **D219/477** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សាមុត ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ កំណត់សម្គាល់របស់អ្នកស៊ើបអង្កេត បន្ទាប់ពីសំណួរនិងចម្លើយ៤១ (ERN 01134151-01134152 ជាភាសាខ្មែរ)។

## ៤.៤. របាយការណ៍កំណត់ផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

129. ចំពោះគម្រោងកំណត់ផែនទី ដើម្បីបង្ហាញផ្នូររួមនៅទូទាំងប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបរាប់របាយការណ៍ជាច្រើន ដែលរួមមានព័ត៌មានអាចមានការពាក់ព័ន្ធនឹងការស៊ើបអង្កេតនៅក្នុងការចោទប្រកាន់ **យឹម ទិត្យ**។ សំណុំរឿងក៏រួមបញ្ចូលទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយបានបង្ហាញលទ្ធផលដែលទំនងជាលទ្ធផលនៃគម្រោងកំណត់ផែនទី និងអាចរួមមានព័ត៌មានពាក់ព័ន្ធ។ ក្នុងនោះ របាយការណ៍ និងទស្សនាវដ្ដីផ្ដល់ព័ត៌មានអំពីចំនួនផ្នូរជនរងគ្រោះពាក់ព័ន្ធនឹងទីតាំងដែលជាផ្នែកមួយនៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤[309]។

130. ការយល់ឃើញជារួមរបស់ខ្ញុំលើតម្លៃនៃភ័ស្តុតាងត្រូវបានបង្ហាញរួមគ្នាជាមួយសហសេវិកជាតិរបស់ខ្ញុំ នៅក្នុង*ដីកាដំណោះស្រាយ (សំអាងហេតុ)* នៃសំណុំរឿង ០០៤/១[310]។ ជាពិសេស របាយការណ៍កំណត់ផែនទី ដែលបានសំអាងលើការចុះពិនិត្យទីតាំង និងកិច្ចសម្ភាសន៍ជាមួយប្រភពនានា ពុំបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ពាក់ព័ន្ធនឹងប្រភពនៃការដឹងឮរបស់សាក្សីអំពីចំនួនជនរងគ្រោះ ដើម្បីផ្ដល់លទ្ធភាពសម្រាប់ការវាយតម្លៃឱ្យមានភាពទុកចិត្តបាន និងពាក់ព័ន្ធលើភ័ស្តុតាង។ កាលបរិច្ឆេទ និងមូលហេតុនៃមរណភាពរបស់ជនរងគ្រោះក៏ពុំបានដឹង ឬ ពុំបង្ហាញច្បាស់លាស់ ដូច្នេះវាពុំអាចជួយដល់ការកំណត់ថាតើមរណភាពទាំងនោះស្ថិតក្រោមយុត្តាធិការពេលវេលាពាក់ព័ន្ធដែរឬទេ។ ដូច្នេះ ខ្ញុំយល់ឃើញថា ចំនួនជនរងគ្រោះដែលមាននៅក្នុងរបាយការណ៍កំណត់ផែនទី ពុំអាចទុកចិត្តបាន ហើយខ្ញុំពុំបានសំអាងលើរបាយការណ៍ទាំងនេះទេ។ ការពិចារណាដូចគ្នានឹងអនុវត្តចំពោះរបាយការណ៍នៃទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅពេលពិចារណាលើចំនួនជនរងគ្រោះដែលពាក់ព័ន្ធនឹង **យឹម ទិត្យ** ខ្ញុំបានសំអាងលើសាក្សីដែលបានផ្ដល់ភ័ស្តុតាងដល់ ក

---

309 <u>របាយការណ៍ផែនទី៖</u> ឯកសារ **D1.3.10.14** របាយការណ៍ DC-Cam គម្រោងផែនទី៖ ខេត្ត តាកែវ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៨។ ឯកសារ **D6.1.472** របាយការណ៍ DC-Cam គម្រោងផែនទី៖ ខេត្ត តាកែវ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៥។ ឯកសារ **D1.3.27.7** របាយការណ៍ DC-Cam គម្រោងផែនទី៖ ខេត្ត បាត់ដំបង ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៧។ ឯកសារ **D1.3.10.15** របាយការណ៍ DC-Cam គម្រោងផែនទី៖ ខេត្ត បាត់ដំបង ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៨។ ឯកសារ **D6.1.1232** របាយការណ៍ DC-Cam គម្រោងផែនទី៖ ខេត្ត តាកែវ ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៩៧។ ឯកសារ **D1.3.10.10** របាយការណ៍ DC-Cam គម្រោងផែនទី៖ ខេត្ត បន្ទាយមានជ័យ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧។ ឯកសារ **D1.3.27.10** របាយការណ៍ DC-Cam គម្រោងផែនទី៖ ខេត្ត បន្ទាយមានជ័យ ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨។ <u>ទស្សនាវដ្ដី៖</u> ឯកសារ **D219/844.1.1** ឯកសារភ្ជាប់១៖ ការស្វែងរកការពិត លេខ៣១ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ (ថ្ងៃខែដាក់ឯកសារ) ERN 00081231-00081233។

310 *សូមមើល* ឯកសារ **D261** *ដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/០១* ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ១៣១-១៣៥។

.ស.ច.ស អំពីចំនួន និងមូលហេតុមរណភាព ហើយក្នុងករណីសមស្រប អំពីបញ្ជីឈ្មោះនៅ ស-២១ របស់ ក.ស.ច.ស[311]។

## ៤.៥. ចំនួនជនរងគ្រោះ

131. ផ្នែកនីមួយៗនៃសំអាងហេតុស្តីពីឧក្រិដ្ឋកម្មនៅក្នុងដីកាដំណោះស្រាយនេះរួមបញ្ចូល ក្នុងករណីពាក់ព័ន្ធ ការប៉ាន់ស្មានចំនួនជនរងគ្រោះដែលពាក់ព័ន្ធនឹងសេណារីយ៉ូ ឬ ទីតាំងឧក្រិដ្ឋកម្មនីមួយៗ។ ដូច្នេះ វាតម្រូវឲ្យមានការពន្យល់អំពីគោលការណ៍ និងវិធីសាស្ត្រដែលខ្ញុំបានប្រើប្រាស់នៅក្នុងរឿងក្តីនេះឈានដល់ការប៉ាន់ស្មានទាំងនេះ។

132. ពាក់ព័ន្ធនឹងសេណារីយ៉ូ ឬ ទីតាំងឧក្រិដ្ឋកម្មទាំងអស់ ខ្ញុំបានអនុវត្តដោយតឹងរ៉ឹងលើចំនួនអប្បបរមានៃជនរងគ្រោះ ដែលអាចត្រូវបានប៉ាន់ស្មានលើភ័ស្តុតាង ដោយអនុវត្តគោលការណ៍ដូចខាងក្រោម។ ទោះបីជាគោលការណ៍មួយចំនួនតម្រូវឲ្យមានវិធីសាស្ត្រតឹងរ៉ឹងចំពោះការវាយតម្លៃលើភ័ស្តុតាងជាងវិធីសាស្ត្រអនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏ខ្ញុំបានអនុវត្តវិធីសាស្ត្រមួយដើម្បីជៀសវាងហានិភ័យនៃការរាប់ចំនួនជនរងគ្រោះពីរដង។ ជាលទ្ធផល រឿងរ៉ាវរបស់សាក្សីដែលពិពណ៌នាជនរងគ្រោះ មិនត្រូវបានរាប់បញ្ចូលពីការរាប់ចំនួនសរុប ក្នុងករណីដែលមានហានិភ័យថា ជនរងគ្រោះដដែលត្រូវបានរៀបរាប់ពីរដង ឬ ការរាប់បញ្ចូលជនរងគ្រោះ ដែលមរណភាព ឬ ការរងគ្រោះរបស់ពួកគេមិនអាចកំណត់ដោយសមហេតុផលថាពាក់ព័ន្ធនឹងវិសាលភាពពេលវេលានៃការស៊ើបអង្កេតនេះ។ ការមិនរាប់បញ្ចូលដ៏តឹងរ៉ឹងទាំងនេះ មានបំណងធានាថា ការប៉ាន់ស្មានទាំងនេះស្ថិតនៅក្នុងចំនួនអប្បបរមា ប៉ុន្តែក៏មានន័យថា ចំនួនជនរងគ្រោះជាក់ស្តែងទំនងជាមានចំនួនខ្ពស់ជាងចំនួនជាក់ស្តែងនៅក្នុងដីកាដំណោះស្រាយ។

### ៤.៥.១. ការរាប់ចំនួនជនរងគ្រោះដោយផ្អែកលើភ័ស្តុតាងផ្តល់ជូនដោយសាក្សីម្នាក់

133. ក្នុងករណីសាក្សីម្នាក់ផ្តល់ចំនួនជនរងគ្រោះក្នុងរង្វង់តួលេខណាមួយ (ឧ. ចន្លោះពី១០០ ទៅ ២០០) ខ្ញុំបានយកចំនួនទាបជាងគេបំផុតនៅក្នុងចន្លោះតួលេខនោះ (១០០) ដោយមិនរាប់ចំនួនមធ្យមភាគនោះទេ។

134. នៅក្នុងករណីខ្លះ សាក្សីពិពណ៌នាហេតុការណ៍ដែលបានកើតឡើងដដែលៗ ដែលជាផ្នែកមួយនៃការអនុវត្តទៀងទាត់ ឬ ដែលជាផ្នែកមួយនៃដំណើរការ ប៉ុន្តែ ដោយមិនបានបញ្ជាក់ចំនួនជាក់លាក់នៃហេតុការណ៍កើតឡើងដែលពួកគេបានដឹង។ ប្រសិនបើភ័ស្តុតាងបង្ហាញច្បាស់ថា ហេតុការណ៍បាន

[311] *សូមមើល* កថាខណ្ឌ១៤៧។

កើតឡើងដោយទៀងទាត់ និង/ឬ ក្នុងរយៈពេលមួយយូរជាងនេះ ពោលគឺ ជាក់ស្តែង លើសពីចំនួនពីរដង ខ្ញុំបានសន្មតថា ហេតុការណ៍នោះបានកើតឡើងចំនួនប ០៣ដង។ បើមិនដូច្នោះទេ ការរាប់ដែលកំណត់នោះគឺ ត្រឹមតែពីរដងប៉ុណ្ណោះ។

135. ក្នុងករណីសាក្សីសំដៅលើចំនួនមនុស្សនៅក្នុងក្រុម "លើសពីពាក់កណ្តាល" ខ្ញុំបានរាប់ថាវាមានចំនួនពាក់កណ្តាលបូកមួយប៉ុណ្ណោះ។

136. ខ្ញុំបានគណនាចំនួនប្រហាក់ប្រហែលទៅតាមចំនួនដែលបានផ្តល់ឲ្យ ប្រសិនបើខ្ញុំជឿជាក់លើមូលដ្ឋាននៃការដឹងឮរបស់សាក្សី ដោយសារពុំមានវិធីជាក់លាក់ជាងនេះក្រៅពីការបន្ថយចំនួនប៉ាន់ស្មានយ៉ាងរឹតត្បិត។ ឧទាហរណ៍ ក្នុងករណីសាក្សីណាម្នាក់លើកឡើងថា *"ប្រហែល១០"* *"ទំនង ១០"* ឬ *"អាច ១០"* នាក់នោះ ដូច្នេះចំនួននោះត្រូវបានរាប់ត្រឹម ១០ ប៉ុណ្ណោះ។

137. ចំពោះការសំដៅមិនជាក់លាក់លើចំនួន *"រាប់រយ"* ត្រូវបានរាប់ត្រឹមចំនួន ២០០ ហើយការសំដៅលើចំនួន *"រាប់ពាន់"* ត្រូវបានរាប់ត្រឹមចំនួន ២០០០។

138. ក្នុងករណីជនរងគ្រោះត្រូវបានពិពណ៌នាថាបាន *"បាត់ខ្លួន"* ជនរងគ្រោះនោះត្រូវបានរាប់បញ្ចូលនៅក្នុងការគណនាចំនួនមរណភាព ប្រសិនបើភ័ស្តុតាងគាំទ្រការសន្និដ្ឋានថា បុគ្គលនោះត្រូវបានគេសម្លាប់ចោល (ឧ. ករណីបាត់ខ្លួនកើតឡើងនៅក្នុងបរិបទនៃប្រតិបត្តិការសម្លាប់រង្គាល និងក្នុងករណីដែលបុគ្គលនោះពុំដែលបានឃើញសាជាថ្មីនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ)។

**៤.៥.២. ការគណនាចំនួនជនរងគ្រោះដោយផ្អែកលើភ័ស្តុតាងពីសាក្សីច្រើននាក់**

139. ពាក់ព័ន្ធនឹងការគណនាចំនួនជនរងគ្រោះសរុបដោយផ្អែកលើភ័ស្តុតាងរួមគ្នារបស់សាក្សីច្រើននាក់វិញ មានតែការប៉ាន់ស្មានចំនួនអប្បបរមាពីសាក្សីនីមួយត្រូវបានរាប់បន្ថែម។

140. ក្នុងករណីដែលអាចថា សាក្សីបានពិពណ៌នាហេតុការណ៍ដូចគ្នា ខ្ញុំពុំបានបន្ថែមចំនួនរួមគ្នាដែលបានផ្តល់ដោយសាក្សីច្រើននាក់នោះទេ។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើភ័ស្តុតាងបញ្ជាក់ថា ក្រុមជនរងគ្រោះដែលត្រូវបានពិពណ៌នា ខុសគ្នារវាងសាក្សីនីមួយៗ នៅពេលនោះចំនួននឹងបានដាក់បញ្ចូលបន្ថែម។

141. ក្នុងករណីសាក្សីច្រើននាក់រៀបរាប់ហេតុការណ៍តែមួយផ្តល់ការរៀបរាប់ផ្ទុយគ្នាលើចំនួនជនរងគ្រោះ នៅពេលនោះចំនួនទាបជាងគេដែលបានផ្តល់ឲ្យនឹងត្រូវបានជ្រើសរើស លើកលែងតែតួលេខផ្តល់ឲ្យដោយសាក្សីម្នាក់ទៀតអាចទុកចិត្តបានជាង ដោយសារ ឧទាហរណ៍ ភាពអាចជឿជាក់បានចំណុចស៊ីសង្វាក់គ្នា ឬ មូលដ្ឋាននៃការដឹងឮអាចមានភាពរឹងមាំជាង។ ឧទាហរណ៍ ប្រសិនបើ

សាក្សីពីរនាក់លើកឡើងថា ពួកគេបានឃើញមនុស្ស ២០នាក់ ត្រូវបានគេសម្លាប់នៅក្នុងហេតុការណ៍មួយ ប៉ុន្តែ សាក្សីម្នាក់ទៀតបានត្រឹមតែឮថា មនុស្សត្រឹមតែ ១០ នាក់ ត្រូវបានសម្លាប់នៅក្នុងហេតុការណ៍នោះ (ភ័ស្តុតាងចចាមអារ៉ាម) នៅពេលនោះ ការគណនានឹងសំអាងលើមនុស្ស ២០ នាក់ ដែលជាចំនួនផ្តល់ឲ្យដោយសាក្សីឃើញហេតុការណ៍ផ្ទាល់ភ្នែក។

142. ផ្អែកលើការវាយតម្លៃរួមលើភ័ស្តុតាង ប្រសិនបើមិនអាចវាយតម្លៃជាក់លាក់បានទេថា មរណភាពរបស់ជនរងគ្រោះបានកើតឡើងនៅក្រៅក្របខ័ណ្ឌពេលវេលានៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤ នៅពេលនោះជនរងគ្រោះត្រូវបានដកចេញពីការគណនាទាំងនោះ។

### ៤.៥.៣. ការរាប់គ្រួសារ

143. សាក្សីខ្លះ ជាពិសេស អ្នកដែលបានផ្តល់ភ័ស្តុតាងអំពីការប្រព្រឹត្តលើខ្មែរក្រោម ពិពណ៌នាអំពីចំនួនជនរងគ្រោះ ដោយរាប់ជាចំនួនគ្រួសារ ពុំមែនរាប់បុគ្គលម្នាក់ៗ ឬ បូកចំនួនបុគ្គលម្នាក់ៗនោះឡើយ។ បើនិយាយឲ្យជាក់លាក់ទៅ ទោះបីជាចំនួនអប្បបរមានៃមនុស្សដែលត្រូវចាត់ទុកជាគ្រួសារអាចពិចារណាថាត្រូវមានចំនួនពីរនាក់ក៏ដោយ ក៏កត្តានានាដែលខ្ញុំពន្យល់ខាងក្រោម នៅពេលពិចារណារួមគ្នា បង្ហាញថា ការប៉ាន់ស្មានដ៏សមហេតុផល និងអប្បបរមាដ៏សមស្របមួយចំពោះគ្រួសារមួយគឺមានមនុស្សបួននាក់។

144. សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីស្ទើរតែទាំងអស់ដែលបានផ្តល់ភ័ស្តុតាងអំពីទំហំគ្រួសារខ្មែរក្រហោម បានបញ្ជាក់ថាមានចំនួនចន្លោះពីបួនទៅដប់នាក់នៅក្នុងមួយគ្រួសារ ដែលជាចំនួនមធ្យមដោយផ្អែកលើឧទាហរណ៍អំពីគ្រួសារខ្មែរក្រោមធំមួយ ឬ ដោយផ្អែកលើការផ្តល់ឧទាហរណ៍ជាក់លាក់អំពីទំហំគ្រួសារ។ មានតែសាក្សីម្នាក់ដែលលើកឡើងថា គ្រួសារខ្លះមានមនុស្សបីនាក់ ហើយគាត់ក៏ចង់មានន័យថា គ្រួសារស្ទើរតែទាំងអស់មានចំនួនច្រើនជាងនេះ[312]។ ដូច្នេះ ភ័ស្តុតាងបង្ហាញច្បាស់ថា គ្រួសារដែលមានកូនទោលនៅក្នុងប្រទេសកម្ពុជាមិន

---

[312] <u>ចំនួនសមាជិកគ្រួសារជាមធ្យម៖</u> ឯកសារ **D219/408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ជោត ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៥ ឆ.២៦ ERN 01117260។ ឯកសារ **D118/202** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ សារិន ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ឆ.១១ ERN 00979030។ ឯកសារ **D118/125** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខួង ចាប ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ឆ.៧៧-៨០ ERN 00955736 ឆ.៩២ ERN 00955737។ ឯកសារ **D118/175** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ឺន ដារ៉ា ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ ឆ.៥៨ ERN 00973951។ <u>ចំនួនសមាជិកគ្រួសារឯកជន:</u> ឯកសារ **D219/781** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ាន ប្រាក់ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឆ.២៥-២៦ ERN 01299998 ឆ.៦៩ ERN 01300003។ ឯកសារ **D6.1.758** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចាប ខួង ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៩ ERN 00385091។ ឯកសារ **D118/191** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋ

ច្រើននោះទេ។ សាក្សីភាគច្រើនមកពីគ្រួសារដែលមានកូន/បងប្អូនបង្កើតបួនប្រាំនាក់។ ដើម្បីប៉ាន់ស្មានថា គ្រប់គ្រួសារមានសមាជិកតែពីរនាក់គឺផ្ទុយនឹងភ័ស្តុតាងរបស់សាក្សីជាច្រើននាក់ដែលពិពណ៌នាថាគ្រួសារមានសមាជិកលើសពីពីរនាក់។

145. ចំណុចចុងក្រោយ ប្រសិនបើមានករណីថា គ្រួសារមួយចំនួនគឺជាជនរងគ្រោះ នៅពេលនោះវាអាចថា ពួកគេអាចមានទំហំគ្រួសារនៅក្រោមចំនួនមធ្យមការតែតិចទៅទៀត។ ក៏ប៉ុន្តែ ដោយសារគ្រួសារជាជនរងគ្រោះដូចសាក្សីបានពិពណ៌នាមានចំនួនច្រើន វាអាចជាក់ស្តែងថា គ្រួសារទាំងអស់អាចមានទំហំតូចខុសពីធម្មតា។

146. ការពិចារណាទាំងអស់នេះនាំឱ្យខ្ញុំសន្និដ្ឋានថា លើកលែងតែទំហំគ្រួសារត្រូវបានបញ្ជាក់ជាក់លាក់ពីសាក្សី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បើមិនដូច្នោះទេ ការប៉ាន់ស្មានសមហេតុផលទាបបំផុតសម្រាប់ទំហំគ្រួសារគឺមានចំនួន ០៤ នាក់។

## **៤.៦. បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស**

147. បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស[313] ("បញ្ជីឈ្មោះ ស-២១ របស់ ក.ស.ច.ស") ត្រូវបានសំអាងនៅក្នុងរឿងក្តីណេះ ដើម្បីបង្ហាញកាលបរិច្ឆេទនៃថ្ងៃចូល ស-២១ របស់បុគ្គលនានា ហើយ ក្នុងករណីមានការបញ្ជាក់ជាក់លាក់ កាលបរិច្ឆេទនៃការកាប់សម្លាប់បុគ្គលដែលជាប់ឃុំនៅ ស-២១ និងចំនួននៃអ្នកដែលបានបញ្ជូនទៅ និង/ឬ សម្លាប់ចោលក្រោយជាប់ឃុំនៅ ស-២១។ ការសំអាងបែបនោះគឺសមស្របដោយសារមានការវិភាគលម្អិតច្រើន ហើយមានការប្រើប្រាស់វិធីសាស្ត្ររឹងមាំ និងជាក់លាក់ដោយអ្នកវិភាគ ក.ស.ច.ស នៅពេលរៀបចំបញ្ជីឈ្មោះ ស-២១ របស់

---

ប្បវេណី ចាប ង៉ែត ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ឆ.២-១០ ERN 00977061-00977060។ ឯកសារ **D219/342** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សើន ធឿន ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ឆ.៣-៧ ERN 00102877។ ឯកសារ **D118/215** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជា អូន ហៅ ជា សារី ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤ ឆ.២-៣ ERN 00982158។ ឯកសារ **D118/226** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត រុធ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ច.២-ច.៥ ERN 00985414។ ឯកសារ **D118/214** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចឹង ភី ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៣ ឆ.២៧-២៨ ERN 00982149។ គ្រួសារដែលមានសមាជិកពីបីទៅប្រាំពីរនាក់៖ ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឆ.២៤ ERN 01171494។

[313] ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ការិយាល័យ ស.ច.ស ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (ថ្ងៃខែដាក់ឯកសារ) ERN 01222328-01222936។

ក.ស.ច.ស[314]។ ទោះបីជាយ៉ាងនេះក្តី ដូចបានលើកឡើងនៅកនុងសំអាងហេតុខាងក្រោមស្តីពីសហឧក្រិដ្ឋកម្មរួម (សូមមើលកថាខណ្ឌ ២៨៦) បញ្ជីឈ្មោះ ស-២១ របស់ ក.ស.ច.ស ពុំបានផ្តល់ទិន្និន័យគ្រប់គ្រាន់សម្រាប់ការសន្និដ្ឋានអំពីឋានន្តរសក្តិ ឬ ប្រភពនៃបុគ្គលគ្រប់រូបដែលបានបញ្ជូនទៅ ស-២១ នោះឡើយ។

## ៤.៧. លិខិតធានា

148. លិខិតធានាត្រូវបានផ្តល់ជូនដល់សាក្សី អនុលោមតាមវិធាន ២៨ នៃវិធានផ្ទៃក្នុង ដែលបានស្នើសុំ [315]។ បទពិសោធន៍បានបង្ហាញថា ការផ្តល់ការធានាបែបនេះពុំបានធ្វើឲ្យសាក្សីលែងមានភាព

---

[314] ឯកសារ **D322/8** *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ឯកសារប.ក.ក ទៅក្នុងសំណុំរឿង ០០៤* ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ កថាខណ្ឌ៤៧។ ឯកសារ **D219/825.1.1** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ERN 01399603-01399605។

[315] *សូមមើល* ឯកសារ **D117/71/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ប្រាក់ យុត ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣។ ឯកសារ **D118/170/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ សេក សំអាត (ហៅ យាយរឹម) ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣។ ឯកសារ **D118/179/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ស៊ូ ហឿន ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤។ ឯកសារ **D118/285/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ណុប ងឹម ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤។ ឯកសារ **D119/108/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ សុខ រុំ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤។ ឯកសារ **D119/110.1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ជុំ កន ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤។ ឯកសារ **D119/142/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ សែម នួន ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤។ ឯកសារ **D119/65/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ទុំ សឿន ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។ ឯកសារ **D119/69/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ក្រូច ទឹម ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៣។ ឯកសារ **D119/96/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ អ៊ឹម ម៉ន ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២១៤។ ឯកសារ **D174/2** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ សូត្រ សាំង ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣។ ឯកសារ **D219/102/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ទុំ សឿន ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **D219/103/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ស៊ុម សល់ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **D219/188/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោ[redacted] ខ[redacted] យន ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥។ ឯកសារ **D219/284/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ពៅ សារ៉ុម ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥។ ឯកសារ **D219/347/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ឈឹម ផន ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៥។ ឯកសារ **D219/397.1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ប៊ិន សុខ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។ ឯកសារ **D219/427/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ហ៊ឹម ហ៊ុយ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥។ ឯកសារ **D219/442/2** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ជុំ វង្ស ហៅ ង៉ូវ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។ ឯកសារ **D219/497/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ សួន ឡុញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥។ ឯកសារ **D219/497/2** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ អោម ឡូញ ហៅ សួន

ស្ទាក់ស្ទើរក្នុងការលើកឡើងអំពីហេតុការណ៍នោះឡើយ ជាពិសេស នៅក្នុងករណីដែលមានសញ្ញាបញ្ជាក់ថា សាក្សីអាចជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពនេះ។ ចំណុចនេះគឺទំនងដោយសារបំណងចង់រក្សា "មុខមាត់" និងជៀសវាងការជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា។ ដូច្នេះ ភាពអាចជឿជាក់បាននៃសាក្សីមួយចំនួនត្រូវបានកំណត់ដោយផ្អែកលើខ្លឹមសារនៃសក្ខីកម្ម និងស្របតាមលទ្ធភាពដែលអាចពាក់ព័ន្ធនៅក្នុងអំពើឧក្រិដ្ឋដូចបានចោទប្រកាន់ បើទោះជាបានផ្តល់លិខិតធានាក៏ដោយ។

## ៤.៨. ផលប៉ះពាល់នៃសាលក្រមសំណុំរឿង០០២/២

149. នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/២[316] អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសម្រេចមួយចំនួនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលនាំឱ្យមានចំណុចខុសគ្នាជាមួយនឹងការសម្រេចពាក់ព័ន្ធនឹងទីតាំងនោះនៅក្នុងដីកាដំណោះស្រាយ។ ចំណុចទី១ ស.ច.ស ពុំមានកាតព្វកិច្ចគោរពតាមការសម្រេចលើអង្គហេតុ (ឬ លើអង្គច្បាប់) នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ជាពិសេស ប្រសិនបើវាស្ថិតនៅក្រោមបណ្តឹងសាទុក្ខ។ ចំណុចទី២ ដូចបានទទួលស្គាល់ដោយ អ.ជ.ស.ដ ខ្លួនឯងនៅក្នុងសំណុំរឿង ០០២/២ បើទោះជាពាក់ព័ន្ធនឹងកិច្ចដំណើរការនៃសំណុំរឿង ០០២/១ និងសំណុំរឿង ០០២/២ ក៏ដោយ ទោះបីជាអាចមានចំណុចដូចគ្នាផ្នែកខ្លះរវាងភ័ស្តុតាងនៅក្នុងរឿងក្តីខុសៗគ្នានៅចំពោះមុខ អ.វ.ត.ក សេចក្តីសន្និដ្ឋានខុសគ្នាអាចធ្វើឡើងរួមទាំង លើភ័ស្តុតាង និងបញ្ហានានាដែលមានចំណុចពាក់ព័ន្ធដូចគ្នា[317]។ ករណីនេះអនុវត្តដូចគ្នាពាក់ព័ន្ធនឹងករណីនៅចំពោះមុខ ស.ច.ស ពោលគឺ ការសម្រេចនៅក្នុងដីកាដំណោះស្រាយត្រូវបានធ្វើឡើងដោយផ្អែកលើការបកស្រាយលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០៤។

---

ឡូញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។ ឯកសារ **D219/499/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ លោក ញ៉េវ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥។ ឯកសារ **D219/518/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ស៊ិន សុត ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥។ ឯកសារ **D219/626.1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ម៉ុយ សុត ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥។ ឯកសារ **D219/672/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦។ ឯកសារ **D219/870/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ រី ញ៉ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦។ ឯកសារ **D219/871/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ គន់ គីម ហៅ ពីន ពៅ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។ ឯកសារ **D230/1** លិខិតធានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះ ទុំ សឿន ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤។

[316] សំណុំរឿង ០០២-ឯកសារ **E465** *សាលក្រម សំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។*

[317] សំណុំរឿង ០០២-ឯកសារ **E465** *សាលក្រម សំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ៣៦។*

## ៤.៩. ការព្យាយាមស្នើសុំការជួយជ្រោមជ្រែងពីវៀតណាម ថៃ និងអង្គការសហប្រជាជាតិ

150. មានការព្យាយាមច្រើនដងស្នើសុំការជួយជ្រោមជ្រែងពីវៀតណាម និងថៃ ពាក់ព័ន្ធនឹងការផ្តល់ឯកសារ និងស្នើសុំពិនិត្យបណ្ណសារដែលនៅសេសសល់ពីសម័យមុននៅក្នុងប្រទេសទាំងនោះ ដែលអាចមានភស្តុតាងពាក់ព័ន្ធនឹងបទចោទនៅក្នុងរឿងក្តីចំពោះមុខ អ.វ.ត.ក។ នៅទីបំផុត ការព្យាយាមបែបនេះពុំទទួលបានផ្លែផ្កា។ ស្រដៀងគ្នានេះដែរ អង្គការសហប្រជាជាតិបានបដិសេធមិនផ្តល់ឯកសារសម្ងាត់មកពីបណ្ណសារដ្ឋានរបស់ខ្លួនពាក់ព័ន្ធនឹងការចរចាក្នុងការបង្កើត អ.វ.ត.ក[318]។

## ៥. ការវិភាគ និងសំអាងហេតុ

## ៥.១. រចនាសម្ព័ន្ធរដ្ឋបាល

151. សកម្មភាពរបស់ យឹម ទិត្យ ពាក់ព័ន្ធដីកាដំណោះស្រាយនេះ គ្របដណ្តប់លើភូមិភាគចំនួនពីរ គឺភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ ភូមិភាគទាំងអស់ រួមទាំងភូមិភាគស្វយ័ត ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា (ហៅថា គណៈ ៨៧០ ផងដែរ)[319] ដែលមានប៉ុល ពត នួន ជា អៀង សារី និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត[320]។

### ៥.១.១. នៅថ្នាក់ជាតិ

152. កម្ពុជាប្រជាធិបតេយ្យស្ថិតក្រោមការគ្រប់គ្រងរបស់រចនាសម្ព័ន្ធឋានានុក្រមរដ្ឋបាល ដោយគណៈកម្មាធិការមជ្ឈិមមានតួនាទីជា "អង្គការរបស់បក្ស មានសិទ្ធិអំណាចធំជាងគេបំផុត សម្រាប់ទូទាំងប្រទេស"[321]។ គណៈកម្មាធិការមជ្ឈិមមានសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងលេខាភូមិភាគ ដែលជាសមាជិកមិនអចិន្ត្រៃយ៍[322]។ ទោះបីជាតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គណៈកម្មា

---

[318] សំណុំរឿង ០០១-ឯកសារ **D267** *[កោសល្យ] ដីកាដំណោះស្រាយ* ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ១៤៨។

[319] ឯកសារ **D6.1.503**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ (នង សេងជឹម) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៩ ERN 00294539។

[320] ឯកសារ **D6.1.503**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ (នង សេងជឹម) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៩ ERN 00294539។

[321] ឯកសារ **D1.3.20.1** លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ERN 00053025 មាត្រា ៧(១)។ ឯកសារ **D1.3.20.2** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ ERN 00089845 មាត្រា១។

[322] ឯកសារ **D179/1.2.11** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (កាំង ហ្កេចអ៊ាវ ហៅ ឌុច) ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ERN 00794078, ERN 00794087។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (កាំង ហ្កេចអ៊ាវ ហៅ ឌុច) ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ERN 00794521 បន្ទាត់២០-២៥។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00340575។ *សូមមើលផងដែរ* ឯក

ធិការមជ្ឈិម ប្រើប្រាស់សិទ្ធិអំណាចផ្នែកប្រតិបត្តិលើកម្ពុជាប្រជាធិបតេយ្យក្តី តែការត្រួតត្រាជាក់ស្តែងត្រូវធ្វើឡើងដោយស្ថាប័នក្រៅលក្ខន្តិកៈ ដែលមានឈ្មោះថា គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលកើតចេញពីគណៈកម្មាធិការមជ្ឈិម[323]។

153. គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលខុសត្រូវចំពោះការបង្កើតគោលនយោបាយ និងការណែនាំ ព្រមទាំងផ្សព្វផ្សាយគោលនយោបាយទាំងនោះ ទៅកាន់លេខាភូមិភាគ និងតំបន់ស្វយ័ត ដែលផ្សព្វផ្សាយបន្តទៅលេខាកម្រិតតំបន់ និងស្រុក ដើម្បីអនុវត្ត[324]។ បន្ទាប់មក

---

សារ **D219/702.1.137** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០១ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ ERN 00339538-00339539។

[323] កសារ **D179/1.2.34** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [David Chandler] ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ERN 00826703 បន្ទាត់២៤។ ឯកសារ **D179/1.2.11** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (កាំង ហ្គេចអ៊ាវ ហៅ ឌុច) ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ERN 00794078-00794079។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (កាំង ហ្គេចអ៊ាវ ហៅ ឌុច) ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ERN 00794527 បន្ទាត់៩។ ឯកសារ **D219/702.1.137** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០១ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ ERN 00339538-00339539។ ឯកសារ **D1.3.36.1** កំណត់ហេតុស្តួរចម្លើយ ខៀវ សំផន ថ្ងៃទី១៣ ខែធ្នូ ២០០៧ ERN 00156619។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00340575។ ឯកសារ **D6.1.1051** កំណត់ហេតុស្តួរចម្លើយ ឌុច ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ ERN 00154927។ ឯកសារ **D6.1.91** កំណត់ហេតុស្តួរចម្លើយ ឌុច ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00239832។ ឯកសារ **D118/103.3** សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយដោយជនជាប់ចោទ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404803 កថាខណ្ឌ៥៦។

[324] ឯកសារ **D1.3.20.1** លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ERN 00053024 មាត្រា ៦(៤)-៦)៥), ERN 00053028 មាត្រា ១២, ERN 00053030 មាត្រា ១៥(២), ERN 00053031 មាត្រា ១៨(២), ERN 00053033-00053034 មាត្រា ២៣(១)-២៣(៣)។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (កាំង ហ្គេចអ៊ាវ ហៅ ឌុច) ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ERN 00794526-00794527។ ឯកសារ **D179/1.2.24** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (សៅ សារុន) ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ERN 00814446 បន្ទាត់៣-៧។ *សូមមើលផងដែរ* ឯកសារ **D267.1.80** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (ពេជ្រ ជឹម) ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣ ERN 00934800-00934803។ ឯកសារ **D6.1.989**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ ERN 00486471-00486472 ឆ.១៤-១៥។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373498។ ឯកសារ **D219/442**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥ ERN 01125503 ឆ.២ ERN 01125506 ឆ.២៩។

ការអនុវត្តគោលការណ៍ណែនាំ ត្រូវបានរាយការណ៍ត្រឡប់ទៅលើវិញ តាមរយៈខ្សែបណ្តាញបញ្ជាទៅកាន់គណៈកម្មាធិការទាំងពីរ ("មជ្ឈិម")[325]។

[1034] ឯកសារ **D219/763** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244133-01244135 ឆ.១១៥-ឆ.១២១, ឆ.១៣៣-ឆ.១៣៥។ *សូមមើលផងដែរ* ឯកសារ **D219/368** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ុន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01110185-01110186 ឆ.៨៧-ឆ.៩០។ ឯកសារ **D219/533** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ុន ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01153592-01153593 ឆ.១១-ឆ.១៤។

394. នៅឯការប្រជុំមួយនៅការដ្ឋានទំនប់កង្កួតដែលមានអ្នកចូលរួមពី ៧០០ ទៅ៨០០ នាក់ រួមមានប្រជាជនធម្មតា ព្រមទាំងប្រធានភូមិ ប្រធានឃុំ និងប្រធានស្រុក[1035] **យឹម ទិត្យ** បាននិយាយអំពី *"វៀយួន"* និង *"ខ្មាំងផ្ទៃក្នុង"* ដែលរួមមាន *"យួន សេ.អ៊ី.អា និង កា.ហ្សេ.បេ"* ដែលកំពុងលាក់ខ្លួនក្នុងចំណោមប្រជាជន[1036]។ **យឹម ទិត្យ** បានជំរុញឱ្យប្រជាជនតាមដាន និងរាយការណ៍ពីខ្មាំងទាំងនោះ *"ទៅអង្គការលើ ដើម្បីកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង"*[1037]។ ទោះបី សាក្សីអះអាងថា ការប្រជុំនេះបានកើតឡើងនៅចុងឆ្នាំ១៩៧៨ ក៏ដោយ តែវត្តមានរបស់ តាប៉ែត ដែលត្រូវបានចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៨ បង្ហាញថា ការប្រជុំប្រហែលជាបានកើតឡើង មុនកាលបរិច្ឆេទនេះ ហើយសាក្សីមានការភាន់ច្រឡំអំពីកាលបរិច្ឆេទ[1038]។

395. អតីតប្រធានកងសន្តិសុខមួយរូបនៅរោងចក្រស្ករសកំពង់គល់ក្នុងស្រុកសង្កែ បានរម្លឹកពីការប្រជុំមួយដែលបានធ្វើតាំងពីដើម រហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧៨ នៅសាកលវិទ្យាល័យបាត់ដំបងក្នុងទីរួមខេត្តបាត់ដំបង ដែលក្នុងពេលនោះ **យឹម ទិត្យ** ដែលត្រូវបានបង្ហាញខ្លួនថាជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ បាននិយាយបំផុសប្រឆាំងនឹងការគំរាមកំហែងរបស់ *"យួន"* ក្នុងការបំផ្លាញរោងចក្រស្ករស[1039]។ ការប្រជុំនោះមានការចូលរួមពីសន្តិសុខ និងទាហានប្រហែល

---

[1035] ឯកសារ **D219/85** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040093-01040094 ឆ.១, ឆ.៣។

[1036] ឯកសារ **D219/85** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040093-01040094 ឆ.៣-ឆ.៥។

[1037] ឯកសារ **D219/85** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040094 ឆ.៥។

[1038] ឯកសារ **D219/85** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040093-01040094 ឆ.៣។ ឯកសារ **D118/69** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នួន មួន ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ERN 00920212 ឆ.១១។ ឯកសារ **D219/117** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គុប សឹង ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046466-01046467 ឆ.៦៨-ឆ.៦៩, ឆ.៧៩។ ឯកសារ **D118/136** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាន ប៉ា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ERN 00960667-00960668 ឆ.៣៧។ *សូមមើល ការតែងតាំង យឹម ទិត្យ ទៅក្នុងតំណែងនៅភូមិភាគពាយ័ព្យ នៅអំឡុងខែមិថុនា ឆ្នាំ១៩៧៨* កថាខណ្ឌ ៣៦៣។

[1039] ឯកសារ **D118/108** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម ទីម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ERN 00951928 ឆ.១៧-ឆ.១៨ ERN 00951929 ឆ.២២។ ឯកសារ **D219/649** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម ទីម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ERN 01196453-01196454 ឆ.១០, ERN 01196460 ឆ.៤០, ERN 01196463-01196464 ឆ.៦២, ឆ.៦៤, ឆ.៦៩។

២០០ នាក់ មកពីតំបន់នានាក្នុងភូមិភាគពាយ័ព្យ[1040]។ នៅពេលគេសាកសួរថា តើ **យឹម ទិត្យ** បាននិយាយសំដៅដល់កងទ័ព ឬប្រជាជនស៊ីវិលវៀតណាម សាក្សីបានឆ្លើយតបថា គាត់មិនដឹងថាពេលនោះ **យឹម ទិត្យ** និយាយប្រឆាំងនឹងអ្នកណាទេ[1041]។ ទោះជាយ៉ាងណាក្តី ក្រោយមកសាក្សីអះអាងថា ប្រជាជនត្រូវបានចាប់ខ្លួន និងនាំយកទៅដោយកម្មាភិបាលភូមិភាគនិរតី ដោយសារពួកគេត្រូវបានចោទថា *"ជាប់ខ្សែរយៈយួន" "ជាប់ខ្សែស្រឡាយ ខ្សែចិនខ្សែយួន ជាប់ពូជអំបូរ កូនកាត់ ព្រោះពាក្យខ្មែរនិយាយអញ្ចឹង"*[1042]។

396. **យឹម ទិត្យ** ក៏មានវត្តមានផងដែរនៅឯការប្រជុំមួយទៀត *"ធ្វើការបោសសម្អាតចារបុរសវៀតណាម"* ដែលបានធ្វើឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៨ នៅសាកលវិទ្យាល័យបាត់ដំបង ដែលដឹកនាំដោយ តាម៉ុក។ សាក្សីដែលត្រូវបានតែងតាំងជាលេខាស្រុកបវេល (តំបន់ ៣) ដោយ តាម៉ុក ឲ្យ *"ធ្វើការងារនេះ"*[1043] រម្លឹកថា ការប្រជុំនោះមានការចូលរួមពីកម្មាភិបាល ៣០ នាក់ រួមទាំងអ្នកនៅថ្នាក់តំបន់ និងថ្នាក់ស្រុក ដូចជា **យឹម ទិត្យ** តាអាន និង យាយរីម[1044]។

---

[1040] ឯកសារ **D118/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **លឹម ទឹម** ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ERN 00951929 ឆ.២៤។ ឯកសារ **D219/649** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **លឹម ទឹម** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ERN 01196460-01196461 ឆ.៤២-ឆ.៤៣, ឆ.៤៧។

[1041] ឯកសារ **D219/649** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **លឹម ទឹម** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ERN 01196465 ឆ.៧១។

[1042] ឯកសារ **D219/649** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **លឹម ទឹម** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ERN 01196466-01196467 ឆ.៧៥-ឆ.៧៦, ឆ.៧៩-ឆ.៨០, ឆ.៨២, ឆ.៨៥-ឆ.៨៧ ERN 01196474 ឆ.១២៩-ឆ.១៣០។ ឯកសារ **D118/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទឹម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ERN 00951928 ឆ.១៩, ERN 00951931-00951932 ឆ.៤៧-ឆ.៥៤។

[1043] ឯកសារ **D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095237-01095238 ឆ.៥-ឆ.៦, ឆ.១៤, ERN 01095241 ឆ.៣៦, ឆ.៤១។ ឯកសារ **D219/900** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ ERN 01379787-01379788 ឆ.៥-ឆ.៦, ឆ.១២, ERN 01379790 ឆ.៣៥-ឆ.៣៦។

[1044] ឯកសារ **D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095243-01095244 ឆ.៥៥-ឆ.៥៧ ERN 01095246 ឆ.៦៨, ឆ.៧០-ឆ.៧១។ ឯកសារ **D219/900** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ ERN 01379790 ឆ.៣៥-ឆ.៤០, ERN 01379797 ឆ.១០៨។

397. ពីពាក់កណ្ដាលរហូតដល់ចុងឆ្នាំ១៩៧៨ **យឹម ទិត្យ** បានដឹកនាំការប្រជុំជាច្រើននៅឃុំបាយដំរាំ ស្រុកសង្កែ[1045]។ ក្នុងអំឡុងពេលប្រជុំទាំងនេះ **យឹម ទិត្យ** បានសង្កត់ធ្ងន់ពីការគំរាមកំហែងដោយពួកវៀតណាម រួមទាំងអ្នកដែលមានទំនាក់ទំនងជាមួយវៀតណាម និងភ្នាក់ងារ *"ស៊ីរូងផ្ទៃក្នុង"* និងបានព្រមានដល់ប្រធានអង្គភាព ឈ្លប និងប្រជាជនស៊ីវិលធម្មតាដែលបានចូលរួមប្រជុំ ប្រឆាំងនឹងការចូលដៃជាមួយពួកវៀតណាម[1046]។ នៅឯការប្រជុំមួយក្នុងចំណោមការប្រជុំទាំងនោះ **យឹម ទិត្យ** បានបញ្ជា *"បងប្អូនកុំឱ្យចូលដៃចូលជើងជាមួយយួន ហើយរួបរួមជាមួយនិរតីហ្នឹងទៅ"*[1047] ហើយគាត់បាននិយាយពីភាពចាំបាច់ក្នុងការសម្លាប់អ្នកដែលអាចនិយាយភាសាវៀតណាមបាន ឬអ្នកដែល ជាប់ *"ខ្មែរយួន"*[1048]។ បើតាមសាក្សី គោលបំណងនៃការប្រជុំរយៈពេល ៦ម៉ោងពេញនេះគឺដើម្បីឱ្យ **យឹម ទិត្យ** និយាយពីវៀតណាម និងអ្នកជាប់ខ្មែរវៀតណាម[1049]។ នៅឯការប្រជុំមួយក្នុងចំណោមការប្រជុំទាំងនេះ **យឹម ទិត្យ** បានរៀបរាប់ថា កម្មាភិបាលភូមិភាគពាយ័ព្យគឺ

---

[1045] ឯកសារ **D118/77** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណង នី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ERN 00934388-00934389 ឆ.២៤, ឆ.២៩-ឆ.៣០។ ឯកសារ **D219/953** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ERN 01425164-01425165 ឆ.១៥-ឆ.១៨, ERN 01425168 ឆ.៣៤, ERN 01425173-01425174 ឆ.៥៩, ឆ.៦១-ឆ.៦៤, ERN 01425176 ឆ.៧៣-ឆ.៧៤។ ឯកសារ **D219/368** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01110185-01110186 ឆ.៨៧-ឆ.៩០, ឆ.៩៣-ឆ.៩៤, ERN 01110191-01110192 ឆ.១១៤, ឆ.១១៦។ ឯកសារ **D219/430** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ERN 01122420 ឆ.១២៦-ឆ.១២៧។

[1046] ឯកសារ **D219/533** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01153591-01153594 ឆ.២-ឆ.៤, ឆ.១១-ឆ.១៤, ឆ.១៩-ឆ.២១ ERN 01153595-01153596 ឆ.៣៦-ឆ.៣៩។ ឯកសារ **D219/368** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01110185-01110187 ឆ.៨៧-ឆ.៩០, ឆ.៩៣-ឆ.៩៥។ ឯកសារ **D219/953** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ERN 01425175-01425178 ឆ.៦៧-ឆ.៧២, ឆ.៧៥, ឆ.៨២-ឆ.៨៤។ ឯកសារ **D219/954** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧ ERN 01425184-01425186 ឆ.១, ឆ.៧-ឆ.៨, ឆ.១៣-ឆ.១៤។

[1047] ឯកសារ **D219/953** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ERN 01425175 ឆ.៦៧-ឆ.៦៩ ERN 01425177-01425178 ឆ.៨២-ឆ.៨៤។ ឯកសារ **D219/954** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧ ERN 01425185-01425186 ឆ.៧-ឆ.៨។

[1048] ឯកសារ **D219/953** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ERN 01425176-01425178 ឆ.៧០-ឆ.៧២, ឆ.៧៥, ឆ.៨២-ឆ.៨៤។

[1049] ឯកសារ **D219/953** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ERN 01425176 ឆ.៧០-ឆ.៧២។ ឯកសារ **D219/954** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧ ERN 01425184-01425185 ឆ.១, ឆ.៧។

*"ក្បាលយួនខ្លួនខ្មែរ"* ជាឃ្លាដែលគេយកមកប្រើជាញឹកញាប់ ដើម្បីនិយាយសំដៅដល់ប្រជាជនខ្មែរក្រោម ហើយបានប្រកាសថា កម្មាភិបាលត្រូវបានសម្លាប់ ដោយសារពួកគេជាប់ខ្សែវៀតណាម[1050]។ នៅក្នុងអំឡុងពេលនោះ ឬមួយរយៈខ្លីក្រោយមក នៅខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៨ អ្នកក្រោមបង្គាប់ផ្ទាល់របស់ **យឹម ទិត្យ** ឈ្មោះ តាញឹម កំពុងចាប់ខ្លួន និងសម្លាប់ប្រជាជននៅឃុំចែងមានជ័យ ដែលនៅក្បែរនោះ ក្នុងស្រុកសង្កែ ដោយសារសង្ស័យថាជា *"យួន"* ឬជាប់ខ្សែវៀតណាម ឬបើមិនអីចឹងទេ ក៏មានជាប់ទំនាក់ទំនងជាមួយវៀតណាមដែរ[1051]។

### ៥.៣.៥. ការប្រព្រឹត្តិ និងការចូលរួមរបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួមនៅភូមិភាគពាយ័ព្យ

#### *៥.៣.៥.១. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន*

398. **យឹម ទិត្យ** និង តាម៉ុក បានដើរតួនាទីសំខាន់ក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងកសិកម្មរបស់ ប.ក.ក នៅភូមិភាគពាយ័ព្យ ដែលមានគោលដៅបង្កបង្កើនផលជាតិរបស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្កើតការដ្ឋាន និងសហករណ៍។ **យឹម ទិត្យ** បានទទួលខុសត្រូវទៅលើផលិតកម្ម និងការសាងសង់នៅក្នុងតំបន់នានាដែលគាត់គ្រប់គ្រង ពិនិត្យនៅតាមការដ្ឋាន ដឹកនាំការប្រជុំ និងថ្លែងសុន្ទរកថាអំពីការបង្កបង្កើនផលកសិកម្ម បណ្ដុះបណ្ដាលប្រធានអង្គភាពការងារ និងណែនាំឱ្យខិតខំប្រឹងប្រែងធ្វើការ ដើម្បីទៅតាមផែនការរបស់ ប.ក.ក។

399. ការកាន់មុខតំណែងរបស់ **យឹម ទិត្យ** នៅភូមិភាគពាយ័ព្យបានធ្វើឱ្យលក្ខខណ្ឌការងារកាន់តែធ្ងន់ធ្ងរ ស្បៀងអាហារកាន់តែមិនគ្រប់គ្រាន់ ការថែទាំសុខភាពកាន់តែដុនដាប និងការចាត់វិធានការវិន័យកាន់តែធ្ងន់ធ្ងរ[1052]។

---

[1050] ឯកសារ **D118/77** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណាង នី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ERN 00934388-00934389 ឆ.២៤, ឆ.២៩-ឆ.៣០។

[1051] ឯកសារ **D219/263** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆាំ លុយ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ERN 01086094 ឆ.៣២ ERN 01086097-01086098 ឆ.៦២-ឆ.៧៨។ ឯកសារ **D118/243** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆាំ លុយ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ERN 00990630-00990631 ឆ.១៤-ឆ.១៥។

[1052] ឯកសារ **D219/689** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01205215 ឆ.៧៤។ ឯកសារ **D219/368** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01110192 ឆ.១១៧, ERN 01110194 ឆ.១២៣-ឆ.១២៥, ឆ.១២៧, ERN 01110196-01110198 ឆ.១៣៦-ឆ.១៣៧, ឆ.១៣៩, ឆ.១៤១។ ឯកសារ **D219/430** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ERN 01122420 ឆ.១២៤។ ឯកសារ **D219/533** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01153611 ឆ.១៣៨។ ឯកសារ **D219/9** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យុន សាមឿន ចុះថ្ងៃទី១៦ ខែ

*ការចុះពិនិត្យ*

400. ការចូលរួមរបស់ **យឹម ទិត្យ** ក្នុងការបង្កើត និងគ្រប់គ្រងការដ្ឋាន និងសហករណ៍នៅភូមិភាគពាយ័ព្យ ចាប់ផ្ដើមពីដើមឆ្នាំ១៩៧៦ នៅពេលដែលគាត់ចាប់ផ្ដើមធ្វើដំណើរជាទៀងទាត់ពីភូមិភាគនិរតី ទៅភូមិភាគពាយ័ព្យ ដែលគាត់នឹងទៅពិនិត្យតាមការដ្ឋាន និងសហករណ៍[1053]។ ជារឿយៗដោយអមដំណើរ តាម៉ុក **យឹម ទិត្យ** បានធ្វើដំណើរការទៅពិនិត្យនៅតាមសហករណ៍ និងការដ្ឋាន និង វាយតម្លៃអំពីដំណើរការនៅតាមកន្លែងទាំងនោះ។ ជួនកាល កម្មាភិបាលភូមិភាគពាយ័ព្យ ដូចជា តាចែត តាវ៉ាញ និង តាប៉ែត ក៏បានរួមដំណើរជាមួយ **យឹម ទិត្យ** ក្នុងអំឡុងពេលចុះពិនិត្យទាំងនេះដែរ បន្ទាប់ពីបានបានចូលរួមក្នុងការប្រជុំរួច[1054]។ មានភស្តុតាងថា **យឹម ទិត្យ** បានចុះត្រួតពិនិត្យនានាដូចខាងក្រោម៖

i. នៅពាក់កណ្ដាលឆ្នាំ១៩៧៦ **យឹម ទិត្យ** តាម៉ុក តាវ៉ាញ តាចែត និងមេកងវរសេនាតូច និងមេកងអនុសេនាធំនៅភូមិភាគពាយ័ព្យចំនួន ៣០នាក់ផ្សេងទៀត បានទៅចុះពិនិត្យនៅទំនប់កង្ហត បានចូលរួមក្នុងវគ្គរៀនសូត្រធំមួយ ហើយក្រោយមកបានទៅត្រួតពិនិត្យនៅតាម

---

កញ្ញា ឆ្នាំ២០១៤ ERN 01025559 ឆ.២៨-ឆ.២៩។ *សូមមើល ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ* កថាខណ្ឌ ២៨៥, សហករណ៍ធិបតី (រួមទាំងមន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស) កថាខណ្ឌ ៦១៣-៦១៦, ការដ្ឋានទំនប់កង្ហត កថាខណ្ឌ ៦៧០-៦៧៥។

[1053] ឯកសារ **D219/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាន់ ឡូន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ERN 01029211-01029212 ឆ.៧៧៤-ឆ.៧៨០។ ឯកសារ **D118/75** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ERN 00934370 ឆ.២៧-ឆ.៣៤។ ឯកសារ **D219/763** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244136-01244137 ឆ.១៤១, ឆ.១៤៦-ឆ.១៤៩។

[1054] ឯកសារ **D219/763** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244128 ឆ.៨១ ERN 01244136-01244137 ឆ.១៣៩, ឆ.១៤១-ឆ.១៤២, ឆ.១៤៦-ឆ.១៤៩។ ឯកសារ **D219/956** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ERN 01425218-01425223 ឆ.១១, ឆ.១៣-ឆ.១៦, ឆ.២២, ឆ.២៤-ឆ.៣០, ឆ.៣៨។ ឯកសារ **D219/981** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ERN 01477606 ឆ.៣-ឆ.៥, ERN 01477612 ឆ.៣៥-ឆ.៣៨, ERN 01477614-01477617 ឆ.៥០, ឆ.៥៤, ឆ.៥៨, ឆ.៦០-ឆ.៦១, ឆ.៦៥-ឆ.៦៦។ ឯកសារ **D219/982** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477623-01477624 ឆ.៦-ឆ.៨, ERN 01477627 ឆ.២៣-ឆ.២៤។ ឯកសារ **D219/430** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ERN 01122412-01122413 ឆ.៨៤-ឆ.៩០ ERN 01122418-01122419 ឆ.១១២, ឆ.១២១។

រោងចក្រ សាលារៀន មន្ទីរពេទ្យ និងការដ្ឋានសាងសង់នៅទីរួមខេត្តបាត់ដំបង[1055]។ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ **យឹម ទិត្យ** បានចុះពិនិត្យនៅការដ្ឋាន និងបានចូលរួមក្នុងការប្រជុំមួយជាមួយ តាស្វ៊ូ ដែលជាប្រធានការដ្ឋាន[1056]។ **យឹម ទិត្យ** បានចុះត្រួតពិនិត្យទ្វារទឹកនៅទំនប់នៅខែមេសា ឬខែឧសភា ឆ្នាំ១៩៧៨ ដែលអមដំណើរដោយ តាប៉ែត ជាលេខាតំបន់ ១។ ជាងនេះទៀត ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៨ **យឹម ទិត្យ** បានទៅពិនិត្យការដ្ឋានប្រហែលពីរដងក្នុងមួយខែ ដើម្បីចុះពិនិត្យទៅលើការងាររបស់កងចល័ត និងធ្វើការវាយតម្លៃថាតើ ការងារទាំងនោះត្រូវបានបញ្ចប់ ឬយ៉ាងណា[1057]។

ii. នៅឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧ **យឹម ទិត្យ** បានចុះពិនិត្យដំណើរការសាងសង់ទំនប់ និងការបង្កបង្កើនផលស្រូវនៅការដ្ឋានទួលម្ទេសនៅសហករណ៍ធិបតី ក្នុងតំបន់ ១[1058]។

---

[1055] ឯកសារ **D219/763** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244126-01244128 ឆ.៦៥-ឆ.៧១ ERN 01244128 ឆ.៨១, ERN 01244136-01244137 ឆ.១៣៩, ឆ.១៤២-ឆ.១៤៤។ ឯកសារ **D219/956** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ERN 01425219-01425222 ឆ.១៣-ឆ.១៨, ឆ.២០, ឆ.២២, ឆ.២៤-ឆ.៣០, ERN 01425226-01425228 ឆ.៥៥-ឆ.៥៧, ឆ.៥៩-ឆ.៦៣។ ឯកសារ **D219/981** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ERN 01477606-01477617 ឆ.៣-ឆ.៥, ឆ.៩, ឆ.១១-ឆ.១២, ឆ.១៥-ឆ.២២, ឆ.២៤-ឆ.២៦, ឆ.២៩-ឆ.៣០, ឆ.៣៥-ឆ.៣៨, ឆ.៤៨, ឆ.៥០, ឆ.៥៤, ឆ.៥៨, ឆ.៦០-ឆ.៦១, ឆ.៦៥-ឆ.៦៧។ ឯកសារ **D219/982** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477623-01477624 ឆ.៦-ឆ.៨, ERN 01477627 ឆ.២៣-ឆ.២៤។

[1056] ឯកសារ **D219/46** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ERN 01032222-01032224 ឆ.៣១.៣៦, ឆ.៣៩-ឆ.៤៤។ ឯកសារ **D219/239** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ERN 01080872-01080875 ឆ.២-ឆ.៣, ឆ.៥, ឆ.៧, ឆ.១០, ឆ.១៣។

[1057] ឯកសារ **D219/430** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ុន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ERN 01122412-01122414 ឆ.៨៤-ឆ.៩៩, ERN 01122418-01122419 ឆ.១១២, ឆ.១២១។ ឯកសារ **D219/117** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តុប សឹង ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046465-01046468 ឆ.៥៨-ឆ.៦១, ឆ.៦៧-ឆ.៧៥ ឆ.៧៨-ឆ.៧៩, ឆ.៨៥, ឆ.៨៧-ឆ.៩០, ERN 01046474 ឆ.១៤៣-ឆ.១៤៥, ERN 01046478 ឆ.១៨១។ *សូមមើលផងដែរ* ឯកសារ **D219/368** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ុន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01110176 ឆ.១៦-ឆ.១៧, ឆ.១៩, ឆ.២៤ ERN 01110191 ឆ.១១៤។ ឯកសារ **D219/210** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ERN 01074048 ឆ.៤-ឆ.៦។ ឯកសារ **D219/236** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ERN 01477644 ឆ.១៧។

[1058] ឯកសារ **D219/763** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244136-01244137 ឆ.១៣៩, ឆ.១៤១-ឆ.១៤២, ឆ.១៤៦-ឆ.១៤៩។

iii. **យឹម ទិត្យ** បានចុះត្រួតពិនិត្យនៅតាមវាលស្រែ និងកសិផលផ្សេងទៀតនៅស្រុកបវេល តំបន់ ៣ ក្នុងខែកញ្ញា ឬខែតុលា ឆ្នាំ១៩៧៨[1059]។

401. សាក្សី ហ៊ុយ ក្រឹម ដែលជាអតីតកម្មករធ្វើការនៅស្រុកមោងឬស្សី បានលើកឡើងថា នៅឆ្នាំ ១៩៧៧ កងឈ្លបដែលគាត់បានជួបនៅរាមគន់ ជិតវត្តធម្មយុត្តិ បានបង្ហាញគាត់នូវអត្ថបទមួយនៅក្នុង *"ទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យ"* ដោយមានរូបថត **យឹម ទិត្យ** ដែលពិភាក្សាអំពីការណ៍ដែលគាត់ទៅមើលផ្លូវអយស្ម័យយាន គម្រោងសាងសង់នានា រួមមានគម្រោងសាងសង់អាងផ្ទុកទឹករាមគន់។ ជាងនេះទៀត សាក្សីបានចូលរួមក្នុងការប្រជុំមួយនៅភូមិរាមគន់ ស្រុកមោងឬស្សី ដែលគាត់បានទស្សនាខ្សែភាពយន្តមួយរបស់ ប.ក.ក ដែលរៀបរាប់ពី **យឹម ទិត្យ** ដែលបានចុះពិនិត្យនៅតាមការដ្ឋាននានារួមមាន អាងស្តុកទឹករាមគន់ និងគម្រោងតំបន់ ៣ នៅអាងស្តុកទឹកកំពីងពួយជាដើម។ សាក្សីលើកឡើងថា គាត់បានមើលខ្សែភាពយន្តនៅចុងឆ្នាំ១៩៧៦ ក្រោយពេលបញ្ចប់គម្រោងអាងស្តុកទឹករាមគន់ និងមុនពេលកម្មាភិបាលភូមិភាគនិរតីចូលទៅដល់[1060]។ ទោះជាយ៉ាងណាក្ដី បើតាមសាក្សី ធៀម របៀប ដែលបានធ្វើការនៅការដ្ឋានកំពីងពួយ ហើយក៏មានរូបនៅក្នុងខ្សែភាពយន្តនោះដែរគឺថា ខ្សែភាពយន្តនោះទំនងជាត្រូវបានថតនៅចុងឆ្នាំ១៩៧៧ ឬឆ្នាំ ១៩៧៨[1061]។ ជាងនេះទៀត សាក្សី អ៊ឹម អាន់ ដែលជាអតីតប្រធានភូមិក្រពើជើង ឃុំភ្នំសំពៅ ស្រុកបាណន់ បានលើកឡើងថា ការដ្ឋានកំពីងពួយបានចាប់ផ្ដើមសាងសង់នៅដើមឆ្នាំ១៩៧៧ ហើយបានបញ្ចប់នៅចុងឆ្នាំ១៩៧៧[1062]។ ហេតុនេះ **យឹម ទិត្យ** ទំនងជាបានទៅមើលការដ្ឋានកំពីងពួយនៅឆ្នាំ១៩៧៧ ពុំមែនចុងឆ្នាំ១៩៧៦ ទេ ហើយថា សាក្សីអាចមានការភាន់ច្រឡំពីកាលបរិច្ឆេទ។

---

[1059] ឯកសារ **D219/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095241 ឆ.៤១ ERN 01095247-01095248 ឆ.៧៥-ឆ.៨២។

[1060] ឯកសារ **D105/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00780624 ឆ.៧។ ឯកសារ **D118/75** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ERN 00934366 ឆ.៣, ឆ.៥ ERN 00934370 ឆ.២៧-ឆ.៣៤។ *សូមមើលផងដែរ* ឯកសារ **D219/421** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទៀ ងួន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ ERN 01118807 ឆ.១៣។ ឯកសារ **D219/667** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ុន ម៉ឺន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ERN 01200336 ឆ.៣៥។

[1061] ឯកសារ **D219/914** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ធៀម របៀប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ERN 01388652-01388653 ឆ.២៥-ឆ.២៦, ERN 01388654-01388655 ឆ.៣៩-ឆ.៤៣។

[1062] ឯកសារ **D6.1.165** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197881-00197883។ *សូមមើលផងដែរ* ឯកសារ **D219/784** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុំ ក្រាត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ERN 01300425 ឆ.៤៩។

*ការប្រជុំ សុន្ទរកថា និងការបណ្តុះបណ្តាល*

402. **យឹម ទិត្យ** បានដឹកនាំការប្រជុំ និងវគ្គរៀនសូត្រនៅតាមការដ្ឋាននានា ថ្លែងសុន្ទរកថា និងការណែនាំ និងការបណ្តុះបណ្តាលដល់កម្មាភិបាលថ្នាក់ក្រុមស្តីពីការសាងសង់ និងការបង្កបង្កើនផល[1063]។ ការណែនាំរបស់គាត់ត្រូវបានផ្សព្វផ្សាយដល់ថ្នាក់ក្រោម[1064]។

---

[1063] ឯកសារ **D219/698** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01210567-01210568 ឆ.៤៧-ឆ.៥៨។ ឯកសារ **D219/689** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01205215 ឆ.៧៣។ ឯកសារ **D118/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ERN 00945429-00945430 ឆ.២៤-ឆ.២៨។ ឯកសារ **D118/149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាម សោម ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00967985 ឆ.១៩-ឆ.២៦ ERN 00967988 ឆ.៥៣។ ឯកសារ **D219/534** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ាន យ៉ុន ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ERN 01153632 ឆ.១៧-ឆ.២១។ ឯកសារ **D219/416** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស គង់ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៥ ERN 01117355-01117356 ឆ.១១-ឆ.១២។ ឯកសារ **D219/627** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ERN 01184313 ឆ.៨, ERN 01184315-01184316 ឆ.២០-ឆ.២២, ឆ.២៩។ ឯកសារ **D219/515** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹន ឈួយ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149402-01149404 ឆ.២៧, ឆ.៣០-ឆ.៣៥។ ឯកសារ **D219/943** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡឹម លិន ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ ERN 01415376-01415377 ឆ.២៩-ឆ.៣៦។ ឯកសារ **D219/416** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស គង់ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៥ ERN 01117352-01117353 ឆ.១, ERN 01117355-01117356 ឆ.១១-ឆ.១២។ *សូមមើលផងដែរ* ឯកសារ **D219/368** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ុន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01110195 ឆ.១៣១។ ឯកសារ **D118/136** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ហ៊ា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ERN 00960665 ឆ.១៧ ERN 00960668 ឆ.៤៣។ ឯកសារ **D219/861** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក សំអាត ហៅយាយរឹម ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01347282 ឆ.១២០-ឆ.១២៤។ ឯកសារ **D219/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040093-01040094 ឆ.២-ឆ.៥។ ឯកសារ **D219/953** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹង ឈឿត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ERN 01425164- ERN 01425166 ឆ.១៥-ឆ.២៣។

[1064] ឯកសារ **D118/290** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ វ៉ាច ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022369-01022370 ឆ.៥៧-ឆ.៦៤ ERN 01022376 ឆ.១១៨-ឆ.១១៩។ ឯកសារ **D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មួល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095247-01095248 ឆ.៧៥-ឆ.៨២, ERN 01095250 ឆ.៩៧-ឆ.៩៩, ERN 01095252 ឆ.១០៩, ERN 01095260 ឆ.១៦១-ឆ.១៦២, ERN 01095261 ឆ.១៧៤-ឆ.១៧៥, ERN 01095265 ឆ.២០០-ឆ.២០៣។ ឯកសារ **D219/222** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សេង ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01075734-01075735 ឆ.១២១-ឆ.១២២, ឆ.១២៥-ឆ.១២៧។ ឯកសារ **D101/1.1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ERN 00743545-00743546។ ឯកសារ **D219/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01066323 ឆ.៣៨។ ឯកសារ **D219/465** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ុន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ERN 01132084-01132085 ឆ.៤៤។

403. បើតាមសាក្សី សៅ ជាប់ ដែលជាអតីតប្រធានកងវរសេនាតូចនៅស្រុកគាស់ក្រឡគឺថា នៅពាក់កណ្ដាលឆ្នាំ១៩៧៦ **យឹម ទិត្យ** និង តាម៉ុក រួមជាមួយកម្មាភិបាលមួយចំនួនធំ ដែលមានមុខតំណែងជាថ្នាក់ដឹកនាំមកពីគ្រប់តំបន់ទាំងអស់នៅទូទាំងភូមិភាគពាយ័ព្យ បានចូលរួមវគ្គរៀនសូត្ររយៈពេលបីថ្ងៃនៅទំនប់កង្ហត ដែលដឹកនាំដោយ តាវ៉ាញ ដែលជាលេខាតំបន់ ១ នាពេលនោះ។ តាម៉ុក **យឹម ទិត្យ** និង តាប៉ែត ជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ ដើរតួនាទីជា *"អ្នកបណ្ដុះបណ្ដាល"* ធ្វើបទបង្ហាញស្ដីពីសមិទ្ធផលនៃការបង្កបង្កើនផលនៅក្នុងតំបន់នីមួយៗ និងបានចែករំលែកបទពិសោធរបស់ពួកគេពាក់ព័ន្ធការអនុវត្តល្អៗក្នុងការបង្កបង្កើនផល[1065]។ នៅក្នុងវគ្គរៀនសូត្រ **យឹម ទិត្យ** និង តាម៉ុក បានចុះត្រួតពិនិត្យនៅការដ្ឋាន និងបានផ្ដល់ការណែនាំអំពីរបៀបកែលម្អការអនុវត្តផែនការការងារ[1066]។

404. សាក្សី លេខ ភីវ ដែលជាអតីតអនុប្រធានសហករណ៍គាស់ក្រឡ (និងជាអតីតលេខាសហករណ៍ធិបតី) បានលើកឡើងថា ក្រោយពេល **យឹម ទិត្យ** ត្រូវបានតែងតាំងជាលេខាតំបន់ ១ នៅពាក់កណ្ដាលឆ្នាំ១៩៧៨ មក **យឹម ទិត្យ** បានដឹកនាំការប្រជុំនានាជាទៀងទាត់ ដែលមានការចូលរួមពីតំណាងនានាមកពីសហករណ៍ទាំង ៩ នៅក្នុងស្រុកគាស់ក្រឡ។ កិច្ចប្រជុំទាំងនេះបានរៀបចំឡើងរៀងរាល់១០ថ្ងៃម្ដង និងដែលបានរៀបចំក្នុងមន្ទីរមួយ ដែលស្ថិតនៅការដ្ឋានទំនប់កង្ហត ឬ ជួនកាលនៅព្រៃតូច។ ពីមុនមក ការប្រជុំទាំងនេះដឹកនាំដោយ តាប៉ែត (អតីតលេខាតំបន់ ១ និងកាន់មុខតំណែងមុន **យឹម ទិត្យ**) និង តាយឹន (លេខាស្រុកគាស់ក្រឡ) រហូតដល់ពេលដែលពួកគេត្រូវបានដកចេញពីមុខតំណែង។ នៅឯការប្រជុំទាំងនេះ **យឹម ទិត្យ** បាននិយាយអំពីគោលនយោបាយ ប.ក.ក ពាក់

---

[1065] ឯកសារ **D219/763** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244119 ឆ.៧-ឆ.៨, ERN 01244120 ឆ.១៦-ឆ.១៧, ERN 01244121 ឆ.២៧-ឆ.២៨, ERN 01244124 ឆ.៥០-ឆ.៥១, ERN 01244126-01244127 ឆ.៦៥-ឆ.៧០។ ឯកសារ **D219/956** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ERN 01425219-01425223 ឆ.១៣-ឆ.១៨, ឆ.២០, ឆ.២២, ឆ.២៤-ឆ.៣៦ ERN 01425226-01425228 ឆ.៥៥-ឆ.៥៧, ឆ.៥៩-ឆ.៦៣។ ឯកសារ **D219/981** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ERN 01477606-01477614 ឆ.៣-ឆ.៥, ឆ.៩, ឆ.១១, ឆ.១៥-ឆ.២២, ឆ.២៤-ឆ.២៦, ឆ.២៩-ឆ.៣០, ឆ.៣៧-ឆ.៣៨, ឆ.៤៨, ERN 01477617 ឆ.៦៧។

[1066] ឯកសារ **D219/981** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ERN 01477613-01477616 ឆ.៤១-ឆ.៤៣, ឆ.៥០, ឆ.៥៤, ឆ.៥៨, ឆ.៦០-ឆ.៦១។ ឯកសារ **D219/982** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477623-01477624 ឆ.៦-ឆ.៨, ERN 01477627 ឆ.២៣-ឆ.២៤។

ព័ន្ធនឹងការបង្កបង្កើនផល និង *"ពង្រឹកស្មារតីឲ្យប្រជាជនជឿជាក់ទាំងស្រុងទៅលើបក្ស"*[1067]។ សាក្សីដដែលនេះបានចូលរួមវគ្គរៀនសូត្ររយៈពេលបីថ្ងៃ ស្តីពីការបង្កបង្កើនផលនៅសហករណ៍ធិបតី ដែលគ្រប់គ្រងដោយ **យឹម ទិត្យ** និង តាប៉ែត។ ការប្រជុំក៏មានចូលរួមផងដែរពីប្រធានសហករណ៍ផ្សេងទៀត រួមមាន តាសុន ដែលបានជំនួសសាក្សីជាប្រធានសហករណ៍ធិបតី។ ទោះបីសាក្សីរម្លឹកថា ព្រឹត្តិការណ៍នោះបានកើតឡើងនៅចុងឆ្នាំ១៩៧៨ វត្តមានរបស់ តាប៉ែត មានន័យថា ព្រឹត្តិការណ៍នោះប្រហែលជាបានកើតឡើង មុនពេលចាប់ខ្លួន តាប៉ែត នៅខែសីហា ឆ្នាំ១៩៧៨[1068]។

405. **យឹម ទិត្យ** បាននិយាយនៅឯការប្រជុំផ្សេងទៀតជាច្រើនដែលគាត់ជំរុញការអនុវត្តគោលនយោបាយ ប.ក.ក និងផ្តល់ការណែនាំអំពីការសាងសង់ទំនប់ និងជីកប្រឡាយ និងការអនុវត្តផ្សេងៗទៀតនៃការបង្កបង្កើនផល និងពលកម្មៈ

i. នៅឆ្នាំ១៩៧៦ **យឹម ទិត្យ** បានដឹកនាំការប្រជុំមួយនៅស្វាយបីដើម ស្រុកបាណន់ ដែលគាត់ផ្តល់ការណែនាំអំពីការជីកប្រឡាយ[1069]។

ii. ក្រោយពេលចាប់ខ្លួន តាវ៉ាញ នៅពាក់កណ្តាលឆ្នាំ១៩៧៧[1070] ហើយផ្អែកលើកម្មាភិបាលម្នាក់ដែលរម្លឹកពីការចូលរួមរបស់ ព្រំ នៅឯការប្រជុំនោះ មុនពេលចាប់ខ្លួន ព្រំ នៅខែតុលា ឆ្នាំ១៩៧៧ សាក្សី ទៀប ទិត្យ បានទៅប្រជុំមួយនៅការដ្ឋានទំនប់កង្ហត ដែលមានការចូលរួម ពីកងចល័តស្រុកទាំងអស់នៅតំបន់ ១ ដែល **យឹម ទិត្យ** បាននិយាយអំពីផែនការ

---

[1067] ឯកសារ **D219/210** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ERN 01074048 ឆ.៤-ឆ.៨។ ឯកសារ **D219/236** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ERN 01477644 ឆ.១៧។ ឯកសារ **D219/292** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095209 ឆ.២៤។

[1068] ឯកសារ **D219/292** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095212 ឆ.៣៥។

[1069] ឯកសារ **D219/698** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01210567-01210568 ឆ.៤៧-ឆ.៥៨។

[1070] ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០៦ (កាលបរិច្ឆេទដាក់ឯកសារ) EN ERN 01222369 (លេខរៀង ៩១៣ ជា ហួន ហៅ វ៉ាញ លេខាតំបន់ ១ - ចូល ស-២១ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧)។ ឯកសារ **D219/464** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ERN 01132052-01132053 ឆ.៣-ឆ.៥, ឆ.៧-ឆ.១២, ERN 01132055-01132056 ឆ.៣៣-ឆ.៤៥។ ឯកសារ **D118/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00960688-00960689 ឆ.២, ឆ.៦, ឆ.៩-ឆ.១១។

ការងារ និងការសាងសង់ទំនប់ និងជីកប្រឡាយ និងផ្តល់ចំណាប់អារម្មណ៍របស់គាត់ចំពោះការដ្ឋាននោះ[1071]។

iii. នៅឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ **យឹម ទិត្យ** បានចូលរួមការប្រជុំមួយនៅគោកអំពិល ដែលគាត់បាននិយាយអំពីការបង្កើន *"ការបង្កបង្កើនផលសម្រាប់អង្គការ"* និង *"ជំរុញឲ្យប្រជាជនខំធ្វើការ"*[1072]។

iv. នៅឯការប្រជុំមួយនៅពាក់កណ្តាលឆ្នាំ១៩៧៨ នៅវត្តភ្នំសំពៅ តំបន់ ៣ **យឹម ទិត្យ** បានថ្លែងទៅកាន់កម្មាភិបាលមួយក្រុមដែលមានគ្នាប្រហែល ១០០នាក់មកពីថ្នាក់កងវរហូតដល់ថ្នាក់ស្រុកមកពីតំបន់ ១ និង តំបន់ ៣។ គាត់បានធ្វើបទបង្ហាញអំពីការបង្កបង្កើនផលស្រូវ និងភោគផលផ្សេងទៀត ហើយបានជំរុញឲ្យអ្នកចូលរួមខិតខំបង្កបង្កើនផលស្រូវពី បីទៅបួនតោនក្នុងមួយហិកតា[1073]។

v. យ៉ាងហោចណាស់ នៅក្នុងវគ្គរៀនសូត្រមួយនៅទីរួមខេត្តបាត់ដំបង រវាងពាក់កណ្តាលឆ្នាំ១៩៧៨ និងមុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ មានការចូលរួមពីកម្មាភិបាលភូមិភាគពាយ័ព្យ និងភូមិភាគនិរតីពី ២០ ទៅ៣០នាក់ **យឹម ទិត្យ** បានធ្វើបទបង្ហាញមួយស្តីពីការសាងសង់ទំនប់ និងជីកប្រឡាយ បច្ចេកទេសរៀបចំប្រព័ន្ធធារាសាស្ត្រសម្រាប់ការបង្កបង្កើនផលស្រូវ ហើយបានជំរុញឲ្យអ្នកចូលរួមខិតខំប្រឹងប្រែងធ្វើការ ដើម្បីអភិវឌ្ឍប្រទេសជាតិឲ្យបានឆាប់រហ័ស[1074]។

---

[1071] ឯកសារ **D118/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00960693 ឆ.៣៤-ឆ.៣៧, ឆ.៣៩។ ឯកសារ **D219/464** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ERN 01132054-01132058 ឆ.២៣-ឆ.៣០, ឆ.៣៣-ឆ.៤៥, ឆ.៥៥-ឆ.៥៦, ឆ.៥៩-ឆ.៦០។ *សូមមើល* ពាក់ព័ន្ធនឹងការចាប់ខ្លួន ព្រំ៖ ឯកសារ **D219/465** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ERN 01132072 ឆ.៥។ ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (កាលបរិច្ឆេទដាក់ឯកសារ) EN ERN 01222575 លេខរៀង ៦២៧៣។

[1072] ឯកសារ **D118/76** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ERN 00934378-00934380 ឆ.៣៤-ឆ.៤៩។

[1073] ឯកសារ **D118/245** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990642-00990643 ឆ.៤, ERN 00990644-00990646 ឆ.១២, ឆ.១៦-ឆ.១៨។ ឯកសារ **D118/299** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៤ ERN 01023875-01023877 ឆ.១១, ឆ.១៣ ឆ.២២-ឆ.២៥។

[1074] ឯកសារ **D219/117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប សឹង ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046468-01046469 ឆ.៩២-ឆ.១០០, ERN 01046473-01046474 ឆ.១៣៦-ឆ.១៣៨។

vi. នៅខែមេសា ឬខែឧសភា ឆ្នាំ១៩៧៨ **យឹម ទិត្យ** បានដឹកនាំការប្រជុំនៅទួលម្ទេស ដែលមានការចូលរួមពីប្រជាជនប្រហែល ៥០នាក់ ហើយបានជំរុញឲ្យពួកគេខិតខំប្រឹងប្រែងបង្កើនផលស្រូវ[1075]។

vii. ក្នុងពេលប្រជុំមួយនៅខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៨ នៅសហករណ៍បឹងខ្ពុំ ស្រុកបាណន់ តំបន់ ១ **យឹម ទិត្យ** បានធ្វើបទបង្ហាញមួយអំពី *"គោលបំណងនៃការដឹកនាំរបស់គាត់"* និងបាននិយាយអំពីបញ្ហានានា ដែលពាក់ព័ន្ធនឹងការបង្កបង្កើនផល។ នៅឯការប្រជុំមួយទៀតដែលបានធ្វើឡើងនៅខែកញ្ញា ឬខែតុលា ឆ្នាំ១៩៧៨ នៅវត្តបាយដំរាំ ស្រុកបាណន់ តំបន់ ១ **យឹម ទិត្យ** បានបញ្ជាឲ្យប្រធានកង និងកម្មករដែលបានប្រមូលផ្តុំគ្នា ឲ្យយកចិត្តទុកចំពោះការបង្កបង្កើនផល[1076]។

viii. នៅឆ្នាំ១៩៧៨ តាម៉ុក និង **យឹម ទិត្យ** បានដឹកនាំការប្រជុំជាច្រើននៅផ្ទះ តាម៉ុក នៅខេត្តបាត់ដំបង ដែលពួកគេបានណែនាំឲ្យកម្មាភិបាលរាប់រយនាក់មកពីថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បី *"ដឹកនាំឲ្យបានរលូន រួបរួមសាមគ្គីគ្នា ហើយខិតខំប្រឹងប្រែងកសាងជាតិ"*[1077]។

*វិន័យ*

406. **យឹម ទិត្យ** បានចូលរួមចំណែកក្នុងការជំរុញការអនុវត្តវិន័យតឹងតែងសម្រាប់កម្មករ ជាពិសេសនៅទំនប់កង្ហត។

---

[1075] ឯកសារ **D219/943** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូម លិន ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ ERN 01415374 ឆ.១១, ERN 01415376-01415377 ឆ.២៩-ឆ.៣៦។

[1076] ឯកសារ **D219/368** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ិន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01110185-01110187 ឆ.៨៧-ឆ.៩០, ឆ.៩៣-ឆ.៩៥, ERN 01110198 ឆ.១៤៤។ ឯកសារ **D219/533** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ិន ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01153592-01153593 ឆ.១១-ឆ.១៤, ERN 01153595-01153596 ឆ.៣៦-ឆ.៣៨។

[1077] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008706 ឆ.៥៥-ឆ.៥៦។ ឯកសារ **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ERN 01095987-01095990 ឆ.១៣-ឆ.២២។ ឯកសារ **D219/835** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ERN 01329392 ឆ.៣៣-ឆ.៣៤ ERN 01329397-01329402 ឆ.៧៧, ឆ.៧៩-ឆ.៨៦, ឆ.៩៨-ឆ.៩៩, ឆ.១០៤-ឆ.១១០, ឆ.១១៣, ឆ.១១៦-ឆ.១២៦, ឆ.១៣០។

407. អតីតកម្មករម្នាក់នៅកងចល័តដែលមានមូលដ្ឋាននៅការដ្ឋានទំនប់កង្ហួតរយៈពេលពីរខែ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ បានរៀបរាប់អំពីរបៀបដែលប្រធានកងបានព្រមានប្រាប់កម្មករមិនឱ្យឈប់ធ្វើការនៅពេលដែល **យ៉ឹម ទិត្យ** ចុះទៅមើល ដោយសារអ្នកដែលឃើញថាមិនបានធ្វើការ នឹងត្រូវគេចោទថាជាមនុស្ស *"ខ្ជិល"* ហើយនឹងត្រូវយកចេញទៅបាត់។ ក្នុងអំឡុងពេលការប្រជុំមួយនៅការដ្ឋាន សាក្សីរម្លឹកថា **យ៉ឹម ទិត្យ** និង តាស៊ូ (ប្រធានការដ្ឋានទំនប់កង្ហួត) ដែលបានព្រមានប្រាប់កម្មករថា *"អ្នកណាដែលវិលមិនទាន់កង់ប្រវត្តិសាស្ត្រអី គេមិនទុកទេ"*។ សាក្សីលើកឡើងថា គាត់បានចាប់ផ្ដើមធ្វើការនៅការដ្ឋាននោះនៅខែកក្កដា ឆ្នាំ១៩៧៧។ ទោះជាយ៉ាងណាក្ដី ការប្រជុំដែល **យ៉ឹម ទិត្យ** និង តាស៊ូ បានដឹកនាំប្រហែលជាបានកើតឡើងមុនពេល តាស៊ូ ចូលមន្ទីរ ស-២១ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៧៧[1078]។ ហេតុនេះ សាក្សីមានការភាន់ច្រឡំពីខែដែលគេចាត់តាំងឱ្យគាត់ទៅធ្វើការនៅទំនប់នោះ។ សាក្សីលើកឡើងថា *"តែបើឃើញមុខ តាទិត្យ នៅពេលថ្ងៃ យប់ឡើងគឺនឹងមានបាត់ខ្លួនមនុស្សហើយ"*។ មនុស្សជាច្រើនពីកងល័តបានបាត់ខ្លួន។ ប្រធានកងបានរាយការណ៍អំពីអ្នកដែល *"ខ្ជិល"* ឬ *"មិនស្មោះត្រង់នឹងអង្គការ"* ហើយបន្ទាប់មក នៅពេលយប់មានទាហានមកចាប់ខ្លួនមនុស្សពីម្នាក់ទៅបីនាក់ ដែលគេលែងឃើញត្រឡប់មកវិញ[1079]។

408. បើតាមអតីតប្រធានកងចល័តម្នាក់នៅទំនប់កង្ហួតគឺថា ក្នុងពេលដែល **យ៉ឹម ទិត្យ** ទៅមើលការដ្ឋានជាញឹកញាប់នៅពាក់កណ្ដាលឆ្នាំ១៩៧៨ នោះ គាត់បានជួប យ៉េ ជាកម្មាភិបាលភូមិភាគនិរតីដែលជាប្រធានកងវរសេនាធំ និងទទួលខុសត្រូវកម្មករនៅក្នុងកងចល័តដែលមានចំនួនប្រហែល ៧០០-៨០០ នាក់។ ក្រោយពីការប្រជុំទាំងនោះចប់ភ្លាម យ៉េ បានណែនាំសាក្សីឱ្យខិតខំប្រឹងប្រែងធ្វើការ

---

[1078] ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (កាលបរិច្ឆេទដាក់ឯកសារ) EN ERN 01222421 (លេខរៀង ២១៨០ ខែក ពិន ហៅ ស៊ូ ប្រធានគណៈកម្មាធិការទំនាក់ទំនងព្រំប្រទល់កម្ពុជា-ថៃ ពីមុនធ្វើការជាអនុលេខាតំបន់ ៤ - ចូល ស-២១ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៧៧)។ ឯកសារ **D6.1.1013** របាយការណ៍ស្ដីពីការចាប់ខ្លួន ខែក ប៉ែន ហៅ ស៊ូ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៧៧ ERN 00174021។ ឯកសារ **D219/46** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ERN 01032221-01032223 ឆ.២៣-ឆ.២៤, ឆ.៣១-ឆ.៣៧, ឆ.៣៩-ឆ.៤០។ ឯកសារ **D219/239** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ERN 01080872-01080875 ឆ.២-ឆ.៣, ឆ.៥, ឆ.៧, ឆ.១០។

[1079] ឯកសារ **D219/46** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ERN 01032222 ឆ.២៥, ERN 01032223-01032224 ឆ.៤១-ឆ.៤៤។ ឯកសារ **D219/239** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ERN 01080873-01080875 ឆ.៤-ឆ.៥, ឆ.១៣-ឆ.១៤។

និងបញ្ជាឲ្យគាត់ប្រុងប្រយ័ត្នចំពោះសកម្មភាពខ្មាំង។ យ៉ េ បានប្រកាស *"ថា បើសិនជាមនុស្សឈឺញ៉ាកនោះ នឹងត្រូវចាត់ទុកថាជាសកម្មភាពមួយរបស់ខ្មាំង"*។ សាក្សីត្រូវបានតម្រូវឲ្យកំណត់អត្តសញ្ញាណ និងរបាយការណ៍អំពីមនុស្សទាំងនោះទៅថ្នាក់លើ ដើម្បីយកទៅអប់រំ[1080]។

*ការមើលខុសត្រូវរួមលើកម្លាំងការងារ*

409. ក្រោយពេលតែងតាំងគាត់ជាផ្លូវការទៅកាន់ភូមិភាគពាយ័ព្យ **យឹម ទិត្យ** បានផ្តល់ព័ត៌មានពីការបង្កបង្កើនផល និងលក្ខខណ្ឌការងារនៅតាមតំបន់ដែលគាត់គ្រប់គ្រង តាមរយៈប្រព័ន្ធរាយការណ៍ជាធម្មតារបស់ ប.ក.ក ហើយគាត់បានគ្រប់គ្រងទៅលើសហករណ៍ និងការដ្ឋាន តាមរយៈខ្សែចង្វាក់បញ្ជាជាធម្មតារបស់ ប.ក.ក ដោយសារបញ្ជាត្រូវបានបញ្ជូនចេញពីគាត់ទៅថ្នាក់ក្រោម ដែលរាយការណ៍ត្រឡប់មកវិញទៅតាមឋានានុក្រម[1081]។ ក្នុងនាមជាលេខាតំបន់ ១ **យឹម ទិត្យ** ជាអ្នកចាត់ចែងនូវការបែងចែកសម្ភារៈ និងបរិក្ខារនៅក្នុងតំបន់[1082]។ ទោះបីពុំមានភ័ស្តុតាងផ្ទាល់អំពីបញ្ហានេះនៅក្រៅតំបន់ ១ ក៏ដោយ តែមានភាពសមហេតុផលពីភាពប្រហាក់ប្រហែលដែលថាគាត់ក៏អាចមានសិទ្ធិអំណាចបែបនេះដែរ នៅតាមតំបន់ទាំងអស់ដែលគាត់មានមុខតំណែងជាលេខា។

410. សាក្សី មូល អេង ដែលជាអតីតលេខាស្រុកបវេល (តំបន់ ៣) បានទទួលបញ្ជាជាលាយលក្ខណ៍អក្សរពី **យឹម ទិត្យ** ដើម្បីឲ្យស្រុកផលិតស្រូវឲ្យបានបីតោនក្នុងមួយហិកតា។ បន្ទាប់មក បញ្ជាទាំងនេះត្រូវបានផ្សព្វផ្សាយទៅកម្មាភិបាលថ្នាក់ឃុំ និងភូមិ។ សាក្សីបានរាយការណ៍ទៅ **យឹម ទិត្យ** ជា

---

[1080] ឯកសារ **D219/117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប សឹង ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046461-01046462 ឆ.១៧-ឆ.២០, ឆ.៣១, ERN 01046466-01046468 ឆ.៦៧-ឆ.៧៥, ឆ.៧៨-ឆ.៨០, ឆ.៨៧-ឆ.៩០, ERN 01046470-01046472 ឆ.១០៨-ឆ.១២៦, ERN 01046474-01046476 ឆ.១៤៣-ឆ.១៥៦, ERN 01046478 ឆ.១៨១។

[1081] ឯកសារ **D118/290** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ វ៉ាច ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022369-01022370 ឆ.៥៧-ឆ.៦៤, ERN 01022376 ឆ.១១៨-ឆ.១១៩។ ឯកសារ **D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095247-01095248 ឆ.៧៥-ឆ.៨២, ERN 01095250 ឆ.៩៧-ឆ.៩៩ ERN 01095252 ឆ.១០៩, ERN 01095260 ឆ.១៦១-ឆ.១៦២, ERN 01095261 ឆ.១៧៤-ឆ.១៧៥, ERN 01095265 ឆ.២០០-ឆ.២០៣។ ឯកសារ **D219/222** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សេង ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01075734-01075735 ឆ.១២១-ឆ.១២២, ឆ.១២៥-ឆ.១២៧។ ឯកសារ **D101/1.1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ERN 00743545-00743546។ ឯកសារ **D219/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01066323 ឆ.៣៨។ ឯកសារ **D219/465** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ERN 01132084-01132085 ឆ.៤៤។

[1082] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037147 ឆ.៦៣។

រៀងរាល់សប្ដាហ៍ និងប្រចាំខែ តាមរយៈនីរសារ អំពី *"ដំណាំស្រូវ ឬក៏បញ្ហាដែលកើតឡើងពីការដាំដុះផ្សេងៗ"* ព្រមទាំងលក្ខខណ្ឌនានានៅតាមសហករណ៍។ សាក្សីបានប្រមូលព័ត៌មាននេះពីប្រធានឃុំនៅស្រុកនោះ។ ទំនាក់ទំនងការងារទាំងនេះបន្តធ្វើរហូតដល់ខែធ្នូ ឆ្នាំ១៩៧៨[1083]។

411. បើតាមសាក្សី ណុប ងឹម ដែលជាអតីតអនុលេខាស្រុកសំឡូត (តំបន់ ១) **យឹម ទិត្យ** បានណែនាំគាត់ឱ្យរាយការណ៍ពី *"ចំនួនប្រជាជន [នៅក្នុងស្រុក] ពីចំនួនអ្នកឈឺ និងថាតើប្រជាជនមានសម្លៀកបំពាក់ និងម្ហូបអាហារគ្រប់គ្រាន់ដែរឬអត់។* [គាត់] *ក៏បានទទួលសេចក្ដីណែនាំពីគាត់ផងដែរ [ដើម្បីរាយការណ៍] ថា តើប្រជាជននៅក្នុងស្រុកមានទំនាស់ជាមួយគ្នាដែរឬអត់ ហើយក្នុងករណីមានទំនាស់ ថ្នាក់ស្រុកត្រូវធ្វើការណែនាំកុំឱ្យមានទំនាស់គ្នាតទៅទៀត"*[1084]។ គណៈកម្មាធិការស្រុកផ្សេងទៀតនៅតំបន់ ១ ក៏ត្រូវបានណែនាំឱ្យរាយការណ៍ដូចគ្នាដែរ[1085]។

*៥.៣.៥.២. ការបោសសម្អាតភូមិភាគពាយ័ព្យ និងការកំណត់ជាគោលដៅលើក្រុមជាក់លាក់*

412. កម្មាភិបាលភូមិភាគនិរតីដែលដឹកនាំដោយ តាម៉ុក និង **យឹម ទិត្យ** ចាប់ផ្ដើមរៀបចំការបោសសម្អាតភូមិភាគពាយ័ព្យក្នុងអំឡុងឆ្នាំ១៩៧៦ ហើយបានបន្តការបោសសម្អាតរហូតដល់ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅខែមករា ឆ្នាំ១៩៧៩[1086]។

*ការចូលរួមចំណែករបស់ យឹម ទិត្យ ទៅក្នុងសហឧក្រិដ្ឋកម្មរួម មុនពេលគាត់ទទួលការតែងតាំងជាផ្លូវការនៅភូមិភាគពាយ័ព្យ នៅពាក់កណ្ដាលឆ្នាំ១៩៧៨*

413. សាក្សី សៅ ជាប់ ដែលជាអតីតប្រធានកងវរសេនាតូចឈរជើងនៅស្រុកគាស់ក្រឡ បានរម្លឹកពីការចូលរួមពីដំបូងៗរបស់ **យឹម ទិត្យ** ក្នុងការបោសសម្អាតភូមិភាគពាយ័ព្យដែលគាត់បានដឹង។

---

[1083] ឯកសារ **D219/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095241 ឆ.៤១, ERN 01095247-01095248 ឆ.៧៥-ឆ.៨២, ERN 01095250 ឆ.៩៧-ឆ.៩៩, ERN 01095252 ឆ.១០៩, ERN 01095260 ឆ.១៦១-ឆ.១៦២, ERN 01095261 ឆ.១៧៤-ឆ.១៧៥, ERN 01095265 ឆ.២០០-ឆ.២០៣។

[1084] ឯកសារ **D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008701 ឆ.៣១, ERN 01008704 ឆ.៤៤, ERN 01008707 ឆ.៦៣, ឆ.៦៥។ ឯកសារ **D219/298** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ERN 01095984-01095985។

[1085] ឯកសារ **D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008712 ឆ.៩២។

[1086] *សូមមើល ការអប់រំរៀនសូត្រ និងការសម្លាប់ "ខ្មាំង" និង "សមាសមភាពមិនល្អ" និងការកំណត់គោលដៅក្រុមជាក់លាក់* កថាខណ្ឌ ២៩៥។

គាត់បានរៀបរាប់ពីរបៀបដែល **យឹម ទិត្យ** និង តាម៉ុក ដឹកនាំការប្រជុំបួន ឬប្រាំដងក្នុងមួយខែ ក្នុងឆមាសទីមួយឆ្នាំ១៩៧៧ នៅមន្ទីរស្រុកគាស់ក្រឡ។ សាក្សីបានចូលរួមក្នុងការប្រជុំទាំងនោះជាមួយមេដឹកនាំយោធានៅស្រុកគាស់ក្រឡ មានឈ្មោះ អន (មេបញ្ជាការ) ប៉ក់ (អនុ) និង ថាច (សមាជិក)។ ការប្រជុំមានរយៈពេលពីរទៅបីម៉ោង ហើយផ្តោតទៅលើការស្រាវជ្រាវរកគិញវៀតណាម និង សេ.អ៊ី.អា[1087]។ ក្រោយពេលប្រជុំ សាក្សីបានសង្កេតឃើញថា យោធាស្រុកគាស់ក្រឡធ្វើការចាប់ខ្លួននិងសម្លាប់[1088]។ ជាពិសេស គាត់បានឃើញ អន, ប៉ក់ និង ថាច ចាប់ខ្លួន និងសម្លាប់អ្នកដែលត្រូវបានចោទថាជាខ្មាំង នៅកន្លែងមួយមានឈ្មោះថា ឈ្លាវ ដែលស្ថិតនៅខាងត្បូងភ្នំធិបតី ទោះបីទីកន្លែងនោះមិនត្រូវបានចោទប្រកាន់ជាទីកន្លែងឧក្រិដ្ឋកម្មក៏ដោយ ហើយបានប៉ាន់

[1087] ឯកសារ **D219/763** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244119 ឆ.៧-ឆ.៨, ERN 01244120 ឆ.១៦-ឆ.១៧, ERN 01244121 ឆ.២៧-ឆ.២៨, ERN 01244124 ឆ.៥០-ឆ.៥១, ERN 01244126-01244127 ឆ.៦៥-ឆ.៧១, ERN 01244128 ឆ.៧៩, ឆ.៨១, ERN 01244131-01244137 ឆ.១០៥-ឆ.១១៨, ឆ.១២០-ឆ.១២៤, ឆ.១២៦-ឆ.១៣៥, ឆ.១៣៨-ឆ.១៤០, ឆ.១៤២, ឆ.១៤៤។ ឯកសារ **D219/956** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ERN 01425223 ឆ.៣៩, ERN 01425225 ឆ.៥១។ ឯកសារ **D219/980** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ ERN 01477598-01477599 ឆ.៩-ឆ.១៥, ERN 01477601 ឆ.២៣, ឆ.២៦។ ឯកសារ **D219/981** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ERN 01477610-01477611 ឆ.២៥-ឆ.២៦, ឆ.៣០។ ឯកសារ **D219/982** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477629-01477631 ឆ.៣៣-ឆ.៣៤, ឆ.៣៧-ឆ.៣៨, ឆ.៤០-ឆ.៤៧។ ឯកសារ **D219/983** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ERN 01477636-01477639 ឆ.៣-ឆ.៧, ឆ.១០-ឆ.១១, ឆ.១៣-ឆ.១៤, ឆ.១៦-ឆ.២៥, ERN 01477641 ឆ.៣១, ERN 01477643 ឆ.៤៤-ឆ.៤៧។ *សូមមើលផងដែរ* ឯកសារ **D219/984** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ ERN 01477653-01477654 ឆ.៨-ឆ.១០។

[1088] ឯកសារ **D219/982** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477628 ឆ.២៩-ឆ.៣០។ ឯកសារ **D219/983** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ERN 01477641-01477643 ឆ.៣៣-ឆ.៣៤, ឆ.៣៦-ឆ.៤០, ឆ.៤២។

ស្មានថា មានមនុស្សជាងមួយពាន់នាក់រួមទាំង *"ប្រជាជនថ្មី"* ផង ត្រូវបានសម្លាប់នៅទីនោះ[1089]។ អន បានប្រាប់សាក្សីថា **យឹម ទិត្យ** ជាអ្នកចាត់តាំងឲ្យគាត់ធ្វើការសម្លាប់[1090]។

414. សាក្សីក៏បានលើកឡើងដែរថា នៅពេលគាត់សង្កេតឃើញ តាម៉ុក និង **យឹម ទិត្យ** បានចុះត្រួតពិនិត្យនៅមន្ទីរសន្តិសុខមួយនៅគាស់ក្រឡ ក្រោយពេលប្រជុំមួយដែលបានធ្វើនៅមន្ទីរស្រុកគាស់ក្រឡ (ដោយសារ រឿងនេះបានកើតឡើងនៅមុនពាក់កណ្ដាលឆ្នាំ១៩៧៨ មុនពេលបង្កើតទីតាំងមន្ទីរសន្តិសុខគាស់ក្រឡដែលត្រូវបានចោទប្រកាន់[1091] ហើយហេតុនេះ ប្រហែលជានៅមន្ទីរសន្តិសុខមួយផ្សេងទៀត) ព្រមទាំងមន្ទីរសន្តិសុខមួយនៅចកកកោះ ក្នុងតំបន់ ៤ នៅពេលគាត់កំពុងធ្វើស្រែនៅជិតនោះ[1092]។

415. សាក្សី សុខ ជាតិ ដែលជាក្មួយប្រុសរបស់ តាប៉ែត អតីតលេខាតំបន់ ១ បានលើកឡើងថា ក្រោយពេល **យឹម ទិត្យ** បានទៅដល់តំបន់ ១ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ *"ការសម្លាប់មនុស្សកាន់តែខ្លាំងនៅតំបន់ ១ ... មនុស្សជាច្រើនបាត់ខ្លួន"*។ គាត់បានលើកឡើងថា *"ឲ្យតែមនុស្សសម្លាប់ទាំងអស់ សម្លាប់ទាំងកូនជាំទៀតផង។ ... អត់មាននរណារួចទេ"*[1093]។ ក្រោមការគ្រប់គ្រងរបស់ **យឹម ទិត្យ** កម្មាភិបាលថ្នាក់ភូមិភាគ និងថ្នាក់តំបន់ រួមទាំង តាវ៉ាញ លេខាតំបន់ ១ មុន តាប៉ែត ហើយក្រោយ

---

[1089] ឯកសារ **D219/982** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477628-01477631 ឆ.៣១-ឆ.៣៤, ឆ.៣៧-ឆ.៣៨, ឆ.៤០-ឆ.៤៧។ ឯកសារ **D219/983** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ERN 01477638 ឆ.១៤-ឆ.១៧, ERN 01477641-01477642 ឆ.៣៣-ឆ.៣៤, ឆ.៣៦-ឆ.៤១។

[1090] ឯកសារ **D219/982** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477628 ឆ.២៦-ឆ.៣០។ ឯកសារ **D219/983** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ERN 01477643 ឆ.៤២។ *សូមមើលផងដែរ* ឯកសារ **D219/763** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244132 ឆ.១១០។

[1091] *សូមមើល មន្ទីរសន្តិសុខគាស់ក្រឡ* កថាខណ្ឌ ៥៨៦។

[1092] ឯកសារ **D219/983** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ERN 01477638-01477639 ឆ.១៩, ឆ.២៤-ឆ.២៥, ERN 01477643-01477645 ឆ.៤៧-ឆ.៥៨, ERN 01477646 ឆ.៦១។ *សូមមើលផងដែរ* ឯកសារ **D219/982** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ERN 01477626 ឆ.១៩។

[1093] ឯកសារ **D219/689** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01205202-01205203 ឆ.១៧, ឆ.២០, ERN 01205223-01205224 ឆ.១០៥-ឆ.១០៧។ ឯកសារ **D219/654** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ERN 01196530-01196531 ឆ.៥-ឆ.៦, ERN 01196544-01196545 ឆ.៧៥, ឆ.៧៨។

មកពូរបស់សាក្សីគឺ តាប៉ែត រួមជាមួយលេខាភូមិភាគពាយ័ព្យ តាញឹម និងខ្សែបណ្ដាញរបស់ពួកគេ ត្រូវបានចាប់ខ្លួនជាប្រព័ន្ធ និងអ្នកទាំងនោះជាច្រើនត្រូវបានសម្លាប់[1094]។ បើតាមបញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរ ស-២១ តាវ៉ាញ បានចូលទួលស្លែងនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧[1095]។

416. នៅចុងឆ្នាំ១៩៧៧ សាក្សីបានចូលរួមការប្រជុំមួយនៅវត្តបាណន់ដែលដឹកនាំដោយ **យឹម ទិត្យ** ដែលបានដាស់តឿនប្រជាជនរាប់រយនាក់ដែលបានចូលរួម មកពីគណៈកម្មាធិការស្រុក តំណាងកងចល័ត និងតំណាងយុវជនយុវនារី ដើម្បីធ្វើតាមបញ្ជាអង្គការ[1096]។

417. នៅខែសីហា ឆ្នាំ១៩៧៧ សាក្សីដដែលនេះបានទទួលការតែងតាំងឱ្យគ្រប់គ្រងកងចល័តមួយរបស់តំបន់ នៅទួលម្ទេស។ គាត់បានរៀបរាប់ថាបានចូលរួម *"ប្រជុំជីវភាពប្រចាំថ្ងៃ"* ដែលគាត់ទទួលខុសត្រូវរាយការណ៍ពីចំនួនកម្មករឈឺ និងសមិទ្ធផលការងារប្រចាំថ្ងៃទៅថ្នាក់លើរបស់គាត់គឺ សមមិត្ត ខេន (ជាកម្មាភិបាលភូមិភាគពាយ័ព្យ ដែលបានរាយការណ៍ផ្ទាល់ទៅ **យឹម ទិត្យ**)។ សាក្សីលើកឡើងថា *"ពីរបីថ្ងៃម្ដង"* មួយរយៈខ្លី ក្រោយពីការប្រជុំជីវភាព ខេន បញ្ជាឱ្យកងឈ្លបចាប់ខ្លួន *"មនុស្សប្អូនដប់នាក់ ... ទៅរៀនសូត្រ"* អ្នកទាំងនេះត្រូវបានចោទថាជាខ្មាំង ដោយសារពួកគេធ្វើឱ្យបែកបាក់របស់របរ ឬរអ៊ូរទាំ ហើយចុងក្រោយពួកគេបានបាត់ខ្លួន។ សាក្សីលើកឡើងថា គាត់ទទួលខុសត្រូវរៀបចំបញ្ជីឈ្មោះមនុស្ស ដែលត្រូវបានជ្រើសរើសយកទៅអប់រំ គាត់ក៏លើកឡើងផងដែរថា មេបញ្ជាការគាត់បានបញ្ជាមិនឱ្យគាត់កត់ត្រាក្នុងរបាយការណ៍លាយលក្ខណ៍អក្សរចំពោះអ្នកដែលនឹងត្រូវយកមកអប់រំនោះទេ។ នៅពេល ខេន ប្រាប់សាក្សីថា *"អង្គការថ្មីគេមកគ្រប់គ្រង"* សាក្សីបានសន្និតថា អង្គការថ្មីនេះសំដៅដល់ **យឹម ទិត្យ**។ សាក្សីមិនបានលើកឡើងពីពេលនៃការប្រជុំទេ ទោះបីការប្រជុំទាំងនោះហាក់ដូចជាបានធ្វើឡើងពីចុងខែសីហា ឆ្នាំ១៩៧៧ រហូតដល់ខែសីហា ឆ្នាំ១៩៧៨ ក៏ដោយ ដោយសារនៅពេលនោះ គាត់ឈរជើងនៅទួលម្ទេស ហើយសាក្សី

[1094] ឯកសារ **D219/654** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ERN 01196536 ធ.៣៦ ERN 01196542-01196545 ធ.៦៩, ធ.៧៣, ធ.៧៥, ធ.៧៨។ ឯកសារ **D219/689** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01205201 ធ.៧-ធ.១០, ERN 01205202-01205204 ធ.១៧-ធ.២០, ធ.២៤-ធ.២៥, ERN 01205220 ធ.៩២។

[1095] ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (កាលបរិច្ឆេទដាក់ឯកសារ) EN ERN 01222369 លេខរៀង ៩១៣។

[1096] ឯកសារ **D219/654** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ERN 01196544 ធ.៧៥-ធ.៧៦។ ឯកសារ **D219/689** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01205207-01205210 ធ.៤០-ធ.៥៦។

លើកឡើងថា ការប្រជុំ និងក្រោយមកមានការចាប់ខ្លួនបានធ្វើឡើងក្រោយពេល **យឹម ទិត្យ** បានដឹកនាំការប្រជុំនៅវត្តបាណន់នៅចុងឆ្នាំ១៩៧៧[1097]។

418. សាក្សី ហួន ជឿម ជាអតីតកម្មាភិបាលភូមិភាគពាយ័ព្យ បានឮពីទាហានភូមិភាគម្នាក់ថា **យឹម ទិត្យ** បានកោះប្រជុំប្រធានកងវរសេនាតូចពីរនាក់ ដែលទទួលខុសត្រូវនៅរោងចក្រស្កករសកំពង់គល់ យកទៅអប់រំនៅបាត់ដំបង ហើយនៅពេលពួកគេទៅដល់ភ្លាម ក៏ត្រូវបានចាប់ខ្លួនតែម្តង ហើយជំនួសដោយ យ៉ាន ជាកម្មាភិបាលភូមិភាគនិរតី[1098]។ សាក្សីនេះមិនបានលើកឡើងពីពេលដែលឧបទ្ទវហេតុ នេះកើតឡើង ឬថាតើគាត់បានឮរឿងនេះពីពេលណាទេ។ ថ្វីត្បិតតែយ៉ាងនេះក្តី សាក្សីជាច្រើនលើកឡើងថា យ៉ាន ត្រូវបានតែងតាំងឱ្យកាន់មុខតំណែងមួយរយៈខ្លី ក្រោយពេលកម្មាភិបាលភូមិភាគ
ពាយ័ព្យដែលគ្រប់គ្រងទីតាំងនោះត្រូវបានដកចេញនៅចុងឆ្នាំ១៩៧៧ ហេតុនេះប្រធានកងវរសេនាតូចទាំងពីរនាក់នោះទំនងជាត្រូវបានចាប់ខ្លួន ក្នុងពេលជាមួយគ្នានោះហើយមើលទៅ[1099]។

*ការចូលរួមចំណែករបស់ យឹម ទិត្យ ទៅក្នុងសហឧក្រិដ្ឋកម្មរួម ក្រោយពេលគាត់ទទួលការតែងតាំងផ្លូវការនៅភូមិភាគពាយ័ព្យ នៅពាក់កណ្តាលឆ្នាំ១៩៧៨*

419. ក្រោយពេលគាត់ទទួលការតែងតាំងផ្លូវការនៅភូមិភាគពាយ័ព្យនៅខែមិថុនា ឆ្នាំ១៩៧៨ **យឹម ទិត្យ** បានប្រកាសថា គាត់បានមកដល់ហើយ ដើម្បីជំនួយសកម្មាភិបាលភូមិភាគពាយ័ព្យ ដោយសារពួកគេជាជនក្បត់ និងមានទំនាក់ទំនងជាមួយវៀតណាម[1100]។ ក្នុងអំឡុងពេលប្រជុំមួយប្រហែលបីខែ

---

[1097] ឯកសារ **D219/654** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ERN 01196531-01196532 ឆ.៨-ឆ.១៤, ERN 01196534-01196538 ឆ.៣១-ឆ.៣៣, ឆ.៣៥, ឆ.៣៧-ឆ.៤៧, ERN 01196541 ឆ.៦៣-ឆ.៦៥, ERN 01196544 ឆ.៧៥-ឆ.៧៦។ ឯកសារ **D219/689** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01205200 ឆ.៤, ERN 01205203 ឆ.២១-ឆ.២៣, ERN 01205205-01205209 ឆ.២៩, ឆ.៣៥, ឆ.៤០-ឆ.៤៧, ERN 01205211 ឆ.៥៧, ERN 01205218-01205219 ឆ.៨២, ឆ.៨៤, ឆ.៨៦, ERN 01205220 ឆ.៩០។

[1098] ឯកសារ **D118/106** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួ ជឿម ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ ERN 00951902-00951903 ឆ.២, ERN 00951904-00951905 ឆ.១២, ឆ.១៨។

[1099] *សូមមើល ការដ្ឋានរោងចក្រស្ករសកំពង់គល់* កថាខណ្ឌ ៧៣៩។

[1100] ឯកសារ **D118/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទីម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ERN 00951928 ឆ.១៨, ERN 00951930-00951931 ឆ.៣៧, ឆ.៤១។ ឯកសារ **D118/136** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៉ា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ERN 00960664-00960665 ឆ.១៣-ឆ.១៤, ERN 00960668 ឆ.៤០។ *សូមមើលផងដែរ* ឯកសារ **D118/77** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណង នី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ERN 00934384-00934385 ឆ.១, ERN 00934389 ឆ.២៩-ឆ.៣០។

មុនរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅឃុំបាយដំរាំ ដែលនៅក្នុង ឬក្បែរស្រុកសង្កែនៅតំបន់ ១ **យឹម ទិត្យ** លើកឡើងថា ហើយកម្មាភិបាលភូមិភាគនិរតីជាសហការីគាត់បានសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ ដោយសារពួកគេ *"ក្បាលយួនខ្លួនខ្មែរ"*[1101]។ នៅឯការប្រជុំមួយនៅក្បែរទំនប់កង្ហត ដែលមានការចូលរួមពីកម្មករកងចល័តរាប់ពាន់នាក់ និងដែលរៀបចំដោយ **យឹម ទិត្យ** មានការប្រកាសថា *"តាកៅត្រូវបានគេចាប់យកទៅសម្លាប់នៅម៉ុងចិន។ តាប៉េត ត្រូវបានគេចាប់ខ្លួនហើយ"*[1102]។ ទោះបីសាក្សីលើកឡើងថា ការប្រជុំនេះបានធ្វើឡើងនៅឆ្នាំ១៩៧៧ ក៏ដោយ តែ តាប៉ែត ត្រូវបានចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៨ ហេតុនេះ ការប្រជុំនោះប្រហែលធ្វើឡើងក្រោយពេលនោះ ហើយសាក្សីអាចមានការភាន់ច្រឡំអំពីកាលបរិច្ឆេទ[1103]។

420. ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៨ **យឹម ទិត្យ** បានធ្វើដំណើរទៅទូទាំងភូមិភាគពាយ័ព្យ និងបានដឹកនាំការប្រជុំនានា បញ្ជាកម្មាភិបាលថ្នាក់ក្រោមរាប់រយនាក់ចាប់ពីថ្នាក់កងដល់ថ្នាក់តំបន់ និងប្រជាជនសាមញ្ញជាច្រើនក្រុមឱ្យបន្តប្រុងប្រយ័ត្នចំពោះសកម្មភាពខ្មាំង នៅតាមមូលដ្ឋាន និងរាយការណ៍ពីខ្មាំងទៅថ្នាក់លើ ដើម្បីយកទៅអប់រំ ឬ *"កម្ទេច"*[1104]។ សកម្មភាពខ្មាំងរួមមាន ការក្បត់របប ការ

---

[1101] ឯកសារ **D118/77** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ERN 00934384-00934385 ឆ.១, ERN 00934388-00934389 ឆ.២៤-ឆ.២៥, ឆ.២៩-ឆ.៣០។

[1102] ឯកសារ **D219/538** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿន ម៉ត ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ ERN 01155822-01155823 ឆ.១៤-ឆ.១៥, ឆ.១៧-ឆ.១៩, ERN 01155825-01155828 ឆ.៣០, ឆ.៣២-ឆ.៣៣, ឆ.៣៤, ឆ.៤៤, ឆ.៤៨-ឆ.៤៩។

[1103] ឯកសារ **D118/136** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ERN 00960667-00960668 ឆ.៣៧។ *សូមមើលផងដែរ ការតែងតាំង យឹម ទិត្យ ទៅក្នុងតំណែងនៅភូមិភាគពាយ័ព្យ នៅអំឡុងខែមិថុនា ឆ្នាំ ១៩៧៨* កថាខណ្ឌ ៣៦២។

[1104] ឯកសារ **D118/245** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990642-00990643 ឆ.៤ ERN 00990644 ឆ.៧-ឆ.៨, ឆ.១២, ERN 00990645 ឆ.១៦-ឆ.១៧។ ឯកសារ **D219/117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប សឹង ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046461-01046462 ឆ.១៩-ឆ.២០, ឆ.២៤, ERN 01046466-01046469 ឆ.៦៧-ឆ.៧៥, ឆ.៧៨-ឆ.៧៩, ឆ.៨៩-ឆ.៩០, ឆ.៩២-ឆ.១០០, ERN 01046474-01046475 ឆ.១៤៣-ឆ.១៤៨។ ឯកសារ **D219/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040093-01040094 ឆ.៣។ ឯកសារ **D219/763** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244119 ឆ.៧-ឆ.៨, ERN 01244120 ឆ.១៦-ឆ.១៧, ERN 01244121 ឆ.២៧-ឆ.២៨, ERN 01244124 ឆ.៥០-ឆ.៥១, ERN 01244126-01244127 ឆ.៦៥-ឆ.៧១, ERN 01244128 ឆ.៧៩, ERN 01244131-01244134 ឆ.១០៤-ឆ.១១៨, ឆ.១២០-ឆ.១២៤។ *សូមមើលផងដែរ* ឯកសារ **D118/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទឹម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ERN 00951928-00951929 ឆ.១៨-ឆ.២២។

ប្រព្រឹត្តិកំហុសធ្ងន់ធ្ងរ ខុសសីលធម៌ និងការលួច[1105]។ **យឹម ទិត្យ** បានព្រមានអ្នកចូលរួមពីខ្មាំងផ្ទៃក្នុង *"ស៊ីរ៉ុង"* ខាងក្នុង រួមជាមួយខ្មាំងពីក្រៅ ជាពិសេសវៀតណាម *"យួន"* សេ.អ៊ី.អា និង កា.ហ្សេ.បេ[1106] ។ ក្រោយមក លេខាស្រុកបានផ្សព្វផ្សាយការព្រមានទាំងនេះទៅថ្នាក់ក្រោម[1107]។ **យឹម ទិត្យ** បានចេញបញ្ហាទាំងនេះ និងការព្រមាន នៅឯការប្រជុំនានាដូចខាងក្រោម៖

i. នៅឆ្នាំ១៩៧៨ តាម៉ុក និង **យឹម ទិត្យ** បានដឹកនាំការប្រជុំជាច្រើននៅស្រុកសំឡូត ដែលពួកគាត់បានណែនាំឲ្យកម្មាភិបាលរាប់រយនាក់ពីថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ ធ្វើការប្រុងប្រយ័ត្នពីខ្មាំងដែលលាក់ខ្លួននៅតាមអង្គភាពពួកគេ និងរាយការណ៍ទៅថ្នាក់លើ ប្រសិនបើ

---

[1105] ឯកសារ **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ERN 01095989-01095990 ឆ.១៩-ឆ.២២។ ឯកសារ **D219/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040093-01040095 ឆ.៣, ឆ.៧។ ឯកសារ **D219/763** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244119 ឆ.៧-ឆ.៨, ERN 01244124 ឆ.៥០-ឆ.៥១, ERN 01244126-01244127 ឆ.៦៥-ឆ.៧១, ERN 01244128 ឆ.៧៩, ERN 01244131-01244134 ឆ.១០៤-ឆ.១១៨, ឆ.១២០-ឆ.១២៤។ ឯកសារ **D219/654** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ERN 01196531-01196532 ឆ.៨-ឆ.១៤, ERN 01196534-01196538 ឆ.៣១-ឆ.៣៣, ឆ.៣៥។ ឯកសារ **D118/245** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ចន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990645 ឆ.១៦-ឆ.១៧។ ឯកសារ **D219/533** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ិន ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01153592-01153593 ឆ.១១-ឆ.១៤, ERN 01153595-01153596 ឆ.៣៦-ឆ.៣៨, ERN 01153604-01153596 ឆ.១០១-ឆ.១១១។

[1506] ឯកសារ **D118/291** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃិន សួរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022434 ធ.១០១ ERN 01022435 ធ.១១០។ ឯកសារ **D118/203** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ERN 00979206 ធ.៤០ ERN 00979206 ធ.៤៩ (គឺនៅក្នុងភូមិស្តែងនៅដើមឆ្នាំ១៩៧៨ សូមមើល ERN 00979202 ធ.៤ ERN 00979207 ធ.៥៦)។ ឯកសារ **D118/203** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ERN 00979206 ធ.៥០។

[1507] ឯកសារ **D118/291** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃិន សួរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022436 ធ.១១២-ធ.១១៣។

[1508] ឯកសារ **D219/482** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាច សែម ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ERN 01136304 ធ.៥ (ចំពោះពេលវេលានៃការផ្លាស់ទី នៅក្នុង ខែមិថុនា ឆ្នាំ១៩៧៨ សូមមើល ERN 01136304 ធ.១ ធ.៤-ធ.៥)។ ឯកសារ **D219/449** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129734 ធ.១៥-ធ.១៦ (នៅពេលមួយក្រោយ ខែមេសា ឬ ខែឧសភា ឆ្នាំ១៩៧៨ សូមមើល ERN 01129732 ធ.១)។

[1509] ឯកសារ **D219/449** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129734 ធ.១៤ ERN 01129734 ធ.៣៧-ធ.៣៩។

ហោចណាស់ ខ្មែរក្រោមមួយក្រុមបានចេញពីកម្ពុជាក្រោមទៅដល់ទីនោះ ត្រូវបានបញ្ជូនទៅឃុំកំពែងក្រោយពេលនៅភូមិស្ពែងបាន ២ ឬ ៣ ខែ[1510]។

558. ក្រោយពេលនាំទៅវត្តស្ពែង ខ្មែរក្រោមត្រូវបានប្រគល់ឲ្យទៅប្រធានភូមិ និងអនុប្រធានភូមិ ហើយបានបែងចែកទៅតាមកងការងារ[1511]។ ពួកគេត្រូវបានគេដាក់នៅក្នុងវត្ត ឬអគារសាលារៀន[1512]។ អ្នកដែលបែងចែកចូលកងទាំងនោះពុំអនុញ្ញាតឲ្យទៅលេងផ្ទះនៅក្នុងភូមិ ឬមិនឲ្យចាកចេញពីភូមិឡើយ។ កងឈ្លបបានតាមដានការដើរហើររបស់ពួកគេ[1513]។

559. ភ័ស្តុតាងអំពីនរណារស់នៅក្នុងភូមិនៅពេលណាពុំឃើញមានច្បាស់លាស់នោះទេ។ ខ្មែរក្រោមពីរនាក់ដែលរស់នៅក្នុងភូមិស្ពែងក្នុងឆ្នាំ១៩៧៨ លើកឡើងថា មានតែមនុស្សដែលជម្លៀសពីកម្ពុជា

---

[1510] ឯកសារ **D118/203** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ERN 00979207 ឆ. ៥៦។

[1511] ឯកសារ **D118/291** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃិន សួរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022437-01022441 ឆ.១២៦ ឆ.១២៩-ឆ.១៣០ ឆ.១៣៨ ឆ.១៤២។ ឯកសារ **D118/253** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គង់ សំណាង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ERN 00993596 ឆ.២៣-ឆ.២៤ ERN 00993599 ឆ.៤៩។ ឯកសារ **D118/203** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ERN 00979206 ឆ.៥១ ERN 00979209 ឆ.៧៨។ ឯកសារ **D219/449** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129735 ឆ.២៣។ ឯកសារ **D219/482** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឡាច សែប ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ERN 01136310 ឆ.៦៤-ឆ.៦៥។

[1512] ឯកសារ **D118/203** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ERN 00979202 ឆ. ៤។ ឯកសារ **D118/253** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គង់ សំណាង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ERN 00993595 ឆ.២១។ ឯកសារ **D118/291** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃិន សួរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022434 ឆ.១០១។ ឯកសារ **D219/449** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129736 ឆ.២៦ ERN 011297337 ឆ.៣៤ ឆ.៤០។

[1513] ឯកសារ **D118/203** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ERN 00979207 ឆ. ៦០។ ឯកសារ **D219/449** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129736 ឆ.៣០។ ឯកសារ **D219/482** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឡាច សែប ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ERN 01136310 ឆ.៦៥។

ក្រោមប៉ុណ្ណោះដែលស្នាក់នៅក្នុងភូមិ[1514]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់អះអាងថា ប្រហែលជាចាប់ពីខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៨ ប្រជាជនមូលដ្ឋានរស់នៅក្នុងភូមិ ខណៈខ្មែរក្រោមនៅក្នុងក្រុមគាត់ត្រូវបានគេឱ្យរស់នៅក្នុងវត្ត[1515]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតលើកឡើងថា ទោះបីជាភូមិគ្មានមនុស្សនៅពេលគាត់បានទៅដល់ប្រហែលជាក្នុងខែឧសភា ឬមិថុនា ក្នុងឆ្នាំ១៩៧៨ ក៏ដោយ ក៏នៅពេលមួយក្រោយប្រជាជនមូលដ្ឋាន *"ពីកន្លែងផ្សេងទៀត"* ត្រូវបានបញ្ជូនទៅភូមិស្ពែងដែរនោះដើម្បីធ្វើការជាមួយខ្មែរក្រោម[1516]។ គាត់ចងចាំថា នៅពេលនោះ មានខ្មែរក្រោមប្រហែល ១០០ នាក់ នៅភូមិស្ពែង ហើយជារួមមានប្រជាជនរាប់រយនាក់រស់នៅក្នុងភូមិ[1517]។

*ការកាប់សម្លាប់*

560. នៅក្នុងវត្តស្វ័យទិតៀនក្នុងភូមិស្ពែងក្នុងពាក់កណ្តាល ឬចុងឆ្នាំ១៩៧៨ ប្រធានភូមិបានសុំឱ្យខ្មែរក្រោមមកជួបកត់ឈ្មោះនៅក្នុងបញ្ជីដោយឡែកចំនួនពីរ មួយសម្រាប់អ្នកចង់ត្រឡប់ទៅកម្ពុជាក្រោមវិញ និងមួយទៀតសម្រាប់អ្នកដែលចង់នៅ។ នៅល្ងាចនោះ អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីទី១ ត្រូវបានដឹកតាមរទេះសេះចេញទៅ ហើយពុំដែលឃើញវិលត្រឡប់មកវិញនោះទេ[1518]។ នៅក្នុងកិច្ចប្រជុំបែបនេះមួយទៀតនៅក្នុងឆ្នាំ១៩៧៨ *"ខ្មែរក្រហម"* បានព្រមានខ្មែរក្រោមកុំឱ្យរត់ទៅ

---

[1514] ឯកសារ **D118/203** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ERN 00979204 ឆ. ៥៤។ ឯកសារ **D118/253** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សំណាង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ERN 00993597 ឆ.៣៧ ERN 00993599 ឆ.៤៩។

[1515] ឯកសារ **D118/291** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃិន សួរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022438 ឆ.១២៩ ERN 01022440 ឆ.១៣៧-ឆ.១៣៨។

[1516] ឯកសារ **D219/449** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129736 ឆ.២៦ ERN 01129736 ឆ.៣៤ ឆ.៣៧-ឆ.៤០ ERN 01129737ឆ.៤១ ERN 01129737 ឆ.៤១ ឆ.៤៣ (ចំពោះពេលវេលា សូមមើល ERN 01129734 ឆ.១៦)។

[1517] ឯកសារ **D219/449** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129736 ឆ.៣៤។

[1518] ឯកសារ **D118/291** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃិន សួរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022443 ឆ.១៥៤ សូមមើល *ទាក់ទងពេលវេលា* ERN 01022444 ឆ.១៦១។

វៀតណាម។ ពួកគេបានប្រកាសថា ខ្មែរក្រោមដែលរត់គេចទៅវៀតណាមគឺជា *"ខ្មែរដែលមានក្បាលយួនខ្លួនខ្មែរ"* ដែលត្រូវកម្ចាត់ចោល ហើយមិនគួរទុកជីវិតឲ្យនរណាម្នាក់ឡើយ[1519]។

561. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់រម្លឹកឡើងវិញថា នៅចុងឆ្នាំ១៩៧៨ មានបុរសខ្មែរក្រោម ៣ នាក់ ត្រូវបានសម្លាប់នៅវត្តស្លែង ដោយ *"ខ្មែរក្រហម"* ដោយសារបានលួចគោ។ ដោយសារឃ្លាន ពួកគេបានលួចសម្លាប់គោមួយក្បាលក្នុងពេលឃ្វាលគោលនោះ ហើយបានលាក់សាច់នៅក្នុងព្រៃ[1520]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានហូបសាច់គោនោះ ប៉ុន្តែមិនច្បាស់ថាតើគាត់បានឃើញបុរសទាំងបីនាក់នោះត្រូវបានគេសម្លាប់ ឬយ៉ាងណានោះឡើយ[1521]។ សាក្សីម្នាក់ដែលនៅភូមិស្លែងរយៈពេល ១ ទៅ ៣ ខែ នៅដើមឆ្នាំ១៩៧៨ លើកឡើងថាអ្នកដែលមិនព្រមទៅធ្វើការ ពុំដែលឃើញមកវិញនោះទេ ហើយការសន្និដ្ឋានសមហេតុផលមួយគឺថាពួកគេត្រូវបានគេសម្លាប់អស់ហើយ[1522]។ ប្រហែលជាមួយខែក្រោយមក ពួកគេទៅដល់ភូមិស្លែងក្នុងខែមេសា ឬឧសភា ឆ្នាំ១៩៧៨ បងប្រុសម្នាក់ និងកូនពីរនាក់របស់អ្នកដាក់ពាក្យសុំទាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបាត់ខ្លួនរហូតក្រោយគេប្រាប់ថា គេនឹងបញ្ជូនពួកគាត់ទៅធ្វើការកន្លែងផ្សេងវិញ[1523]។ ទោះបីជាយ៉ាងនេះក្តី វាពុំបង្ហាញច្បាស់ថាតើពួកគេត្រូវបានសម្លាប់នៅភូមិស្លែងឬនៅកន្លែងផ្សេងនោះទេ។

562. នៅចុងឆ្នាំ១៩៧៨ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានប្រទះឃើញឆ្អឹងមនុស្សជាច្រើនគំនរនៅក្នុងព្រៃក្រោយវត្ត នៅជើងភ្នំប៉ែកក្លៅសាន។ ទិដ្ឋភាពនៃការឃើញគំនរឆ្អឹងដែលគាត់

[1519] ឯកសារ **D118/253** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សំណាង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ERN 00993603 ឆ.៨៤។

[1520] ឯកសារ **D118/253** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សំណាង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ERN 00993598 ឆ.៤៥-ឆ.៤៦។

[1521] ឯកសារ **D118/253** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សំណាង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ERN 00993598 ឆ.៤៥។

[1522] ឯកសារ **D118/203** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌឹក ប៉ែត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ERN 00979209 ឆ.៧៨-ឆ.៨០។

[1523] ឯកសារ **D219/449** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យែម យោន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ERN 01129734 ឆ.១៧ ឆ.២០ ERN 01129735 ឆ.២១ (សូមមើលទាក់ទងពេលវេលាERN 01129732 ឆ.១ ERN 01129734 ឆ.១៥)។

ឃើញនោះមិនច្បាស់[1524]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតបានឃើញរណ្តៅមួយពេញដោយលលាដ៍ក្បាល នៅពេលគាត់កំពុងរកគោគាត់ដែលបានបាត់នៅជិតវត្តស្លែង ប្រហែលជាក្រោយខែឧសភា ឆ្នាំ១៩៧៨។ លលាដដែលគាត់ឃើញនោះមានខ្លះរលួយ និងខ្លះមិនទាន់រលួយ[1525]។ សាក្សីម្នាក់ទៀតដែលពុំមែនជាខ្មែរក្រោមបានឃើញសាកសពនៅចុងឆ្នាំ១៩៧៨ ក្នុងពេលគេជម្លៀសកាត់ភូមិស្លែង។ ស្ថានភាពរលួយសាកសពនោះមិនបានរៀបរាប់ច្បាស់ដូចគ្នា[1526]។ ទោះបីជាយ៉ាងនេះក្តី គេអាចសន្និដ្ឋានពីភ័ស្តុតាងទាំងអស់បានថា ការកាប់សម្លាប់នោះបានបន្តរហូតដល់អំឡុងពេលមុនពួកគេសង្កេតឃើញបន្តិច ដោយសារមានការលើកឡើងពុំច្បាស់លាស់អំពី *"ឆ្អឹង"* និង *"លលាដ៍"* ពុំផ្ទុយនឹងសក្ខីកម្មជាក់លាក់ជាមួយនឹងស្ថានភាពរលួយនៃឆ្អឹង និងលលាដ៍ទាំងនោះ។

563. មានភ័ស្តុតាងចចាមអារ៉ាមបង្ហាញអំពីការកាប់សម្លាប់នៅភូមិស្លែង ប៉ុន្តែភ័ស្តុតាងនោះពុំអាចទុកចិត្តបានគ្រប់គ្រាន់នោះឡើយ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបានដឹងក្រោយសម័យកម្ពុជាប្រជាធិបតេយ្យដួលរលំថា ខ្មែរក្រោមត្រូវបានគេសម្លាប់នៅភូមិស្លែង ប៉ុន្តែភ័ស្តុតាងចចាមអារ៉ាមនេះពុំដឹងចេញមកពីប្រភពណាឡើយ[1527]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតភ្ជាប់រឿងនេះដោយលើកឡើងថា បងស្រីរបស់ខ្លួន ដែលត្រូវបានជម្លៀសទៅភូមិស្លែងនៅក្នុងខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៨ បានប្រទះឆ្អឹងមនុស្សនៅក្នុងព្រៃឫស្សី។ ទោះបីជាយ៉ាងនេះក្តី វាពុំបង្ហាញច្បាស់ថាតើព្រៃនោះនៅក្នុង ឬនៅជិតភូមិស្លែងឡើយ[1528]។

---

[1524] ឯកសារ **D118/253** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សំណាង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ERN 00993596 ឆ.២២-ឆ.២៣ ERN 00993596 ឆ.២៦។

[1525] ឯកសារ **D219/482** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាច សែប ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ERN 01136310-01136311 ឆ.៧០-ឆ.៧២ (ចំពោះពេលវេលា សូមមើល ERN 01136304 ឆ.១ ឆ.៤-ឆ.៥)។ ឯកសារ **D118/233** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាច សែម ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ERN 00987238-00987239 ឆ.១០៨-ឆ.១១២។

[1526] ឯកសារ **D219/326** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ERN 01099690 ឆ.៧២-ឆ.៧៣។

[1527] ឯកសារ **D118/131** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាន់ ទូច ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤ ERN 00960608 ឆ.៧៨។ សូមមើលផងដែរ ឯកសារ **D65.1.28**, ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន់ ទូច ERN 00426780.

[1528] ឯកសារ **D118/291** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃិន សួរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ERN 01022442 ឆ.១៤៨។

*ចំនួនជនរងគ្រោះសរុប*

564. ទោះបីជាភស្តុតាងរបស់សាក្សីជាច្រើនអាចឲ្យសន្និដ្ឋានថា ក្រុមមនុស្ស រួមទាំង ខ្មែរក្រោមត្រូវបានគេសម្លាប់ ដោយសារពួកគេបានបាត់ខ្លួន និងមិនដែលឃើញវិលត្រឡប់មកវិញ និងដោយសារមានឆ្អឹង និងសាកសពមនុស្សនៅជិតភូមិស្តែងក៏ដោយ ក៏ភស្តុតាងពុំជាក់លាក់គ្រប់គ្រាន់អាចឲ្យបង្កើតជាមូលដ្ឋានសម្រាប់ការគណនាចំនួនជនរងគ្រោះនៅទីតាំងនេះថាជាខ្មែរក្រោម ឬប្រជាជនផ្សេងពីខ្មែរក្រោម។

*ការចុះពិនិត្យរបស់ យឹម ទិត្យ*

565. គ្មានភស្តុតាងបង្ហាញថា **យឹម ទិត្យ** បានចុះពិនិត្យទីតាំងនេះ។

### *៥.៥.១.៦. វត្តអង្គសិរីមាលី និងកន្លែងសម្លាប់ព្រៃសុខុន*

566. វត្តអង្គសិរីមាលីគឺជាមន្ទីរឃុំឃាំងនៅភូមិសំភ្លី ឃុំព្រៃខ្លា ស្រុកកោះអណ្ដែត តំបន់ ១៣ ភូមិភាគនិរតី[1529]។ វត្តនេះវិហារមួយប្រើប្រាស់ជាមន្ទីរស្រុក អគារសាលាដំបូងប្រើប្រាស់សម្រាប់ឃុំអ្នកទោស ហើយចាប់ពីខែឧសភា ឆ្នាំ១៩៧៦ រហូតមក ត្រូវបានសង់រោងសម្រាប់ការឃុំឃាំង[1530]។

567. មានកន្លែងសម្លាប់មនុស្សមួយនៅព្រៃសុខុន[1531] ចម្ងាយ ២ គីឡូម៉ែត្រខាងលិចផ្លូវមួយដែលមានចម្ងាយ ២,៥ គីឡូម៉ែត្រភ្ជាប់ពីភូមិសំភ្លី និងភូមិស៊ីស្លា[1532]។ សព្វថ្ងៃ ទីតាំងនេះចេញចូលតាមផ្លូវ

[1529] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866856-00866857 **ឆ.៣ ឆ.១២** ERN 00866861 **ឆ.៣៦**។ ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171491 **ឆ.៧-ឆ.៨**។ ឯកសារ **D219/568** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ERN 01165966 **ឆ.៥១** ERN 01165966 **ឆ.៥៤**។ ឯកសារ **D119/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ERN 00971368 **ឆ.១៦** ERN 00971375 **ឆ.៦២**។ សូមមើលផងដែរ ឯកសារ **D119/9** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ ERN 00887253-00887254។ ឯកសារ **D119/9.1** ឧបសម្ព័ន្ធ១៖ ផែនទីបណ្ដាញផ្លូវខេត្តតាកែវ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ EN ERN 00887256។ គេហៅផងដែរថា៖ វត្តអង្គសេរីមុនី/សេរីមាលី។

[1530] ឯកសារ **D119/9**, របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ ERN 00887254។ ឯកសារ **D119/9.2** ឧបសម្ព័ន្ធ 2: រូបថតនៃ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ ERN 00882068-00882073។ ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866856 **ឆ.២** ERN 00866856-00866857 **ឆ.៨-៩ ឆ.១១-ឆ.១២ ឆ.១៤** ERN 00866860 **ឆ.៣៣**។ ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171493 **ឆ.១៦**។

ដែលចាប់ពី ១ គីឡូម៉ែត្រ ខាងជើងភូមិសំភ្លី នៅលើផ្លូវទៅកាន់ភូមិស៊ីស្ដា។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តំបន់នេះមានព្រៃក្រាស់ ដែលតាំងពីពេលនោះមកត្រូវបានគេកាប់ឆ្ការក្លាយជាវាលស្រែវិញ[1533]។

568. មានទីតាំងឃុំឃាំងមួយទៅនៅទួលគោកស្រុកក្នុងភូមិស៊ីស្ដា ដែល ស.ច.ស ពុំបានទទួលសំណុំរឿង[1534]។ សាក្សីខ្លះនៅទីតាំងព្រៃសុខុនមកពីទួលគោកស្រុកនោះ។

569. វត្តអង្គសិរីមាលី និងព្រៃសុខុន បានចាប់ដំណើរការក្រោយថ្ងៃ១៧ មេសា ១៩៧៥ តែបន្តិច ហើយបន្តយ៉ាងហោចណាស់ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៨[1535]។

---

[1531] ឯកសារ **D119/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហង់ សុង ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872457 ឆ.៣៥-ឆ.៣៧។ ឯកសារ **D119/7** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872468-00872469 ឆ.២១-ឆ.២៨។ ឯកសារ **D119/2** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866859-00866860 ឆ.២៨ ឆ.៣០ ERN 00866860 ឆ.៣៣-ឆ.៣៤។ ឯកសារ **D219/591** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169866-01169867 ឆ.៣៤ ឆ.៣៦ ERN 01169867 ឆ.៣៧។ ឯកសារ **D119/16** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ERN 00893282 ឆ.១២។ ឯកសារ **D219/604** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01173501 ឆ.៦៩-ឆ.៧០។ សូមមើលផងដែរ ឯកសារ **D119/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872486 ឆ.៣០។

[1532] ឯកសារ **D119/10**, របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ ERN 00887251។ ឯកសារ **D119/10.2** ឧបសម្ព័ន្ធ 2: រូបថតនៃ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ EN ERN 00882060-00882067។

[1533] ឯកសារ **D119/10**, របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ ERN 00887250-00887252។ ឯកសារ **D119/10.2** ឧបសម្ព័ន្ធ 2: រូបថតនៃ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ EN ERN 00882060-00882067។

[1534] ឯកសារ **D119/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហង់ សុង ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872456-00872457 ឆ.២៨-ឆ.៣២។ ឯកសារ **D219/591** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169870 ឆ.៦៦។ ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានា នៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៥។

[1535] ឯកសារ **D119/2** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866856 ឆ.៤ ERN 00866856 ឆ.៨ ERN 00866860 ឆ.៣៤។ ឯកសារ **D219/591** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169868 ឆ.៤៧។

*វចនាសម្ព័ន្ធ និងបុគ្គលិក*

570. វត្តអង្គសិរីមាលី ស្ថិតក្រោមការគ្រប់គ្រងរបស់យោធាស្រុកកោះអណ្តែត ដែលឈរជើងនៅទីនោះ នោះចាប់ពីឆ្នាំ១៩៧៥ រហូតដល់ ពេលកងទ័ពវៀតណាមចូលមកដល់[1536]។

571. សាក្សី វង ណុប នៅរស់នៅជិតវត្តរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៥ ហើយនៅបន្តរស់នៅក្នុងភូមិសំភ្លី នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[1537]។ គាត់លើកឡើងថា នៅក្នុងអំឡុងពេលក្រោយថ្ងៃ១៧ មេសា ១៩៧៥ មិត្តរបស់គាត់កាលពីតូចឈ្មោះ ម៉ោង គឺជាប្រធានមន្ទីរសន្តិសុខ ដែលមើលការខុសត្រូវវត្តអង្គសិរីមាលី ហើយសម្រេចថាតើត្រូវសម្លាប់នរណាខ្លះ[1538]។ វង់ ណុប ក៏លើកឡើងផងដែរថា ម៉ោង កាន់តួនាទីជាប្រធានសន្តិបាល *"តំបន់ ១០៨"* ប៉ុន្តែ តាមពិត បានសំដៅរួមបញ្ចូល តំបន់ ១៣ និងស្រុក ១០៨ ជាមួយគ្នា[1539]។ ដោយសារតំបន់នោះស្ថិតក្រោមការគ្រប់គ្រងរបស់ស្រុក វាទំនងដែលថា ម៉ោង ទទួលខុសត្រូវសន្តិសុខស្រុក ១០៨ (កោះអណ្តែត)។ ម៉ោង ប្រហែលជាត្រូវបានគេសម្លាប់ចោលនៅប្រហែលជាពាក់កណ្តាលរបបកម្ពុជាប្រជាធិបតេយ្យ ហើយគេពុំដឹងថានរណាជំនួសគាត់នោះទេ[1540]។

---

[1536] ឯកសារ **D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872485 ឆ.១៨-ឆ.២១។ ឯកសារ **D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169867 ឆ.៤០ ERN 01169868 ឆ.៤៧។ ឯកសារ **D119/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ERN 00893283 ឆ.២០។

[1537] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866855-00866856 ឆ.១-ឆ.២ ឆ.៥។ ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171491-01171492 ឆ.៩ ERN 01171501 ឆ.៦៤។

[1538] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866859 ឆ.២៦។

[1539] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171496ឆ.៣៥-ឆ.៣៩។ ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866859 ឆ.២៦។

[1540] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171496ឆ.៤០។ ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866859ឆ.២៦។

572. ទោះបីជាមានភស្តុតាងមិនសូវច្រើនពាក់ព័ន្ធនឹងពេលវេលាជាក់លាក់ក៏ដោយក៏ដោយ យ៉ាងហោច ណាស់នៃរបបកម្ពុជាប្រជាធិបតេយ្យ សាន គឺជាលេខាស្រុកកោះអណ្តែត[1541] ហើយ សឿន ធ្វើ ការបម្រើនៅក្នុងគណៈស្រុកកោះអណ្តែត[1542]។

*ការចាប់ខ្លួន និងការឃុំខ្លួន*

573. ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ភ្លាម ប្រជាជនរាប់ពាន់នាក់ ភាគច្រើន ជាខ្មែរក្រោម ត្រូវបានបញ្ជូន ពីភ្នំពេញ តាកែវ និងកំពង់សោម ទៅកាន់ស្រុកកោះអណ្តែត រួមទាំង ភូមិសំភ្លី និងភូមិស៊ីស្លានៅជិត នោះផងដែរ[1543]។ អ្នកមកពីភ្នំពេញ និងតាកែវ ត្រូវបានចាត់ទុកជា *"ខ្មាំង"* ហើយត្រូវបានគេឃុំនៅ ក្នុងអគារសាលារៀនក្នុងវត្តអង្គសិរីមាលី[1544]។ ប្រជាជនដែលជាប់ឃុំនៅក្នុងសាលារៀន ពុំត្រូវ

[1541] ឯកសារ **D119/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ សុង ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872457 ឆ. ៣៩។ ឯកសារ **D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169873 ឆ.៥០។ ឯកសារ **D119/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ERN 00893281 ឆ.៦ ERN 00893284 ឆ.២៧។ ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០១២ ERN 00866856 ឆ.៤។ សូមមើល ឯកសារ **D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០១២ ERN 00872485 ឆ.២០-ឆ.២១។

[1542] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866856 ឆ.៤ 00866857 ឆ.១៥។ ឯកសារ **D119/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872492 ឆ.១៦។ *សូមប្រៀបធៀបជាមួយ* ឯកសារ **D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០១២ ERN 00872485 ឆ.២០-ឆ.២១។ ឯកសារ **D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169868 ឆ.៤៨។

[1543] ឯកសារ **D119/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ សុង ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872453-00872454 ឆ.៣-ឆ.៧ 00872454 ឆ.៥ ERN 00872454-00872455 ឆ.១២ ឆ.១៦។ ឯកសារ **D119/2** កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866856-00866857 ឆ.៨ ឆ.៩ ឆ.១៣ ERN 00866858 ឆ .១៧-ឆ.១៨។ ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171491 ឆ.៧-ឆ.៨ ERN 01171493-01171494 ឆ.២១-ឆ.២៣។ ឯកសារ **D119/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872467 ឆ.៥ ERN 00872468 ឆ.១៥។

[1544] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171491ឆ .៧ ERN 01171494-01171495 ឆ.២៥ ឆ.២៨។ ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866856-00866857 ឆ.៩ ឆ.១៤។

បានគេដាក់ខ្នោះទេ ប៉ុន្តែពុំត្រូវបានគេឱ្យដើរហើរដោយសេរីនៅក្នុងបរិវេណនោះឡើយ[1545]។ សាក្សី វង់ ណុប លើកឡើងថា គាត់ពុំដឹងចំនួនខ្មែរក្រោមប៉ុន្មាននាក់ ដែលមកពីតាកែវ និងភ្នំពេញនោះទេ ដោយសារគេពុំអនុញ្ញាតឱ្យនៅជិតពួកគេ ប៉ុន្តែ តាមភ័ស្តុតាងចចាមអារ៉ាមពីអ្នកភូមិ គាត់ប៉ាន់ស្មានថា មានគ្រួសារខ្មែរក្រោមចំនួនប្រហែល ៤០០ គ្រួសារ[1546]។ គាត់បានដឹងថា ពួកគេជាខ្មែរក្រោម ដោយសារគាត់បាននិយាយជាមួយពួកគេ នៅពេលពួកគេបានទៅដល់ភូមិសំរ៉ោង[1547]។ កងសន្តិសុខក៏បានប្រាប់គាត់ផងដែរថា មានគ្រួសារដែលមិនមែនជាខ្មែរក្រោមប្រហែលជា ៤០០ ទៀត ដែលគាត់និយាយថានៅជាប់ឃុំក្នុងអគារសាលារៀននៅវត្តអង្គសិរីមាលី[1548]។ ទោះបីជាយ៉ាងនេះក្តី នៅពេលពិចារណាទំហំអគារសាលារៀនតូច ដែលមិនអាចដាក់ដល់ទៅ ៤០០ គ្រួសារ ដែលមានសមាជិកជាមធ្យម ៤ នាក់ ទេនោះ ខ្ញុំពុំជឿថា ការប៉ាន់ស្មានរបស់ វង ណុប ថាមានខ្មែរក្រោម ៤០០ គ្រួសារ ត្រូវបានឃុំនៅសាលារៀនផ្អែកលើភ័ស្តុតាងចចាមអារ៉ាម អាចទុកចិត្តបានគ្រប់គ្រាន់នោះឡើយ[1549]។ ក៏ប៉ុន្តែ នៅពេលថ្លឹងថ្លែង និងពិនិត្យខ្លឹមសារនៃភ័ស្តុតាងរបស់ វង ណុប ទាំងមូល យើងអាចសន្និដ្ឋានថា មនុស្សជាច្រើននាក់ដែលជាប់ឃុំនៅវត្តអង្គសិរីមាលីគឺជាខ្មែរក្រោម ហើយពួកគេមានចំនួនដល់រាប់រយនាក់។

574. ក្រោយការបង្កើតអគារសម្រាប់ឃុំឃាំងនៅវត្តអង្គសិរីមាលី ក្នុងខែឧសភា ឆ្នាំ៧៦ អ្នកទោសថ្មីមកពីភូមិនានា ក្នុងស្រុកកោះអណ្តែតត្រូវបានគេឃុំនៅក្នុងអគារនោះ[1550]។ ទោះបីជាយ៉ាងនេះក្តី

---

[1545] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866857 ឆ.១៤ ERN 00866859 ឆ.២៦-ឆ.២៨។ ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171493 ឆ.១៦។

[1546] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171493-01171495 ឆ.២២-ឆ.២៤ ឆ.៣២-ឆ.៣៣។

[1547] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171493ឆ.២០។

[1548] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171497 ឆ.៤៦។ *Cf:* ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866857-00866858 ឆ.១៣ ឆ.១៧-ឆ.១៨។ សូមមើលផងដែរ ឯកសារ **D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169865-01169866 ឆ.២៦-៣៥។

[1549] ឯកសារ **D119/9.2** ឧបសម្ព័ន្ធ 2: រូបថតនៃ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ ERN 00882068-00882073.

[1550] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866860 ឆ.៣៣។

អ្នកទោសត្រូវបានគេដាក់ខ្នោះគ្រប់ពេល[1551]។ ពុំមានភ័ស្តុតាងបង្ហាញច្បាស់ថាតើពួកគេគឺជាខ្មែរក្រោមឬក៏យ៉ាងណានោះឡើយ។

*ការកាប់សម្លាប់*

575. ខ្មែរក្រោមទាំងអស់ដែលជម្លៀសទៅកាន់វត្តអង្គសិរីមាលីពីតាកែវ និងភ្នំពេញ ត្រូវបានសម្លាប់នៅព្រៃសុខុន ក្នុងរយៈពេលតែប៉ុន្មានសប្តាហ៍តែប៉ុណ្ណោះក្រោយពេលមកដល់[1552]។ អ្នកដែលមិនមែនជាខ្មែរក្រោមមួយចំនួនមកពីភ្នំពេញ និងតាកែវ អាចត្រូវបានគេយកទៅកន្លែងផ្សេងមួយទៀតនាពេលណាមួយនោះ ប៉ុន្តែ អ្នកផ្សេងទៀត ត្រូវបានគេសម្លាប់ចោលរួមជាមួយខ្មែរក្រោម[1553]។

576. ការកាប់សម្លាប់នៅព្រៃសុខុន ត្រូវបាន *"ថ្នាក់លើ"* បញ្ជា នៅពេលប្រជាជនមកពីភ្នំពេញ និងតាកែវត្រូវបានចាត់ទុកជា *"ខ្មាំង"*[1554]។ ប្រធានវត្តអង្គសិរីមាលី បានរាយការណ៍អំពីដំណើរការប្រតិបត្តិការកាប់សម្លាប់ទៅតាមការចាត់តាំងពីថ្នាក់លើ[1555]។

577. នៅក្នុងរយៈពេល ២ ទៅ ៣ ខែ ពីខែឧសភា ឬខែមិថុនា ឆ្នាំ១៩៧៥ វង ណុប បានឃើញយ៉ាងហោចណាស់មានអ្នកជាប់ឃុំ ១០ នាក់ ក្នុងមួយថ្ងៃ (តាមចំនួនទាបបំផុត ៦០ ថ្ងៃ x ១០ នាក់ = **៦០០**) ត្រូវបានឃ្លបប្រដាប់ដោយអាវុធបណ្តើរចេញពីវត្តកាត់មុខផ្ទះរបស់គាត់ (ខាងលិចវត្ត) សំដៅទៅព្រៃសុខុន[1556]។ មិត្តរបស់ វង ណុប ឈ្មោះ ម៉ោង ដែលជាប្រធានមន្ទីរសន្តិសុខ បាន

[1551] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866860 ឆ.៣៣។

[1552] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171491 ឆ.៧ ERN 01171497-01171499 ឆ.៤៦-ឆ.៤៧, ឆ.៥១-ឆ.៥២។ ឯកសារ **D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872487 ឆ.៣៦។ ឯកសារ **D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169867 ឆ.៣៦-ឆ.៣៧។

[1553] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171497-01171498 ឆ.៤៦-ឆ.៤៩។ ឯកសារ **D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169867 ឆ.៣៦។

[1554] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171494-01171495 ឆ.២៥, ឆ.២៨ ERN 01171497 ឆ.៤៤-ឆ.៤៥។

[1555] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171497 ឆ.៤៤ ERN 01171501 ឆ.៦៧។

[1556] ឯកសារ **D219/592** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171500 ឆ.៦១ ERN 01171501-01171502 ឆ.៦៤-ឆ.៦៦, ឆ.៧៣។

ប្រាប់គាត់អំពីជោគវាសនារបស់អ្នកដែលគេនាំយកទៅនោះ ពោលគឺ អ្នកជាប់ឃុំដែលគេបណ្ដើរជាជួរត្រូវបានឈ្នួបប្រដាប់ដោយអាវុធនាំទៅកាន់ *"កន្លែងប្រជុំ"* ដោយឈ្នួបម្នាក់នៅពីមុខ និងម្នាក់ទៀតនៅពីក្រោយ។ នៅ *"កន្លែងប្រជុំ"* គេបានប្រាប់ថា ពួកគេត្រូវបានជម្លៀសទៅភូមិថ្មី។ តាមការពិត ពួកគេបានប្រគល់ឲ្យឈ្នួបជាច្រើននាក់ផ្សេងទៀត ចាប់ចង និងនាំយកទៅកន្លែងសម្លាប់ដែលនៅទីនោះ ពួកគេត្រូវបានវាយសម្លាប់ចោល[1557]។ វង ណុប ដែលពុំបានឃើញការកាប់សម្លាប់ដោយខ្លួនឯង ត្រូវបានគេស្នើសុំឲ្យជួយយកអ្នកទោស វាយពួកគេ និងកប់ជនរងគ្រោះ ប៉ុន្តែគាត់បានបដិសេធថាពុំបានធ្វើឡើយ[1558]។ គេអាចសន្និដ្ឋានថា ករណីនេះកើតឡើងនៅមុនពេល **យឹម ទិត្យ** ឡើងកាន់មុខនាទីផ្លូវការនៅតំបន់ ១៣។ ដូច្នេះ អ្នកទោសទាំងនេះមិនអាចរាប់បញ្ចូលចំនួនជនរងគ្រោះសរុបនោះឡើយ។

578. អ្នកដែលរក្សាទុកនៅទួលគោកស្រុក នៅភូមិស៊ីស្លា ក៏ត្រូវបានគេសម្លាប់នៅព្រៃសុខុនដែរ។ ជារៀងរាល់ថ្ងៃ នៅក្នុងខែមករា ឬកុម្ភៈ ឆ្នាំ១៩៧៦ សាក្សីដែលទៅឃ្វាលគោលនៅជិតនោះបានឃើញមនុស្សពីរ ឬបី នាក់ ត្រូវបានគេដឹកចេញពីកន្លែងដែលគាត់អះអាងថាជាទួលគោកស្រុក ទៅកាន់ព្រៃសុខុន ដែលនៅទីនោះ ពួកគេត្រូវបានវាយនឹងបំពង់ឫស្សីរហូតដល់ស្លាប់ ក្រោយពេលត្រូវបានបង្ខំឲ្យជីករណ្ដៅសម្រាប់ខ្លួនឯង[1559]។ ជនរងគ្រោះខ្លះមិនបានស្លាប់ដោយការវាយទេ ប៉ុន្តែត្រូវបាន

---

[1557] ឯកសារ **D119/2** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866856-00866857 ឆ.៨, ឆ.១៤ ERN 00866859-00866860 ឆ.២៥, ឆ.៣១, ឆ.៣៣។ ឯកសារ **D219/592** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171492-01171493 ឆ.១៣, ឆ.១៦-ឆ.១៨ ERN 01171498-01171500 ឆ.៤៧, ឆ.៥១-ឆ.៦០។

[1558] ឯកសារ **D119/2** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866859 ឆ.២៨។ ឯកសារ **D219/592** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171494 ឆ. ២៥។

[1559] ឯកសារ **D219/604** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01173499-01173500 ឆ.៧០-ឆ.៧៤, ឆ.៧៩-ឆ.៨០។ *សូមមើល* ឯកសារ **D119/6** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872491 ឆ.៧-ឆ.១២។

គេកប់ទាំងរស់ជាមួយនឹងអ្នកស្លាប់[1560]។ ទោះបីជាយ៉ាងនេះក្តី សាក្សីលើកឡើងថា ពុំឃើញមានខ្មែរក្រោមនៅក្នុងចំណោមជនរងគ្រោះនៅទួលគោកស្រុកនោះទេ[1561]។

579. សាក្សីម្នាក់ទៀត មានអាយុ ១១ ឬ ១២ ឆ្នាំនៅពេលនោះ រៀបរាប់អំពីកម្មាភិបាល ប.ក.ក សំពងមនុស្សរួចដល់ស្លាប់ ហើយបោះសាកសពចូលទៅក្នុងរណ្តៅក្នុងព្រៃសុខុន នៅក្នុងឆ្នាំ១៩៧៧ ឬ ឆ្នាំ ១៩៧៨[1562]។ ខណៈពេលគាត់កំពុងធ្វើការនៅក្នុងស្រែជិតនោះក៏ដោយ គាត់បានឃើញសមាជិកឈ្លប ដឹកបុរសស្ត្រីប្រហែល **៣០ នាក់** រួមទាំងកូនក្មេង ៥ ឬ ៦ នាក់ ដោយត្រូវបានគេចងស្លាបសេក សំដៅទៅរណ្តៅដែលត្រូវបានជីករួចជាស្រេច បន្ទាប់មកត្រូវបានសម្លាប់នឹងដំបង រួចបោះសាកសពចូលទៅក្នុងរណ្តៅ[1563]។ ក្រោយមក សាក្សីបានឮថា អ្នកដែលយកទៅសម្លាប់ចោលនៅព្រៃគឺជាខ្មែរក្រោម ប៉ុន្តែភ័ស្តុតាងរបស់គាត់ពុំច្បាស់គ្រប់គ្រាន់អាចសន្និដ្ឋានបានថា ជនរងគ្រោះមួយចំនួនជាក់លាក់ដែលគាត់បានឃើញគឺជាខ្មែរក្រោមនោះទេ[1564]។

580. ការរៀបរាប់ទាំងនេះស៊ីចង្វាក់គ្នាជាមួយនឹងសាក្សីផ្សេងទៀត ដែលលើកឡើងថា ប្រជាជននៅទួលគោកស្រុក ត្រូវបានគេចាប់ចងឥតដាច់ ហើយយកទៅក្នុងព្រៃ ដោយពុំដែលឃើញវិលត្រឡប់មកវិញនោះឡើយ[1565]។ម្យ៉ាងវិញទៀត *"ប្រជាជនមូលដ្ឋាន"* នៅភូមិស៊ីស្លាហៅព្រៃសុខុនថាជា

---

[1560] ឯកសារ **D219/604** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01173499 ឆ. ៧៤។

[1561] ឯកសារ **D219/604** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01173499 ឆ. ៧៥។

[1562] ឯកសារ **D119/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872469-00872470 ឆ.២២-ឆ.២៤, ឆ.៣២។ ឯកសារ **D219/568** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ERN 01165970 ឆ.៩៥-ឆ.៩៧។

[1563] ឯកសារ **D219/568** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ERN 01165967-01165969 ឆ.៦៤-ឆ.៧៣, ឆ.៧៨-ឆ.៨១។

[1564] ឯកសារ **D219/568** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ERN 01165968 ឆ .៧៤ ERN 01165969 ឆ.៨២, ឆ.៨៤។

[1565] ឯកសារ **D119/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ សុង ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872456-00872457 ឆ.២៩-ឆ.៣៧។ ឯកសារ **D119/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872467 ឆ.៨។ ឯកសារ **D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណា ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872486 ឆ.២៦។ ឯកសារ **D219/568** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ERN 01165972 ឆ.១១០-ឆ.១១២។

*"កន្លែងដែលគេយកមនុស្សទៅវៃចោល"*[1566]។ ទោះបីជាតាមទម្លាប់អ្នកភូមិបានដើរឆ្លងពីភូមិសំភ្លី និងស៊ីស្តាបានក៏ដោយ នៅព្រៃសុខុនត្រូវបានរឹតត្បិតមិនឲ្យចេញចូលឡើយ[1567]។

581. នៅក្នុងអំឡុង និងក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ អ្នកភូមិឃើញរណ្តៅមានសាកសពនៅតំបន់ព្រៃសុខុន។ មានពេលខ្លះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ទំនងជាមុនឆ្នាំ១៩៧៨ សាក្សី វង ណុប បានឃើញសាកសពក្មេងស្រីពីរនាក់ ដែលត្រូវបានគេសម្លាប់នៅជិតព្រៃសុខុន នៅតាមផ្លូវទៅកាន់ទួលគោកស្រុក។ តាមបញ្ជារបស់ប្រធានរបស់គាត់ គាត់បានកប់សាកសពនោះម្តងទៀតនៅកន្លែងដដែល[1568]។ នៅតាមផ្លូវទៅធ្វើការនៅក្នុងស្រែក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ វង ណុប ដែលពុំបានប្រាប់កាលបរិច្ឆេទជាក់លាក់លើរឿងនេះ ក៏បានឃើញរណ្តៅមានសាកសពនៅព្រៃសុខុន[1569] ដែលចំហពុំមានដីកប់ ហើយសាក្សីបានដាក់បញ្ចូលបន្ថែមជារៀងរាល់ថ្ងៃ ដែលនាំឲ្យមានក្លិនស្អុយ *"ហើយមានហ្វូងរុយខ្មៅងងឹតហើរពេញព្រៃតែម្តង"*[1570]។ វង ណុប បាននាំអ្នកស៊ើបអង្កេត ក.ស.ច.ស ទៅកាន់ទីតាំងដែលធ្លាប់មានរណ្តៅចំនួន ៣ ក្នុងចំណោមរណ្តៅទាំងនោះ នៅក្នុងតំបន់ ដែលបច្ចុប្បន្ន ជាវាលស្រែ នៅពាយ័ព្យភូមិសំភ្លី និងខាងលិចផ្លូវចន្លោះពីភូមិសំភ្លី និង ស៊ីស្តា[1571]។ គាត់បានពន្យល់ថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មានរណ្តៅមូល អង្កត់

[1566] ឯកសារ **D119/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាង់ សុង ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872457 ឆ.៣៥-ឆ.៣៦។ *សូមមើលផងដែរ* ឯកសារ **D119/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872491 ឆ.១២។

[1567] ឯកសារ **D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872486 ឆ.២៨-ឆ.២៩។

[1568] ឯកសារ **D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872486-00872487 ឆ.៣០-ឆ.៣២។ ឯកសារ **D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01169870 ឆ.៦០-ឆ.៦៦។

[1569] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866860 ឆ.៣០-ឆ.៣១។

[1570] ឯកសារ **D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ ERN 00866860-00866861 ឆ.៣៤-ឆ.៣៥។

[1571] ឯកសារ **D119/10** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ ERN 00981801-00981803។

ផ្ចិតប្រហែល ២០ ម៉ែត្រ ហើយមានជម្រៅប្រហែល ២ ម៉ែត្រ ហើយរណ្តៅចតុកោណកែង ២ ដែលមានបណ្តោយ ១០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ និងជម្រៅ ២ ម៉ែត្រ[1572]។

582. សាក្សីពីរនាក់ទៀតក៏បានឃើញរណ្តៅជាច្រើន និងឆ្អឹងមនុស្សនៅសេសសល់នៅព្រៃសុខុន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ[1573]។

*ចំនួនជនរងគ្រោះសរុប*

583. ចំនួនជនរងគ្រោះតិចបំផុត **៩០** នាក់ ត្រូវបានសម្លាប់នៅវត្តអង្គសិរីមាលី និងព្រៃសុខុន ប៉ុន្តែអាចមានចំនួនច្រើន។ ការប៉ាន់ស្មាននេះគឺផ្អែកលើការគណនាដូចខាងក្រោម៖

i. ការកាប់សម្លាប់មនុស្ស ២ ឬ ៣ នាក់ ក្នុងមួយថ្ងៃ ក្នុងរយៈពេលមួយខែក្នុងខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៧៦ ពីទួលគោកស្រុក និងព្រៃសុខុន មានចំនួនជនរងគ្រោះ **៦០** នាក់ ហើយ

ii. ជនរងគ្រោះ **៣០** នាក់ ត្រូវបានសម្លាប់នៅក្នុងហេតុការណ៍មួយនៅព្រៃសុខុន ក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨។

584. ភស្តុតាងពុំបង្ហាញច្បាស់ថាតើពួកគេមួយចំនួននោះគឺជាខ្មែរក្រោមមែន ឬមិនមែននោះឡើយ។

*ការចុះពិនិត្យរបស់ យឹម ទិត្យ*

585. ពុំមានភស្តុតាងបង្ហាញថា **យឹម ទិត្យ** បានទៅពិនិត្យវត្តអង្គសិរីមាលី ឬព្រៃសុខុននោះឡើយ។

### ៥.៥.២. តំបន់ ១

#### *៥.៥.២.១. មន្ទីរសន្តិសុខគាស់ក្រឡ*

*ទីតាំង និងការបង្កើត*

[1572] ឯកសារ **D119/10.2** ឧបសម្ព័ន្ធ ២៖ រូបថតនៃរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ EN ERN 00882066-00882067។

[1573] ឯកសារ **D119/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872468 ធ.២១។ ឯកសារ **D119/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ERN 00872491 ធ.១១។ ឯកសារ **D219/604** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01173501 ធ.៨៨-ធ.៩២។

586. មន្ទីរសន្តិសុខគាស់ក្រឡស្ថិតនៅក្នុងវត្តគាស់ក្រឡ ភូមិគាស់ក្រឡ ឃុំគាស់ក្រឡ ស្រុកគាស់ក្រឡ តំបន់ ១ ភូមិភាគពាយ័ព្យ[1574] ហើយមានមន្ទីរឃុំឃាំងយ៉ាងហោចណាស់ចំនួន ២ (មួយជាអតីតរោងកិនស្រូវ និងកន្លែងរៀនសូត្រ)[1575]។ កម្មាភិបាលភូមិភាគនិរតីបានបង្កើតមន្ទីរសន្តិសុខនេះនៅវត្តគាស់ក្រឡ យ៉ាងយូរបំផុតត្រឹមពាក់កណ្ដាលឆ្នាំ១៩៧៨[1576] ដែលនៅទីនោះមន្ទីរនេះដំណើរការរហូតយ៉ាងហោចណាស់ដល់ចុងឆ្នាំ១៩៧៨ មុនពេលកងទ័ពវៀតណាមចូលមកដល់តែបន្តិច[1577] ដែលបានមកដល់តំបន់ ១ ក្រោយភ្នំពេញដួលរលំ ទោះបីជាភ័ស្តុតាងពុំបង្ហាញច្បាស់ថាតើករណីនេះកើតឡើងនៅក្នុងរយៈពេលតែប៉ុន្មានថ្ងៃ ឬប៉ុន្មានសប្ដាហ៍ក៏ដោយ[1578]។ ទោះបីជាសាក្សីលើក

[1574] ឯកសារ **D118/37** របាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៣ ERN 00950669។ *សូមមើល* ឯកសារ **D219/547** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆន ឡូញ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01157557 ឆ.៣១។

[1575] ឯកសារ **D118/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882711 ឆ.២៨ ERN 00882713 ឆ.៣២។ ឯកសារ **D118/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ អើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882721 ឆ.២០។ ឯកសារ **D118/6** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ERN 00882728-00882729 ឆ.១២។ ឯកសារ **D219/625** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ី ពឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184293 ឆ.២៦-ឆ.២៨។

[1576] ឯកសារ **D118/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882709 ឆ.១៥។ ឯកសារ **D118/6** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ERN 00882728-00882729 ឆ.១២ ERN 00882729 ឆ.១៦។ ឯកសារ **D118/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ERN 01023824 ឆ.២-ឆ.៣។ ឯកសារ **D118/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ អើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882719 ឆ.១៥។ *សូមមើល* ឯកសារ **D219/547** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆន ឡូញ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01157557 ឆ.៣៣។ ឯកសារ **D219/625** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ី ពឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184293 ឆ.២៧។ ឯកសារ **D219/513** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៀន ស៊ឹម ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149385 ឆ.៣៩-ឆ.៤២ *បញ្ជាក់អះអាង* ឯកសារ **D219/456** របាយការណ៍ស្ដីពីសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ERN 01215926។

[1577] ឯកសារ **D118/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ អើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882719-00882720 ឆ.១៧។ ឯកសារ **D219/624** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ី ពឿត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184279-01184280 ឆ.១-ឆ.៥។

[1578] ឯកសារ **D219/142** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព សារុន ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ERN 01056128 ឆ.៤០-ឆ.៤១។ ឯកសារ **D219/517** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សយ ឈឿន ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149414 ឆ.៨ ERN 01149431 ឆ.១១២។ ឯកសារ **D219/20** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឈុំ វ៉ាន់នី ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ERN 01029502-01029503 ឆ.៩៧-ឆ.១០១។ ឯកសារ

ឡើងថាមន្ទីរសន្តិសុខបានដំណើរការនៅស្រុកគាស់ក្រឡ មុនពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់ក៏ដោយ[1579] គ្មានភស្តុតាងបង្ហាញថា មន្ទីរសន្តិសុខទាំងនេះដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតីនោះឡើយ។

*វចនាសម្ព័ន្ធ និងបុគ្គលិក*

587. មន្ទីរសន្តិសុខនេះស្ថិតក្រោមការគ្រប់គ្រងរបស់ស្រុកគាស់ក្រឡ[1580]។ លេខាស្រុកឈ្មោះ គីម (ឬគឹម) មកពីភូមិភាគនិរតី ជំនួសកម្មាភិបាលភូមិភាគពាយ័ព្យឈ្មោះ យឺន (ឬយ៉ាន) ក្រោយពេល យ៉ានត្រូវគេសម្លាប់នៅអំឡុងឆ្នាំ១៩៧៨[1581] ហើយ អនុរបស់ គីម ជាកម្មាភិបាលភូមិភាគនីរតី ឈ្មោះ ប៉ោង ជាអ្នកទទួលខុសត្រូវ ហើយ ភាគច្រើនមានវត្តមាននៅមន្ទីរសន្តិសុខ (ចេញបញ្ជាដល់អ្នកយាម និងអ្នកសម្លាប់) ព្រមទាំងអនុវត្ត និងត្រួតពិនិត្យការចាប់ខ្លួន និងការសម្លាប់[1582]។

*ការចាប់ខ្លួន និងការឃុំឃាំង*

---

**D219/134** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នេត សារឿន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤ ERN 01052666-01052668 ឆ.១២៤-ឆ.១៣១។

[1579] ឯកសារ **D219/984** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ ERN 01477654-01477655 ឆ.៨-ឆ.១១។ ឯកសារ **D219/763** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ERN 01244127-01244128 ឆ.៧៣-ឆ.៧៨។ ឯកសារ **D118/3** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេក អេម ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ERN 00882700 ឆ.១០។

[1580] ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882710 ឆ.២១។

[1581] ឯកសារ **D219/514** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀន ស៊ឹម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149390-01149391 ឆ.៤។ ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុំ ញឿត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184280 ឆ.៧។ ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882708 ឆ.៣។

[1582] ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុំ ញឿត ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184280-01184281 ឆ.៧-ឆ.៩ ERN 01184283-01184285 ឆ.១៨។ ឯកសារ **D219/625** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុំ ញឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184294 ឆ.៣១។ ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882710 ឆ.១៨ ERN 00882712 ឆ.៣០-ឆ.៣១។ ឯកសារ **D219/547** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆន ឡូញ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01157556 ឆ.២៤-ឆ.២៥, ឆ.២៨។

588. នៅពេលកម្មាភិបាលភូមិភាគនិរតីមកដល់ អ្នកស្រុកមកពីកន្លែងផ្សេងៗ ដូចជា ភូមិដូនបា គាស់ក្រឡ និងព្រៃភ្លាស ត្រូវបានចាប់យកទៅមន្ទីរសន្តិសុខ[1583]។ អ្នកខ្លះត្រូវបានចោទថា "ក្បត់"[1584] ហើយអ្នកទោសរួមមានអ្នករដ្ឋការរបបសាធារណរដ្ឋ[1585] កម្មាភិបាលភូមិភាគពាយ័ព្យ និង សាច់ញាតិ[1586] និងកម្មករមកពីការដ្ឋានជិតៗនោះ ដូចជា សហករណ៍ធិបតី និងអន្លង់ប្រេង រួមទាំង អ្នកដែល "ខុសសីលធម៌"[1587]ផង។ គីម ឬ ប៉ោង បានប្រកាសនៅក្នុងអង្គប្រជុំនៅចុងឆ្នាំ១៩៧៨ នៅ

---

[1583] ឯកសារ **D118/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882719 ឆ. ១២។ ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ី ញឿត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184279 ឆ. ១។ ឯកសារ **D118/3** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេក អេម ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ERN 00882700 ឆ. ១១។ ឯកសារ **D118/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ERN 00882728-00882729 ឆ.១២។ ការសរសេរច្រើនបែបផ្សេងៗគ្នា៖ Doun/Daun Ba/Pa។

[1584] ឯកសារ **D118/3** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេក អេម ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ERN 00882700 ឆ .៧ ERN 00882701 ឆ.១៣។

[1585] ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882709-00882710 ឆ.១៥ ERN 00882711 ឆ.២៥-ឆ.២៧ ERN 00882712 ឆ.៣០-ឆ.៣១។ ឯកសារ **D118/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882719 ឆ.១៥ ERN 00882721 ឆ.២២។ ឯកសារ **D219/547** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆន ឡូញ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01157557 ឆ.៣៤-ឆ.៣៥។

[1586] ឯកសារ **D118/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882721 ឆ. ២២។ ឯកសារ **D219/513** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀន ស៊ីម ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149385 ឆ.៤១-ឆ.៤២។ ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ី ញឿត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184280 ឆ.៥ ERN 01184282-01184283 ឆ.១៥។ ឯកសារ **D219/625** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ី ញឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184289 ឆ.៤-ឆ.៦។ *សូមមើលផងដែរ* ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882711 ឆ.២៤-ឆ.២៧។ ឯកសារ **D118/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ERN 01023824 ឆ.៥។

[1587] សហករណ៍ធិបតី៖ ឯកសារ **D219/313** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ជោត ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ ERN 01097709-01097710 ឆ.១២។ ឯកសារ **D219/408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ជោត ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៥ ERN 01117257 ឆ.៧ (ដើងទីងមានទីតាំងស្ថិតនៅក្នុងសហករណ៍ធិបតី *សូមមើល សហករណ៍ធិបតី (រួមទាំងមន្ទីរសន្តិសុខវត្តធិបតី និងការដ្ឋាន និងមន្ទីរសន្តិសុខខ្ទូលម្ទេស)* កថាខណ្ឌ ៥៩៦-៥៩៨)។ ការដ្ឋានអន្លង់វិលប្រេង៖ ឯកសារ **D118/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ERN 01023824-01023825 ឆ.៤, ឆ.៧។ ឯកសារ **D118/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ERN 00882728-00882729 ឆ.១២ ERN 00882730-00882731 ឆ.២២-ឆ.២៥។ ឯកសារ **D118/3** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេក អេម ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ERN 00882703 ឆ.៣០។ ឯកសារ **D219/550** កំណត់ហេតុនៃការ

វត្តដូនបា (ស្ថិតក្នុងស្រុកគាស់ក្រឡដែរ[1588]) ថា នឹងមានការសម្រិតសម្រាំង។ បន្ទាប់មក មិនយូរប៉ុន្មាន ប្រហែលជាពីរសប្តាហ៍មុនពេលវៀតណាមមកដល់ កម្មាភិបាលភូមិភាគពាយ័ព្យ និង ក្រុមគ្រួសារត្រូវបានចាប់យកទៅឃុំនៅមន្ទីរសន្តិសុខ[1589]។

589. កូនស្រីរបស់កម្មាភិបាលភូមិភាគពាយ័ព្យ ប៊ុ ពឿត ដែលជាសាក្សីដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែក បានរៀបរាប់ថា ឪពុករបស់គាត់ត្រូវគេដាក់ខ្នោះ (ភាគច្រើនជាមួយបុរសដទៃទៀត) អស់រយៈពេលយ៉ាងហោចណាស់ចំនួនបីយប់ ហើយសាក្សីម្នាក់ទៀតក៏បានបញ្ជាក់អំពីការដាក់ខ្នោះអ្នកទោសដែរ[1590]។ កូនស្រីនោះមិនជាប់ខ្នោះទេ ប៉ុន្តែគេឃុំជាមួយស្ត្រី និងកុមារ និងបញ្ជូនទៅធ្វើការនៅវាលស្រែដោយមានឈ្លបប្រដាប់អាវុធឃ្លាំមើល[1591]។ លោកស្រីបានប៉ាន់ប្រមាណថា ពេលនោះមានទោស ចន្លោះពី២០០ទៅ ៣០០នាក់។ សាក្សីម្នាក់ទៀត ឈ្មោះ ទុំ ពឹយ និយាយថា ទីតាំងនេះដំណើរការរហូតដល់ចុងឆ្នាំ ១៩៧៨។ គាត់រម្លឹកថា បានឃើញអ្នកទោសដែល ជាប់ខ្នោះចំនួនប្រមាណ១០០នាក់នៅក្នុងអគារមួយ។ សាក្សីទីបីលើកឡើងថា មនុស្ស ៣០ ទៅ ៥០ នាក់ត្រូវបានចាប់ពីភូមិរបស់គាត់យកទៅមន្ទីរសន្តិសុខ[1592]។ អ្នកបររទេះគោបីនាក់លើកឡើងថា នៅចន្លោះ

---

ស្តាប់ចម្លើយសាក្សី ពេក អេម ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ERN 01157586 ឆ.១៨, ឆ.២១-ឆ.២៣។ *សូមមើលផងដែរ* ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882712 ឆ.៣០។

[1588] ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882710 ឆ. ២០។

[1589] ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុ ពឿត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184279-01184280 ឆ.១-ឆ.៥ ERN 01184281-01184282 ឆ.១០-ឆ.១៣។

[1590] ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុ ពឿត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184281-01184282 ឆ.១៣ ERN 01184283-01184285 ឆ.១៨។ ឯកសារ **D219/625** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុ ពឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184295 ឆ.៣២។ ឯកសារ **D118/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882720-00882721 ឆ.១៩-ឆ.២០។ *សូមមើលផងដែរ* ឯកសារ **D219/517** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ឈឿន ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149430 ឆ.១០៥។

[1591] ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុ ពឿត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184281-01184282 ឆ.១៣។ ឯកសារ **D219/625** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុ ពឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184295 ឆ.៣២។

[1592] ឯកសារ **D219/625** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុ ពឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184293 ឆ. ២៨។ ឯកសារ **D118/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882720 ឆ. ១៩។ ឯកសារ **D219/547** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆន ឡូញ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01157557 ឆ.៣៦-ឆ.៣៧។

ពាក់កណ្តាល ដល់ចុងឆ្នាំ ១៩៧៨ ពួកគាត់បានដឹកមនុស្សចំនួន១៤នាក់ ក្នុងចំណោម នោះមាន១៣ នាក់ជាកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារទៅកាន់មន្ទីរសន្តិសុខ ឬ ទៅវត្ត ដូនបា ពីវត្តដូន បា ដែលជាកន្លែងដែលយោធាភូមិភាគនិរតីដឹកពួកគេទៅមន្ទីរសន្តិសុខ ដោយម្នាក់ ដឹកសមាជិក គ្រួសារចំនួន ៣ នាក់នៃកម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបានដកចេញ និង ជនម្នាក់ ទៀតដែល មិនស្គាល់អត្តសញ្ញាណ។ ម្នាក់ទៀតដឹកកម្មាភិបាលភូមិភាគពាយ័ព្យ ប្រពន្ធ និង កូន៣ នាក់។ អ្នក ទីបីដឹកកម្មាភិបាលភូមិភាគពាយ័ព្យម្នាក់ ព្រមទាំង សមាជិកគ្រួសារចំនួនបួននាក់[1593]។

590. ទោះបីជាគេមិនអាចផាត់ចោលការរៀបរាប់របស់ ប៊ី ពឿត ដោយផ្អែកលើភាពមិនប្រាកដប្រជា នៃ កាលបរិច្ឆេទនៃការមកដល់របស់វៀតណាមនៅតំបន់នេះក្តី ការរៀបរាប់របស់ ប៊ី ពឿត ទាក់ទិន នឹងហេតុការណ៍ដែលបានកើតឡើង យ៉ាងហោចណាស់មួយផ្នែក ក្រៅពីយុត្តាធិការពេលវេលា របស់តុលាការ ហើយក៏មិនទំនងដែរថា គ្មាននរណាម្នាក់ដែលគាត់បានឃើញជាប់ឃុំឃាំង ត្រូវ បានយកទៅទីតាំងនោះ នៅចំថ្ងៃ ឬមុនថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ហើយ លើសពីនេះទៀត ក៏មិន ទំនងដែរថា លក្ខខណ្ឌដែលគាត់ និងអ្នកដទៃ ជួបប្រទះ ត្រូវបានកំណត់ចេញនៅក្រោយថ្ងៃទី០៦ ខែ មករា ឆ្នាំ១៩៧៩ ជាពិសេសនៅពេលពិចារណាលើភ័ស្តុតាងរបស់ ទុំ ភើយ។ តាមការប៉ាន់ ប្រមាណកម្រិតអប្បបរមាផ្អែកលើការរៀបរាប់ដំណើររឿង និងកត្តាផ្សេងៗខាងលើ យ៉ាងហោច ណាស់មានមនុស្សចំនួន ១០០ នាក់ត្រូវបានឃុំឃាំងនៅទីតាំងនោះ នៅក្នុងយុត្តាធិការពេលវេលា របស់តុលាការ។

*ការធ្វើមនុស្សឃាត*

[1593] ឯកសារ **D219/513** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀន ស៊ឹម ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149385 ឆ.៣៩-ឆ.៤២ *បញ្ជាក់អះអាង* ឯកសារ **D219/456** របាយការណ៍ស្តីពីសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ERN ERN 01215926 (ស៊ាន សឿម និង សៀន ស៊ឹម ជាមនុស្សតែម្នាក់ *សូមមើល* ឯកសារ **D219/519** របាយការណ៍ស្តីពី សកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01218571)។ ឯកសារ **D219/514** កំណត់ហេតុនៃការស្តាប់ ចម្លើយសាក្សី សៀន ស៊ឹម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149390-01149391 ឆ.១-ឆ.៤។ ឯកសារ **D118/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882717-00882719 ឆ.១០-ឆ.១១។ ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882711 ឆ.២៤-ឆ. ២៧។

591. សាក្សីម្នាក់បានឮប្រធានភូមិប្រាប់បន្ទាប់ពីត្រឡប់ពីប្រជុំនៅស្រុកថា អ្នកដែលគេបញ្ជូនទៅមន្ទីរសន្តិសុខគាស់ក្រឡ *"នឹងមិនអាចដោះលែងទេ"*[1594] ។ ភស្តុតាងខាងក្រោមគាំទ្រសេចក្តីសន្និដ្ឋានថា ការធ្វើមនុស្សឃាតទ្រង់ទ្រាយធំបានកើតឡើង។

592. ប៊ី ពឿត បានសង្កេតឃើញយោធាហៅអ្នកជាប់ឃុំឃាំងពីរោងដោយប្រាប់ថាឲ្យត្រឡប់ទៅភូមិវិញ និងឃើញពួកគេត្រឡប់មកវិញដោយមានដៃប្រឡាក់ឈាម ហើយគាត់ខ្លួនឯងបានរួចផុតពីការសម្លាប់ទ្រង់ទ្រាយធំដែលមានអ្នកទោសប្រមាណ១០០នាក់ យ៉ាងហោចណាស់ពាក់កណ្ដាលនៃអ្នកទោសទាំងនោះពាក់ព័ន្ធនឹងឪពុករបស់គាត់ ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ[1595]។ ទោះបីយ៉ាងណាក៏ដោយ គេមិនអាចផាត់ចោលថា ហេតុការណ៍ទាំងនេះបានកើតឡើងនៅក្រៅយុត្តាធិការពេលវេលារបស់តុលាការ ប៉ុន្តែ ទោះបីជាមិនអាចបង្កើតជាមូលដ្ឋាននៃបទចោទក្នុងបរិបទនេះក្ដី ក៏នេះគឺជាភស្តុតាងប្រយោលដែលថា មនុស្សឃាតបានកើតឡើងនៅទីតាំងនេះរហូតដល់ជិតចប់របបកម្ពុជាប្រជាធិបតេយ្យ[1596]។ ទន្ទឹមនឹងនេះ ក៏មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ការសម្លាប់ដទៃទៀតបានកើតឡើងមុនហេតុការណ៍នេះទៀត។ សាក្សីម្នាក់បានឮដោយផ្ទាល់ពីអ្នករស់រានមានជីវិតម្នាក់នៃហេតុការណ៍ស្រដៀងគ្នាមួយ មុនពេលវៀតណាមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ០៧ ខែមករា ឆ្នាំ១៩៧៩ ដែលបានលើកឡើងថា មានមនុស្ស ៧៥ នាក់ ត្រូវបានគេនាំពីមន្ទីរ សន្តិសុខទៅកាន់កន្លែងសម្លាប់ភាគខាងលិច ដែលនៅទីនោះយ៉ាងហោចណាស់ មានមួយចំនួន ត្រូវបានប៉ោង អារក[1597]។ ការរៀបរាប់នេះត្រូវបានគាំទ្រមួយផ្នែកដោយការលើកឡើងរបស់សាក្សីម្នាក់ទៀត ទោះបីវាទំនងជាពាក្យចចាមអារ៉ាមក្តី ដោយគាត់មិនបានប្រាប់ថា គាត់ដឹងអំពីការ សម្លាប់នោះដោយរបៀបណាទេ ហើយបាននិយាយថា គាត់មិនបានចូលទៅក្នុងមន្ទីរសន្តិសុខនោះ ញឹកញាប់ ហើយគាត់បានប្រាប់ឈ្មោះអ្នករស់រានមានជីវិតពីការសម្លាប់នេះដូចគ្នា ដោយរៀប រាប់

---

[1594] ឯកសារ **D118/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ERN 01023824 ឆ.៥។

[1595] ឯកសារ **D219/624** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ី ពឿត ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ERN 01184279-01184280 ឆ.១, ឆ.៥ ERN 01184281-01184282 ឆ.១៣។ ឯកសារ **D219/625** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ី ពឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184289 ឆ.៤ ERN 01184290-01184291 ឆ.៩-ឆ.១៦។

[1596] ឯកសារ **D219/625** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ី ពឿត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ERN 01184294 ឆ. ៣០។

[1597] ឯកសារ **D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ERN 00882712 ឆ .៣០-ឆ.៣១។

ស្រដៀងគ្នាអំពីការគេចខ្លួន និងរៀបរាប់ស្រដៀងគ្នាអំពីវិធីសម្លាប់[1598]។ សាក្សីម្នាក់ទៀត ត្រូវបានកម្មាភិបាលខ្មែរក្រហមប្រាប់អំពីការសម្លាប់សមាជិកគ្រួសារគាត់ចំនួនពីរនាក់នៅមន្ទីរ សន្តិសុខនោះនៅក្នុងហេតុការណ៍ផ្សេងគ្នាមួយភ្លាមៗក្រោយពីកម្មាភិបាលភូមិភាគនិរតីមកដល់ តំបន់នេះ[1599]។

593. សាក្សីបីរូបបានឃើញសាកសពនៅក្នុងទីតាំង និងជុំវិញទីតាំងនោះក្នុងរង្វង់ពេល១២ខែនៅចុងរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សីទីមួយបានប៉ាន់ស្មានថាមានរណ្ដៅចំនួន ១០ ដែលមានទទឹង ៣ ម៉ែត្របណ្ដោយ ៤ ម៉ែត្រ ដោយក្នុងរណ្ដៅនីមួយៗ គាត់រាប់ឃើញ ២០ ទៅ ៣០ សាកសព[1600]។ សាក្សីទីពីរឃើញមនុស្សជីករកវត្ថុមានតម្លៃនៅជិតវត្ត និងប៉ាន់ប្រមាណថា មានសាកសពរាប់រយ[1601]។ សាក្សីទីបីឃើញលលាដ៏សាកសពពី ៤ ទៅ ១០ លៀនចេញពីរណ្ដៅសាកសពរួមចំនួន២ ដោយរណ្ដៅនីមួយៗមានទំហំ ៥ គុណនឹង ៦ ម៉ែត្រ ស្ថិតនៅផ្នែកខាងកើតបរិវេណវត្ត[1602]។ សាក្សីទីបួនបានរកឃើញរណ្ដៅ ក.ស.ច.ស ដែលមានទំហំផ្សេងៗគ្នា នៅខាងក្នុង និងក្រៅបរិវេណវត្ត ដែលគាត់ឃើញដំបូងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយពីកម្មាភិបាលភូមិភាគនិរតីមកដល់តំបន់នោះ[1603] ហើយសាក្សីទីប្រាំ ថាបានឃើញរណ្ដៅ "ជាច្រើន" ដែលមានសាកសព នៅក្នុងបរិវេណនោះ។ ប៉ុន្តែ មិនច្បាស់ទេថា នៅពេលណាដែលគាត់សង្កេតឃើញបែបនេះនោះ[1604]។

---

[1598] ឯកសារ **D118/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882719-00882720 ឆ.១៧។

[1599] ឯកសារ **D118/3** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេក អេម ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ERN 00882700-00882701 ឆ.១១-ឆ.១៤។

[1600] ឯកសារ **D219/514** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៀន ស៊ីម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149392 ឆ.១២-ឆ.១៣ *បញ្ជាក់អះអាង* ឯកសារ **D219/456** របាយការណ៍ស្ដីពីសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ERN ERN 01215926។

[1601] ឯកសារ **D219/517** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សយ ឈឿន ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149430 ឆ.១០៥-ឆ.១០៦។

[1602] ឯកសារ **D219/547** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆន ឡូញ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01157559 ឆ.៤៩-ឆ.៥២។

[1603] ឯកសារ **D118/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ ភើយ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៣ ERN 00882720-00882721 ឆ.១៨-ឆ.២១។

[1604] ឯកសារ **D118/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាយ អេង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ERN 01023825 ឆ.១០។

594. ដោយហេតុថា យ៉ាងហោចណាស់ ការសម្លាប់សំខាន់មួយមិនអាចមិនថា បានកើតឡើងក្រៅយុត្តាធិការពេលវេលារបស់តុលាការ ហើយភ័ស្តុតាងផ្សេងទៀតនៃមនុស្សឃាតផ្អែកលើពាក្យចចាម អារ៉ាមនោះ ភ័ស្តុតាងអំពីចំនួនជនរងគ្រោះមិនមានភាពច្បាស់លាស់ទេ។ ប៉ុន្តែ នៅពេលពិចារណា រួមគ្នាជាមួយនឹងភ័ស្តុតាងអំពីរណ្តៅ គេអាចសន្និដ្ឋានបានថា មនុស្សជាច្រើនត្រូវបានសម្លាប់នៅ មន្ទីរសន្តិសុខនោះ ក្រោយពេលកម្មាភិបាលភូមិភាគនិរតីមកដល់ និងថា ការសម្លាប់នោះបន្ត រហូតដល់ជិតថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។

*ទស្សនកិច្ចរបស់ យឹម ទិត្យ*

595. ពុំមានភ័ស្តុតាងបញ្ជាក់ថា យឹម ទិត្យ មកទស្សនកិច្ចមន្ទីរសន្តិសុខទេ។

*៥.៥.២.២. សហករណ៍ធិបតី (រួមមានមន្ទីរសន្តិសុខវត្តធិបតី និង មន្ទីរសន្តិសុខទួលម្ទេស និងការដ្ឋានទួលម្ទេស*

596. សហករណ៍ធិបតីស្ថិតនៅជុំវិញភ្នំធិបតីក្នុងឃុំធិបតី ស្រុកគាស់ក្រឡ តំបន់១ ភូមិភាគពាយ័ព្យ[1605]។ សហការណ៍នេះមានទំហំ យ៉ាងហោចណាស់ មួយរយហិកតា និងមាន៤ភូមិ គឺ ភូមិជើងទេញ ភូមិតាថុក ខាងលិចភ្នំធិបតី ភូមិឆាយបល្ល័ង្គ នៅភាគពាយ័ព្យ និង ភូមិថ្មី នៅទិសខាងកើត[1606]។ ភូមិ

---

[2243] ឯកសារ **D219/225** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] សៀង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៥ ERN 01075697-01075711 ឆ.២, ឆ.១២-ឆ.៨៤ ERN 01075712 ឆ.៨៦-ឆ.៨៩។ *សូមមើលផងដែរ* ឯកសារ **D219/344** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ភេ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ERN 01102906 ឆ.៥៧ ERN 01102909 ឆ.៨៣។

[2244] ឯកសារ **D219/344** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ភេ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ERN 01102909-ERN 01102911 ឆ.៨៥-ឆ.១០៤។

[2245] ឯកសារ **D219/587** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ប៉ាន់ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01167528-01167530 ឆ.១១១-ឆ.១១៤, ឆ.១១៦, ឆ.១១៨-ឆ.១២៣។

៥. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត បានរៀបរាប់អំពីហេតុការណ៍មួយ ដែលហាក់ដូចជាហេតុការណ៍ដដែល ប៉ុន្តែគាត់ហាក់ដូចជាគិតថា ហេតុការណ៍នេះកើតឡើងនៅចុងខែមករា ឆ្នាំ១៩៧៩៖ គឺហេតុការណ៍ដែលមានអ្នកដែលជម្លៀសមកពីភូមិភាគបូព៌ារាប់ពាន់នាក់ ត្រូវបានប្រមូលផ្តុំនៅក្នុងក្រោលមួយ ដែលស្ថិតនៅខាងត្បូងវត្តស្រោង ក្នុងភូមិស្វាយ សហករណ៍ស្រោង បន្ទាប់ពីមានការប្រកាសតាមមេក្រូថា មានការរៀបចំពិធីបុណ្យ។ អ្នកដាក់ពាក្យសុំដែលបានរត់គេចរួចបានរម្លឹកថា មានការបញ្ជូនសន្តិសុខទៅក្នុងក្រោល ដែលពួកគេខ្លះមានប្រដាប់ទៅដោយកាំបិតនិងដំបង។ អ្នកជិះសេះនៅចាំខាងក្រៅ ត្រៀមចាំបាញ់អ្នកណាដែលព្យាយាមរត់គេច។ នៅពេលដែលអ្នកដែលជម្លៀសមកពីភូមិភាគបូព៌ា ចូលទៅដល់ក្នុងក្រោលហើយ ពួកគេត្រូវបានគេវាយដល់ស្លាប់និងបាញ់។ គាត់ក៏បានរម្លឹកផងដែរថា មានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់[2246]។ ដោយផ្អែកលើព័ត៌មានមុនៗ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះប្រហែលជាចាំកាលបរិច្ឆេទខុស។

822. ព័ត៌មានទាំងអស់នេះនៅពេលពិនិត្យរួមគ្នាបង្ហាញថា ការសម្លាប់ដែលកើតឡើងនៅក្រោលមួយ នៅក្បែរព្រៃក្របៅ នៅក្នុងអំឡុងពេលមួយខែ ឬមិនដល់មួយខែ មុនពេលដែលវៀតណាមមកដល់។

823. នៅចុងឆ្នាំ១៩៧៨ និងនៅក្រោយពេលដួលរលំ នៃរបបកម្ពុជាប្រជាធិបតេយ្យ គេសង្កេតឃើញមានក្រមាពណ៌ខៀវនៅក្នុងចំណោមសាកសព នៅព្រៃក្របៅ[2247]។

824. ចំនួននៃការសម្លាប់ខ្មែរក្រោមនៅព្រៃក្របៅ ចាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ដាច់ឆ្នាំ១៩៧៨ គឺមានដូចតទៅ៖ ១០០នាក់ (កថាខណ្ឌ ៨១៤) ២០០នាក់ (កថាខណ្ឌ ៨១៥) ១០០០នាក់ (កថាខណ្ឌ ៨១៦) ៤០នាក់ (កថាខណ្ឌ ៨១៧) និងបួននាក់ (កថាខណ្ឌ ៨១៨) ដែលសរុបទៅគឺមានចំនួន **១៣៤៤** នាក់។ អ្នកដែលជម្លៀសមកពីភូមិភាគបូព៌ា ២០០០នាក់ ក៏ត្រូវបានសម្លាប់ផងដែរ នៅក្នុងក្រោលមួយនៅក្បែព្រៃក្របៅ ដែលប្រហែលជាអាចច្រើនជាងនេះផងក៏ថាបាន។ ហេតុដូច្នេះការប៉ាន់ប្រមាណបែបចង្អៀតគឺថា ជនរងគ្រោះ **៣៣៤៤** នាក់ ត្រូវបានសម្លាប់នៅព្រៃក្របៅ។

---

[2246] ឯកសារ **D118/126** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៣ ERN 00955753-00955754 ឆ.៤៩-ឆ.៥៧ *បញ្ជាក់អះអាង*ឯកសារ **D5/197** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ី សារឿន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១០ ERN 00571256។

[2247] ឆ្នាំ១៩៧៨៖ ឯកសារ **D118/127** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពៅ ស៊ីនួន ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ERN 00955769-00955770 ឆ.៤៦-ឆ.៥១។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ៖ ឯកសារ **D118/213** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យឹម ខុន ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ERN 00982139 ឆ.១០២។

825. ចំនួនទាំងអស់នេះត្រូវបានគាំទ្របន្ថែម ដោយភស្តុតាងនៃផ្នូរកប់សពរួម។ ឧទាហរណ៍នៅក្នុងឆ្នាំ ១៩៧៨ សាក្សីបានឃើញសាកសពឥតសម្លៀកបំពាក់ ដែលភាគច្រើនជានារី នៅគរពេញព្រៃក្រៅ ដោយសាកសពខ្លះមានមុខរបួស និងស្លាកស្នាមកាំបិតផ្គាក់។ អតីតឈ្លបស្រោងបានរៀបរាប់អំពី "*សាកសពរាប់រយនាក់*"[2248]។ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យបន្តិច សាក្សីពីររូបបានឃើញ សាកសពមិនទាន់កប់ ឆ្អឹងនិងលលាដ៍ក្បាលនៅរាយប៉ាយពាសពេញដី និងនៅក្នុងរណ្តៅដែលមិន បានលប់ នៅព្រៃក្របៅ[2249]។ នៅក្នុងឆ្នាំ១៩៧៩ មានការដឹកជញ្ជូនឆ្អឹងប្រមាណ៣ទៅ៤ត្រាក់ទ័រទៅ ចេតិយ[2250]។ សាក្សីម្នាក់ដែលបានឃើញឆ្អឹង និងអដ្ឋិធាតុនៅទីតាំងសម្លាប់មនុស្ស បន្ទាប់ពី អ៊ុនតាក់មកដល់ បានប៉ាន់ប្រមាណថា មានសាកសពប្រហែល២០០ទៅ៣០០[2251]។

*ការចុះពិនិត្យរបស់ យឹម ទិត្យ*

826. មិនមានភស្តុតាងអំពីការចុះពិនិត្យរបស់ យឹម ទិត្យ នៅព្រៃក្របៅឡើយ។

*៥.៥.៣.៥. ទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សី*

827. វត្តច័ន្ទរង្សីដែលគេហៅផងដែរថាវត្តរំលេច ស្ថិតនៅក្នុងភូមិរំលេច ឃុំរំលេច ស្រុកបាកាន តំបន់ ២[2252]។

---

[2248] ឯកសារ **D219/225** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] សៀង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៥ ERN 01075697 ឆ.២ ERN 01075705 ឆ.៥១។ ឯកសារ **D118/127** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពៅ ស៊ីនួន ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ERN 00955769 ឆ.៤៦-ឆ.៤៧។

[2249] ឯកសារ **D118/177** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លន ហេង ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤ ERN 00973984 ឆ.៧៤-ឆ.៧៥។ ឯកសារ **D219/223** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួន រិន ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ERN 01075617 ឆ.៧៥។

[2250] ឯកសារ **D219/664** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ផន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ERN 01198091 ឆ.៤៩ ERN 01198093 ឆ.៦៨។ ឯកសារ **D118/188** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទិត សុផារី ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ERN 00977012 ឆ.៣១-ឆ.៣២។ ឯកសារ **D118/124** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី Kim So ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ERN 00955720 ឆ.១០៧។

[2251] ឯកសារ **D118/13** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងសម្លាប់មនុស្សព្រៃក្របៅ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ERN 00901541-00901542។

[2252] ឯកសារ **D118/14** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សី និងរណ្តៅសាកសពរួមភូមិកួនត្នោត ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ERN 00901544-00901546។

828. អ្នកដែលជម្លៀសមកពីភូមិភាគបូព៌ាមួយក្រុម ត្រូវបានសម្លាប់នៅវត្តច័ន្ទរង្សី បន្ទាប់ពីកងកម្លាំងវៀតណាមបានមកដល់ខេត្តពោធិ៍សាត់ហើយ[2253] ដែលហេតុការណ៍នេះមិនកើតឡើង នៅមុនថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ឡើយ[2254]។ ហេតុដូច្នេះការសម្លាប់ទាំងអស់នេះ កើតឡើងក្រោយយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

**៥.៥.៤. តំបន់៣**

*៥.៥.៤.១. មន្ទីរសន្តិសុខវត្តគិរីរម្យ*

*ទីតាំងនិងការបង្កើត*

829. មន្ទីរសន្តិសុខវត្តគិរីរម្យ ស្ថិតនៅក្នុងឃុំភ្នំសំពៅ ស្រុកភ្នំសំពៅ ក្នុងតំបន់៣ នៃភូមិភាគពាយ័ព្យ[2255]។

---

[2253] ឯកសារ **D118/217** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សំ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ERN 00982195 ឆ.៥៩-ឆ.៦២។ ឯកសារ **D118/122** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចឹក ប៊ុនរឿន ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ ERN 00955685-00955686 ឆ.៥៤-ឆ.៥៧។ ឯកសារ **D118/1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សឿម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ERN 00872598ឆ.១៦។ ឯកសារ **D219/639** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កែវ ម៉ី ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ERN 01186828 ឆ.៦៣-ឆ.៦៤ ERN 01186829 ឆ.៧១-ឆ.៧៣។ ឯកសារ **D6.1.143** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩ ERN 00273432-00273433។ *សូមប្រៀបធៀបជាមួយ* ឯកសារ **D219/664** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ផន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ERN 01198096 ឆ.៩៨-ឆ.១០២។ ឯកសារ **D118/216** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង្ស ង៉ែត ERN 00982180-00982181 ឆ.៧៥-ឆ.៧៨។

[2254] សូមមើល ឯកសារ **D219/396** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សិន បាន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៥ ERN 01114716-01114717 ឆ.១២។ ឯកសារ **D219/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ចិន្តា ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ ERN 01032628 ឆ.១៤៩-ឆ.១៥០។ ឯកសារ **D219/263** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ERN 01086102-01086103 ឆ.១០៩-ឆ.១១០។ ឯកសារ **D118/136** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៉ា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ERN 00960666 ឆ.២០។

[2255] ឯកសារ **D6.1.150** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ERN 00365714-00365716។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304359។ ឯកសារ **D6.1.173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សារឿន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197931។ ឯកសារ **D118/76** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុច ពន្លក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ERN 00934375 ឆ.៨។ ការសរសេររបៀបផ្សេងទៀត៖ Phnom Sampeou/Sampov សូមមើលសម្រង់ខាងដើមក្នុងជើងទំព័រនេះ និងសម្រង់ក្នុងជើងទំព័របន្ទាប់។

830. មន្ទីរសន្តិសុខមានទីកន្លែងឃុំឃាំង២ ដែលដំណើរការរួមគ្នា៖ វត្តគិរីរម្យនៅលើកំពូលភ្នំសំពៅ និងទីកន្លែងឃុំឃាំងនៅក្នុងជ្រលងភ្នំ ដែលនៅចម្ងាយប្រហែល២០០ ទៅ៣០០ម៉ែត្រភាគខាងលិច ផ្នែកក្រោមបំផុតនៃជណ្តើរឡើងទៅភ្នំសំពៅ ដែលកសាងដោយកម្មាភិបាលភូមិភាគនិរតី នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨[2256]។ គុកនេះគេហៅថាចន្លោះក្តោង ឬ "*កន្លែងនគរបាល*" ដែលជាតំបន់មួយមានទំហំប្រហែល២០០ ទៅ៥០០ម៉ែត្រ ហើយហ៊ុំព័ទ្ធដោយរបងលួសបន្លា កម្ពស់២ម៉ែត្រកន្លះ ហើយមានអគារធំៗចំនួន៥ និងអគារតូចៗមួយចំនួន[2257]។

831. នៅលើកំពូលភ្នំសំពៅ ប្រមាណ៧០ម៉ែត្រពីវត្តគិរីរម្យ មានរូងភ្នំចំនួន៣ ដែលត្រូវបានប្រើប្រាស់ជារណ្តៅសពរួម៖ ល្អាងតែងខ្លួន ល្អាងល្ខោន និងល្អាងកង្កែប[2258]។

---

[2256] <u>ចន្លោះក្តោង</u>៖ ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912, 00197913។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។ ឯកសារ **D6.1.166** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន ជឿន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197887, 00197891-00197892។ ឯកសារ **D6.1.172** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផេ សឿ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197908។ *សូមមើលផងដែរ* ឯកសារ **D219/415** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌី ពៀច ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ ERN 01117343 ឆ.១ ERN 01117344-01117346 ឆ.៣ ERN 01117346-01117347 ឆ.៤, ឆ.៦, ឆ.៨, ឆ.៩។ <u>តាមអ្នកភូមិក្នុងមូលដ្ឋាន ចន្លោះក្តោងសំដៅផងដែរដល់ "កន្លែងនគរបាល"</u>៖ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242226។ ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912។ ឯកសារ **D6.1.172** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផេ សឿ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197908។ <u>ប្រហែលជាមានមន្ទីរឃុំឃាំងមួយនៅ *"កន្លែងមន្ទីរឃុំចាស់ នៅខាងជើងចម្ងាយ ៥០០ ទៅ ៦០០ ម ពីវត្តគីរីរម្យ"* ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងពីទីតាំងនេះទេ</u>៖ ឯកសារ **D118/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទឹម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ERN 00951933 ឆ.៦០-ឆ.៦៣។

[2257] ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200325-01200326 ឆ.៧៤។ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242226។ ឯកសារ **D6.1.173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សារឿន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197931។ ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242231។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។ ឯកសារ **D6.1.172** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផេ សឿចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197908។

[2258] ឯកសារ **D6.1.150** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ERN 00365717-00365723។ ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212422។ ឯកសារ **D6.1.167** កំណត់ហេតុនៃការស្តាប់ចម្លើយ

832. ទោះបីជាចន្លោះក្តោងត្រូវបានសាងសង់ នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ក្តី តែសាក្សីបានឃើញគេចាប់មនុស្សយកទៅភ្នំសំពៅ នៅពាក់កណ្តាលឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដែលការនេះបង្ហាញថា វត្តគិរីរម្យមានដំណើរការជាមន្ទីរសន្តិសុខ នៅក្រោមកម្មាភិបាលភូមិភាគពាយ័ព្យ[2259]។ ទីកន្លែងទាំង២នៅតែមានដំណើរការ រហូតដល់ពេលកងទ័ពវៀតណាមចូលមកដល់តំបន់ នៅក្នុងខែមករា ឆ្នាំ១៩៧៩[2260]។

*វចនាសម្ព័ន្ធនិងបុគ្គលិក*

833. មន្ទីរសន្តិសុខវត្តគិរីរម្យ ត្រូវបានយាមកាមដោយឈ្លប ប្រដាប់ដោយអាវុធ ដែលឆ្នាំខ្លះជាមនុស្សពេញវ័យ ឯឆ្នាំខ្លះទៀតជាកុមារនិងមនុស្សវ័យជំទង់ អាយុចន្លោះពី១២ ទៅ១៧ឆ្នាំ[2261]។

834. មិនមានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់កំណត់អំពីកម្រិត នៃឋានានុក្រមណាមួយរបស់ ប.ក.ក ដែលគ្រប់គ្រងលើមន្ទីរសន្តិសុខ។ អ្នកភូមិនៅទីនោះម្នាក់បានបញ្ជាក់ថា ទីតាំងនេះស្ថិតក្រោមការគ្រប់

---

សាក្សី ប៉ែន លាប ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197924។ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242227។ ឯកសារ **D6.1.169** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197904។

[2259] <u>ពាក់កណ្តាលឆ្នាំ១៩៧៦</u>៖ ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197917។ <u>ដើមឆ្នាំ១៩៧៧</u>៖ ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242230-00242231។ ឯកសារ **D219/651** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិច ពេក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៦ ERN 01196499-01196500 ឆ.៣៣-ឆ.៣៧។ *សូមប្រៀបធៀបជាមួយ* <u>ឆ្នាំ១៩៧៥</u>៖ ឯកសារ **D6.1.115** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ERN 00221547។ ឯកសារ **D6.1.118** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុច ភ្លី ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ERN 00221591។ *ផ្ទុយពី* ឯកសារ **D6.1.165** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197884។

[2260] ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242227។ ឯកសារ **D6.1.118** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុច ភ្លី ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ERN 00221593។ ឯកសារ **D6.1.115** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ERN 00221547។ ឯកសារ **D6.1.116** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេស ប៉ាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ERN ERN 00221599-00221600។

[2261] ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200319 ឆ.៤៩។ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242226-00242227។ ឯកសារ **D6.1.169** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197903។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។

គ្រងរបស់ស្រុកភ្នំសំពៅ ប៉ុន្តែមូលដ្ឋាននៃការដឹងឮរបស់គាត់ មានភាពមិនច្បាស់លាស់ទេ[2262]។ សាក្សីម្នាក់ទៀតបញ្ជាក់ថា បុរសម្នាក់ឈ្មោះ តាអេង ទទួលខុសត្រូវលើការសម្លាប់មនុស្ស នៅភ្នំសំពៅ។ សាក្សីបានបញ្ជាក់ថា គាត់ធ្លាប់ជួបតាអេង នៅក្នុងឆ្នាំ១៩៧៥ ហើយថា នៅពេលក្រោយមក មានកងទ័ពម្នាក់បានប្រាប់គាត់ថា តាអេង ជាប្រធាននគរបាលភ្នំសំពៅ និងជា "*អ្នកសម្លាប់មនុស្សនៅទីនោះ*"[2263]។ ទោះជាយ៉ាងនេះក្តី បើទោះបីជាភស្តុតាងចចាមអារ៉ាម ដែលមិនមានការគាំទ្រនេះ អាចត្រូវបានទទួលយកក្តី ប៉ុន្តែនៅតែមានភាពមិនច្បាស់លាស់ ថាតើតាអេង មានតួនាទីអ្វីទាក់ទងមន្ទីរសន្តិសុខវត្តគិរីរម្យ។ ភស្តុតាងមិនអាចឱ្យទាញសន្និដ្ឋានបានអំពីការភ្ជាប់ទីតាំងនេះទៅនឹងឋានានុក្រមរដ្ឋបាលៈ គឺ មិនមានការចង្អុលបង្ហាញថា នេះគឺជាទីតាំងកម្រិតភូមិភាគ ហើយក៏មិនច្បាស់លាស់ថាតើនេះ គឺជាទីតាំងកម្រិតស្រុក ឬកម្រិតតំបន់។ ទោះជាយ៉ាងណាក្តី ក្នុងករណីណាក៏ដោយ ក៏ទីតាំងនេះស្ថិតក្នុងតំបន់៣ ហើយដោយមិនមានភស្តុតាងបង្ហាញថា ទីតាំងនេះត្រូវបានកំណត់ទៅតំបន់ ៤ ឬតំបន់៥វិញនោះ គឺប្រាកដណាស់ថា ទីតាំងនេះស្ថិតនៅជាផ្នែកមួយ នៃខ្សែចង្វាក់បញ្ជារបស់តំបន់នោះ។

*ការចាប់ខ្លួននិងការឃុំខ្លួន*

835. ភស្តុតាងអនុញ្ញាតឱ្យមានការសន្និដ្ឋានថា បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីមកដល់ កម្មាភិបាលភូមិភាគពាយ័ព្យនៅស្រុកភ្នំសំពៅ ត្រូវបានចាប់ខ្លួនហើយមនុស្សជាច្រើនបានបាត់ខ្លួន[2264] ប៉ុន្តែ

[2262] ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197919។

[2263] ឯកសារ **D219/697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណូក ឆៀត ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01210556 ឆ.១៨ ERN 01210558 ឆ.៣៦។

[2264] *សូមមើលឧទាហរណ៍* ឯកសារ **D118/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920194 ឆ.២២។ ឯកសារ **D219/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួម សាវឿន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ ERN 01032092 ឆ.១២។ ឯកសារ **D6.1.117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌី ពៀច ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ERN 00221552។ ឯកសារ **D6.1.118** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុច ភ្លី ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ERN 00221590។ ឯកសារ **D6.1.127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុន ណាត់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242236។ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242225។ ឯកសារ **D219/415** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌី ពៀច ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ ERN 01117343 ឆ.១ ។ ឯកសារ **D118/67** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920202 ឆ.៣១-ឆ.៣២។ *សូមមើលផងដែរ* ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197919។ ឯកសារ **D6.1.173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សា

កាលៈទេសៈជាក់លាក់នៅតែមិនប្រាកដនៅឡើយ។ សាក្សីមួយរូបបានបញ្ជាក់ថា ពួកគេភាគច្រើនត្រូវបានយកទៅវត្តគិរីរម្យ ប៉ុន្តែមូលដ្ឋានដែលគាត់បានដឹងឮនោះ មានភាពមិនច្បាស់លាស់[2265]។ សាក្សីមួយរូបទៀតបានឮថា ពួកគេត្រូវបានសម្លាប់នៅលើកំពូលភ្នំសំពៅ ប៉ុន្តែភស្តុតាងចចាមអារ៉ាមនេះមិនមានប្រភពនោះឡើយ[2266]។ ថ្លឹងថ្លែងជារួម និងដោយចងចាំអំពីបទដ្ឋាន នៃការបង្ហាញភស្តុតាង នៅក្នុងដំណាក់កាលស៊ើបអង្កេត ភស្តុតាងគឺគ្រប់គ្រាន់ដើម្បីសម្រេចថា យ៉ាងហោចណាស់ក៏មានកម្មាភិបាលភូមិភាគពាយ័ព្យខ្លះ ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខវត្តគិរីរម្យ។

836. មនុស្សត្រូវបានដឹកតាមឡានធំ ទៅមន្ទីរសន្តិសុខវត្តគិរីរម្យ។ សាក្សី យ៉ង់ សារៀប ដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាមេកងកុមារនៅភូមិក្បែរនោះ បានឃើញ "*ឡានដំរីទឹក*" ដឹកអ្នកជាប់ឃុំទៅចន្លោះក្តោងម្តងក្នុងមួយថ្ងៃ នៅពេលល្ងាចឬយប់ រយៈពេលប្រហែលមួយខែ នៅពាក់កណ្តាលឆ្នាំ១៩៧៨[2267]។ ទោះបីជាគាត់មិនបានដឹងថា មានអ្នកជាប់ឃុំប៉ុន្មាននាក់ នៅលើឡានធំនោះក្តី តែគេអាចសន្និដ្ឋានបានថា ឡាននោះដឹកពេញប្រៀប ហើយអាចពិចារណាបាន ដោយសមហេតុផលថា ជាការត្រឹមត្រូវដែលឡានមួយដឹក យ៉ាងហោចណាស់បាន១៤នាក់ ព្រោះនៅចុងឆ្នាំ១៩៧៨ សាក្សីមួយរូបបានឃើញឆ្មាំគុក បណ្តើរមនុស្ស១៤នាក់ចុះពីលើឡាន ហើយនាំពួកគេឡើងជណ្តើរទៅវត្តគិរីរម្យ[2268]។ ដូច្នេះគឺមានមនុស្សសរុប ៤២០នាក់ (៣០ឡាន ហើយក្នុងមួយឡានមាន១៤នាក់) បើតាមព័ត៌មានរបស់ យ៉ង់ សារៀប។

837. សាក្សីម្នាក់ទៀតបានឃើញកម្មាភិបាល ប.ក.ក ដឹកអ្នកជាប់ឃុំ "*២ឡានពេញ*" ទៅភ្នំសំពៅ "*នៅថ្ងៃទី១៦ ឬ១៧ ខែមេសា*"[2269]។ ទោះបីជាមានលទ្ធភាពដែលថា សាក្សីបញ្ជាក់ហេតុការណ៍នេះក្នុងពេលវេលាខុស ដោយសារតែហេតុការណ៍នេះអាចកើតឡើងតាំងពីរាប់ខែ មុនពេលវៀតណាម

---

រឿន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197931។ ឯកសារ **D219/667** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន ម៉ឺន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ERN 01200334-01200335 ឆ.២២។

[2265] ឯកសារ **D6.1.172** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផេ សឿចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197908។

[2266] ឯកសារ **D219/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួម សារឿន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ ERN 01032092 ឆ.១២។

[2267] ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200322-01200323 ឆ.៥៨-ឆ.៦៤។

[2268] ឯកសារ **D6.1.115** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ERN 00221547។

[2269] ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242226-00242227។

មកដល់ក្តី តែផ្អែកលើភាពជាក់ស្តែង គឺចាំបាច់ត្រូវតែដកព័ត៌មាននេះចេញ ដោយសារវាតែស្ថិតក្រោយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

838. ភ័ស្តុតាងមានភាពមិនច្បាស់លាស់ អំពីចំនួនមនុស្សប៉ុន្មាននាក់ ដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ៖ ចន្លោះពីដើមឆ្នាំ១៩៧៧ រហូតដល់បញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ សាក្សីជាច្រើនរូបបានសង្កេតឃើញអ្នកជាប់ឃុំឃាំងត្រូវបានឆ្នាំប្រដាប់ដោយអាវុធបណ្តើរ ទាំងជាប់ច្រវាក់ ឡើងនិងចុះជណ្តើរទៅវត្តគិរីវង្សទាំងក្រុមៗ ដែលមានគ្នាពី៣ទៅ២០នាក់[2270]។ ដូចគ្នានេះនៅដើមឆ្នាំ១៩៧៨ ឈ្លបម្នាក់ដែលចែកថ្នាំពេទ្យឲ្យអ្នកភូមិ ដែលរស់នៅក្នុងជ្រលង បានឃើញមនុស្សប្រមាណ៥០ ទៅ៦០នាក់ ត្រូវបានឃុំឃាំងនៅចន្លោះក្តោង[2271]។ តួលេខនេះ នៅដើមឆ្នាំ១៩៧៨ ដោយមិន
មានហានិភ័យអំពីការរាប់ត្រួតគ្នា រួមបញ្ចូលទាំងអ្នកដែលមកដល់តាមឡានធំនៅពាក់កណ្តាលឆ្នាំ១៩៧៨ (៤២០នាក់) និងនៅចុងឆ្នាំ១៩៧៨ (១៤នាក់) អាចមានចំនួនសរុបយ៉ាងតិចបំផុតរហូតដល់ ៤៨៤ នាក់។

839. មន្ទីរសន្តិសុខវត្តគិរីវង្ស ឃុំឃាំងទាំងបុរសនិងនារី ហើយមានទាំងមនុស្សចាស់និងកុមារ ហើយការដាក់គុកនិងសូម្បីការសម្លាប់នៅមន្ទីរនោះ នៅពេលខ្លះ ត្រូវបានគេប្រើប្រាស់ជាការគំរាមកំហែង ដើម្បីឲ្យកម្មករគោរពតាម[2272]។ មានភ័ស្តុតាងចចាមអារ៉ាម ដែលមិនមានប្រភពថា អ្នកដែលត្រូវបានគេចោទប្រកាន់ពីទោសធ្ងន់ ត្រូវបានគេយកទៅវត្តគិរីវង្ស ចំណែកអ្នកដែលចោទ

---

[2270] ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912។ ឯកសារ **D6.1.166** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន ជឿន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197887-00197888។ ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212420-00212421។ ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242230-00242231។

[2271] ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។

[2272] ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។ ឯកសារ **D6.1.166** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន ជឿន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197888-00197889។ ឯកសារ **D6.1.165** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ អាន់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197884។ ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212421។ ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200318 ឆ.៤២។ ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197917។

ប្រកាន់ពីទោសស្រាល ត្រូវបានគេទុកនៅគុកចន្លោះក្តោង[2273]។ ការនេះគឺស្របគ្នាជាមួយភ័ស្តុតាងចចាមអារ៉ាមដែលអាចជឿជាក់បានជាងដទៃទៀត មកពីសាក្សីម្នាក់ដែលមេកងអនុសេនាតូចគាត់បានប្រាប់ថា វត្តគិរីរម្យត្រូវប្រើប្រាស់សម្រាប់សម្លាប់មនុស្ស ចំណែកឯចន្លោះក្តោងគឺជាទីតាំងលត់ដំកែប្រែ[2274] ព្រមទាំងភ័ស្តុតាងដែលថា ជាទូទៅ អ្នកជាប់ឃុំនៅចន្លោះក្តោងមិនជាប់ខ្នោះឡើយ ចំណែកអ្នកដែលគេនាំឡើងចុះភ្នំសំពៅ និងអ្នកដែលជាប់ឃុំឃាំងនៅក្នុងវត្ត ត្រូវជាប់ខ្នោះ[2275]។

*ស្ថានភាពនៃការឃុំឃាំង*

840. អ្នកជាប់ឃុំនៅចន្លោះក្តោង ត្រូវបានបង្ខំឲ្យវាយបំបែកថ្ម សែងថ្មកំបោរ ឬវត្ថុធ្ងន់ៗ ជីកប្រឡាយ ដាំបន្លែ ធ្វើរបង ព្រមទាំងចិញ្ចឹមជ្រូកនិងគោក្របី[2276]។ ទោះបីជាអ្នកជាប់ឃុំនៅចន្លោះក្តោង ជាទូទៅមិនជាប់ខ្នោះក្តី ប៉ុន្តែនៅពេលធ្វើពលកម្ម អ្នកខ្លះត្រូវបានគេដាក់ខ្នោះដៃ ឬច្រវាក់ជាប់គ្នា[2277]។ អ្នកជាប់ឃុំមើលទៅហេវហត់អស់កម្លាំង និងមិនមានសុខភាពល្អឡើយ[2278]។ មានម្តងម្កាលដែលអ្នក

---

[2273] ឯកសារ **D6.1.173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សារឿន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197932។ ឯកសារ **D118/67** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហួ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920202-00920203 ឆ.៣៧-ឆ.៣៨។

[2274] ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212421 ។

[2275] *សូមមើល* កថាខណ្ឌ ៨៣៨, ៨៤០-៨៤១។

[2276] <u>វាយថ្ម</u>៖ ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242231។ <u>សែងកំបោរថ្ម ឬវត្ថុផ្សេងៗ</u>៖ ឯកសារ **D6.1.169** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហួ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197904។ ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912។ <u>ជីកប្រឡាយ ធ្វើរបង ចិញ្ចឹមសត្វ</u>៖ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242226-00242227។ <u>ដាំបន្លែ</u>៖ ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912។

[2277] ឯកសារ **D6.1.169** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហួ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197903។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។ ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912។

[2278] ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242230-00242231។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។ ឯកសារ **D6.1.169** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហួ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197903។ ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912។

ជាប់ឃុំ ត្រូវបានគេបណ្តើរទាំងខ្សែ ចុះទៅប្រឡាយនៅជើងភ្នំ ដើម្បីមុជទឹក[2279]។ ពួកឆ្មាំឃាមវាយក្បាលពួកគេនឹងស្វាយកាំភ្លើងនិងដំបង ប្រសិនបើពួកគេដើរយឺតពេក[2280]។

841. នៅក្នុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៨ សាក្សី យ៉ង់ សារៀប បានទៅភ្នំសំពៅដើម្បីរកអាចម៍ប្រចៀវយកមកប្រើធ្វើជាជី ហើយគាត់បានឮសំឡេងមនុស្សស្រែក។ គាត់ដើរតាមសំឡេងដោយឆ្លងកាត់ព្រៃភ្នំ រហូតមកដល់វត្តគិរីរម្យ។ ទ្វារបង្អួចវត្តបើកចំហ ដែលធ្វើឲ្យគាត់អាចមើលទៅក្នុងឃើញអ្នកទោស៤ជួរ មួយជួរមានអ្នកទោស៨នាក់ ដែលត្រូវបានគេចងដៃព្យួរផុតពីដីប្រហែលមួយចំអាម[2281]។ នៅក្រោមអ្នកទាំងនោះ មានអ្នកជាប់ឃុំប្រហែល៣០ទៅ៤០នាក់ ដែលជើងជាប់ខ្នោះ ហើយដៃជាប់ចំណងស្ពាបសេក ដោយមានអ្នកខ្លះដេកទល់ខ្នងគ្នា និងអ្នកខ្លះទៀតទល់ជើងគ្នា[2282]។

842. សាក្សីជាច្រើននាក់បានឃើញអដ្ឋិធាតុ នៅវត្តគិរីរម្យ ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ។ នៅខាងក្នុងឬនៅក្បែរវិហារ គេឃើញខ្នោះជើង របារដែក ខ្នោះដៃ ខ្សែព្យួរ និងដំបង[2283]។

*ការសម្លាប់*

---

[2279] ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242231-00242231។ ឯកសារ **D6.1.172** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផេ សឿ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN 00197908។ ឯកសារ **D6.1.170** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ភិរុណ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197912។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឹន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។

[2280] ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឹន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360។ ឯកសារ **D118/64** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឹន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៣ ERN 00920177 ឆ. ១៥។ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242227។

[2281] ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200317 ឆ.៣៩, ឆ.៤១ ERN 01200318-01200319 ឆ.៤៥-ឆ.៤៦, ឆ.៤៧-ឆ.៤៨, ឆ.៥០ ERN 01200322 ឆ.៥៨-ឆ. ៥៩។

[2282] ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200318 ឆ.៤២។

[2283] ខ្នោះ៖ ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212422។ ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197920។ ដែកស្បែង៖ ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៨ ERN 00242231។ ខ្នោះដៃ ខ្សែព្យួរ និងដំបងឈើ៖ ឯកសារ **D6.1.166** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន ជឿន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197890។

843. ទោះបីជាមានការរឹតបន្តឹងលើការចូលទៅភ្នំសំពៅក្តី អ្នកភូមិនៅទីនោះបានដឹងថា វត្តគិរីរម្យគឺជាទីតាំងសម្លាប់មនុស្ស[2284]។

844. នៅពេលសាក្សី យ៉ង់ សារៀប ទៅវត្តគិរីរម្យនៅពាក់កណ្តាលឆ្នាំ១៩៧៨ គាត់បានឃើញឆ្មាំវះពោះអ្នកជាប់ឃុំម្នាក់ទាំងរស់ ដើម្បីយកថ្លើម។ មានទបង្ហូរឈាមចូលទៅក្នុងអាងធំមួយ។ យ៉ង់ សារៀប ឃើញមានឆ្នាំងមួយសម្រាប់ដាក់ថ្លើម បើទោះបីជាគាត់មិនបានដឹង ថាតើថ្លើមនោះជាថ្លើមមនុស្សមែនឬមិនមែនក្តី[2285]។ បន្ទាប់មកឆ្មាំបាននាំគាត់ទៅរូងភ្នំនៅក្បែរនោះ។ នៅរូងភ្នំល្អាងតែងខ្លួន យ៉ង់ សារៀប បានឃើញឆ្មាំចងដៃអ្នកជាប់ឃុំពីរនាក់ទៅក្រោយ ហើយវាយពួកគេនឹងកំណាត់ឈើ ហើយធាក់ពួកគេចូលទៅក្នុងរូងភ្នំ។ នៅរូងភ្នំល្អាងល្ហេន ឆ្មាំបានសម្លាប់អ្នកជាប់ឃុំជាមនុស្សពេញវ័យម្នាក់ នៅក្នុងលក្ខណៈដូចគ្នានេះ និងក្មេងពីរនាក់ ដែលត្រូវបានគេបោះចូលទៅក្នុងរូងភ្នំ ប៉ុន្តែទៅទើជាប់មែកឈើ។ យ៉ង់ សារៀប បានបញ្ជាក់ថា គាត់បានឃើញសាកសពកូនក្មេងស្អុយរលួយ នៅជាប់លើមែកឈើ នៅពេលដែលគាត់ត្រឡប់មកទីតាំងនោះវិញ នៅក្នុងឆ្នាំ១៩៨២[2286]។

845. ភស្តុតាងនេះត្រូវបានគាំទ្រមួយផ្នែក ដោយសាក្សីម្នាក់ផ្សេងទៀត ដែលបានទៅវត្តគិរីរម្យ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលអ្នកខ្លះទៅប៉ុន្មានសប្តាហ៍ក្រោយ ឯអ្នកខ្លះទៀតទៅប៉ុន្មានខែក្រោយការបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេបានឃើញអាងដែកនៅក្នុងវត្ត ដែលមានទបង្ហូរប្រឡាក់ដោយឈាម ដែលហូរកាត់ប្រឡោះមួយ នៅជញ្ជាំងខាងត្បូង សម្រាប់បង្ហូរទៅខាងក្រៅ ចូលទៅក្នុងអាងស្តុករាងការ៉េ៤ជ្រុងមួយ ដែលមានទំហំ៣ម៉ែត្រគុណ៣ម៉ែត្រ ហើយមាន

---

[2284] ឯកសារ **D6.1.165** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197884។ ឯកសារ **D219/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួម សារ៉ុន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ ERN 01032092 ឆ. ១២។ ឯកសារ **D6.1.362** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល សឺន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ERN 00304360 ។ ឯកសារ **D118/67** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹម ហូ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920202-00920203 ឆ.៣៧-ឆ.៣៨។ ឯកសារ **D219/515** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆឹន ឈួយ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01149400 ឆ.១៩។ *សូមមើលផងដែរ* ឯកសារ **D219/654** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ERN 01196544 ឆ.៧៦។

[2285] ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200327-01200319 ឆ.៣៨-ឆ.៤៦ ERN 01200322 ឆ.៥៨។

[2286] ឯកសារ **D219/666** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200322 ឆ.៥៧។

ឈាមកកនៅក្នុងនោះ[2287]។ នៅក្នុងអគារវិហារ មានសាកសពយ៉ាងតិច៥ ដែលនៅជាប់ខ្នោះជើង នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៩[2288]។ ភស្តុតាងអំពីសាកសពទាំងអស់នេះបង្ហាញថា ពួកគេគឺជាមនុស្ស ដែលគេទុកចោល ហើយក្រោយមកបានស្លាប់។ ដូច្នេះហើយមិនអាចសន្និដ្ឋានបានថា តើការស្លាប់ នេះកើតឡើងនៅក្រោយថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែរឬយ៉ាងណាទេ។

846. នៅល្អាងតែងខ្លួន ល្អាងល្ខោន និងល្អាងកង្កែប មានសាកសពរាប់រយ ដែលស្ថិតក្នុងស្ថានភាពរលួយ ខុសៗគ្នា[2289]។ សាក្សីម្នាក់ដែលបានឃើញ នៅក្នុងពាក់កណ្ដាលឆ្នាំ១៩៧៩ ថាលលាដ៍ក្បាល

---

[2287] ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212422 ។ ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242231។ ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197920។ ឯកសារ **D118/67** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920203 ឆ.៤០។ ឯកសារ **D6.1.163** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សួម ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197935។ ឯកសារ **D6.1.169** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197904។ ឯកសារ **D6.1.164** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គឹមលី ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197895។ ឯកសារ **D118/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920195 ឆ.២៦។

[2288] ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197920។ សូមមើលផងដែរ ឯកសារ **D6.1.167** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លាប ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197924។

[2289] ឯកសារ **D6.1.166** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន ជឿន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197889-00197890។ ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212422។ ឯកសារ **D6.1.168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197920។ ឯកសារ **D6.1.167** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លាប ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197924។ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242227។ ឯកសារ **D219/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួម សារ៉េន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ ERN 01032097 ឆ.៣៥។ ឯកសារ **D6.1.165** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197884។ ឯកសារ **D6.1.128** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242231។ ឯកសារ **D118/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920195 ឆ.២៦។ ឯកសារ **D347/2.1.25** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០១ [ព្រំ សារុន] ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ERN 01181340-01181341។ ឯកសារ **D6.1.115** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុច ពន្លក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ERN 00221547។ ឯកសារ **D118/67** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920203 ឆ.៤០។ ឯកសារ **D219/784** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ក្រាត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ERN 01300427-01300428 ឆ.៥៨, ឆ.៦០, ឆ.៦១។ ឯកសារ **D219/654** កំណត់ហេតុនៃ

ក្រោយបែក ក្នុងលក្ខណៈដែលអាចបង្ហាញថា លលាដ៍ក្បាលទាំងនោះ ត្រូវបានគេវាយនឹងឧបករណ៍ទាល ឬប៉ះទង្គិចខ្លាំងជាមួយផ្ទៃរឹង។ សាកសពទាំងនោះមើលទៅហាក់ដូចជាត្រូវបានគេគ្រវែងចូលក្នុងរូងភ្នំ ដោយក្បាលទៅមុន[2290]។ អ្នកខ្លះទៀត នៅពេលមួយក្នុងឆ្នាំ១៩៧៩ បានឃើញសាកសពដែលមានដៃជាប់ចំណងទៅក្រោយ[2291] និងឃើញឧបករណ៍ដែលប្រឡាក់ដោយឈាម នៅមាត់រូងភ្នំ ដូចជាកាំបិត កាំបិតផ្គាក់ ពូថៅ រនុករដែក និងបំពង់ទីបដែក[2292]។

847. មិនមានភាពប្រាកដថាតើ សាកសពទាំងអស់នោះ ដែលរកឃើញនៅក្នុងរូងភ្នំ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេសម្លាប់នៅមុន ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ដែរឬយ៉ាងណា។ ប៉ុន្តែមានភ័ស្តុតាងកាលៈទេសៈ និងភ័ស្តុតាងចចាមអារ៉ាមដែល នៅពេលគិតរួមគ្នា បានគាំទ្រដល់ការសម្រេចដែលថា ភាគច្រើន ឬអាចថាអ្នកជាប់ឃុំទាំងអស់ នៅមន្ទីរសន្តិសុខវត្តគិរីរម្យ ត្រូវបានសម្លាប់នៅមុនបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ។ មិនអាចរកឃើញថាមាន អ្នកជាប់ឃុំណាដែលនៅរស់រានមានជីវិតឡើយ ក្នុងពេលស៊ើបអង្កេត ហើយមិនមានប្រជាជននៅក្នុងមូលដ្ឋានណាម្នាក់ ដែលបានផ្តល់ភ័ស្តុតាងដល់ ក.ស.ច.ស ដែលអាចនាំដល់ការកំណត់អត្តសញ្ញាណ អ្នកនៅរស់រានមានជីវិតណាម្នាក់ឡើយ[2293]។ កម្មករម្នាក់មកពីទីកន្លែងនៅក្បែរនោះបានបញ្ជាក់ថា ការសម្លាប់ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ នៅក្នុងអំឡុងពេល២ទៅ៣ខែចុងក្រោយ មុនពេលកងទ័ពវៀតណាមមកដល់។ ទោះជាយ៉ាងនេះក្តី មិនមានភាពច្បាស់លាស់ថាតើ គាត់បានឃើញផ្ទាល់នូវហេតុការណ៍ទាំង

---

ការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ERN 01196544 ឆ.៧៦, ឆ.៧៧។ ឯកសារ **D219/689** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01205223-01205224 ឆ.១០៥-ឆ.១០៧។

[2290] ឯកសារ **D6.1.167** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លាប ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197924។

[2291] ឯកសារ **D6.1.163** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សួម ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197935។

[2292] ឯកសារ **D6.1.115** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ERN 00221547។ ឯកសារ **D6.1.169** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ERN 00197904។ ឯកសារ **D219/784** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ក្រាត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ERN 01300427 ឆ.៦០។

[2293] ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212421-00212422។ ឯកសារ **D118/64** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុល សឺន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៣ ERN 00920180 ឆ.៤៧។ ឯកសារ **D6.1.166** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន ជឿន ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ERN 00197888។ ឯកសារ **D118/67** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម ហូ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 00920203 ឆ.៤៣។

អស់នេះដែរ ឬអត់នោះទេ[2294]។ មានភស្តុតាងចចាមអារ៉ាមខ្លះ ដែលបើទោះបីជាមិនមានការគាំទ្រ និងមិនមានប្រភពច្បាស់លាស់ក្តី បានលើកឡើងថា អ្នកជាប់ឃុំដែលនៅសេសសល់ នៅក្នុងវត្តត្រូវបានគេសម្លាប់នៅក្នុងពេលមួយសប្តាហ៍ មុនពេលកងទ័ពវៀតណាមមកដល់ភ្នំសំពៅ[2295]។ ៥ ទៅ៥មួយថ្ងៃមុនពេលកងទ័ពវៀតណាមមកដល់ មានសាក្សីម្នាក់បានឃើញឆ្មាំពីរនាក់ ចុះមកពីលើភ្នំសំពៅ មកលាងដៃប្រឡាក់ឈាម ហើយដើរទៅចន្លោះក្តោងវិញ[2296]។

848. បើតាមការប៉ាន់ប្រមាណបែបចង្អៀត ដោយផ្អែកលើចម្លើយសាក្សី ដែលនិយាយថាសាកសព *"រាប់រយ"* ត្រូវបានរកឃើញនៅក្នុងរូងភ្នំ ដោយមិនមានការបញ្ជាក់លម្អិតបន្ថែម និងសាក្សីមួយរូបដែលនិយាយថា *"ច្រើនរយនាក់"* គឺអាចសន្និដ្ឋានបានថា យ៉ាងហោចណាស់ក៏មានមនុស្ស២០០នាក់ ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខវត្តគិរីរម្យ នៅចន្លោះពេលដែលរដ្ឋបាលភូមិភាគនិរតីមកដល់ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ថាតើក្នុងចំណោមនោះមានកម្មាភិបាលភូមិភាគពាយ័ព្យច្រើនប៉ុណ្ណានោះគឺមិនច្បាស់លាស់ឡើយ។

*ការចុះពិនិត្យរបស់ យឹម ទិត្យ*

849. មិនមានភស្តុតាងថា **យឹម ទិត្យ** បានចុះពិនិត្យមន្ទីរសន្តិសុខវត្តគិរីរម្យឡើយ។

### ៥.៥.៥. តំបន់៤

#### *៥.៥.៥.១. មន្ទីរសន្តិសុខវត្តសម្តេច*

ទីតាំងនិងការបង្កើត

---

[2294] ឯកសារ **D219/987** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួម សារឿន ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ ERN 01489851-01489852 ឆ.២-ឆ.៥។ ឯកសារ **D219/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួម សារឿន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ ERN 01032097 ឆ.៣៥។

[2295] ឯកសារ **D6.1.116** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេស ប៉ាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ERN 00221599-00221600។ ឯកសារ **D6.1.132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន សា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242227។

[2296] ឯកសារ **D6.1.186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម សាត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ERN 00212421-00212422។

850. មន្ទីរសន្តិសុខវត្តសម្តេច ស្ថិតនៅក្នុងភូមិសម្តេច ឃុំតាប៉ុន ស្រុកបាក់ព្រារ (ស្រុក៥) (បច្ចុប្បន្នស្រុកសង្កែរ) ខេត្តបាត់ដំបង តំបន់៤ ភូមិភាគពាយ័ព្យ[2297]។

851. នៅក្រោមការគ្រប់គ្រងរបស់ភូមិភាគពាយ័ព្យ វត្តសម្តេចត្រូវបានប្រើប្រាស់ជាមន្ទីរពេទ្យថ្នាក់ស្រុក[2298]។

852. នៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី បរិវេណវត្តសម្តេច ត្រូវបានកែប្រែទៅជាមន្ទីរឃុំឃាំង[2299] និងទីតាំងសម្លាប់មនុស្ស[2300] ហើយការសម្លាប់មនុស្សបានកើតឡើង រហូតដល់ពេល

---

[2297] ឯកសារ **D105/11** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00790591។ ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165916 ឆ.៥០។ ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203918 ឆ.២៨។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213259-01213260 ឆ.៤២, ឆ.៤៧។ ឯកសារ **D105/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00780646 ឆ.២៦។ *សូមមើលផងដែរ* ឯកសារ **D219/719** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឿង មាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01213266-01213267 ឆ.៤។ សូមមើល តំបន់ ៤ កថាខណ្ឌ ១៦៦។ *សូមប្រៀបធៀបជាមួយ* ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន រ៉ើន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203946 ឆ.៥។ ឯកសារ **D219/720** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213284 ឆ.២៦។

[2298] ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165924 ឆ.៧។ ឯកសារ **D219/681** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203885 ឆ.៩។ ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203920 ឆ.៤០-ឆ.៤១។ ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន រ៉ើន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203945 ឆ.៣ ERN 01203949 ឆ.១៩។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213254 ឆ.២១ ERN 01213261 ឆ.៥៤-ឆ.៥៥។ ឯកសារ **D219/719** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឿង មាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01213266-01213267 ឆ.២-ឆ.៤, ឆ.៦-ឆ.៩។ *សូមមើលផងដែរ* ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165911 ឆ.១៤, ឆ.១៧, ឆ.១៩ ERN 01165914 ឆ.៤០។

[2299] ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165914 ឆ.៤១-ឆ.៤២។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165927 ឆ.១៩-ឆ.២០។ ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន រ៉ើន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203945-01203946 ឆ.៣-ឆ.៤។ *សូមមើលផងដែរ* ឯកសារ **D105/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00780645-00780646 ឆ.១២, ឆ.២៣-ឆ.២៥។

កងទ័ពវៀតណាមចូលមកដល់ទីកន្លែងនោះ[2301]។ វត្តនេះនៅតែត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរពេទ្យដោយកម្មាភិបាលភូមិភាគនិរតីផងដែរ[2302]។ ភស្តុតាងមិនមានភាពប្រាកដប្រជា ថាតើវត្តសម្តេចដំណើរការក្នុងកម្រិតស្រុក ឬកម្រិតតំបន់ឡើយ[2303]។

853. គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ផ្លូវនៅមុខវត្តឡើយ។ ការចូលទៅក្នុងវត្តត្រូវបានរឹតបន្តឹង ដោយកន្លែងត្រួតពិនិត្យ ជាពិសេសនៅថ្ងៃដែលមានការសម្លាប់មនុស្ស។ កន្លែងត្រួតពិនិត្យត្រូវបានដកចេញ ក្រោយពេលសម្លាប់មនុស្សរួច។ ដើម្បីចូលទៅក្នុងមន្ទីរពេទ្យ នៅក្នុងបរិវេណវត្តបាន ទាមទារឲ្យមានការអនុញ្ញាតពីមេកង[2304]។

---

[2300] ឯកសារ **D219/720** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213279-01213281 ឆ.៤-ឆ.៦, ឆ.៨-ឆ.៩ ERN 01213285-01213286 ឆ.៣០-ឆ.៣៤ (*សូមប្រៀបធៀបជាមួយ* ឆ.៣៧)។ *សូមមើលផងដែរ* ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203921 ឆ.៤២-ឆ.៤៣។ ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165910 ឆ.៣ ERN 01165914 ឆ.៣៦, ឆ.៤២។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213253 ឆ.១៤ ERN 01213258 ឆ.៣៧-ឆ.៣៨, ឆ.៤០។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165926-01165927 ឆ.១៧។

[2301] ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165913 ឆ.៣៣ ERN 01165915 ឆ.៤៣។ ឯកសារ **D219/566** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ERN 01165939 ឆ.៧, ឆ.៩។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213255 ឆ.២៣ ERN 01213257 ឆ.៣៥-ឆ.៣៦។ *សូមមើលផងដែរ* ឯកសារ **D219/719** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឿង មាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01213266 ឆ.២-ឆ.៣ ERN 01213268 ឆ.១១។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165927 ឆ.១៩ ERN 01165933- ERN 01165934 ឆ.៥៦, ឆ.៥៩-ឆ.៦១។

[2302] ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203917-01203918 ឆ.១៧, ឆ.២៦ ERN 01203925 ឆ.៦៥។ ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន រ៉ឺន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203949 ឆ.២០។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213254 ឆ.២១។

[2303] ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165917 ឆ.៦២-ឆ.៦៣។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213261 ឆ.៥៤-ឆ.៥៥។

[2304] ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន រ៉ឺន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203946 ឆ.៤ ERN 01203951-01203952 ឆ.៣១-ឆ.៣២។ ឯកសារ **D219/720** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះ

854. យ៉ាងហោចណាស់មានរណ្តៅសព២ ត្រូវបានរកឃើញនៅក្នុងបរិវេណវត្តសម្តេច[2305]។

*វចនាសម្ព័ន្ធនិងបុគ្គលិក*

855. ភស្តុតាងអំពីពេលវេលា ដែលកម្មាភិបាលភូមិភាគនិរតី មកជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ នៅក្នុងភូមិសម្តេច គឺមានចាប់ពីពាក់កណ្តាល ឬចុងឆ្នាំ១៩៧៧ រហូតដល់ដើមឆ្នាំ១៩៧៨[2306]។

856. សាក្សីបាននិយាយអំពីកម្មាភិបាលមួយចំនួន ដែលមកភូមិសម្តេច ក្រោមការដឹកនាំរបស់ភូមិភាគនិរតី បើទោះបីជាសាក្សីមិនមានភាពស្របគ្នាអំពីមុខងាររបស់កម្មាភិបាលទាំងនោះក្តី។ សាក្សីមួយរូបបានរម្លឹកថា ភូមិសម្តេចស្ថិតក្រោមការគ្រប់គ្រងរបស់មេភូមិឈ្មោះ តាឆឹល ហើយអនុប្រធានភូមិឈ្មោះ តានឹង និងសមាជិកគណៈកម្មាធិការភូមិឈ្មោះ តាវ៉ាត់[2307]។ សាក្សីម្នាក់ទៀតបាន

---

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213280 ឆ.៨ ERN 01213285 ឆ.៣២។ ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165916 ឆ.៥៥។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165930-01165931 ឆ.៣៦-ឆ.៣៧។ ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203925 ឆ.៦៥។ *សូមមើលផងដែរ* ឯកសារ **D219/681** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203883 ឆ.៥ ERN 01203887 ឆ.១៩, ឆ.២២។

[2305] ឯកសារ **D219/681** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203883-01203884 ឆ.៥-ឆ.៦ ERN 01203888-01203889 ឆ.២៦។ ឯកសារ **D105/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00780645 ឆ.១៣ ERN 00780647-00780648 ឆ.៣៦-ឆ.៣៨, ឆ.៤១-ឆ.៤៣។ ឯកសារ **D219/720** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213285-01213286 ឆ.៣៤-ឆ.៣៦។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165934 ឆ.៦២។

[2306] ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165911 ឆ.១៧។ ឯកសារ **D219/681** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203882-01203884 ឆ.៤, ឆ.៧។ ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203916 ឆ.១៦។ ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន វ៉ើន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203948 ឆ.១០។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213253-01213254 ឆ.១៧។ ឯកសារ **D219/719** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វឿង មាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01213266 ឆ.៤ ERN 01213268 ឆ.១១-ឆ.១២។ ឯកសារ **D219/720** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213283 ឆ.២៤។

[2307] ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165927-01165928 ឆ.២១-ឆ.២៥។

រៀបរាប់ថា តាវ៉ាត់ គឺជាមេភូមិសម្តេច និងជាមនុស្សដែលអាចហៅឈ្មោះ អ្នកដែលត្រូវយកទៅសម្លាប់[2308]។ សាក្សីម្នាក់ក៏បាននិយាយយោងទៅរក តាងួន ថាទទួលខុសត្រូវលើវត្តសម្តេច[2309]។

857. នៅកម្រិតសហករណ៍ សាក្សីម្នាក់បានបញ្ជាក់ថា ក៏ក គឺជាប្រធានសហករណ៍ និងបញ្ជាឲ្យចាប់ខ្លួន ចំណែកឯសៀ គឺជាអនុប្រធាន ហើយ នុយ និង ជៀវ ងួន គឺជាសមាជិកគណៈកម្មាធិការសហករណ៍[2310]។ ទោះជាយ៉ាងនេះក្តី សាក្សីម្នាក់ទៀតបានរៀបរាប់ថា សៀ គឺជា "*អ្នកគ្រប់គ្រង*" ភូមិសម្តេច និងវត្តសម្តេច ហើយជា "*អ្នកគ្រប់គ្រងកងធំលេខ៩*"[2311]។ សៀ មានសិទ្ធិអំណាចចាប់ខ្លួនមនុស្ស រួមទាំងខ្មែរក្រោម ចាម និងប្រជាជនដែលជាប់ខ្សែស្រឡាយវៀតណាម[2312]។

*ការចាប់ខ្លួននិងឃុំខ្លួន*

858. កម្មាភិបាលភូមិភាគនិរតីកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់ ដើម្បីចាប់ខ្លួននិងបញ្ជូនទៅវត្តសម្តេច ដូចជាកម្មាភិបាលភូមិភាគពាយ័ព្យ[2313] និងសមាជិកគ្រួសាររបស់ពួកគេ[2314] និងអ្នកដែល

---

[2308] ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន រ៉ើន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203948 ឆ.១១, ឆ.១៣។ *សូមមើលផងដែរ* ឯកសារ **D105/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00780645 ឆ.២២។

[2309] ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213254 ឆ.១៨-ឆ.១៩ ERN 01213258-01213259 ឆ.៤១-ឆ.៤២។

[2310] ឯកសារ **D219/720** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213279 ឆ.៦ ERN 01213281-01213282 ឆ.១២, ឆ.១៥។

[2311] ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203918 ឆ.២៩ ERN 01203927 ឆ.៨០។

[2312] ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203921 ឆ.៤៥ ERN 01203923 ឆ.៥៦។

[2313] ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165910-01165911 ឆ.៦-ឆ.១០, ឆ.១៤។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165925-01165926 ឆ.១៣, ឆ.១៦។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213254-01213255 ឆ.២១-ឆ.២៣។

[2314] ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165925 ឆ.១០, ឆ.១៣។ ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213254-01213255 ឆ.២២។

ត្រូវបានចោទប្រកាន់ ថាជិតស្និទ្ធជាមួយទាហានសាធារណរដ្ឋខ្មែរ[2315]។ ប្រជាជនទូទៅ[2316] គ្រប់វ័យ (រួមទាំងកុមារផង)[2317] និងគ្រប់អាជីពការងារ[2318] ក៏ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅទីនោះ។ សាក្សីម្នាក់ក៏បានផ្តល់ភស្តុតាងចចាមអារ៉ាមថា នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ តាមបញ្ជារបស់ តាសៀ កម្មាភិបាលភូមិភាគនិរតី បានយកជនជាតិចាម ជាខ្មែរក្រោម និងប្រជាជនដែលមានខ្សែស្រឡាយវៀតណាម នៅក្នុងកងរបស់គាត់ ហើយដែលរស់នៅក្នុងតំបន់នោះ ទៅសម្លាប់នៅវត្តសម្តេច។ ទោះបីជាសាក្សីមិនបានឃើញហេតុការណ៍នេះផ្ទាល់ក្តី គាត់បង្ហាញថា នេះគឺជាការដឹងឮជាទូទៅក្នុងចំណោមប្រជាជននៅក្នុងទីកន្លែងនេះ ដោយគាត់បញ្ជាក់ថា "*អ្នកស្រុកគេនិយាយគ្រប់គ្នា ព្រោះគេឃើញ*"[2319]។

859. កម្មាភិបាលភូមិភាគនិរតីបានចាប់ផ្តើមការចាប់ខ្លួន និងសម្លាប់មនុស្ស ចាប់ពីពេលដែលពួកគេមកដល់ទីតាំងភូមិសម្តេច[2320] ហើយការនេះបន្តរហូតនៅក្នុងអំឡុងពេលដែលពួកគេគ្រប់គ្រង[2321]។

---

[2315] ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165926-01165927 ឆ.១៧។ *សូមមើលផងដែរ* ឯកសារ **D105/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ហេង ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00780644 ឆ.៦ ERN 00780648-00780649 ឆ.៤៥-ឆ.៤៧, ឆ.៥៦។

[2316] ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203913-01203914 ឆ.៤, ឆ.៦ ERN 01203915-01203916 ឆ.១២។ ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165910 ឆ.៣ ERN 01165918 ឆ.៦៨-ឆ.៦៩។ ឯកសារ **D219/685** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន រ៉េន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203946 ឆ.៤។

[2317] ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213251-01213252 ឆ.៦-ឆ.៧។ ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165912 ឆ.២១។ ឯកសារ **D219/720** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213280 ឆ.៨។

[2318] ឯកសារ **D219/718** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213257-01213258 ឆ.៣២, ឆ.៣៧-ឆ.៣៨។ ឯកសារ **D219/719** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឿង មាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01213268 ឆ.១៣។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165926-01165927 ឆ.១៧។

[2319] ឯកសារ **D219/683** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203923-01203925 ឆ.៥៥-ឆ.៦១, ឆ.៦៦។

[2320] ឯកសារ **D219/564** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165911 ឆ.១៤។ ឯកសារ **D219/565** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165926 ឆ.១៦។ ឯកសារ **D219/719** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឿង មាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01213268 ឆ.១៣។

សាក្សីម្នាក់ដែលធ្វើការងារជាគ្រូបង្រៀន នៅក្រោមកម្មាភិបាលភូមិភាគនិរតី[2322] បានរម្លឹកអំពីហេតុការណ៍ចំនួន២ នៃការចាប់ខ្លួនទ្រង់ទ្រាយធំ ដែលមានមនុស្ស១០៥នាក់ និង១០០នាក់ ដែលហេតុការណ៍នេះកើតឡើងឃ្លាតពីគ្នា២យប់ ហើយដែលក្រោយមកមានកម្មាភិបាលម្នាក់បានប្រាប់ថា "*គេកម្ទេចខ្មាំង*" នៅក្នុងវត្ត[2323]។

860. ក្រោមការត្រួតត្រារបស់ភូមិភាគនិរតី វត្តសម្ដេចជាទូទៅគឺមានអ្នកទោសពេញ[2324] ហើយអ្នកទោសទាំងនោះត្រូវបានឃុំឃាំង ត្រឹមតែ២ទៅ៣ថ្ងៃប៉ុណ្ណោះ រហូតដល់ពេញវត្ត ទើបគេយកទៅសម្លាប់[2325]។ ទោះជាយ៉ាងនេះក្ដី មិនអាចមានការទាញសន្និដ្ឋានបានច្បាស់លាស់ពីភស្តុតាងដែល

---

[2321] ឯកសារ **D219/718** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213251-01213252 ឆ.៦-ឆ.៨ ERN 01213255 ឆ.២៣។ ឯកសារ **D219/719** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រឿង មាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01213268 ឆ.១៣។ ឯកសារ **D219/566** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ERN 01165938-01165939 ឆ.២-ឆ.៨។ ឯកសារ **D219/565** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165924 ឆ.៣ ERN 01165925 ឆ.១៣ ERN 01165927 ឆ.១៩។ ឯកសារ **D219/683** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203914 ឆ.៥-ឆ.៦ ERN 01203920-01203921 ឆ.៤១-ឆ.៤២។ *សូមមើលផងដែរ* ឯកសារ **D219/564** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ERN 01165912-01165913 ឆ.២៤-ឆ.២៥, ឆ.២៧។ ឯកសារ **D219/685** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ន រ៉េន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203950-01203951 ឆ.២៥-ឆ.២៧។ ឯកសារ **D219/720** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វ៉ាន់ វឿត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01213279-01213280 ឆ.៤-ឆ.៥, ឆ.៨។

[2322] ឯកសារ **D219/565** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165924 ឆ.៣។

[2323] ឯកសារ **D219/565** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រុន ឡាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ERN 01165926-01165927 ឆ.១៦-ឆ.១៧, ឆ.១៩-ឆ.២០ ERN 01165930-01165931 ឆ.៣៥-ឆ.៣៧។

[2324] ឯកសារ **D219/683** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ិន ណុន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203924-01203925 ឆ.៦៣។ *សូមមើលផងដែរ* ឯកសារ **D219/566** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហេង ផាត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ERN 01165939 ឆ.៨។ ឯកសារ **D219/718** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហេង លាប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ERN 01213256 ឆ.៣១។

967. សាក្សីនានា និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់ភ័ស្ដុតាងផ្ទាល់អំពីពិធីរៀបការដោយបង្ខំដែលបានកើតឡើងនៅអូរសទូក[2630], ឃុំ ៣០[2631], ភូមិកាច់រទេះ[2632] ភូមិកំពង់គោ[2633] និងភូមិថ្មី[2634]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ផ្ដល់ភ័ស្ដុតាងចចាមអារ៉ាមអំពីពិធីរៀបការដោយបង្ខំដែលបានកើតឡើងនៅភូមិទួលពូ[2635]។

968. ភ័ស្ដុតាងឲ្យដឹងថា ពិធីរៀបការដោយបង្ខំនៅឃុំកំពង់ព្រៀង បានធ្វើច្រើននៅចុងឆ្នាំ១៩៧៧[2636] និងឆ្នាំ១៩៧៨ រួមទាំងនៅក្នុងខែសីហា ឆ្នាំ១៩៧៨[2637]ផង។ សាក្សីផ្សេងទៀត និងអ្នកដាក់ពាក្យសុំតាំង

---

[2630] ឯកសារ **D219/137** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃៀម សោន ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៥ ERN 01053278 ឆ.៣១ ERN 01053279 ឆ.៣៥-៣៦ ឆ.៤១ ឆ.៤៦។ ឯកសារ **D118/298** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃៀម បូ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ ERN 01023865 ឆ.៧៣-៧៤។

[2631] ឯកសារ **D219/840** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335637 ឆ.២០ ERN 01335639 ឆ.៣៨។

[2632] ឯកសារ **D219/302** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ERN 01096547 ឆ.១៩។ ឯកសារ **D219/303** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៥ ERN 01096552 ឆ.២។ ឯកសារ **D219/125** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047394 ឆ.១១៥។ *សូមមើលផងដែរ* ឯកសារ **D219/424** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វៀម ដុះ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥ ERN 01121683 ឆ.២៩-៣០។

[2633] ឯកសារ **D219/307** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096600 ឆ.៣៧។ ឯកសារ **D219/528** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡូញ លន់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01151012 ឆ.១០៨។ ឯកសារ **D219/167** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃៀម គៀយ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01062688 ឆ.២៤។ ឯកសារ **D219/306** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096585 ឆ.១២។ ឯកសារ **D219/396** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៥ ERN 01114715 ឆ.៣។

[2634] ឯកសារ **D219/300** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096522 ឆ.៧។

[2635] ឯកសារ **D118/240** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយ សាន្ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ERN 00988054 ឆ.៨១។

[2636] ឯកសារ **D219/840** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335639 ឆ.៣៩។ ឯកសារ **D219/302** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំង

ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលមិនបានចាំជាក់លាក់អំពីពេលវេលាដែលពួកគេបានរៀបការ ឬបានឃើញពិធីរៀបការនោះ យ៉ាងណាមិញ គាត់បន្ថែមថា គឺបន្ទាប់ពីពួកកងទ័ពភូមិភាគនិរតីបាន មកដល់ភូមិភាគពាយ័ព្យ (មានន័យថា ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨)[2638]។

969. សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានផ្តល់ភ័ស្តុតាងអំពី អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងឃុំកំពង់ព្រៀង ទោះបីជាបានរៀបការដោយខ្លួនឯង ឬបានចូលរួម ក្នុងពិធីនោះក្តី គឺពួកគេជាកម្មករមកពីអង្គភាពផ្សេងៗគ្នានៅក្នុងភូមិជិតៗនោះ ដោយមានករណី លើកលែងចំនួនពីរ៖ គឺមានម្នាក់ជាសមាជិកគណៈសហករណ៍កំពង់គោ ពីឆ្នាំ១៩៧៧-១៩៧៨[2639] និងម្នាក់ទៀតជាអនុប្រធានកងវរៈសេនាតូច នៅកងចល័តភូមិកាច់រទេះ[2640]។

970. សាក្សីម្នាក់ក៏បាននិយាយផងដែរថា គាត់ក៏បានចូលរួមក្នុងពិធីមួយដែលមានទាំងកងទ័ព និង ប្រជាជនធម្មតាបានរៀបការ[2641]។

---

ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ERN 01096547 ឆ.២០-២១។ *សូមមើលផងដែរ* ឯកសារ **D219/137** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យៀម សោន ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៥ ERN 01053279 ឆ.៣៦។

[2637] ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096520 ឆ.៣ ERN 01096524 ឆ.១៧។ ឯកសារ **D219/424** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀម ឌុះ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥ ERN 01121683 ឆ.២៩-៣០។ ឯកសារ **D219/306** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096585 ឆ.១១។ ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047392 ឆ.៩០-៩១ ERN 01047396 ឆ.១២៥-១២៧។ *សូមមើលផងដែរ* ឯកសារ **D219/307** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096600 ឆ.៣៩-៤០។

[2638] ឯកសារ **D219/528** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូញ លន់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01151012 ឆ.១០៤-១០៦។ ឯកសារ **D219/167** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យៀម កឿយ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01062687 ឆ.២៣។ *សូមមើលផងដែរ* ឯកសារ **D219/446** កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី គិក ស៊ឹម ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ ERN 01129702 ឆ.៤៣។

[2639] ឯកសារ **D219/528** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូញ លន់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01151001 ឆ.៣១។

[2640] ឯកសារ **D219/424** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀម ឌុះ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥ ERN 01121678 ឆ.៦-៧។

[2641] ឯកសារ **D219/528** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូញ លន់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01151012 ឆ.១០៤។

971. បុគ្គលម្នាក់ៗដែលបានរៀបការ ជាទូទៅមានអាយុខ្ទង់ម្ភៃឆ្នាំ[2642] ប៉ុន្តែមានខ្លះទៀតបានរៀបការក្នុងអាយុ១៩ឆ្នាំ[2643]។

972. កាលៈទេសៈដូចបានរៀបរាប់ខាងលើទាក់ទងនឹងការជ្រើសរើសគូស្រករ ការផ្គូផ្គង និងការតាមដាន រួមទាំងករណីលើកលែងម្តងម្កាល ក៏ត្រូវបានអនុវត្តផងដែរ[2644]។

---

[2642] ឯកសារ **D219/424** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀម ដុះ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥ ERN 01121683 ឆ.២៩-៣០។ ឯកសារ **D219/306** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096582 ឆ.២ ERN 01096585 ឆ.១១។ ឯកសារ **D219/137** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃៀម សោន ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៥ ERN 01053279 ឆ.៣៦។

[2643] ឯកសារ **D219/840** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335639 ឆ.៣៩។ ឯកសារ **D219/302** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ERN 01096547 ឆ.២០-២១។

[2644] ឯកសារ **D219/307** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096601 ឆ.៤៤-៤៦ ឆ.៤៩ ERN 01096602-01096603 ឆ.៥៨-៦១។ ឯកសារ **D219/306** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096585 ឆ.១១ ERN 01096587 ឆ.២២-២៧ ERN 01096588-01096589 ឆ.៣៥-៣៨។ ឯកសារ **D219/303** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៥ ERN 01096552-53 ឆ.១-១១ ERN 01096554 ឆ.១៣។ ឯកសារ **D219/528** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូញ លន់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01151012 ឆ.១០៦-១០៧។ ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096521-22 ឆ.៦ ERN 01096522-23 ឆ.៩-១០ ERN 01096524-01096525 ឆ.១៧-១៩។ ឯកសារ **D219/424** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀម ដុះ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥ ERN 01121683 ឆ.២៩។ ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047391-01047392 ឆ.៨៨-៨៩ ឆ.៩២ ឆ.៩៧ ERN 01047395 ឆ.១១៨-១១៩ ERN 01047397 ឆ.១៣៩ ERN 01047398-99 ឆ.១៤៤-១៤៥។ ឯកសារ **D219/302** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ERN 01096546 ឆ.១២-១៣ ERN 01096547 ឆ.១៨ ERN 01096548 ឆ.២៥។ ឯកសារ **D118/298** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃៀម បូ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ ERN 01023865 ឆ.៧៣-៧៤។ ឯកសារ **D219/396** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៥ ERN 01114715 ឆ.១។ ឯកសារ **D219/167** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃឿម កឿយ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01062687-01062688 ឆ.២៣-២៤។ ឯកសារ **D118/240** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយ សាន្ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ERN 00988054 ឆ.៨២។ ឯកសារ **D219/301** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿង ចាន់ថន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ERN 01096535 ឆ.២៤។

973. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់មានមតិថា នារីអាចច្រានចោលការរៀបការដែលបានរៀបចំដោយប្រធានកងដោយគ្មានការភ័យខ្លាច ប៉ុន្តែនេះគ្រាន់តែជាការសម្តែងមតិមួយខុសគេ ដែលមានលក្ខណៈផ្ទុយគ្នាស្រឡះទៅនឹងភ័ស្តុតាងនៅសល់ដ៏ច្រើនលើសលុបផ្សេងទៀត ដូច្នេះ មតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នេះមិនអាចជឿទុកចិត្តបានឡើយ[2645]។

974. ភ័ស្តុតាងក៏ឱ្យដឹងផងដែរថា កម្មាភិបាលនឹងផ្គូផ្គង "ប្រជាជនមូលដ្ឋាន" តែជាមួយនឹង "ប្រជាជនមូលដ្ឋាន" ហើយ "ប្រជាជនថ្មី" តែជាមួយនឹង "ប្រជាជនថ្មី" ប៉ុណ្ណោះ[2646]។

975. ដោយមានភាពស៊ីចង្វាក់គ្នាជាមួយនឹងភ័ស្តុតាងនៅឃុំវាំងកេសី ភ័ស្តុតាងស្តីពីអាពាហ៍ពិពាហ៍នៅឃុំកំពង់ព្រៀងគាំទ្រដល់ការសន្និដ្ឋានថា គូស្រករមិនបានបដិសេធសំណើ ឬសេចក្តីស្នើសុំរៀបការណាមួយទេ[2647] ដោយខ្លាចការគំរាមកំហែង ឬការភ័យខ្លាចគេបញ្ជូនទៅអប់រំ[2648] បញ្ជូនទៅ

---

ឯកសារ **D219/453** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ាត យឿន ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ERN 01129779 ទ.៤០-៤២។ ធៀបទៅនឹង ឯកសារ **D219/840** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335640 ទ.៤៧-៤៨។ ឯកសារ **D219/301** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿង ចាន់ថន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ERN 01096535 ទ.២៤។

[2645] ឯកសារ **D219/840** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335640 ទ.៤៤ ERN 01335640-01335641 ទ.៥០-៥១។

[2646] ឯកសារ **D219/307** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096602 ទ.៥៦។ ឯកសារ **D219/306** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096587 ទ.២៤។ ធៀបទៅនឹង ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047397 ទ.១៣២ ១៣៤-១៣៦។

[2647] ឯកសារ **D219/307** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096601 ទ.៤៤ ទ.៤៧។ ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096522 ទ.៨ ERN 01096524 ទ.១៧។ ឯកសារ **D219/302** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ERN 01096546 ទ.១៥-១៦។ ឯកសារ **D219/781** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ាន ប្រាក់ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ERN 01300002 ទ.៦៤។ ឯកសារ **D219/306** កំណត់ ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096587 ទ.២៣ ERN 01096588 ទ.៣៤។ ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047393 ទ.១០៦-១០៨។ *សូមមើលផងដែរ* ឯកសារ **D118/240** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយ សាន្ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ERN 00988054 ទ.៨៥-៨៦។

ការដ្ឋានផ្សេង (មានន័យថា ប្រឈមនឹងហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺគ្រុនចាញ់ អាចមកជួបឪពុកម្តាយខាងប្រពន្ធ/ប្តីបានតែម្តងក្នុងមួយឆ្នាំ និង *"គ្មានសង្ឃឹមថានឹងបានវិលត្រឡប់មកផ្ទះវិញ"*)[2649] ឬ ត្រូវបានសម្លាប់ចោល[2650]។ ជាពិសេស មានសាក្សីម្នាក់និយាយថា ទោះបីគាត់មិនបានឃើញផ្ទាល់ភ្នែកអំពីនរណាម្នាក់ត្រូវបានគេសម្លាប់ក៏ដោយ គាត់សង្កេតឃើញថា កម្មាភិបាលនឹងរាយការណ៍ទៅប្រធានអង្គភាពអំពីគូស្រករណាដែលមិនចុះសម្រុងនឹងគ្នា ហើយថា គូស្រករទាំងនោះនឹងត្រូវបានគេយកចេញទៅដោយមិនឃើញវិលត្រឡប់មកវិញឡើយ[2651]។ សាក្សីដដែលក៏បានឃើញពួកឈ្លបចាប់ប្តីប្រពន្ធពីរគូយកទៅដាក់នៅក្នុងផ្ទះមួយ បានឮពួកគេស្រែកថ្ងូរ ហើយគិតថាពួកគេកំពុងត្រូវបានគេធ្វើទារុណកម្ម ហើយនៅព្រឹកបន្ទាប់ កម្មាភិបាលក៏បានបញ្ជាឲ្យសាក្សីរូបនេះកប់សាកសពប្តីប្រពន្ធទាំងពីរគូនេះ[2652]។

976. ភ័ស្តុតាងផ្ទាល់គាំទ្រដល់ការរកឃើញថា ពិធីទាំងនោះត្រូវបានគេធ្វើឡើងសម្រាប់គូស្រករមានចាប់ពីពីរគូ ដល់៤០គូ[2653] និងភ័ស្តុតាងចចាមអារ៉ាមដែលគួរឲ្យទុកចិត្តបានអំពីពិធីទាំងនោះថា មានការរៀបការរហូតដល់៧០គូ[2654]។

---

[2648] ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047394 ឆ.១០៩-១១០។

[2649] ឯកសារ **D219/304** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៥ ERN 01096561 ឆ.១។ ឯកសារ **D219/302** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ERN 01096547 ឆ.១៧។ ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096522 ឆ.៨។

[2650] ឯកសារ **D219/307** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096601 ឆ.៤៤ ERN 01096602 ឆ.៥១-៥២ ៥៤។ ឯកសារ **D219/781** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ាន ប្រាក់ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ERN 01300002 ឆ.៦៤។ ឯកសារ **D219/306** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096585 ឆ.១៦ ERN 01096588 ឆ.៣៣ ឆ.៣៤។ ធៀបទៅនឹង ឯកសារ **D219/840** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335641 ឆ.៥១។

[2651] ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096522-01096523 ឆ.១០។

[2652] ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096522-23 ឆ.១០-១១។

[2653] <u>២គូ៖</u> ឯកសារ **D219/840** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335639 ឆ.៤០។ ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំ

977. ខណៈការរៀបការខ្លះដែលបានធ្វើនៅក្នុងឃុំកំពង់ព្រៀងនៅចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨ ត្រូវបានធ្វើឡើងដោយកម្មាភិបាលភូមិភាគពាយ័ព្យក៏ដោយ[2655] ក៏ការរៀបការដោយបង្ខំភាគច្រើនដែលបានធ្វើឡើងនៅចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ត្រូវបានធ្វើឡើងដោយមានការចូលរួមជាអធិបតីរបស់កម្មាភិបាលភូមិភាគនិរតី[2656]។

---

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047394 ឆ.១១៦។ ពាគូ៖ ឯកសារ **D219/307** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096601 ឆ.៥០។ ឯកសារ **D219/306** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096587 ឆ.២៨។ ៧គូ៖ ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096521-01096522 ឆ.៦។ ១០គូ៖ ឯកសារ **D219/528** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូញ លន់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01151013 ឆ.១១២។ ១១គូ៖ ឯកសារ **D219/167** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃៀម កឿយ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01062688 ឆ.២៤។ ជាង២០គូ៖ ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047396 ឆ.១២៥-១២៧។ ៤០គូ៖ ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047396 ឆ.១២៥-១២៧។

[2654] ១០ទៅ២០គូ៖ ឯកសារ **D219/446** កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី តិក ស៊ីម ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ ERN 01129702 ឆ.៤៣។ ឯកសារ **D219/840** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃឹម ដេត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335639 ឆ.៤០។ ១០ទៅ៥០គូ៖ ឯកសារ **D118/240** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយ សាន្ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ERN 00988054 ឆ.៨២។ ៥០/៦០/៧០គូ៖ ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096521-01096522 ឆ.៦។

[2655] ឯកសារ **D219/301** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿង ចាន់ថន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ERN 01096533 ឆ.១៧។ ឯកសារ **D219/841** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហេង គុយឡាង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335658 ឆ.៥៥។ ឯកសារ **D118/298** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃៀម ប៊ូ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ ERN 01023865 ឆ.៧៣-៧៤។ ឯកសារ **D219/261** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃឿន ស្បឿន ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៥ ERN 01085795 ឆ.៩ ERN 01085804 ឆ.៥០។

[2656] ឯកសារ **D219/300** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096521-01096522 ឆ.៦។ ឯកសារ **D219/528** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូញ លន់ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01151012 ឆ.១០៥-១០៦។ ឯកសារ **D219/307** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាល់ យ៉ុង ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ERN 01096599 ឆ.៣០ ERN 01096600 ឆ.៣៧ ៤២។ ឯកសារ **D219/306** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096587 ឆ.២៣

978. ភស្តុតាងបង្ហាញថា ចរិតលក្ខណៈនៃអាពាហ៍ពិពាហ៍ទាំងនោះបានធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តនៅក្នុងរយៈពេលវែង ទៅលើបុគ្គលទាំងឡាយដែលពាក់ព័ន្ធ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនបាននិយាយអំពីការលំបាកខាងផ្លូវចិត្ត ដែលពួកគេបានជួបប្រទះក្នុងការរៀបការជាមួយមនុស្សដែលគេមិនស្គាល់ ឬមិនស្រឡាញ់[2657] និងដែលមិនបានរៀបការទៅតាមប្រពៃណីខ្មែរ។

979. មានគូស្រករមួយចំនួនដែលត្រូវបានគេបង្ខំឱ្យរៀបការជាមួយគ្នានៅក្នុងឃុំកំពង់ព្រៀង តាំងតែពីពេលនោះមក ក៏បានបែកបាក់គ្នា ឬលែងលះគ្នាអស់ហើយ[2658]។

*៥.៥.៧.៣. តំបន់១៖ ស្រុកសំឡូត*

980. សាក្សីពីររូបគឺជាផ្នែកមួយនៃពិធីរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨ នៅក្នុងស្រុកសំឡូត ដែល **យឹម ទិត្យ** បង្ហាញវត្តមានយ៉ាងហោចក៏រហូតដល់កម្មវិធីបានចាប់ផ្ដើម និងដែល តា ម៉ុក បានចូលរួម។ អ្នករៀបការគឺ ព្រាប កប ជាទាហានពិការ ចំណែកប្រពន្ធរបស់គាត់គឺ ណុប ងឹម ដែលជាអនុលេខាស្រុកសំឡូតនាពេលនោះ។

---

ERN 01096589 ឆ.៤០។ ឯកសារ **D219/396** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៥ ERN 01114715 ឆ.៩។ ឯកសារ **D219/125** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047387 ឆ.៥១ ERN 01047392 ឆ.៩០ ERN 01047396 ឆ.១២៨។ ឯកសារ **D219/167** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឃៀម កឿយ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01062687 ឆ.២៣។ *សូមមើលផងដែរ* ឯកសារ **D219/446** កំណត់ហេតុនៃការ ស្ដាប់ចម្លើយសាក្សី តិក ស៊ីម ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ ERN 01129702 ឆ.៤៣។

[2657] ឯកសារ **D219/303** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៥ ERN 01096552-01096553 ឆ.១-១១ ERN 01096554 ឆ.១៤។ ឯកសារ **D219/306** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សិន បាន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ERN 01096587 ឆ.២៣ ERN 01096588 ឆ.៣៣។ ឯកសារ **D219/125** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ERN 01047395 ឆ.១២០ ERN 01047395-01047396 ឆ.១២៤ ERN 01047399-01047400 ឆ.១៥១ ERN 01047402 ឆ.១៦៩-១៧១។

[2658] ឯកសារ **D219/300** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិម ប៊ុនឈឿន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ERN 01096522 ឆ.៩។ ឯកសារ **D219/301** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សឿង ចាន់ថន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ERN 01096535 ឆ.២៤។ ឯកសារ **D219/841** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហេង គុយឡាង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ ERN 01335662 ឆ.៨៦។

981. ភស្តុតាងអំពីការរៀបការរបស់ពួកគេគឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងខាងលើ។ ពិធីត្រូវបានធ្វើឡើងយ៉ាងតក់ក្រហល់ ដោយមិនធ្វើតាមប្រពៃណីឡើយ។ យ៉ាងណាមិញ មានមន្ទិលសង្ស័យមួយចំនួនធំអំពីថាតើ ព្រាប កប ខ្លួនគាត់ផ្ទាល់ត្រូវបានគេបង្ខំឱ្យរៀបការជាមួយ ណុប ងឹម ដែរ ឬអត់។

982. ព្រាប កប ជាទាហានដែល "មើលមិនឃើញ" ដោយពិការក្នុងឆ្នាំ១៩៧៥ ហើយបន្ទាប់មកទើបត្រូវបានគេបញ្ជូនទៅអង្គភាពជនពិការកងទ័ព[2659]។ គាត់ត្រូវបានគេបញ្ជូនពីភូមិតាខ្មៅ នៅក្នុងភូមិភាគនិរតី ទៅកាន់ស្រុកសំឡូត នៃភូមិភាគពាយ័ព្យ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៨[2660]។ ពេលមកដល់ស្រុកសំឡូត តាម៉ុក បានហៅឱ្យទៅចូលរួមប្រជុំ ហើយបាននិយាយប្រាប់ជនពិការដែលមានគ្នា៤០នាក់ថា គាត់កំពុងតែរៀបចំឱ្យពួកគេរៀបការ ប៉ុន្តែមិនបាននិយាយអ្វីលម្អិតជាងនេះទៀតទេ[2661]។ នៅថ្ងៃរៀបការរបស់គាត់ ប្រធានក្រុមបានប្រាប់ក្រុមយោធាពិការឱ្យរៀបចំខ្លួនឱ្យហើយស្រេចសម្រាប់ការអប់រំនយោបាយ ដែលនឹងត្រូវធ្វើនៅមន្ទីរស្រុកសំឡូត[2662]។ ពេលយោធាទាំងនោះបានមកដល់មន្ទីរស្រុក ពួកគេបានឃើញតុវែងមួយដែលគេបានរៀបចំរួចជាស្រេច ឃើញមានស្លាកឈ្មោះដែលបានដាក់នៅលើតុនោះ ហើយបន្ទាប់មក គេក៏បានបញ្ជាឱ្យពួកគេអង្គុយចុះ ដោយយោធាអង្គុយនៅម្ខាង ចំណែកនារីដែលនឹងក្លាយជាប្រពន្ធរបស់ពួកគេអង្គុយនៅម្ខាងទៀត[2663]។

983. គូស្រករទើបរៀបការថ្មីថ្មោងទទួលបានគ្រែ មុង និងអង្រឹង បន្ទាប់ពីបានរៀបការជាមួយគ្នាហើយមានលិខិតមួយដែលបានចុះហត្ថលេខាសរសេរថា *"ពីគណៈតំបន់ ១ ទិត្យ"*[2664]។ ព្រាប កប ចាំថាគាត់បានអានលិខិតនេះ ព្រោះគាត់បានយកលិខិតនោះមកដាក់ក្បែរភ្នែកគាត់ ទោះបីគាត់មើលមិន

[2659] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037138-01037139 ឆ.១៥-១៦។

[2660] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037142 ឆ. ៣២។

[2661] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037143 ឆ. ៤៤។

[2662] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037145 ឆ. ៥១។

[2663] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037145 ឆ. ៥១។

[2664] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037143 ឆ. ៤៤។

ស្ទូវច្បាស់ក៏ដោយ និងត្រូវពឹងលើប្រពន្ធរបស់គាត់ក្នុងការធ្វើដំណើរទៅណាមកណាម្ដងៗ[2665]។ ក៏ប៉ុន្តែ ការពិតនៃពិការភាពដែលធ្វើឲ្យគាត់មើលមិនឃើញនេះ នាំឲ្យមានមន្ទិលសង្ស័យចំពោះសក្ខីកម្មរបស់គាត់អំពីការកើតមានឡើងនៃលិខិតនោះ និងនៅលើសេចក្ដីសង្កេតរបស់គាត់ខ្លះៗទៀត។

984. គាត់ក៏មានការផ្ដល់ចម្លើយផ្ទុយគ្នាជាហូរហែមកផងដែរ ដែលនាំឲ្យប៉ះពាល់ដល់ភាពជឿជាក់បាននៃសាច់រឿងរបស់គាត់។ តាមកំណត់ហេតុមួយរបស់គាត់ គាត់ថាគាត់មិនដែលបានស្នើសុំរៀបការទេ គឺគាត់បានធ្វើតាមបញ្ជា និងសេចក្ដីណែនាំ ដោយសារ *"បើមិនដូច្នោះ យើងនឹងមានបញ្ហា"*[2666]។ ការណ៍នេះ បើតាមរូបភាពរបស់វា ត្រូវបានបញ្ជាក់បន្ថែមតាមរយៈចំណាប់អារម្មណ៍របស់ ណុប ងឹម ចំពោះពិធីនោះ[2667]។ យ៉ាងណាមិញ សាច់រឿងរបស់គាត់មិនស៊ីគ្នានឹងសេចក្ដីរៀបរាប់ដែលខុសគ្នាក្នុងកំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពីមុនរបស់គាត់ ដោយសារក្នុងឯកសារនោះគាត់ថា តាមពិតគាត់បានស្នើសុំដើម្បីរៀបការជាមួយប្រពន្ធគាត់[2668]។

985. ណុប ងឹម និយាយថា គាត់ *"ខឹង"* នឹងតាម៉ុក *"យ៉ាងខ្លាំង"* នៅពេល តាម៉ុក ប្រាប់គាត់ឲ្យរៀបការព្រោះគាត់អត់ស្រឡាញ់ ព្រាប កប ទេ ប៉ុន្តែគាត់ព្រមរៀបការ ក៏ដោយសារគាត់ខ្លាច*អង្គការ*[2669]។ គាត់មិនដឹងទាល់តែសោះថាហេតុអ្វីបានជាគេរៀបចំឲ្យមានពិធីនេះឡើង *"ស្រាប់តែគាត់ចាប់ការៗ"*[2670]។ បើតាមគាត់ ព្រាប កប មិនបានធ្វើសំណើសុំណាមួយទៅកម្មាភិបាលដើម្បីរៀបការជាមួយគាត់ទេ បើតាមគាត់ដឹងគឺសូម្បីតែមួយក៏គ្មានផង ដូច្នេះវាហាក់ដូចជាគ្មានតក្កវិជ្ជានោះទេដែលគាត់អាចបំភ្លឺអំពីអវត្តមាននៃអ្វីម្យ៉ាងដែលគាត់មិនបានដឹង។ បន្ទាប់មក សាក្សីរូបនេះក៏បានប្រឈមមុខជាមួយនឹងកំណត់ហេតុ DC-Cam របស់ប្ដីគាត់ដែលនិយាយថា: *"ខ្ញុំចូលចិត្តគាត់។ តា*

---

[2665] ឯកសារ **D219/62** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037139 ឆ.១៧ ERN 01037143 ឆ.៤៤។

[2666] ឯកសារ **D219/62** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037149 ឆ.៧៥។

[2667] ឯកសារ **D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008708 ឆ.៦៨។

[2668] ឯកសារ **D219/62.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 00734877។

[2669] ឯកសារ **D219/298** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ERN 01095986-01095987 ឆ.១០-១១។

[2670] ឯកសារ **D219/835** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ERN 01329405 ឆ.១៥៤។

*មុ៉ក បានឲ្យខ្ញុំជ្រើសរើស។ គាត់មិនបានបង្ខំខ្ញុំទេ"*[2671] ដោយគាត់បានឆ្លើយតបទៅនឹងចំណុចនេះ ថាគាត់មិនធ្លាប់ឮពាក្យនេះពីប្តីរបស់គាត់ទេ[2672]។ ដូច្នេះ យើងមានហេតុផលឲ្យជឿបាន យ៉ាង ហោចណាស់ក៏សម្រាប់ករណីពួកគាត់ ថាអាពាហ៍ពិពាហ៍អាចត្រូវបានធ្វើឡើងដោយការបង្ខំ តែពី ខាង ទស្សនៈយល់ឃើញរបស់ ណុប ធីម ប៉ុណ្ណោះ។

986. ភ័ស្តុតាងទាក់ទងនឹងវត្តមានរបស់ **យឹម ទិត្យ** នៅក្នុងពិធីនោះ មិនស៊ីចង្វាក់គ្នាទេ។ ម្យ៉ាងវិញទៀត ព្រាប កប និយាយថា គាត់បានស្គាល់អត្តសញ្ញាណ **យឹម ទិត្យ** នៅថ្ងៃរៀបការ[2673] នៅពេលប្រពន្ធ គាត់ប្រាប់គាត់ថា **យឹម ទិត្យ** និង តាម៉ុក បានចូលរៀបរួមក្នុងពិធីរៀបការរបស់ពួកគាត់[2674] បន្ទាប់ មកគាត់ពន្យល់ថា តាម៉ុក បានណែនាំឲ្យស្គាល់ ***"សមមិត្ត ទិត្យ"*** នៅក្នុងពេលពិធីនោះ ហើយ **យឹម ទិត្យ** បានថ្លែងសុន្ទរកថា[2675]។ គាត់បន្ថែមថា យាយ ឡេង ជាលេខាស្រុក បានមកចូលរួម ពេលបិទពិធី[2676] ហើយ **យឹម ទិត្យ** ក៏បានចូលរួមក្នុងពិធីនោះរហូតដល់ចប់[2677]។ សំខាន់យើងត្រូវ ចាំថា អាស្រ័យដោយភ្នែករបស់គាត់មើលមិនច្បាស់ វាមិនទំនងទាល់តែសោះថា ព្រាប កប អាច មើលឃើញ **យឹម ទិត្យ** យ៉ាងច្បាស់។ តាមពិត គាត់សារភាពនៅក្នុងកំណត់ DC-Cam របស់គាត់

---

[2671] ឯកសារ **D219/62.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 00734877។

[2672] ឯកសារ **D219/974.1.2** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សំណុំរឿង ០០២/០២ [ណុប ធីម] ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ERN 01382512-01382513។

[2673] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037144 ឆ. ៤៥។

[2674] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037141 ឆ. ២៩។

[2675] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037144 ឆ. ៤៦។

[2676] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037144 ឆ. ៤៧។ *សូមមើលផងដែរ* ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៤ ERN 01008701 ឆ.៣៣ ERN 01008709 ឆ.៧៤។ ធៀបទៅនឹង ឯកសារ **D219/974.1.2** កំណត់ហេតុជា លាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សំណុំរឿង ០០២/០២ [ណុប ធីម] ចុះថ្ងៃទី៥ ខែ កញ្ញា ឆ្នាំ២០១៦ ERN 01382500 បន្ទាត់ទី៣-៤។

[2677] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037144 ឆ. ៤៨។

ថាគាត់មិនដែលឃើញមុខគាត់ទេ[2678]។ ម្យ៉ាងវិញទៀត ភស្តុតាងរបស់ ណុប ធីម មិនគាំទ្រចំពោះការពាក់ព័ន្ធរបស់ **យឹម ទិត្យ** នៅក្នុងពិធីទាំងមូលទេ។ យោងតាមគាត់ *"យឹម ទិត្យ បានមកជួបនិយាយជាមួយ តាម៉ុក មុនពេលពិធីរៀបការចាប់ផ្តើម"*[2679] មានតែ តាម៉ុក ទេ ដែលបានមកចូលរួមក្នុងពិធីនោះ ហើយពីរបីថ្ងៃក្រោយមកទើបឃើញ **យឹម ទិត្យ** បានមកចូលរួម ដើម្បីពិនិត្យមើលការអនុវត្តរបស់ប្តីប្រពន្ធដែលទើបរៀបការរួច[2680]។ ហេតុដូច្នេះ ភស្តុតាងមិនអាចបញ្ជាក់បានឡើយអំពីការចូលរួមរបស់ **យឹម ទិត្យ** នៅក្នុងពិធីរៀបការនោះ។ ប៉ុន្តែ ភស្តុតាងពិតជាបានបញ្ជាក់ថា **យឹម ទិត្យ**មានវត្តមាន រហូតដល់ពេលពិធីចាប់ផ្តើមមែន។

987. ទាំង ព្រាប កប ទាំង ណុប ធីម ផ្តល់ភស្តុតាងស្របគ្នាថា មានគូស្រករ ៤០គូ នៅក្នុងពិធីនោះ។ នារីពីរនាក់បានដើរចេញ ហើយនៅចុងបញ្ចប់ពួកនាងមិនត្រូវឲ្យរៀបការទេ ហើយក៏មិនទទួលទណ្ឌកម្មដែរ ដោយសារ តាម៉ុក សម្រេចថា ពួកនាងនៅក្មេងពេកមិនទាន់រៀបការបានទេ[2681]។

988. ភស្តុតាងរបស់អ្នកទាំងពីរ អំពីការតាមដានក្រោយការរៀបការ គឺមានភាពផ្ទុយគ្នា ហើយមិនអាចឲ្យធ្វើការសន្និដ្ឋានបានជាក់លាក់ថាតើ ក្នុងករណីរបស់ពួកគាត់ ការតាមដានដូច្នេះពិតជាបានកើតឡើងដែរ ឬអត់។ ពីដំបូង សាក្សីទាំងពីរថា ពួកគាត់ផ្ទាល់មិនមានគេតាមដានឈ្លបយកការណ៍ក្រោយការរៀបការរបស់ពួកគាត់ទេ[2682] ហើយ ព្រាប កប ក៏មិនបានឮពីនរណាផ្សេងអំពីរឿងនេះ

---

[2678] ឯកសារ **D219/62.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រាប កប ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ ERN 00734877។

[2679] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008708 ឆ.៧៣។

[2680]ឯកសារ **D219/974.1.2** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សំណុំរឿង ០០២/០២ [ណុប ធីម] ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ERN 01382495 បន្ទាត់ទី១៣-១៥ ERN 01382500 បន្ទាត់ទី៣-៤។

[2681] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037145 ឆ.៥១។ ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008708 ឆ.៦៩។ *សូមមើលផងដែរ* ឯកសារ **D219/298** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ERN 01095986-87 ឆ.១១។

[2682] ឯកសារ **D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037145 ឆ.៥២។ ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008708 ឆ.៧០។

ដែរ[2683]។ គាត់ក៏មិនធ្លាប់ត្រូវបានគេប្រាប់ឱ្យរួមដំណេកជាមួយប្រពន្ធគាត់ដែរ[2684] ហើយក៏គ្មានសេចក្ដីណែនាំណាផ្សេង ដែលគេបានរំពឹងទុកពីប្ដីប្រពន្ធនេះទេ[2685]។ យ៉ាងណាមិញ ការងាកចេញពីទម្លាប់អនុវត្តទូទៅនេះហាក់ដូចជាស៊ីចង្វាក់គ្នាទៅនឹងកំណត់ហេតុ DC-Cam របស់គាត់ដែលនិយាយសំដៅដល់ចំណង់របស់គាត់ក្នុងការរៀបការជាមួយ ណុប ងឹម[2686] ដែលដូចជាមិនត្រូវការឱ្យមានការលើកទឹកចិត្តបែបនេះឡើយ។

989. ផ្ទុយទៅវិញ នៅក្នុងកំណត់ហេតុដាច់ដោយឡែកមួយ ណុប ងឹម ចោទថា តាមពិត ពួកឈ្លប *"តាមដាន"* អ្នកដែលទើបរៀបការថ្មីៗ[2687] ដែលមិនមែនជាបទដ្ឋានធម្មតាតាមប្រពៃណីខ្មែរ[2688] ហើយក៏មិនមែនជាទម្លាប់នៃការអនុវត្តរបស់ពួកឈ្លប នៅមុនការរៀបការរបស់ ណុប ងឹម ដែរ[2689] ដូច្នេះជាថ្មីម្ដងទៀត កំណត់ហេតុចុងក្រោយនេះហាក់ដូចជាចម្លែកខុសគេពីភ័ស្តុតាងពីទីតាំងឧក្រិដ្ឋកម្មដទៃទៀត។ គាត់និយាយទៀតថា ពីរបីថ្ងៃក្រោយពិធី **យឹម ទិត្យ** បានមកសួរថា *"តើមាននរណាមិនយល់ព្រមរស់នៅជាមួយគ្នាទេ"* និង *"បានណែនាំ[ឱ្យអ្នកដែលទើបរៀបការហើយ] រស់នៅជាមួយគ្នាឱ្យសប្បាយ"*[2690]។ គាត់បានបំភ្លឺថា គាត់បានយល់ពីការណែនាំរបស់ **យឹម ទិត្យ** ដែលបានផ្ដល់ក្រោយពេលចប់ពិធី ឬក្នុងអំឡុងពេលដែលគាត់បានចុះមកមើលពីរបីថ្ងៃក្រោយមក

[2683] ឯកសារ **D219/62** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037145 ឆ. ៥២។

[2684] ឯកសារ **D219/62** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037149 ឆ. ៧៦។

[2685] ឯកសារ **D219/62** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037149 ឆ. ៧៧។

[2686] ឯកសារ **D219/62.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 00734877។

[2687] ឯកសារ **D219/835** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ERN 01329404-01329405 **ឆ.១៤៦-១៤៧**។

[2688] ឯកសារ **D219/835** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ERN 01329405 **ឆ .១៥៥-១៥៦**។

[2689] ឯកសារ **D219/835** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ERN 01329406 **ឆ .១៥៩**។

[2690] ឯកសារ **D219/974.1.2** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សំណុំរឿង ០០២/០២ [ណុប ងឹម] ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ERN 01382495 បន្ទាត់ទី១៣-១៥ ERN 01382500 បន្ទាត់ទី៣-៥។

ថា *"ពេលរៀបការហើយ គេត្រូវតែដេកជាមួយគ្នា"*[2691] ហើយគាត់ធ្វើដូចជាបានដេកជាមួយគ្នា ព្រោះគាត់ខ្លាចពួកឈ្លបដឹងអំពីគូស្រករណាដែលមិនដេកជាមួយគ្នា ឬមិនស្រឡាញ់គ្នា[2692]។ គាត់បានពន្យល់ថា ឈ្លបនឹងរាយការណ៍ទៅគណៈឃុំអំពីប្ដីប្រពន្ធណាដែលមិនចុះសម្រុងនឹងគ្នា ហើយគណៈឃុំនឹងហៅប្ដីប្រពន្ធនោះទៅ *"ណែនាំឱ្យស្រឡាញ់គ្នា"*[2693]។

990. យ៉ាងណាមិញ នៅក្នុងសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង00២/0២[2694] គាត់មិនអាចបញ្ជាក់ឱ្យបានពេញលេញអំពីភាពផ្ទុយគ្នាទៅនឹងសាច់រឿង ដែលគាត់បានផ្ដល់ពីដំបូងនោះទេ ដែលគាត់បានបំភ្លឺថាគាត់ដឹងថា កម្មាភិបាលតាមដានពួកគេ ដោយសារគេបានឃើញពួកគេនៅពេលយប់ និងបាននិយាយគ្នាថា ពួកគេត្រូវប្រុងប្រយ័ត្ន ដោយសារមានឈ្លប។ នៅពេលសុំឱ្យគាត់និយាយអំពីភាពមិនស្របគ្នានេះនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីពីមុនរបស់គាត់[2695] ដែលគាត់បាននិយាយថា គ្មាននរណាម្នាក់តាមដានពួកគេនោះ គាត់បាននិយាយដដែលយ៉ាងសាមញ្ញថា គាត់ខ្លាចគេតាមដាន ប៉ុន្តែគាត់មិនដែលឮលេខាស្រុក ឡេង និយាយអំពីការដាក់ឈ្លបឱ្យតាមដានអ្នកដែលទើបរៀបការហើយថ្មីៗនោះទេ[2696]។

991. ភ័ស្តុតាងរបស់សាក្សីទាំងពីររួមគ្នា មិនគ្រប់គ្រាន់ដើម្បីកំណត់ថាតើ ការតាមដានក្រោយការរៀបការបានកើតមានឡើងមែន ឬអត់នៅក្នុងឧប្បត្តិហេតុនេះ។ ការណ៍នេះអាចពន្យល់បានមួយផ្នែកនៅករណីផ្ទាល់របស់ពួកគេតាមអង្គហេតុ ដែលនាំឱ្យគេមានមូលហេតុឱ្យជឿបានថា មានការយល់ព្រមយ៉ាងហោចណាស់ក៏ពីខាងកូនកំលោះដែរ។ ទោះបីជាយ៉ាងណាក្ដី ការយល់ព្រមតែពីភាគីកូនកំលោះម្នាក់ មិនមែនជាបុព្វហេតុនាំឱ្យមានការបន្ថយតម្លៃសក្ខីកម្មនោះទេ ទាក់ទងនឹងភាពមិនស្ម័គ្រចិត្ត

---

[2691] ឯកសារ **D219/835** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងីម ចុះថ្ងៃទី២0 ខែកញ្ញា ឆ្នាំ២0១៦ ERN 01329405 ឆ.១៤៩-១៥៣។

[2692] ឯកសារ **D219/835** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងីម ចុះថ្ងៃទី២0 ខែកញ្ញា ឆ្នាំ២0១៦ ERN 01329404-01329405 ឆ.១៤៦-១៤៧។

[2693] ឯកសារ **D219/835** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងីម ចុះថ្ងៃទី២0 ខែកញ្ញា ឆ្នាំ២0១៦ ERN 01329406 ឆ.១៥៧-១៥៨។

[2694] ឯកសារ **D219/974.1.2** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សំណុំរឿង 00២/0២ [ណុប ងីម] ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២0១៦ ERN 01382503 បន្ទាត់ទី១៤-១៥។

[2695] ឯកសារ **D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ងីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២0១៤ ERN 01008708 ឆ.៧0។

[2696] ឯកសារ **D219/974.1.2** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សំណុំរឿង 00២/0២ [ណុប ងីម] ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២0១៦ ERN 01382517 បន្ទាត់ទី២១-២៥។

ក្នុងការរៀបការសម្រាប់គូស្រករភាពច្រើនលើសលុបទាំង ៣៧ គូផ្សេងទៀត ដូចបានពោលខាងលើ។ ការពិតដែល៖

i. កូនក្រមុំទាំងអស់ជាអតីតកម្មករមកពីស្រែអំបិល។

ii. កូនកំលោះទាំងអស់ជាយោធាពិការ មកពីផ្នែកផ្សេងៗនៃប្រទេស ហើយមានការសង្ស័យថា គេឱ្យមានគ្រួសារដើម្បីជា "រង្វាន់លើកទឹកចិត្ត" ដល់ពួកគេដែលបានបម្រើ*អង្គការ* បើមិនដូច្នេះ ពួកគេនឹងមានការលំបាកក្នុងការរកប្រពន្ធតាមរយៈការចែចង់តាមរបៀបធម្មតា ដោយសារពិការភាពរបស់ពួកគេ។

iii. ពួកគេទាំងអស់ត្រូវតែរៀបការ ទោះបីជាមិនធ្លាប់ស្គាល់គ្នាពីមុនក៏ដោយ និងថា

*iv.* ក្នុងចំណោមពួកនារី ពួកគេទាំងអស់ "*ខឹង*" និងខ្លះយំ ហើយមានពីរនាក់បានរត់

ដែលទាំងនេះគាំទ្រដល់សេចក្តីសន្និដ្ឋាន យ៉ាងហោចណាស់ក៏ជាទស្សនៈពីខាងកូនក្រមុំ ថាពិធីរៀបការទាំងនេះមិនធ្វើឡើងដោយស្ម័គ្រចិត្តនោះទេ[2697]។

## ៦. របកគំហើញផ្នែកច្បាប់ស្តីពីយុត្តាធិការបុគ្គល

992. **យឹម ទិត្យ** ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ជាជនម្នាក់នៃ *"ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"* ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានចែងខាងលើ ក្នុងវាក្យខណ្ឌស្តីពីច្បាប់ជាធរមាន។

993. បើនិយាយអំពីមុខតំណែងផ្លូវការរបស់គាត់ គាត់បានឡើងឋានៈយ៉ាងឆាប់រហ័សពីមុខតំណែងជាអនុលេខាស្រុកនៅភូមិភាគនិរតី ទៅជាអនុលេខាភូមិភាគ ហើយរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់ប្រហែលជាបានឡើងឋានៈជាលេខាភូមិភាគពេញលេញនៃភូមិភាគពាយ័ព្យ។ ជាងនេះទៀត គាត់បានធ្វើជាលេខាតំបន់នៅតាមតំបន់មួយចំនួននៅក្នុងភូមិភាគពាយ័ព្យ។ ហេតុដូច្នេះ សិទ្ធិអំណាចរបស់គាត់នៅក្រោម ប.ក.ក លាតសន្ធឹងយ៉ាងឆ្ងាយ ទាំងផ្នែកភូមិសាស្ត្រ និងទាំងនៅក្នុងឋានានុក្រម។

994. មុខតំណែងផ្លូវការរបស់គាត់ – និងការឡើងឋានៈលឿនដូចដុំថ្មធ្លាក់ពីលើមេឃ – ត្រូវបានគាំទ្រដោយចំណងគ្រួសារយ៉ាងជិតស្និទ្ធរបស់គាត់ ជាមួយកម្មាភិបាលថ្នាក់កំពូលម្នាក់ដែលស្ថិតនៅក្នុង

---

[2697] ឯកសារ **D219/974.1.2** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សំណុំរឿង ០០២/០២ [ណុប ធីម] ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ERN 01382488 ERN 01382489-91។

ឋានានុក្រម ប.ក.ក គឺ តាម៉ុក ដែលត្រូវជាបងថ្លៃគាត់។ សូម្បីតែតាំងពីមុនការចូលកាន់តំណែងផ្លូវការនៅភូមិភាគពាយ័ព្យរបស់គាត់ក៏ដោយ ក៏គេបានឃើញគាត់ធ្វើដំណើរជាមួយ តាម៉ុក ទូទាំងភូមិភាគ និងការជួបប្រជុំជាដើម។ គាត់គឺជាមេបញ្ជាការ*តាមព្រឹត្តន័យ*ទីពីររបស់ តាម៉ុក និងបើតាមភ័ស្តុតាង គាត់ក៏មានសិទ្ធិអំណាច*តាមព្រឹត្តន័យ*ទៅលើសកម្មភាពនៅតាមតំបន់មុនៗរបស់គាត់ផងដែរ ទោះបីជាបានទៅភូមិភាគពាយ័ព្យហើយក៏ដោយ។

995. ទម្ងន់នៃអំពើប្រព្រឹត្តរបស់គាត់ក៏គាំទ្រចំពោះការរកឃើញថា គាត់គឺជាជនម្នាក់នៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។ សូម្បីតែនៅក្រោយការកាត់បន្ថយទីតាំងឧក្រិដ្ឋកម្មជិតពាក់កណ្តាលពីបញ្ជីដើម ដែលផ្អែកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយអនុលោមវិធាន៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ហើយក៏ដោយ គឺគាត់នៅតែស្ថិតក្រោមការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាជាង ២០ទីតាំងដែរ។ ឧក្រិដ្ឋកម្មទាំងនេះមានចាប់ពីអំពើប្រល័យពូជសាសន៍នៃការសម្លាប់រង្គាល រហូតដល់ឧក្រិដ្ឋកម្មដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើមនុស្សឃាតក្រោមច្បាប់ក្នុងប្រទេស។

996. ភាពលេចធ្លោពាក់ព័ន្ធនឹងចំណុចនេះគឺការចូលរួមប្រព្រឹត្ត និងការរៀបចំរបស់គាត់ក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម នៅក្នុងតំបន់ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គាត់។ ដូចនៅក្នុងសំណុំរឿង០០៤/០២ និងសំណុំរឿង០០៣ដែរ អង្គហេតុនេះតែមួយគត់ក៏អាចដាក់គាត់យ៉ាងជាប់មិនឲ្យរួចខ្លួនពីយុត្តាធិការបុគ្គលនោះទេ។ វិសាលភាពនៃគោលដៅនៃអំពើប្រល័យពូជសាសន៍ចំពោះខ្មែរក្រោមដែលផ្អែកលើជាតិពន្ធុរបស់ពួកគេ ត្រូវបានបញ្ជាក់តាមរយៈការពិតថា ក្នុងករណីខ្លះ ពួកគេត្រូវបានបញ្ជូនពីកម្ពុជាក្រោម នៅក្នុងប្រទេសវៀតណាម មកកម្ពុជាប្រជាធិបតេយ្យ និងបន្ទាប់មកក៏បានសម្លាប់ចោលនៅទីនោះ។ ភ័ស្តុតាងក្នុងសំណុំរឿងនេះស្តីពីចំនួនខ្មែរក្រោមដែលត្រូវបានសម្លាប់ បានទទួលរងអានុភាពជាក់លាក់នៃការថមថយភ័ស្តុតាងសាក្សីជាតួយ៉ាង ប៉ុន្តែទោះបីជាមានការថមថយយ៉ាងនេះក៏ដោយ ក៏រូបភាពនៃយុទ្ធនាការបោសសម្អាតជាតិពន្ធុដ៏គ្មានត្រាប្រណីនៅតែលេចធ្លោ រហូតដល់ត្រូវបានកាត់ផ្តាច់ដោយការមកដល់របស់វៀតណាម និងការបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ បើកុំតែមានការមកដល់របស់វៀតណាម ចំនួននៃអ្នកស្លាប់ទាំងអស់ ដែលសូម្បីតែការប៉ាន់ស្មានបែបអភិរក្សនិយមផ្អែកលើភ័ស្តុតាងដែលបានរកឃើញក្នុងពេលស៊ើបសួរ អាចមានដល់រាប់ពាន់នាក់ទៅហើយនោះ អាចបន្តកើនឡើងជាងនេះយ៉ាងនេះច្រើនទៀត។

997. ក្រៅពីគោលដៅវាយប្រហារប្រល័យពូជសាសន៍លើខ្មែរក្រោម ជនស៊ីវិលផ្សេងទៀត និងអតីតកម្មាភិបាល ប.ក.ក ដែលបានក្លាយជាជនរងគ្រោះនៅក្រោម **យឹម ទិត្យ** និងដោយ **យឹម ទិត្យ** មានចំនួនរាប់ម៉ឺននាក់ ផ្អែកលើទស្សនៈនយោបាយដែលដើរខុស និងភាពរវើរវាយខាងទស្សនៈនយោបាយ ដែលបង្ហាញតាមរយៈការសម្លាប់ជាបន្តបន្ទាប់ និងក្នុងទ្រង់ទ្រាយធំ ដោយមានការរៀបចំយ៉ាងល្អ ព្រមទាំងការប្រព្រឹត្តដ៏ឃោរឃៅ និងអមនុស្សធម៌ តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង និងពលកម្មយ៉ាងវេទនាក្នុងលក្ខខណ្ឌមិនអាចនិយាយបាន នៅតាមបណ្តាមន្ទីរសន្តិសុខ និងការដ្ឋានការងារ។ កម្រិតនៃភាពមាក់ងាយដ៏អមនុស្សធម៌ ដែលបានបង្ហាញឲ្យឃើញនៅតាមបណ្តាទីតាំងទាំងនេះ និងកម្រិតនៃភាពអមនុស្សធម៌របស់ជនទាំងឡាយដែលកាន់ការងារនៅទីនោះ គឺប្រៀបបានទៅនឹងការភ័យរន្ធត់នៃជំរុំប្រមូលផ្តុំណាស៊ីនៅក្នុងប្រទេសអាល្លឺម៉ង់។

998. ការប្រមាថចំពោះជម្រើសនៃជីវិតសម្រាប់មនុស្សម្នាក់ៗក្នុងកម្រិតដូចគ្នានេះ និងជាពិសេសស្វ័យភាពក្នុងការសម្រេចចំពោះទំនាក់ទំនងផ្លូវភេទ ត្រូវបានអនុវត្តតាមរយៈគោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ។ មនុស្សប្រុស និងស្រី ត្រូវបានដាក់ឲ្យស្ថិតនៅក្រោម **យឹម ទិត្យ** និងអ្នកដែលគាត់បានសហការជាមួយ ចំពោះការពិសោធសង្គមដែលគួរខ្ពើមរបស់ ប.ក.ក ក្នុងការបន្ទាបបន្ថោកប្រពៃណីរៀបអាពាហ៍ពិពាហ៍ ឲ្យមកនៅត្រឹមជាឧបករណ៍សម្រាប់ឃោសនាចំពោះមនុស្ស និងដើម្បីបង្កើនចំនួនប្រជាជនកម្ពុជា ដោយគ្មានអារម្មណ៍ជាមនុស្ស ក្រៅពីបង្កើតការភ័យខ្លាច ភាពស្អប់ខ្ពើមគ្នា កំហឹង និងការនាំមកនូវភាពអាក់អន់ចិត្តចំពោះគ្នាតែប៉ុណ្ណោះ។ ការអនុវត្តគោលនយោបាយនេះ បានបំផ្លាញជីវិតមនុស្សខ្មែរជាច្រើននាក់ និងអស់រយៈពេលជាច្រើនទសវត្សរ៍។ ខណៈដែលមនុស្សប្រុស និងស្រី បានទទួលរងនូវការឈឺចាប់ ផលប៉ះពាល់ដ៏ធំបានធ្លាក់ទៅលើជនរងគ្រោះជាស្ត្រី ដែលជាញឹកញាប់ត្រូវបានគេចាត់ទុកជាចម្បងថា គ្រាន់តែជារង្វាន់លើកទឹកចិត្ត និងការទូទាត់ដល់ពួកយោធាដែលបានពិការដោយសារការប្រយុទ្ធ និងដែលមានការលំបាកក្នុងការស្វែងរកដៃគូតាមរយៈការចែចង់ជាធម្មតា។ ជាសំខាន់ ស្ត្រីទាំងនេះមិនត្រូវបានគេប្រព្រឹត្តខុសពីទាសីឡើយ ផ្អែកលើឥរិយាបថហួសសម័យដែលសូម្បីតែមនោគមន៍វិជ្ជាកុម្មុយនីស្តសមភាពនិយម និងបែបសម្ញែងរបស់ ប.ក.ក ក៏នៅតែអះអាងមិនបញ្ចេញជាក់ស្តែងថា បុរស - ឬ សង្គម - មានសិទ្ធិតាមធម្មជាតិខ្លះៗ ឬមានការត្រួតត្រាទៅលើរាងកាយរបស់ស្ត្រី និងការរួមភេទ។ ក្នុងករណីជាច្រើន ឥរិយាបថជាកម្មសិទ្ធិនេះបានសម្តែងឲ្យឃើញនៅក្នុងការតាមដានលើ "ការរួមដំណេកជាមួយគ្នាក្រោយរៀបការរួច" ដែលនៅក្នុងបរិបទនេះ គ្មានអ្វីក្រៅពីការសម្រាលពាក្យនៃការរំលោភសេពសន្ថវៈ ដែលជាបទឧក្រិដ្ឋមួយ ទោះជាមិនបានសម្រេចថាជាផ្នែកនៃច្បាប់ទម្លាប់នៃ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏វាជាឧក្រិដ្ឋកម្មច្បាស់លាស់មួយដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

999. **យឹម ទិត្យ** បានដើរតួនាទីដ៏សំខាន់នៅក្នុងអំពើយង់ឃ្នងទាំងអស់ ដូចបានរៀបរាប់ខាងលើ ហើយបានយល់ព្រមទទួលយកដោយសុខចិត្តចំពោះមនោគមន៍វិជ្ជាជាស្នូល និងការអនុវត្តគំរូសង្គមអមនុស្សធម៌របស់ ប.ក.ក។ ជាឧទាហរណ៍ តួនាទី និងសកម្មភាពរបស់គាត់អាចប្រៀបធៀបបានយ៉ាងងាយជាមួយនឹងតួនាទី និងសកម្មភាពរបស់ អោ អាន ឬ មាស មុត ហើយប្រាកដណាស់ក៏អាចប្រៀបធៀបបានជាមួយនឹងតួនាទី និងសកម្មភាពរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ដែរ។ ជួនកាលទៀតអាចលើសច្រើនជាងនេះទៀតផង។ ដូច្នេះ គ្មានអ្វីដែលអាចឱ្យគេមានមន្ទិលថា **យឹម ទិត្យ** មិនស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។

## ៧. របកគំហើញផ្លូវច្បាប់អំពីឧក្រិដ្ឋកម្ម

### ៧.១. ធាតុផ្សំគ្រួបដណ្តប់រួមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

1000. នៅចន្លោះចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ ទៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប.ក.ក បានធ្វើការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យនៃកម្ពុជាប្រជាធិបតេយ្យ។ ការវាយប្រហារនោះបានធ្វើឡើងតាមរយៈសសរស្តម្ភចំនួនបួន។

1001. ទីមួយ ប.ក.ក បានអនុវត្តគោលនយោបាយមួយក្នុងការបង្កើតសហករណ៍ និងការដ្ឋានការងារនៅទូទាំងកម្ពុជា និងធ្វើបន្លាស់ទីប្រជាជនទាំងមូលដោយបង្ខំទៅធ្វើការនៅតាមបណ្តាទីតាំងទាំងនោះ។ គោលដៅចុងក្រោយគឺដើម្បីផ្លាស់ប្តូរកម្ពុជា ឱ្យក្លាយជារដ្ឋសង្គមនិយមឯករាជ្យមួយ ដែលនឹងម្ចាស់ការលើខ្លួនឯង ដោយពឹងផ្អែកលើសេដ្ឋកិច្ចស្រែចម្ការ ប.ក.ក បានបង្ខំឱ្យប្រជាជនស៊ីវិលធ្វើការងារដោយគ្មានប្រាក់ឈ្នួល នៅក្រោមលក្ខខណ្ឌការងារ និងការរស់នៅដ៏មហន្តរាយ ដែលនាំឱ្យកម្មករទាំងនោះទទួលរងនូវការឈឺចាប់យ៉ាងវេទនាទាំងលើរាងកាយ និងផ្លូវចិត្ត។ ពួកគេជាច្រើនបានស្លាប់ ដោយសារការហេវហត់អស់កម្លាំង ការបង្អត់អាហារ និងជំងឺ។ ចំណែកឯអ្នកខ្លះផ្សេងទៀតត្រូវបានសម្លាប់ ដោយសារតែការប្រព្រឹត្តខុសឆ្គងតូចតាច ឬមូលហេតុផ្សេងៗទៀត ការចោទប្រកាន់តាមទំនើងចិត្ត។

1002. ផ្នែកទីពីរនៃការវាយប្រហាររបស់ ប.ក.ក ទៅលើជនស៊ីវិលនៅតាមបណ្តាភូមិភាគទាំងនេះ គឺពាក់ព័ន្ធនឹងការអប់រំឡើងវិញចំពោះ *"សមាសធាតុមិនល្អ"* និងការសម្លាប់ *"ខ្មាំង"* ទាំងនៅក្នុងជួរ និងក្រៅជួរ ប.ក.ក។ ប.ក.ក បានបង្កើតមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅពាសពេញភូមិភាគ

ទាំងនោះ ដែលគេប្រើសម្រាប់កំណត់អត្តសញ្ញាណ តាមដាន និងអប់រំ ឬសម្លាប់អ្នកដែលគេគិតថាជាខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ។ ជនណាក៏ដោយដែលគេសង្ស័យសូម្បីតែកំហុសតូចតាច ឬមិនស្មោះត្រង់ គឺជាគោលដៅសក្តានុពលនៃការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់។

1003. ទីបី ប.ក.ក បានកំណត់អត្តសញ្ញាណ កំណត់គោលដៅ និងបានធ្វើការបោសសម្អាតជាប្រព័ន្ធទៅលើប្រភេទប្រជាជនដែលគេគិតថា ជាជនដែលគំរាមកំហែងជាសក្តានុពលដល់របបកម្ពុជាប្រជាធិបតេយ្យ ឬអ្នកដែលគេមានទស្សនៈផ្សេងពីនេះដែលវិសមិតភាពនឹងទ្រឹស្តីរបស់ ប.ក.ក។ ទាំងនេះរួមមានអ្នកជម្លៀសពីភូមិភាគបូព៌ា កម្មាភិបាលភូមិភាគពាយ័ព្យ ប្រជាជនដែលគេបានបន្លាស់ទីដោយបង្ខំពីតំបន់ប្រជុំជននានា អតីតទាហាន និងមន្ត្រីរបស់សាធារណរដ្ឋខ្មែរ ខ្មែរក្រោម និងអ្នកផ្សេងទៀតដែលមានអត្តសញ្ញាខាងសាសនា ជាតិពន្ធុ នយោបាយ សេដ្ឋកិច្ច ឬជាតិសាសន៍ ដែលគេគិតថាជាការគំរាមកំហែងដល់គោលដៅនៃការកែប្រែសង្គមកម្ពុជារបស់ ប.ក.ក។

1004. ទិដ្ឋភាពទីបួននៃការវាយប្រហាររបស់ ប.ក.ក ទៅលើប្រជាជន គឺការបញ្ជាឲ្យមានការរៀបអាពាហ៍ពិពាហ៍ដើម្បីបង្កើនចំនួនប្រជាជន និងកសាងគ្រួសារមនោគមន៍វិជ្ជាបរិសុទ្ធ។ ប.ក.ក បានបង្ខំឲ្យប្រជាជនរៀបការជាមួយប្តី ឬប្រពន្ធដែលអង្គការបានជ្រើសរើស និងក្នុងករណីជាច្រើនបានបង្ខំឲ្យពួកគេរួមភេទជាមួយគ្នា។

1005. លក្ខណៈជាប្រព័ន្ធនៃការវាយប្រហារ គឺត្រូវបានបង្ហាញភ័ស្តុតាងតាមរយៈការធ្វើផែនការ ការរៀបចំ និងការអនុវត្តដែលចេញពីមជ្ឈិម ហើយមានការចូលរួមពីគ្រប់កម្រិតនៃរដ្ឋបាលគ្រប់គ្រងស៊ីវិល និងកងទ័ពបដិវត្តន៍កម្ពុជា។ លើសពីនេះទៀត លក្ខណៈរាលដាលនៃការវាយប្រហារ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិសាលភាពនៃពេលវេលា និងភូមិសាស្ត្រដ៏ធំទូលាយរបស់វា ព្រមទាំងចំនួនដ៏ច្រើននៃជនរងគ្រោះ។ ការវាយប្រហារនេះត្រូវបានគេធ្វើឡើងប្រឆាំងទៅលើប្រជាជនស៊ីវិលដោយផ្ទាល់នៃភូមិភាគទាំងពីរ។ វាត្រូវបានគេធ្វើឡើងដោយមូលហេតុនយោបាយ។ វាគឺជាការអនុវត្តរបៀបវារៈគោលនយោបាយរបស់ ប.ក.ក។

1006. តាមមុខតំណែងរបស់គាត់ដូចបានរាយខាងលើនៅក្នុងកថាខណ្ឌ ៣២៧-៣៨៥ **យឹម ទិត្យ** គឺជាអ្នកចូលរួមប្រព្រឹត្តស្នូលម្នាក់នៅក្នុងការវាយប្រហារជាប្រព័ន្ធ និងយ៉ាងរាលដាលប្រឆាំងប្រជាជនស៊ីវិល។ តាមការជួបប្រជុំ ការចុះពិនិត្យតាមការដ្ឋានជាទៀងទាត់ និងប្រព័ន្ធរាយការណ៍ដ៏តឹងរ៉ឹងរបស់ ប.ក.ក **យឹម ទិត្យ** មានចំណេះដឹងពេញលេញអំពីការវាយប្រហារ និងថា អំពើរបស់គាត់គឺជាផ្នែកនៃការវាយប្រហារនេះ។

## ៧.២. ធាតុផ្សំគ្រប់ជណ្ដាប់រួមនៃអំពើចំពារបំពានយ៉ាងធ្ងន់ធ្ងរនៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩

1007. យ៉ាងហោចណាស់ ចាប់ពីពាក់កណ្ដាលខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ អរិភាពប្រដាប់អាវុធបានកើតឡើងរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាមនៅក្នុងទម្រង់ជាជម្លោះប្រដាប់អាវុធអន្តរជាតិ។ ការពិតនៃការមានឈប់ៗនៃការប្រយុទ្ធគ្នា និងការប៉ុនប៉ងក្នុងការបញ្ឈប់អរិភាពនេះដែលជាចុងក្រោយបានបរាជ័យនោះ មិនបានបង្វែរពីការពិតដែល ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោម ដូចបានពិចារណានៅក្នុងដីកាដំណោះស្រាយនេះដែលថា ជម្លោះប្រដាប់អាវុធអន្តរជាតិមួយបានកើតមានឡើង ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដែលជាផ្នែកមួយនៃជម្លោះនេះ និងថាខ្មែរក្រោមគឺជាជនដែលទទួលបាននូវការការពារ។ ក្នុងនាមជាមន្ត្រី ប.ក.ក មួយរូបតាមឋានៈរបស់គាត់ **យឹម ទិត្យ** គឺចាំបាច់ត្រូវតែបានដឹងអំពីជម្លោះនេះ និងទំនាក់ទំនងនៃជម្លោះនេះទៅនឹងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត។

## ៧.៣. របកគំហើញអំពីឧក្រិដ្ឋកម្មនីមួយៗ

### ៧.៣.១. អំពើប្រល័យពូជសាសន៍ខ្មែរក្រោម

1008. ភស្តុតាងបង្ហាញភរនីយភាពរហូតដល់កម្រិតគ្រប់គ្រាន់ថា ផែនការកម្ទេចក្រុមជាតិពន្ធុឱ្យផុតពូជខ្មែរក្រោម ឬយ៉ាងហោចណាស់ក៏មួយផ្នែកធំនៃពួកគេ ដោយសារតែជាតិពន្ធុរបស់គេ ពិតជាមានអត្ថិភាពនៅទូទាំងប្រទេសយ៉ាងពិតប្រាកដ។ ផែនការកម្ទេចខ្មែរក្រោមត្រូវបានគេអនុវត្តតាមរយៈការសម្លាប់រង្គាលជាប្រព័ន្ធតាមតំបន់នានារបស់កម្ពុជាប្រជាធិបតេយ្យ ដែលមានប្រជាជនខ្មែរក្រោមប្រមូលផ្ដុំគ្នាច្រើន។ ការពិតដែលថាពីដំបូង ខ្មែរក្រោមមួយចំនួនតូចត្រូវបានគេបញ្ចូលទៅក្នុងកងយោធាពិសេសនោះ មិនបានបង្វែរផែនការកម្ទេចនេះដែរ ពីព្រោះជាឧទាហរណ៍ សូម្បីតែនៅក្នុងរបបសង្គមនិយមជាតិមួយនៃជំរុំប្រមូលផ្ដុំ អ្នកទោសជ្វីពត្រូវបានឃុំឃាំងក្នុងចិរវេលាខុសគ្នា និងដែលជាញឹកញាប់ក្នុងរយៈពេលវែង ហើយត្រូវបានផ្ដល់ការងារនៅក្នុងជំរុំ ដែលបានជួយពួកគេឱ្យរស់រានមានជីវិតនោះ។ ទោះបីជាយ៉ាងនេះក៏ដោយ តាមគោលនយោបាយនានារបស់របបនេះ ជីវិតពួកគេត្រូវបានរក្សាទុកសម្រាប់តែដើម្បីសម្លាប់ចោល ដែលជាផ្នែកនៃការប្រព្រឹត្តជាទូទៅក្នុងការបោសសម្អាតជនជាតិជ្វីពទាំងអស់ពីសង្គម។

1009. ខ្មែរក្រោម ត្រូវបានកំណត់គោលដៅសម្រាប់កម្ទេច មិនមែនដោយសារសកម្មភាពរបស់ពួកគេទេ ប៉ុន្តែដោយសារឋានៈនៃជាតិពន្ធុរបស់ពួកគេ ថាពួកគេជាប់ពាក់ព័ន្ធនឹងវៀតណាម ហេតុដូច្នេះ *បើតាមនិយមន័យ* គឺមិនអាចឱ្យទុកចិត្តបាន និងអាចនាំទុក្ខដល់ ប.ក.ក។ តាមន័យម្យ៉ាងទៀតគឺថា

ជាតិពន្ធុរបស់ពួកគេបានញ៉ាំងឲ្យមានការសន្មតមួយដែលមិនអាចកែប្រែបានថា ពួកគាត់គឺជាខ្មាំង ទោះបីជាជាក់ស្តែងវាមិនមែនករណីដូច្នេះក៏ដោយ។ វិសាលភាពនៃការកំណត់គោលដៅប្រល័យពូជសាសន៍ចំពោះខ្មែរក្រោមផ្អែកលើជាតិពន្ធុរបស់ពួកគេ ត្រូវបានបញ្ជាក់តាមការពិតដែលថា ក្នុងករណីខ្លះ ពួកគេត្រូវបានបញ្ជូនពីកម្ពុជាក្រោមនៅក្នុងប្រទេសវៀតណាម មកកម្ពុជាប្រជាធិបតេយ្យ និងបន្ទាប់មកក៏បានត្រូវបានសម្លាប់ចោលនៅទីនេះ។

1010. ព្រឹត្តិការណ៍នីមួយៗ ឧទាហរណ៍ ដូចជា ការចាប់ខ្លួន និងការសម្លាប់អ្នកគេហៅថា "ពួកក្រមាស" ដែលជាសម្ព័ន្ធមិត្តនៃរបបចាស់ មិនផ្លាស់ប្តូរការវាយតម្លៃនេះទេ ពីព្រោះ គ្រាន់តែការពិតមួយដែលថាពួកគេជាសម្ព័ន្ធមិត្តនៃកងកម្លាំងប្រឆាំង មិនមែនជាមូលហេតុសម្រាប់ការសម្លាប់ពួកគេឡើយ នេះបើតាមច្បាប់អន្តរជាតិនោះទេ។ ការពិត វាគួរតែជាការបង្កើតឲ្យមាននូវការការពារតាមច្បាប់មនុស្សធម៌ទៅវិញទេ។ ភស្តុតាងគាំទ្រដល់ការសន្និដ្ឋានថា វាសនារបស់អ្នកដែលគេបានចាប់ខ្លួនត្រូវបានកំណត់ដោយមិនត្រឹមតែតាមរយៈសកម្មភាពរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែជាចម្បងនោះ គឺដោយសារជាតិពន្ធុរបស់ពួកគេ។ ការពិតដែលថាមូលហេតុផ្សេងទៀតអាចមានតួនាទីផងដែរនោះក៏នៅតែមិនពាក់ព័ន្ធនោះទេ ដោយសារថា ចេតនាប្រល័យពូជសាសន៍អាចជាផ្នែកមួយនៅក្នុងបណ្តុំនៃចេតនា និងមូលហេតុទាំងនោះ ហើយចេតនាប្រល័យពូជសាសន៍នេះមិនបាត់បង់នោះទេ ដរាបណាចេតនានេះនៅតែលេចធ្លោជាងមូលហេតុផ្សេងៗទៀត។ នេះគឺជាករណីនៅទីនេះហើយ។

1011. ដូច្នេះ ការប្រព្រឹត្តចំពោះខ្មែរក្រោម ដែលផ្អែកលើមូលហេតុរើសអើង ដោយសារជាតិពន្ធុរបស់ពួកគេ ហើយ ប.ក.ក **យឹម ទិត្យ** និងអ្នកដែលគាត់បានសហការជាមួយ មានចេតនាកម្ទេចពួកគេទាំងស្រុង ឬយ៉ាងហោចណាស់ ក៏មួយផ្នែកធំដែរ។ ចរិតលក្ខណៈជាប្រព័ន្ធនៃប្រតិបត្តិការសម្លាប់នៅលើតំបន់ដ៏ធំធេងដូច្នេះនៃភូមិភាគទាំងពីរគឺភូមិភាគនិរតីនិងពាយ័ព្យ និងចំនួនអ្នកដែលត្រូវបានសម្លាប់តាមបណ្តាទីតាំងឧក្រិដ្ឋកម្ម ដូចបានរាយឈ្មោះខាងលើ គឺជាសក្ខីភាពយ៉ាងច្បាស់ក្រឡែតអំពីរឿងនេះ។ លើសពីនេះ **យឹម ទិត្យ** គឺជាអ្នកគាំទ្រពិតប្រាកដដ៏អសោចក្នុងការកម្ទេច "ខ្មាំង" ណាម្នាក់ ដែលជាប់ពាក់ព័ន្ធជាមួយវៀតណាម រួមទាំងខ្មែរក្រោមផង។

1012. មានភស្តុតាងគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា ឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រោម ដោយការសម្លាប់សមាជិកក្រុម ត្រូវបានប្រព្រឹត្តនៅតាមទីតាំងដូចខាងក្រោម៖

*<u>តំបន់ ១៣ នៃភូមិភាគនិរតី</u>*

*មន្ទីរសន្តិសុខវត្តព្រះធាតុ* (កថាខណ្ឌ ៤៣៣-៤៦៩)

*មន្ទីរសន្តិសុខក្រាំងតាចាន់* (កថាខណ្ឌ ៤៧០-៥២៦)

*ទីតាំងសម្លាប់មនុស្សភូមិព្រាល* (កថាខណ្ឌ ៥២៧-៥៤៦)

*ទីតាំងសម្លាប់មនុស្សវត្តអង្គុញ* (កថាខណ្ឌ ៥៤៧-៥៥៤)

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង* (កថាខណ្ឌ ៥៥៥-៥៦៥)

*តំបន់ ២ នៃភូមិភាគពាយ័ព្យ*

*មន្ទីរសន្តិសុខភូមិវាល* (កថាខណ្ឌ ៧៤៧-៧៧១)

*មន្ទីរសន្តិសុខស្វាយជ្រុំ* (កថាខណ្ឌ ៧៧២-៧៩៦)

*ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ* (កថាខណ្ឌ ៧៩៧-៨១០)

*ទីតាំងសម្លាប់មនុស្សព្រៃក្រពៅ* (កថាខណ្ឌ ៨១១-៨២៦)

*តំបន់ ៤ នៃភូមិភាគពាយ័ព្យ*

*ឃុំកំពង់ព្រៀង (មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ)* (កថាខណ្ឌ ៨៧០-៩១០)

*ឃុំរាំងកេសី* (កថាខណ្ឌ ៨៩៤, ៩១០-៩២០)

## ***បទចោទដែលត្រូវលើកលែង***

គ្មានភ័ស្តុតាងកំណត់អំពីជម្រើសផ្សេងនៃការបង្កការឈឺចាប់ផ្នែករាងកាយ និងផ្លូវចិត្ត ឬអំពីការដាក់លក្ខខណ្ឌផ្សេងៗក្នុងគោលបំណងដើម្បីបំផ្លិចបំផ្លាញទៅលើក្រុម នៅទីតាំងណាមួយនៃទីតាំងឧក្រិដ្ឋកម្មទាំងនេះទេ។ បទចោទទាំងនេះត្រូវតែលើកលែង។

*ការដ្ឋានរោងចក្រស្ករសកំពង់គល់* (កថាខណ្ឌ ៧៣៨-៧៤៦)

គ្មានភ័ស្តុតាងបង្ហាញអំពីការរកឃើញអំពើប្រល័យពូជសាសន៍នៅរោងចក្រស្ករសកំពង់គល់ទេ។ ដូច្នេះបទចោទនេះត្រូវតែលើកលែង។

*ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី* (កថាខណ្ឌ ៥៦៦-៥៨៥)

អាស្រ័យដូចមូលហេតុដែលមានចែងក្នុងកថាខណ្ឌ ១០៣៥ បទចោទនៃអំពើប្រល័យពូជសាសន៍នៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី ត្រូវតែលើកលែង។

## ៧.៣.២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

1013. មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចខាងក្រោម ត្រូវបានប្រព្រឹត្តនៅតាមបណ្តាទីតាំងដូចខាងក្រោម៖

*<u>តំបន់ ១៣ នៃភូមិភាគនិរតី</u>*

*មន្ទីរសន្តិសុខវត្តព្រះធាតុ* (កថាខណ្ឌ ៤៣៣-៤៦៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជន ១៧មេសា និងខ្មែរក្រោម និងការធ្វើទុក្ខបុកម្នេញហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))។

*មន្ទីរសន្តិសុខក្រាំងតាចាន់* (កថាខណ្ឌ ៤៧០-៥២៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ និងការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជន ១៧មេសា និងខ្មែរក្រោម និងការធ្វើទុក្ខបុកម្នេញហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

*ទីតាំងសម្លាប់មនុស្សភូមិព្រាល* (កថាខណ្ឌ ៥២៧-៥៤៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនិងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ))។

*ទីតាំងសម្លាប់មនុស្សវត្តអង្គុញ* (កថាខណ្ឌ ៥៤៧-៥៥៤)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនិងជាតិពន្ធុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង* (កថាខណ្ឌ ៥៥៥-៥៦៥)

ការធ្វើមនុស្សឃាត ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនិងជាតិពន្ធុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ)។

*ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី* (កថាខណ្ឌ ៥៦៦-៥៨៥)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង

អាស្រ័យដូចមូលហេតុដែលមានចែងក្នុងកថាខណ្ឌ ១០៣៥ បទចោទនៃការធ្វើទុក្ខបុកម្នេញនៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី ត្រូវតែលើកលែង។

*<u>តំបន់ ១ នៃភូមិភាគពាយ័ព្យ</u>*

*មន្ទីរសន្តិសុខគាស់ក្រឡ* (កថាខណ្ឌ ៥៨៦-៥៩៥)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង)។

*សហករណ៍ធិបតី (រួមទាំង មន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខនិងការដ្ឋានទួលម្ទេស* (កថាខណ្ឌ ៥៩៦-៦៥១)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))។

*ការដ្ឋានទំនប់កង្ហត* (កថាខណ្ឌ ៦៥២-៧00)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង) អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌)) ។

*មន្ទីរសន្តិសុខបាណន់* (កថាខណ្ឌ ៧០១-៧១៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាម រយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

*មន្ទីរសន្តិសុខខ្នងភ្នំ* (កថាខណ្ឌ ៧២០-៧៣៧)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))។

បទចោទអំពីការធ្វើទារុណកម្ម និងបទចោទដែលពាក់ព័ន្ធអំពីការធ្វើទុក្ខបុកម្នេញតាមរយៈអំពើទារុណកម្មជាមូលដ្ឋាន មិនមានភ័ស្តុតាងគាំទ្រទេ ដូច្នេះត្រូវតែលើកលែង។

*ការដ្ឋានរោងចក្រស្តុកសំពង់គល់* (កថាខណ្ឌ ៧៣៨-៧៤៦)

ការធ្វើមនុស្សឃាត

បទចោទនៃការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ មិនមានភ័ស្តុតាងគាំទ្រទេ ដូច្នេះត្រូវតែលើកលែង។

*ស្រុកសំឡូត* (កថាខណ្ឌ ៩៨០-៩៩១)

អំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ)។

*តំបន់ ២ នៃភូមិភាគពាយ័ព្យ*

*មន្ទីរសន្តិសុខភូមិវាល* (កថាខណ្ឌ ៧៤៧-៧៧១)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងជាតិពន្ធុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

*មន្ទីរសន្តិសុខស្វាយជ្រុំ* (កថាខណ្ឌ ៧៧២-៧៩៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងជាតិពន្ធុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

*ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ* (កថាខណ្ឌ ៧៩៧-៨១០)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងជាតិពន្ធុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

*ទីតាំងសម្លាប់មនុស្សព្រៃក្របៅ* (កថាខណ្ឌ ៨១១-៨២៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងជាតិពន្ធុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

**បទចោទដែលត្រូវលើកលែង**

*ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី* (កថាខណ្ឌ ៨២៧-៨២៨)

គ្មានភស្តុតាងគាំទ្រដល់បទចោទណាមួយទាក់ទងនឹងតាំងសម្លាប់មនុស្សវត្តចន្ទរង្សីទេ។ បទចោទទាំងនេះត្រូវតែលើកលែង។

*តំបន់ ៣ នៃភូមិភាគពាយ័ព្យ*

*មន្ទីរសន្តិសុខវត្តគិរីរម្យ* (កថាខណ្ឌ ៨២៩-៨៤៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងនិងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))

*តំបន់ ៤ នៃភូមិភាគពាយ័ព្យ*

*មន្ទីរសន្តិសុខវត្តសម្តេច* (កថាខណ្ឌ ៨៥០-៨៦៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)

*ឃុំកំពង់ព្រៀង (មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ* (កថាខណ្ឌ ៨៧០-៩១០, ៩១៨-៩២០, ៩៦៧-៩៧៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ អាពាហ៍ពិពាហ៍ដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌)) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល))

*ឃុំរាំងកេសី* (កថាខណ្ឌ ៨៩៤, ៩១១-៩២០, ៩៥០-៩៦៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល អំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងជាតិពន្ធុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)

*តំបន់ ៧ នៃភូមិភាគពាយ័ព្យ*

*គុកលេខ ៨* (កថាខណ្ឌ ៩២១-៩៣៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះអ្នកជម្លៀសមកពីបូព៌ា (តាមរយៈការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))

គ្មានភ័ស្តុតាងគាំទ្រដល់បទចោទនៃការធ្វើទារុណកម្មនៅទីតាំងនេះទេ ហើយក៏គ្មានភ័ស្តុតាងពាក់ព័ន្ធនឹងបទចោទនៃការធ្វើទុក្ខបុកម្នេញដែរ។ បទចោទទាំងនេះត្រូវតែលើកលែង។

*ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង* (កថាខណ្ឌ ៩៤០-៩៤៨)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះអ្នកជម្លៀសមកពីបូព៌ា (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)

### ៧.៣.៣. ឧក្រិដ្ឋកម្មសង្គ្រាម

1014. ភ័ស្តុតាងគាំទ្រដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមដូចខាងក្រោម នៅតាមបណ្តាទីតាំងដូចតទៅ៖

*<u>តំបន់ ១៣ នៃភូមិភាគនិរតី</u>*

*មន្ទីរសន្តិសុខក្រាំងតាចាន់ (កថាខណ្ឌ ៤២៨-៤៣២, ៤៧០-៥២៦)*

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការជម្លៀសជនស៊ីវិលដោយខុសច្បាប់។

*ទីតាំងសម្លាប់មនុស្សភូមិព្រាល (កថាខណ្ឌ ៤២៨-៤៣២, ៥២៧-៥៤៦)*

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការជម្លៀសជនស៊ីវិលដោយខុសច្បាប់។

*ទីតាំងសម្លាប់មនុស្សវត្តអង្គញ (កថាខណ្ឌ ៤២៨-៤៣២, ៥៤៧-៥៥៤)*

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា។

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង (កថាខណ្ឌ ៤២៨-៤៣២, ៥៥៥-៥៦៥)*

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការជម្លៀសជនស៊ីវិលដោយខុសច្បាប់។

### ៧.៣.៤. ការរំលោភក្រុមព្រហ្មទណ្ឌឆ្នាំ១៩៥៦

1015. ភស្តុតាងគាំទ្រដល់ការប្រព្រឹត្តអំពើមនុស្សឃាតគិតទុកជាមុន នៅតាមបណ្តាទីតាំងដូចខាងក្រោម៖

*តំបន់ ១៣ នៃភូមិភាគនិរតី*

*មន្ទីរសន្តិសុខវត្តព្រះធាតុ (កថាខណ្ឌ ៤៣៣-៤៦៩)*

*មន្ទីរសន្តិសុខក្រាំងតាចាន់ (កថាខណ្ឌ ៤៧០-៥២៦)*

*ទីតាំងសម្លាប់មនុស្សភូមិព្រាល (កថាខណ្ឌ ៥២៧-៥៤៦)*

*ទីតាំងសម្លាប់មនុស្សវត្តអង្គុញ (កថាខណ្ឌ ៥៤៧-៥៥៤)*

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង (កថាខណ្ឌ ៥៥៥-៥៦៥)*

*ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី (កថាខណ្ឌ ៥៦៦-៥៨៥)*

*តំបន់ ១ នៃភូមិភាគនិរតី*

*មន្ទីរសន្តិសុខគាស់ក្រឡ (កថាខណ្ឌ ៥៨៦-៥៩៥)*

*សហករណ៍ធិបតី (រួមទាំង មន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស (កថាខណ្ឌ ៥៩៦-៦៥១)*

*ការដ្ឋានទំនប់កង្កួត (កថាខណ្ឌ ៦៥២-៧០០)*

*មន្ទីរសន្តិសុខបាកាន (កថាខណ្ឌ ៧០១-៧១៩)*

*មន្ទីរសន្តិសុខខ្នងតួ (កថាខណ្ឌ ៧២០-៧៣៧)*

*ការដ្ឋានរោងចក្រស្ករសកំពង់តល់ (កថាខណ្ឌ ៧៣៨-៧៤៦)*

*តំបន់ ២ នៃភូមិភាគនិរតី*

*មន្ទីរសន្តិសុខភូមិវាល (កថាខណ្ឌ ៧៤៧-៧៧១)*

*មន្ទីរសន្តិសុខស្វាយជ្រុំ (កថាខណ្ឌ ៧៧២-៧៩៦)*

*ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ (កថាខណ្ឌ ៧៩៧-៨១០)*

*ទីតាំងសម្លាប់មនុស្សព្រៃក្របៅ (កថាខណ្ឌ ៨១១-៨២៦)*

**បទចោទដែលត្រូវលើកលែង**

*ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី (កថាខណ្ឌ ៨២៧-៨២៨)*

គ្មានភស្តុតាងគាំទ្រដល់បទចោទណាមួយទាក់ទងនឹងតាំងសម្លាប់មនុស្សវត្តចាន់រង្សីទេ។ បទចោទទាំងនេះត្រូវតែលើកលែង។

*តំបន់ ៣ នៃភូមិភាគនិរតី*

*មន្ទីរសន្តិសុខវត្តគិរីរម្យ (កថាខណ្ឌ ៨២៩-៨៤៩)*

*តំបន់ ៤ នៃភូមិភាគនិរតី*

*មន្ទីរសន្តិសុខវត្តសម្តេច (កថាខណ្ឌ ៨៥០-៨៦៩)*

*ឃុំកំពង់ត្រៀង - មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ (កថាខណ្ឌ ៨៧០-៩១០, ៩១៨-៩២០)*

*ឃុំរាំងកេសី (កថាខណ្ឌ ៨៩៤, ៩១១-៩២០)*

*តំបន់ ៧ នៃភូមិភាគនិរតី*

*គុកលេខ ៨ (កថាខណ្ឌ ៩២១-៩៣៩)*

*ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង (កថាខណ្ឌ ៩៤០-៩៤៨)*

## ៨. របកគំហើញផ្លូវច្បាប់អំពីទម្រង់នៃការទទួលខុសត្រូវ

### ៨.១. ឧក្រិដ្ឋកម្មអន្តរជាតិ

#### ៨.១.១. ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (JCE)

1016. មានសហឧក្រិដ្ឋកម្មរួមបីខុសៗគ្នាដែល **យឹម ទិត្យ** ជាសមាជិក៖

i. យ៉ាងហោចណាស់ ក៏ចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ដែរ ដែល **យឹម ទិត្យ** តាម៉ុក និងកម្មាភិបាលជាទីទុកចិត្តពីភូមិភាគនិរតី បានធ្វើប្រតិបត្តិការនៅភូមិភាគពាយ័ព្យនៃកម្ពុជាប្រជាធិបតេយ្យ ដើម្បីអនុវត្តគោលនយោបាយនានារបស់ ប.ក.ក ស្តីពីការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ បទប្បញ្ញត្តិអាពាហ៍ពិពាហ៍ដែលត្រូវបានអនុវត្ត*ជាអាទិ៍* តាមរយៈអាពាហ៍ពិពាហ៍ប្រជាជនដោយបង្ខំ ការអប់រំអ្នកដែលហៅថា

"សមាសធាតុមិនល្អ" និងការសម្លាប់ "ខ្មាំង" និង "សមាសធាតុមិនល្អ" ទាំងក្នុងជួរ និងក្រៅជួរ ប.ក.ក ព្រមទាំងការកំណត់គោលដៅក្រុមជាក់លាក់។ អ្នកចូលរួមប្រព្រឹត្តក្នុង JCE នេះ មានចេតនា និងបានអនុវត្តគោលនយោបាយទាំងនេះ តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានធ្វើឡើងដោយសមាជិក JCE ឬមិនមែនជាសមាជិក ដោយប្រើសមាជិក JCE ជាឧបករណ៍ នៅមន្ទីរសន្តិសុខគាស់ក្រឡ សហាករណ៍ធិបតី (រួមទាំង មន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស) ការដ្ឋានទំនប់កង្ហូត មន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខខ្នងគូ ការដ្ឋានរោងចក្រស្ករសកំពង់គល់ ស្រុកសំឡូត មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ មន្ទីរសន្តិសុខវត្តគិរីរម្យ មន្ទីរសន្តិសុខវត្តសម្តេច ឃុំកំពង់ព្រៀង (រួមទាំង ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ និង មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ) ឃុំរាំងកេសី គុកលេខ ៨ ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង ("JCE A")។

ii. យ៉ាងហោចណាស់ ក៏ចាប់ពីដើមឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ដែរ ដែល **យឹម ទិត្យ** តាម៉ុក និងកម្មាភិបាលភូមិភាគនិរតីដទៃទៀតបានរួមចំណែកនៅក្នុងគោលបំណងរួមដើម្បីអនុវត្តនៅក្នុងតំបន់ជាក់លាក់នានានៃកម្ពុជាប្រជាធិបតេយ្យ នូវផែនការទូទាំងប្រទេសមួយក្នុងការកម្ទេចទាំងស្រុង ឬមួយផ្នែកនៃខ្មែរក្រោម។ អ្នកចូលរួមប្រព្រឹត្តក្នុង JCE នេះ មានចេតនា និងបានអនុវត្តផែនការនេះ តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការសម្លាប់សមាជិកក្រុម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានធ្វើឡើងដោយសមាជិក JCE ឬមិនមែនជាសមាជិក ដោយប្រើសមាជិក JCE ជាឧបករណ៍នៅមន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រាល ទីតាំងសម្លាប់មនុស្សវត្តអង្គុញ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពៃង មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ឃុំកំពង់ព្រៀង រួមទាំងភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ ឃុំរាំងកេសី ("JCE B")។

iii. យ៉ាងហោចណាស់ក៏ចាប់ពីខែកញ្ញា-តុលា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ដែរ ដែល **យឹម ទិត្យ** កម្មាភិបាល ប.ក.ក ដទៃទៀត និងបុគ្គលិកមន្ទីរសន្តិសុខ បានរួមចំណែកនៅក្នុងគោលបំណងរួម ដើម្បីពន្លឿនប្រព័ន្ធនៃការធ្វើបាបនៅមន្ទីរសន្តិសុខវត្តព្រះធាតុ។ អ្នកចូលរួមប្រព្រឹត្តក្នុងជំពូកទីពីរនៃ JCE នេះ មានចេតនា និងបានអនុវត្តនូវប្រព័ន្ធធ្វើបាបនេះ តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញ ហើយនឹងអំពើប្រល័យពូជសាសន៍។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានធ្វើឡើងដោយសមាជិក JCE ឬមិនមែនជាសមាជិក ដោយប្រើ JCE ជាឧបករណ៍ *("JCE C")*។

1017. **យឹម ទិត្យ** បានក្លាយជាសមាជិករបស់៖

i. JCE A តាំងពីដើមឆ្នាំ១៩៧៧ គឺពេលដែលគាត់បានចាប់ផ្តើមចុះទៅពិនិត្យទីតាំងនានានៅភូមិភាគពាយ័ព្យ តាំងពីមុនការចាត់តាំងគាត់ឱ្យមកកាន់មុខតំណាងជាផ្លូវការជាច្រើននៅទីនោះ។

ii. JCE B មិនក្រោយពេលដែលគាត់បានចូលកាន់តំណែងជាច្រើននៅក្នុងគណៈតំបន់១៣ ក្នុងពេលណាមួយក្នុងឆ្នាំ១៩៧៦ នោះទេ ហើយនិង

iii. JCE C មិនក្រោយពេលដែលគាត់បានចូលកាន់តំណែងជាច្រើននៅក្នុងស្រុកគិរីវង់ទេ គឺយ៉ាងហោចណាស់ ក៏ចាប់ពីខែកញ្ញា-តុលា ឆ្នាំ១៩៧៥ ដែរ។

1018. គាត់នៅជាសមាជិក JCE ទាំងគ្រប់ទម្រង់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

1019. **យឹម ទិត្យ** បានដឹងអំពីសកម្មភាពទាំងអស់របស់ ប.ក.ក នៅតាមតំបន់ដែលគាត់ត្រួតត្រា។ ចំណេះដឹងនេះបានទទួលតាមរយៈការប្រជុំ និងប្រព័ន្ធប្រាស្រ័យទំនាក់ទំនង និងការរាយការណ៍ ដែលគាត់បានថែរក្សាជាមួយថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់របស់គាត់។ **យឹម ទិត្យ** គឺជាមនុស្សចម្បងម្នាក់ដែលមានការទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយរបស់ ប.ក.ក ក្នុងតំបន់ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គាត់ ដូច្នេះគាត់បានដឹងយ៉ាងច្បាស់ថា ការអនុវត្តគោលនយោបាយទាំងបួនរបស់ ប.ក.ក អាចសម្រេចទៅបាន មានតែអនុវត្តតាមរយៈឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ទាំងនោះ។ ជាមួយនឹងចំណេះដឹងនោះ គាត់បន្តប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ដើម្បីរួមចំណែកយ៉ាងសកម្មទៅក្នុងការអនុវត្តគោលនយោបាយនីមួយៗ។

1020. ចំណុចដែលត្រូវបញ្ជាក់គឺថា ទោះបីជាមិនបានចោទប្រកាន់ដូច្នេះក៏ដោយ កិច្ចស៊ើបសួរដែលបានបន្តជាហូរហែមក បានបង្ហាញឲ្យឃើញថា ម៉្យាង សិទ្ធិអំណាចរបស់គាត់នៅតាមអតីតតំបន់របស់គាត់នៅក្នុងភូមិភាគនិរតីនោះ នៅបន្តមានក្រោយពេលគាត់បានចេញទៅភូមិភាគពាយ័ព្យ និងម៉្យាងទៀត សិទ្ធិអំណាច*តាមព្រឹត្តន័យ* របស់គាត់បានដើរហួសពីការផ្តល់ឲ្យគាត់ជាផ្លូវការតាមរយៈការតែងតាំងជាផ្លូវការរបស់គាត់ទៅទៀត ប៉ុន្តែវាបានកើតឡើងតាមរយៈទំនាក់ទំនងជាបុគ្គលយ៉ាងជិតស្និទ្ធជាមួយតាម៉ុក ដែលជាមនុស្សកំពូលសម្រាប់ប្រតិបត្តិការនៅក្នុងភូមិភាគទាំងពីរ។

1021. **យឹម ទិត្យ** បានចូលរួមចំណែកយ៉ាងច្រើនដល់គោលនយោបាយស្តីពីការដ្ឋានការងារ និងសហករណ៍ តាមរយៈសកម្មភាពផ្សេងៗ*មានជាអាទិ៍* ការរៀបចំការប្រជុំនានាជាមួយអ្នកនៅក្រោមបង្គាប់របស់គាត់ និងការណែនាំពួកគេអំពីរបៀបអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក ការគ្រប់គ្រង និងការពិនិត្យការដ្ឋាន និងការមើលការខុសត្រូវ និងការតាមដានលើការកសាង និងការផលិត ការត្រួតត្រាលើកម្លាំងការងារ និងធនធានផ្សេងៗទៀតសម្រាប់ប្រតិបត្តិការនៅតាមការដ្ឋាន និងសហករណ៍ ដោយប្រកាសថា ប្រជាជនណាដែលមិនបានបំពេញការងាររបស់ខ្លួនគួរជាទីពេញចិត្ត នឹងត្រូវចាត់ទុកថាជាខ្មាំង ហើយតាមរយៈការឆ្លើយដាក់ ពួកគេត្រូវបានសម្លាប់ចោល។

1022. **យឹម ទិត្យ** បានចូលរួមចំណែកយ៉ាងច្រើនដល់គោលនយោបាយនានារបស់ ប.ក.ក ក្នុងការសម្លាប់ខ្មាំង ការកម្ទេចខ្មែរក្រោម និងការកំណត់គោលដៅក្រុមជាក់លាក់ រួមទាំងកម្មាភិបាល ប.ក.ក នៅភូមិភាគពាយ័ព្យ អតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ប្រជាជន១៧មេសា អ្នកជម្លៀសមកពីបូព៌ា និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈ *មានជាអាទិ៍* ការចូលរួមក្នុងការកិច្ចប្រជុំនានានៅក្នុងភូមិភាគទាំងពីរ ការកំណត់អត្តសញ្ញាណ និងការផ្តោលទោសចំពោះប្រជាជននៃក្រុមទាំងនោះថា ជាជនក្បត់ និងខ្មាំងដែលត្រូវបោសសម្អាត ការបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្ស ការរៀបចំកិច្ចប្រជុំ ផ្សេងៗជាមួយអ្នកក្រោមបង្គាប់របស់ខ្លួនស្តីពីប្រតិបត្តិការបោសសម្អាត និងការបញ្ជាឲ្យពួកគេប្រុងប្រយ័ត្នជានិច្ចក្នុងការចាប់ និងសម្លាប់មនុស្ស ការតាមដានលើការអនុវត្តការបោសសម្អាត និងការសម្របសម្រួលលើបណ្តាញមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដែលតាមរយៈនេះ អ្នកទោសត្រូវបានកំណត់អត្តសញ្ញាណ សម្រិតសម្រាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ចោលជាប្រចាំ។ អមជាមួយនឹងកសិណរបស់គាត់ដែលបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់គាត់ដើម្បីអនុវត្តផែនការនានារបស់*អង្គការ* ការនេះបានបង្ហាញអំពីចេតនារបស់គាត់ក្នុងអនុវត្តគោនយោបាយនានាដើម្បីកម្ទេចខ្មាំង និងកំណត់គោលដៅក្រុមជាក់លាក់ដោយមូលហេតុនយោបាយ ជាតិពន្ធុ ឬពូជសាសន៍ ដែលគេអាចយកជាការបាន។

1023. **យឹម ទិត្យ** បានចូលរួមចំណែកចេតនាពិសេសក្នុងការកម្ទេចខ្មែរក្រោម តាមរយៈសកម្មភាពជាមូលដ្ឋានក្នុងការសម្លាប់សមាជិកប្រជាជនខ្មែរក្រោម។

1024. **យឹម ទិត្យ** បានរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់ ប.ក.ក ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ តាមរយៈវត្តមានរបស់គាត់ យ៉ាងហោចណាស់ក៏ចាប់តាំងពីពេលចាប់ផ្តើមដំបូងនៃការមានពិធីរៀបការជាក្រុមនៅក្នុងស្រុកសំឡូត និងពីរបីថ្ងៃក្រោយ ពេលគាត់ទៅផ្តល់ការណែនាំដល់អ្នកដែលទើបរៀបការហើយថ្មីថ្មោង។ ការណ៍នេះក៏បង្ហាញអំពីចេតនារបស់គាត់ដើម្បីអនុវត្តគោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំផងដែរ។

1025. យ៉ាងណាមិញ **យឹម ទិត្យ** មិនមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម ដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី តាមរយៈ JCE ណាមួយឡើយ ដោយសារការចោទប្រកាន់នៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលីពាក់ព័ន្ធនឹងខ្មែរក្រោម បានចាប់ផ្តើមមុនពេលមានសមាជិកភាពរបស់ **យឹម ទិត្យ** នៅក្នុង JCE ដែលពាក់ព័ន្ធ។

### ៨.១.២ . ការប្រព្រឹត្តដោយផ្ទាល់

1026. អំពើប្រព្រឹត្តរបស់ **យឹម ទិត្យ** នៅក្នុងស្រុកសំឡូត តំបន់ ១ ដូចបានរៀបរាប់ខាងលើ មានតម្លៃស្មើនឹងការប្រព្រឹត្តដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើប្រព្រឹត្តដែលបានកំណត់អត្តសញ្ញាណថាជា អាពាហ៍ពិពាហ៍ដោយបង្ខំ។

### ៨.១.៣. ការធ្វើផែនការ

1027. ភស្តុតាងដែលគាំទ្រដល់ការសន្និដ្ឋាននានាទាក់ទងនឹងការរួមចំណែករបស់ **យឹម ទិត្យ** ទៅក្នុងគោលនយោបាយ JCE ក៏គាំទ្រដល់ការសន្និដ្ឋានថា គាត់បានធ្វើផែនការចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដែរ ដូចបានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ គ្មានការសន្និដ្ឋានសមហេតុផលដទៃផ្សេងទៀតទេ។ ដោយសារសិទ្ធិអំណាចរបស់ **យឹម ទិត្យ** និងការចុះពិនិត្យមើលទីតាំងនានាជាញឹកញាប់របស់គាត់ សេចក្តីពិចារណាសមហេតុផលតែមួយគត់គឺថា **យឹម ទិត្យ** ក៏មានចេតនាធ្វើឱ្យឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងផងដែរ។ ការណ៍នេះអនុវត្តចំពោះការដ្ឋានការងារ និងមន្ទីរសន្តិសុខ/ទីតាំងសម្លាប់មនុស្សនានា និងការអនុវត្តចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ។

1028. យ៉ាងណាមិញ **យឹម ទិត្យ** មិនមានការទទួលខុសត្រូវចំពោះការធ្វើផែនការឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម ដែលបាន

ប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី តាមមូលហេតុដូចបានពន្យល់ក្នុងកថាខណ្ឌ ១០២៥ នោះទេ។

### ៨.១.៤. ការបញ្ជា

1029. នៅតាមតំបន់នៃការទទួលខុសត្រូវរបស់គាត់ក្រោមមុខងារផ្លូវការរបស់ខ្លួន និងនៅក្នុងអំឡុងពេលដែលគាត់បានប្រើមុខងារទាំងនោះ ការសន្និដ្ឋានសមហេតុផលតែមួយគត់គឺថា **យឹម ទិត្យ** ត្រូវតែគេចមិនផុតពីការដែលគាត់បានបញ្ជាឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តទាំងនោះឡើយ ដូចបានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតំបន់ ២ និងតំបន់ ៧ នៃភូមិភាគពាយ័ព្យ ការសន្និដ្ឋានដូច្នេះគឺបានផ្អែកលើភស្តុតាងទាក់ទងនឹងតួនាទី និងសិទ្ធិអំណាចរបស់ **យឹម ទិត្យ** ក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ។ ការណ៍នេះអនុវត្តចំពោះការដ្ឋានការងារ និងមន្ទីរសន្តិសុខ/ទីតាំងសម្លាប់មនុស្សនានា និងការអនុវត្តចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ។

1030. យ៉ាងណាមិញ **យឹម ទិត្យ** មិនមានការទទួលខុសត្រូវចំពោះការបញ្ជា៖

i. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីងទេ ដោយសារឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង មុនពេលការតែងតាំងរបស់គាត់ទៅកាន់គណៈកម្មាធិការភូមិភាគពាយ័ព្យ។

ii. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅទីតាំងសម្លាប់មនុស្សភូមិព្រាលទេ ដោយសារឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងក្នុងពេលមិនច្បាស់លាស់ថា គាត់បានចូលកាន់មុខតំណែងក្នុងតំបន់ ១៣ ឬ គណៈកម្មាធិការភូមិភាគនិរតី។

iii. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែងទេ ដោយសារឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងក្នុងពេលមិនច្បាស់លាស់ថា គាត់បានចូលកាន់មុខតំណែងក្នុងតំបន់ ១៣ ឬ គណៈកម្មាធិការភូមិភាគនិរតី។

iv. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម ដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសេរី មុន្នី ទេ ដោយសារឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង មុនពេលការតែងតាំងរបស់គាត់ទៅកាន់គណៈកម្មាធិការភូមិភាគពាយ័ព្យ។

v. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម តាមរយៈសកម្មភាពជាមូលដ្ឋាននៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភូមិព្រាល ទេ ដោយសារឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង មុនពេលការតែងតាំងរបស់គាត់ទៅកាន់គណៈកម្មាធិការភូមិភាគពាយ័ព្យ។

## ៨.១.៥. ការញុះញង់

1031. ក្នុងតំបន់នៃការទទួលខុសត្រូវរបស់គាត់ក្រោមមុខងារផ្លូវការរបស់ខ្លួន និងនៅក្នុងអំឡុងពេលដែលគាត់បានប្រើមុខងារទាំងនោះ ការសន្និដ្ឋានសមហេតុផលតែមួយគត់គឺថា **យឹម ទិត្យ** ត្រូវតែគេចមិនផុតពីការដែលគាត់បានញុះញង់ឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តទាំងនោះឡើយ ដូចបានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការណ៍នេះអនុវត្តចំពោះការដ្ឋានការងារ និងមន្ទីរសន្តិសុខ/ទីតាំងសម្លាប់មនុស្សនានា និងការអនុវត្តចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ។ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតំបន់ ២ និងតំបន់ ៧ នៃភូមិភាគពាយ័ព្យ ការសន្និដ្ឋានដូច្នេះ គឺបានផ្អែកលើភស្តុតាងទាក់ទងនឹងតួនាទី និងសិទ្ធិអំណាចរបស់ **យឹម ទិត្យ** ក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ។ សេចក្តីពិចារណាសមហេតុផលតែមួយគត់គឺថា គាត់ក៏មានចេតនាធ្វើឲ្យឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងផងដែរ។

1032. អាស្រ័យមូលហេតុដូចគ្នាដូចមានចែងនៅក្នុងកថាខណ្ឌ ១០៣០ យ៉ាងណាមិញ **យឹម ទិត្យ** មិនមានការទទួលខុសត្រូវចំពោះការញុះញង់៖

i. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីងទេ។

ii. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅទីតាំងសម្លាប់មនុស្សភូមិព្រាលទេ។

iii. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែងទេ។

iv. ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម ដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលីទេ។

v. លើឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម តាមរយៈសកម្មភាពជាមូលដ្ឋាននៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភូមិព្រាលទេ។

### ៨.១.៦. ការទទួលខុសត្រូវរបស់ថ្នាក់លើ

1033. **យឹម ទិត្យ** បានធ្វើការគ្រប់គ្រងលើកម្មាភិបាលស៊ីវិល និងយោធាដែលជាអ្នកនៅក្រោមបង្គាប់របស់គាត់ និងទោះបីជាគាត់បានដឹងថា ពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅតាមការដ្ឋាន មន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្សនានា និងតាមរយៈការបង្ខំឲ្យប្រជាជនរៀបការក៏ដោយ ក៏គាត់មិនបានចាត់វិធានការណាមួយដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មពួកគេឡើយ។ ផ្ទុយទៅវិញ គាត់ក៏តែងតែជាអ្នកចូលរួមដ៏សកម្មម្នាក់ក្នុងការធ្វើផែនការ និងការសម្លាប់មនុស្សនៅតាមបណ្តាទីតាំងទាំងនេះ។ អាស្រ័យហេតុនេះ នៅតាមតំបន់នៃការទទួលខុសត្រូវរបស់គាត់ក្រោមមុខងាររបស់ខ្លួន និងនៅក្នុងអំឡុងពេលដែលគាត់បានប្រើមុខងារទាំងនោះ ការសន្និដ្ឋានសមហេតុផលតែមួយគត់គឺថា **យឹម ទិត្យ** ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត ដូចបានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតំបន់ ២ និងតំបន់ ៧ នៃភូមិភាគពាយ័ព្យ ការសន្និដ្ឋានដូច្នេះ គឺបានផ្អែកលើភស្តុតាងទាក់ទងនឹងតួនាទី និងសិទ្ធិអំណាចរបស់ **យឹម ទិត្យ** ក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ។ ការណ៍នេះអនុវត្តចំពោះការដ្ឋានការងារ និងមន្ទីរសន្តិសុខ/ទីតាំងសម្លាប់មនុស្សនានា និងការអនុវត្តចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ។

1034. អាស្រ័យមូលហេតុដូចគ្នាដូចមានចែងនៅក្នុងកថាខណ្ឌ ១០៣០ យ៉ាងណាមិញ **យឹម ទិត្យ** មិនមានការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះ៖

i. ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីងទេ។

ii. ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សភូមិព្រាលទេ។

iii. ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែងទេ។

iv. ឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម ដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលីទេ។

v. ឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម តាមរយៈសកម្មភាពជាមូលដ្ឋាននៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភូមិព្រាលទេ។

### ៨.១.៧. បទចោទដែលត្រូវលើកលែង

1035. ដោយសារ **យឹម ទិត្យ** គ្មានការទទួលខុសត្រូវចំពោះទម្រង់នៃការទទួលខុសត្រូវណាមួយចំពោះបទចោទនៃអំពើប្រល័យពូជសាសន៍ ឬការធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោម ដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលីទេ ដូច្នេះបទចោទទាំងនេះត្រូវតែលើកលែង។

## ៨.២. ឧក្រិដ្ឋកម្មក្នុងស្រុក

### ៨.២.១. សហប្រព្រឹត្តកម្ម

1036. **យឹម ទិត្យ** ត្រូវទទួលខុសត្រូវក្នុងនាមជាសហចារី ចំពោះឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតដោយចេតនា ដែលបានប្រព្រឹត្តនៅតាមទីតាំងដូចបានរៀបរាប់ខាងលើ។ **យឹម ទិត្យ** រួមជាមួយអ្នកផ្សេងទៀត បានចូលរួមដោយផ្ទាល់ និងដោយចេតនាក្នុងការប្រព្រឹត្តអំពើមនុស្សឃាតដោយចេតនា តាមរយៈការកំណត់អត្តសញ្ញាណខ្មាំងដែលត្រូវបោសសម្អាត ការបញ្ជាឱ្យអ្នកក្រោមបង្គាប់របស់គាត់សម្លាប់មនុស្សដែលតវ៉ាចំពោះលក្ខខណ្ឌរស់នៅ និងការងាររបស់ខ្លួន និងការសម្របសម្រួលលើបណ្ដាញមន្ទីរសន្តិសុខ ដែលតាមរយៈនេះ អ្នកទោសត្រូវបានកំណត់អត្តសញ្ញាណ ចាប់ខ្លួន និងសម្លាប់ចោល។

### ៨.២.២. ការធ្វើផែនការ

1037. ក្នុងតំបន់នៃការទទួលខុសត្រូវរបស់គាត់ ផ្អែកតាមសិទ្ធិអំណាចផ្លូវការរបស់ខ្លួននៅលើតំបន់យ៉ាងធំទូលាយ និងតាមរយៈការចូលរួមរបស់គាត់នៅក្នុង JCE **យឹម ទិត្យ** ក៏បានធ្វើផែនការចំពោះការធ្វើមនុស្សឃាតដោយចេតនាដូចបានរៀបរាប់ខាងលើ។ គ្មានការសន្និដ្ឋានសមហេតុផលដទៃផ្សេងទៀតទេ។ ដោយសារសិទ្ធិអំណាចរបស់ **យឹម ទិត្យ** និងការចុះពិនិត្យមើលទីតាំងនានាជាញឹកញាប់របស់គាត់ សេចក្ដីពិចារណាសមហេតុផលតែមួយគត់គឺថា **យឹម ទិត្យ** ក៏មានចេតនាធ្វើឱ្យឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងផងដែរ។

### ៨.២.៣. ការបញ្ជា

1038. ក្នុងតំបន់នៃការទទួលខុសត្រូវរបស់គាត់ ផ្អែកតាមសិទ្ធិអំណាចផ្លូវការរបស់ខ្លួននៅលើតំបន់យ៉ាងធំទូលាយ នៅក្នុងអំឡុងពេលដែលគាត់បានប្រើសិទ្ធិអំណាចទាំងនោះ **យឹម ទិត្យ** ក៏បានបញ្ជាឱ្យមានការធ្វើមនុស្សឃាតដោយចេតនាដូចបានរៀបរាប់ខាងលើ។ គ្មានការសន្និដ្ឋានសមហេតុផលដទៃផ្សេងទៀតទេ។ ដោយសារសិទ្ធិអំណាចរបស់ **យឹម ទិត្យ** និងការចុះពិនិត្យមើលទីតាំងនានាជាញឹកញាប់របស់គាត់ សេចក្ដីពិចារណាសមហេតុផលតែមួយគត់គឺថា **យឹម ទិត្យ** ក៏មានចេតនាធ្វើឱ្យឧក្រិដ្ឋ

កម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងផងដែរ។ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតំបន់ ២ និង តំបន់ ៧ នៃភូមិភាគពាយ័ព្យ ការសន្និដ្ឋានដូច្នេះ គឺបានផ្អែកលើភ័ស្តុតាងទាក់ទងនឹងតួនាទី និងសិទ្ធិអំណាចរបស់ **យឹម ទិត្យ** ក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ។

1039. យ៉ាងណាមិញ **យឹម ទិត្យ** មិនមានការទទួលខុសត្រូវចំពោះការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង ទីតាំងសម្លាប់មនុស្សភូមិព្រាល ឬទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែងទេ តាមមូលហេតុដូចបានពន្យល់ក្នុងកថាខណ្ឌ ១០៣០។

## ៨.៣. ចេតនាឧក្រិដ្ឋ

1040. ភ័ស្តុតាងគាំទ្រយ៉ាងច្បាស់ដល់ការសន្និដ្ឋានថា **យឹម ទិត្យ** និងអ្នកដែលគាត់បានសហការជាមួយនៅគ្រប់កម្រិតនៃឋានានុក្រមរបស់ ប.ក.ក មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដូចបានរៀបរាប់ខាងក្រោម រួមទាំងចេតនាទំនើងចិត្តជាក់លាក់ចំពោះអំពើប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ។

## ៩. សេចក្ដីសម្រេចស្ដីពីការឃុំឃាំងមុនសវនាការ

1041. ទោះបីជាយើងបានរកឃើញថា មានបទចោទគ្រប់គ្រាន់ដើម្បីបញ្ជូន **យឹម ទិត្យ** ទៅជំនុំជម្រះក៏ដោយ ក៏យើងមិនពិចារណាថាការឃុំខ្លួនគាត់មុនការជំនុំជម្រះ គឺជាវិធានការចាំបាច់ដើម្បីចៀសវាងកត្តាហានិភ័យណាមួយ ដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង នោះដែរ។ **យឹម ទិត្យ** ត្រូវបានគេដឹងជាច្រើនឆ្នាំមកហើយថា គាត់ស្ថិតនៅក្រោមការស៊ើបអង្កេត ហើយគាត់បានសហការជាមួយ ស.ច.ស នៅក្នុងរយៈពេលនៃកិច្ចស៊ើបសួរទាំងមូល។ គ្មានសញ្ញាបង្ហាញថា គាត់អាចរត់គេចខ្លួនពីយុត្តាធិការ ដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះណាម្នាក់ ឬជ្រៀតជ្រែកដំណើរការតុលាការទេ ទោះតាមមធ្យោបាយណាក៏ដោយ ហើយក៏គ្មានការព្រួយបារម្ភសម្រាប់សន្តិសុខរបស់ **យឹម ទិត្យ** ឬការថែរក្សារបៀបរៀបរយសាធារណៈ ដើម្បីជាយុត្តិកម្មដល់ការឃុំឃាំងខ្លួនគាត់ដែរ។

1042. មូលហេតុបន្ថែមមួយដែលប្រឆាំងនឹងដីកាសម្រេចឃុំខ្លួននៅពេលនេះ គឺភាពមិនប្រាកដប្រជាផ្នែកនីតិវិធី ជាលទ្ធផលដែលកើតចេញពីការប្រឆាំងនឹងដីកាដំណោះស្រាយ ដែលជាលទ្ធផលមួយមិនច្បាស់លាស់ បើតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ថាតើដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះនឹងនៅជាបានការ ប្រសិនបើគ្មានមតិភាគច្រើនដាច់ខាត នៅលើការសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅលើបណ្ដឹងឧទ្ធរណ៍។

## ១០. ដីកាសម្រេចបញ្ចប់កិច្ចស៊ើបសួរ តាមវិធានវិធាន ៦៦ស្ទួន

1043. យើង **បញ្ចប់** កិច្ចស៊ើបសួរទាក់ទងនឹងអង្គហេតុនានាដែលត្រូវបានដកចេញ ស្របតាមសេចក្ដីសម្រេចអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ដូចមានចែងនៅក្នុងកថាខណ្ឌ ៨។

## ១១. ដីកាសម្រេចលើកលែងចោទប្រកាន់មួយផ្នែក

1044. បទចោទដូចខាងក្រោម ត្រូវបាន**លើកលែងចោទប្រកាន់៖**

*អំពើប្រល័យពូជសាសន៍*

*ទីតាំងទាំងអស់*

អំពើប្រល័យពូជសាសន៍ធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា និងធ្វើដោយចេតនាឱ្យទទួលរងនូវស្ថានភាពដែលនាំឱ្យមានការបំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែកដល់ក្រុម។

*ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី*

ទីតាំងទាំងមូល។

*រោងចក្រស្អុរសកំពង់គល់*

ទីតាំងទាំងមូល។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

*ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី*

បទចោទអំពីការធ្វើទុក្ខបុកម្នេញ។

*មន្ទីរសន្តិសុខខ្នងគួ*

បទចោទអំពីការធ្វើទារុណកម្ម និងបទចោទអំពីការធ្វើទុក្ខបុកម្នេញដែលពាក់ព័ន្ធ តាមរយៈសកម្មភាពនៃការធ្វើទារុណកម្មជាមូលដ្ឋាន។

*ការដ្ឋានរោងចក្រស្អុរសកំពង់គល់*

បទចោទអំពីការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ។

*ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី*

ទីតាំងទាំងមូល។

*គុកលេខ ៨*

បទចោទអំពីការធ្វើទារុណកម្ម និងបទចោទអំពីការធ្វើទុក្ខបុកម្នេញដែលពាក់ព័ន្ធ តាមរយៈសកម្មភាពនៃការធ្វើទារុណកម្មជាមូលដ្ឋាន។

*ការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦*

*ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី*

ទីតាំងទាំងមូល។

## ១២. ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ

## **យឹម និត្យ**

កើតនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៣៦

នៅភូមិត្រពាំងគល់

ឃុំត្រពាំងធំ

ស្រុកត្រាំកក់

ខេត្តតាកែវ

ទីលំនៅបច្ចុប្បន្ន:

[redacted]

**ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម**

**បទចោទ ១÷**

**អំពើប្រល័យពូជសាសន៍**

ប្រឆាំងខ្មែរក្រោម តាមរយៈការសម្លាប់សមាជិកនៃក្រុមនេះ

**តំបន់ ១៣ នៃភូមិភាគនិរតី**

*មន្ទីរសន្តិសុខវត្តព្រះធាតុ* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤៣៣-៤៦៩)

(JCE1, JCE2 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*មន្ទីរសន្តិសុខក្រាំងតាចាន់* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤៧០-៥២៦)

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សភូមិព្រាល* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥២៧-៥៤៦)

(JCE1 ការធ្វើផែនការ)

*ទីតាំងសម្លាប់មនុស្សវត្តអង្គុញ* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៤៧-៥៥៤)

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៥៥-៥៦៥)

(JCE1 ការធ្វើផែនការ)

**តំបន់ ២ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខភូមិព្រាល* (កថាខណ្ឌ ១៥១-១៥៨, ១៦១-២៧៥, ៣២៧-៣៩៧, ៧៤៧-៧៧១)

(JCE1 ការធ្វើផែនការ)

*មន្ទីរសន្តិសុខស្វាយជ្រុំ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-២៧៥, ៣២៧-៣៩៧, ៧៧២-៧៩៦)

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-២៧៥, ៣២៧-៣៩៧, ៧៩៧-៨១០)

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សព្រៃក្របៅ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-២៧៥, ៣២៧-៣៩៧, ៧៩៧-៨១០)

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

**តំបន់ ៤ នៃភូមិភាគពាយ័ព្យ**

*ឃុំកំពង់ព្រៀង (រួមទាំង មន្ទីរសន្តិសុខពោធិ៍លង្កា ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ)* (កថាខណ្ឌ ១៥១-១៥៨, ១៦១-២៧៥, ៣២៧-៣៩៧, ៨៧០-៩១០, ៩១៨-៩២០)

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ឃុំរាំងកេសី* (កថាខណ្ឌ ១៥១-១៥៨, ១៦១-២៧៥, ៣២៧-៣៩៧, ៨៩៤, ៩១១-៩២០)

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

## បទចោទ ២÷

## ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

**តំបន់ ១៣ នៃភូមិភាគនិរតី**

*មន្ទីរសន្តិសុខព្រះធាតុ* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤៣៣-៤៦៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជន១៧មេសា និងខ្មែរក្រោម និងការធ្វើទុក្ខបុកម្នេញហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1, JCE2 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*មន្ទីរសន្តិសុខក្រាំងតាចាន់* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤៧០-៥២៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជន១៧មេសា និងខ្មែរក្រោម និងការធ្វើទុក្ខបុកម្នេញហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សភ្នំមិព្រាល* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥២៧-៥៤៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ))។

(JCE1 ការធ្វើផែនការ)

*ទីតាំងសម្លាប់មនុស្សវត្តអង្គុញ* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៤៧-៥៥៤)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្តែង* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៥៥-៥៦៥)

ការធ្វើមនុស្សឃាត ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ))។

(JCE1 ការធ្វើផែនការ)

*ទីតាំងសម្លាប់មនុស្សព្រៃស្មុខុន និងវត្តអង្គសិរីមាលី* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៦៦-៥៨៥)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង។

(ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

**តំបន់ ១ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខវត្តគាស់ក្រឡ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៥៨៦-៥៩៥)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*សហករណ៍ធិបតី (រួមទាំងមន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខនិងការដ្ឋានទួលម្ទេស* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៥៩៦-៦៥១)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ការដ្ឋានទំនប់កង្កួត* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៦៥២-៧០០)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*មន្ទីរសន្តិសុខបាណាន់* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧០១-៧១៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1)

*មន្ទីរសន្តិសុខខ្នងភ្នំ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧២០-៧៣៧)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ការដ្ឋានរោងចក្រស្ពានសក់ពង់គល់* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧៣៨-៧៤៦)

ការធ្វើមនុស្សឃាត

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ស្រុកសំឡូត* (កថាខណ្ឌ ៩៨០-៩៩១)

អំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ)។

(ការប្រព្រឹត្តដោយផ្ទាល់)

**តំបន់ ២ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខភ្នំមិវាល* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧៤៧-៧៧១)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*មន្ទីរសន្តិសុខស្វាយជ្រុំ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧៧២-៧៩៦)

ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៧៩៧-៨១០)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៨១១-៨២៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

**តំបន់ ៣ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខវត្តគិរីរម្យ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៨២៩-៨៤៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត(ការបង្ខាំងនិងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

**តំបន់ ៤ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខវត្តសម្តេច* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៨៥០-៨៦៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ឃុំកំពង់ព្រៀង (មន្ទីរសន្តិសុខវត្តពោធិ៍លង្កា ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៨៧០-៩១០, ៩១៨-៩២០, ៩៤៩, ៩៦៧-៩៧៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ អាពាហ៍ពិពាហ៍ដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ (តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌)) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ឃុំរាំងកេសី* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៨៩៤, ៩១០-៩២០, ៩៤៩-៩៦៦)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល អំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងហួសហេតុចំពោះខ្មែរក្រោម (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

**តំបន់ ៧ នៃភូមិភាគពាយ័ព្យ**

*គុកលេខ ៨* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៩២១-៩៣៩)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះអ្នកជម្លៀសមកពីភូមិភាគបូព៌ា (តាមរយៈការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌))។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជ្រីង* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៩៤០-៩៤៨)

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះអ្នកជម្លៀសមកពីភូមិភាគបូព៌ា (តាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល)។

(JCE1 ការធ្វើផែនការ)

## មនោគមន ៣៖

## ឧក្រិដ្ឋកម្មសង្គ្រាម

### តំបន់ ១៣ នៃភូមិភាគនិរតី

*មន្ទីរសន្តិសុខក្រាំងតាចាន់* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤២៨-៤៣២, ៤៧០-៥២៦)

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា និងការជម្លៀសជនស៊ីវិលដោយខុសច្បាប់។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សភ្នំព្រាល* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤២៨-៤៣២, ៥២៧-៥៤៦)

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការជម្លៀសជនស៊ីវិលដោយខុសច្បាប់។

(JCE1 ការធ្វើផែនការ)

*ទីតាំងសម្លាប់មនុស្សវត្តអង្គុញ* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤២៨-៤៣២, ៥៤៧-៥៥៤)

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា។

(JCE1 ការធ្វើផែនការ ការបញ្ជា ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ)

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្តែង* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤២៨-៤៣២, ៥៥៥-៥៦៥)

អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការជម្លៀសជនស៊ីវិលដោយខុសច្បាប់។

(JCE1 ការធ្វើផែនការ)

## បទចោទ ៤៖

## ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

អំពើមនុស្សឃាតដោយចេតនាតាមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

**តំបន់ ១៣ នៃភូមិភាគនិរតី**

*មន្ទីរសន្តិសុខវត្តព្រះធាតុ* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤៣៣-៤៦៩)

*មន្ទីរសន្តិសុខក្រាំងតាចាន់* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៤៧០-៥២៦)

*ទីតាំងសម្លាប់មនុស្សវត្តអង្គុញ* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៤៧-៥៥៤)

*ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៦៦-៥៨៥)

(ទាំងអស់៖ ការធ្វើផែនការ ការបញ្ជា សហប្រព្រឹត្តកម្ម)

*ទីតាំងសម្លាប់មនុស្សភូមិព្រាល* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥២៧-៥៤៦)

*ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង* (កថាខណ្ឌ ១៥១-១៦០, ១៦៩-២៧៥, ៣២៧-៣៥២, ៣៨៦-៣៩៧, ៥៥៥-៥៦៥)

(ទាំងពីរ៖ ការធ្វើផែនការ សហប្រព្រឹត្តកម្ម)

**តំបន់ ១ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខគាស់ក្រឡ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៥៨៦-៥៩៥)

*សហករណ៍ធិបតី (រួមទាំង មន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខនិងការដ្ឋានទួលម្ទេស* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៥៩៦-៦៥១)

*ការដ្ឋានទំនប់កង្កួត* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៦៥២-៧00)

*មន្ទីរសន្តិសុខខ្នងភ្នំ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧២0-៧៣៧)

*ការដ្ឋានរោងចក្រស្ករសកំពង់គល់* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧៣៨-៧៤៦)

(ទាំងអស់៖ ការធ្វើផែនការ ការបញ្ជា សហប្រព្រឹត្តកម្ម)

*មន្ទីរសន្តិសុខបាណន់* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៧0១-៧១៩)

(សហប្រព្រឹត្តកម្ម)

**តំបន់ ២ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខភូមិវាល* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៧៤៧-៧៧១)

*មន្ទីរសន្តិសុខស្វាយជ្រុំ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៧៧២-៧៩៦)

*ទីទាំងសម្លាប់មនុស្សទួលសេះញ៉ូវ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៧៩៧-៨១០)

*ទីទាំងសម្លាប់មនុស្សព្រៃក្រញៅ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៨១១-៨២៦)

(ទាំងអស់៖ ការធ្វើផែនការ ការបញ្ជា សហប្រព្រឹត្តកម្ម)

**តំបន់ ៣ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខវត្តគិរីវង្ស* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៨២៩-៨៤៩)

(ការធ្វើផែនការ ការបញ្ជា សហប្រព្រឹត្តកម្ម)

**តំបន់ ៤ នៃភូមិភាគពាយ័ព្យ**

*មន្ទីរសន្តិសុខវត្តសម្តេច* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៨៥០-៨៦៩)

*ឃុំកំពង់ព្រៀង - មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៨៧០-៩១០, ៩១៨-៩២០)

*ឃុំរាំងកេសី* (កថាខណ្ឌ ១៥១-១៥៨, ១៦១-៣២២, ៣២៧-៤២៧, ៨៩៤, ៩១១-៩២០)

(ទាំងអស់៖ ការធ្វើផែនការ ការបញ្ជា សហប្រព្រឹត្តកម្ម)

**តំបន់ ៧ នៃភូមិភាគពាយ័ព្យ**

*គុកលេខ ៨* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៩២១-៩៣៩)

(ការធ្វើផែនការ ការបញ្ជា សហប្រព្រឹត្តកម្ម)

*វាលបាក់ជញ្ជីង* (កថាខណ្ឌ ១៥១-១៥៨, ១៦១-១៨៥, ២៧៦-៣២២, ៣៥៣-៣៨៥, ៣៩៨-៤២៧, ៩៤០-៩៤៨)

(ការធ្វើផែនការ សហប្រព្រឹត្តកម្ម)

## ១៣. ការបញ្ចប់កិច្ចស៊ើបសួរដែលនៅសល់ទាក់ទងនឹងសំណុំរឿង 004

ចំណុចសេសសល់នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ ត្រូវបានដោះស្រាយ តាមរយៈដីកាបញ្ចប់កិច្ចស៊ើបសួរដាច់ដោយឡែករួម ដែលបានចេញដោយ ស.ច.ស ទាំងពីររូប នៅថ្ងៃនេះ។

ដីកាដំណោះស្រាយនេះបានដាក់ជាភាសាអង់គ្លេស ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

ភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**